ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការអប់រំ

# ស្តីពី ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

# និង លំនាំនៃការបង្រៀន

## កម្រិតមធ្យមសិក្សា



នាយកដ្ឋាននីតិកម្ម
ឆ្នាំ ២០២០

# ការអប់រំ

# ស្តីពី

# ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស

# និងលំនាំនៃការបង្រៀន

## កម្រិតមធ្យមសិក្សា

នាយកដ្ឋាននីតិកម្ម

ឆ្នាំ២០២០

រក្សាសិទ្ធិ ដោយក្រសួងអប់រំ យុវជន និងកីឡា

បោះពុម្ពលើកទី១ ឆ្នាំ២០២០

ឧបត្ថម្ភដោយ .........................................

ចំនួន ............... ក្បាល

**សេចក្តីថ្លែងអំណរគុណចំពោះ**

- អង្គការ Plan International Cambodia
- អង្គការ Cambodia Acts
- អង្គការ APLE
- អង្គការ Caritas Cambodia
- អង្គការ A21 Foundation
- អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC)
- អង្គការ First Step Cambodia
- អង្គការ Solidar Suisse
- អង្គការ Child Fund Cambodia
- អង្គការ Care Cambodia

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៤៧ **អយក.**ប្រក

# ប្រកាស
# ស្តីពី
# ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
# សៀវភៅ «ការអប់រំ ស្តីពី ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន» កម្រិតមធ្យមសិក្សា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រម លេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញ អនុក្រឹត្យ លេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងសេចក្តីសម្រេចលេខ ១១ អយក.សសរ. ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- របាយការណ៍សកម្មភាពអភិវឌ្ឍសៀវភៅ ការអប់រំ ស្តីពី ការបង្ការ ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន កម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សា ចុះថ្ងៃសុក្រ ១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ របស់នាយកដ្ឋាននីតិកម្ម
- លិខិតលេខ១០៣ ន.នក ចុះថ្ងៃពុធ ២កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ របស់នាយកដ្ឋាននីតិកម្ម
- យោងលិខិតលេខ ២៤៩ អគ.អរ.អកស ចុះថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## សម្រេច

**ប្រការ១.**_ អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ **«ការអប់រំ ស្តីពី ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន»** កម្រិតមធ្យមសិក្សា ដែលជាស្នាដៃនិពន្ធ និងរៀបរៀងដោយគណៈកម្មការនិពន្ធនៃនាយកដ្ឋាននីតិកម្ម ដើម្បីប្រើប្រាស់នៅតាមសាលាមធ្យមសិក្សាចំណេះទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.**_ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋាននីតិកម្ម មន្ទីរអប់រំ យុវជន និង កីឡារាជធានី/ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងសាលាមធ្យមសិក្សាចំណេះទូទៅ មានភារកិច្ចអនុវត្តប្រកាសនេះ។

ថ្ងៃ[illegible] ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់សាលារាជធានីខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- ដូចប្រការ២ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

## គណៈកម្មការគ្រប់គ្រង

ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រី
ឯកឧត្តម បណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ
លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
ឯកឧត្តម **ស សុខា** រដ្ឋលេខាធិការ
លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការ
លោកជំទាវ បណ្ឌិត **សឿ សុជាតា** អនុរដ្ឋលេខាធិការ
លោកជំទាវឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណា សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ
ឯកឧត្តម បណ្ឌិត **ស៊ិន សេងហុក** ប្រធាននាយកដ្ឋាននីតិកម្ម
លោក **យី គឹមថាន** នាយករងប្រចាំប្រទេស អង្គការផ្លែនអន្តរជាតិ កម្ពុជា

## គណៈកម្មការរៀបរៀង

ឯ.ឧ បណ្ឌិត ស៊ិន សេងហុក
លោក ង៉ោ ប៉េងឡុង
លោកស្រី អ៊ុក សុមនី
លោក ម៉ៅ សំរិទ្ធី
លោក យិន ធី
លោក មាស ជុតិមា
លោក សំលៀង សីលា

ឯ.ឧ ឧត្តមសេនីយ៍ឯក ស៊ុន រ៉ូ
ឯ.ឧ ឧត្តមសេនីយ៍ឯក យឹម វិរៈ
ឯកឧត្តម កែប សរឿន
ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា
ឧត្តមសេនីយ៍ទោ រ៉ន សុភ័ក្ត្រវឌ្ឍនា
វរសេនីយ៍ឯក ហ៊ី រតនៈ
អនុសេនីយ៍ឯក ហង្ស ពុទ្ធារិទ្ធិ

លោក លី សុខា
លោក មួង ចាន់ទូច
លោក សេង សូវ៉ាត
លោក សំ សែន
លោក កួយ ចំរើន
លោក ទូ វឌ្ឍនា
លោក លុយ ឡៃម
លោកស្រី អ៊ុំ សុគុណ

## គណៈកម្មការត្រួតពិនិត្យ

ឯ.ឧ ប.សភាចារ្យ ណាត ប៊ុនរឿន
ល.ជ.បណ្ឌិត សឿ សុជាតា
ល.ជ.ឧ.ឯក វេជ្ជ. ប៉ុណ្ណា សំខាន់
ឯ.ឧ បណ្ឌិត ស៊ិន សេងហុក
លោកស្រី អ៊ុក សុមនី
លោក គង់ វីឡា

## ក្រុមការងារបច្ចេកទេស

លោក ស៊ុន ប៊ុណ្ណា
លោក ឈឹម ផាន់ណា
លោក លឹម សុត្ថារិទ្ធ
លោក ឡុង សុវណ្ណា

## ការិយាល័យ

លោក អ៊ុក សាវន
លោក ឈិត ចំរុង
ល. វ.ឯក ហ៊ី រតនៈ
ល.អនុ.ឯក ជុំ សេន

# បុព្វកថា

ប្រសិទ្ធភាពនិងតម្លៃនៃការអប់រំត្រូវបានទទួលស្គាល់ជាសកល ជាចលករដ៏ពិសិដ្ឋសម្រាប់គាំទ្រដល់ដំណើរការអភិវឌ្ឍជាតិគ្រប់វិស័យ។ ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍជាតិ ឆ្នាំ២០៣០ និងវិធានការទប់ស្កាត់ការប្រឈមនានាក្នុងការអនុវត្តនយោបាយសាកលភាវូបនីយកម្មរបស់រាជរដ្ឋាភិបាល មុខងារអភិវឌ្ឍការអប់រំដែលជាថ្នាលបណ្តុះ ចំណេះដឹង ចំណេះធ្វើ និងឥរិយាបថជាធនធានមនុស្សវិជ្ជមានសម្រាប់សង្គមបានតម្រូវឱ្យមានការយកចិត្តទុកដាក់ទ្វេដង។ ក្នុងនោះក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាផ្តល់ទំនុកចិត្តឱ្យទទួលបន្ទុកជាស្ថាប័នសម្របសម្រួល និងដឹកនាំក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមស្មារតីនៃសេចក្តីសម្រេចលេខ០០៥/១៥ សសរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ និងបានធ្វើបច្ចុប្បន្នកម្មតាមរយៈសេចក្តីសម្រេចលេខ០៣២/២០សសរ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

ទន្ទឹមនឹងការបំពេញភារកិច្ច ជាអ្នកសម្របសម្រួលដឹកនាំក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សក្នុងកម្រិតអន្តរវិស័យ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដំណើរការក្រុមការងារផ្ទៃក្នុងវិស័យអប់រំដែលរួមមាន ការចងក្រងរចនាសម្ព័ន្ធគ្រប់គ្រងក្នុងវិស័យអប់រំពីកម្រិតថ្នាក់ជាតិ ដល់រាជធានី ខេត្ត និងតាមគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជនគ្រប់កម្រិតភូមិសិក្សា។ មិនតែប៉ុណ្ណោះ ក្រសួងបានសម្រេចបញ្ចូលប្រធានបទ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទៅក្នុងកម្មវិធីសិក្សាជាតិ មុខវិជ្ជាភាសាខ្មែរ និងសិក្សាសង្គម។ ដើម្បីសម្រេចបេសកកម្មខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតក្រុមការងារបច្ចេកទេសដើម្បីចងក្រងសៀវភៅស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន ក្នុងគោលបំណងបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធរាល់ទម្រង់នៃអំពើជួញដូរមនុស្សនៅក្នុងប្រទេសក៏ដូចជានៅលើសាកលលោក។ ការអប់រំនេះជំរុញឱ្យមានការអនុវត្តបំណិនឆ្លើយតបត្រឹមត្រូវទៅនឹងទង្វើជួញដូរមនុស្ស និងលើកកម្ពស់ការអនុវត្តសិទ្ធិមនុស្សក្នុងការចូលរួមបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីមនុស្សជាតិ និងការអភិវឌ្ឍសង្គម។

ខ្ញុំសង្ឃឹមនិងជឿជាក់ថា ការចូលរួមប្រកបដោយការទទួលខុសត្រូវខ្ពស់របស់លោកគ្រូ អ្នកគ្រូគ្រប់រូបក្នុងការប្រើប្រាស់សៀវភៅនេះជាប្រយោជន៍មូលដ្ឋានកសាងសម្បទារឹងមាំ ជូនដល់កុមារកម្ពុជារួចចាកផុតពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងមានឱកាសអភិវឌ្ឍខ្លួនឱ្យក្លាយជាជនបង្គោលរបស់ជាតិក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ជាពលរដ្ឋល្អ ពលរដ្ឋវិជ្ជមានក្នុងដំណើរការកសាងប្រទេសដែលមានការធានាបាននូវសុខសុវត្ថិភាព និងសន្តិភាព ឈានទៅសម្រេចគោលដៅអភិវឌ្ឍសេដ្ឋកិច្ចជាតិរឹងមាំ។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អង្គការដៃគូអភិវឌ្ឍជាតិ អន្តរជាតិ និងគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់ ដែលបានជួយចងក្រង ផលិត និងសហការគាំទ្រដល់ការរៀបចំសៀវភៅនិងលំនាំនៃការបង្រៀននេះ។

# អារម្ភកថា

លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាជាទីរាប់អាន!

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានជំរុញនិងលើកទឹកចិត្តដល់ប្រជាជនកម្ពុជាគ្រប់រូប គ្រប់វ័យ គ្រប់សាសនាឱ្យមានភាពជាម្ចាស់ក្នុងការប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពនៃការបង្ការ ទប់ស្កាត់អំពើអមនុស្សធម៌របស់ជនខិលខូចឬជនសង្ស័យ ដោយមិនអនុញ្ញាតឱ្យជនខិលខូច ឬជនសង្ស័យទាំងនោះបង្កភាពរងគ្រោះដល់ប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេស។ ក្រុមការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សនៃក្រសួងអប់រំ យុវជន និងកីឡា ដែលដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយនឹងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដែលដឹកនាំដោយសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានការគាំទ្រដោយអង្គការជាតិ-អន្តរជាតិ បានរួមគ្នារៀបចំចងក្រងជាសៀវភៅស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀននេះឡើង ក្នុងគោលបំណងលើកទឹកចិត្តជូនដល់លោកគ្រូ អ្នកគ្រូ ក៏ដូចជាអ្នកសិក្សាអនុវត្តសិទ្ធិមនុស្សពេញលេញរបស់ខ្លួនចូលរួមបង្ការ ទប់ស្កាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ដូចមានបង្ហាញជូននៅក្នុងអត្ថបទមេរៀនទាំង១៦នៃសៀវភៅនេះ។ ករណីសិក្សាដែលបានបង្ហាញក្នុងសៀវភៅនេះជារឿងពិត ដែលទោះបីជារឿងខ្លះមិនទាន់កើតមានឡើងក្នុងប្រទេសកម្ពុជាក៏ដោយ តែគឺជាបំណងរបស់អ្នកនិពន្ធចង់ជំរុញឱ្យមានការយល់ដឹងស៊ីជម្រៅពីបទល្មើសនិងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ដើម្បីបង្ការ ទប់ស្កាត់កុំឱ្យមានការកើតឡើងនៅក្នុងសង្គមជាតិរបស់យើង។

យើងសង្ឃឹមថាសៀវភៅស្តីពី "**ការបង្ការទប់ ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន** " នឹងជួយដល់លោកគ្រូ អ្នកគ្រូ យកជាមូលដ្ឋានសម្រាប់ការអប់រំដល់អ្នកសិក្សាឱ្យទទួលបាននូវចំណេះដឹង បំណិនសម្រាប់អភិវឌ្ឍឥរិយាបថជាសិស្សល្អ កូនល្អ និងជាពលរដ្ឋល្អ ឬពលរដ្ឋវិជ្ជមាន ចៀសផុតពីអំពើជួញដូរមនុស្សគ្រប់រូបភាព និងអាចក្លាយជាជនបង្គោលរបស់សហគមន៍ក្នុងការចូលរួមបង្ការទប់ស្កាត់អំពើជួញដូរមនុស្សដ៏មានប្រសិទ្ធភាព។

សូមឱ្យការប្រើប្រាស់ និងការសិក្សារបស់លោកគ្រូ អ្នកគ្រូ ព្រមទាំងអ្នកសិក្សា និងភាគីពាក់ព័ន្ធនៅទូទាំងប្រទេសទទួលបានជោគជ័យ និងរីកចម្រើនល្អប្រសើរ ដើម្បីអនាគតរុងរឿងរបស់ប្រទេសជាតិនៃយើងតទៅ!

**គណៈកម្មការនិពន្ធ**

# មាតិកា

ទំព័រ


**មុខកថា** ---------------------------------------------------------------------------------------------------- ii

**អារម្ភកថា** ------------------------------------------------------------------------------------------------- iii

**មាតិកា** ------------------------------------------------------------------------------------------------------ iv

**ជំពូកទី១ សិទ្ធិមនុស្ស** ------------------------------------------------------------------------------------- ១

មេរៀនទី១ គោលការណ៍ទូទៅនៃសិទ្ធិមនុស្ស---------------------------------------------------------------------- ២

មេរៀនទី២ ព្រំដែននៃសេរីភាព------------------------------------------------------------------------------------ ៧

មេរៀនទី៣ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ ---------------------------------------------------------- ១២

មេរៀនទី៤ សិទ្ធិចូលរួមក្នុងការអភិវឌ្ឍសង្គម ----------------------------------------------------------------- ១៧

**ជំពូកទី២ ការបង្ការ ទប់ស្កាត់អំពើធ្វើអាជីវកម្ម ផ្លូវភេទ** ---------------------------------------------- ២៤

មេរៀនទី១ សញ្ញាណនិងផលប៉ះពាល់នៃអំពើធ្វើអាជីវកម្មផ្លូវភេទផ្លូវភេទ -------------------------------- ២៥

មេរៀនទី២ ឧបាយកលជនខិលខូចឬជនសង្ស័យ------------------------------------------------------------- ៣០

មេរៀនទី៣ ការការពារខ្លួន និងការបង្ការទប់ស្កាត់**អំពើធ្វើអាជីកម្មផ្លូវភេទ**--------------------------- ៣៥

**ជំពូកទី៣ ការបង្ការ ទប់ស្កាត់អំពើកេងប្រវ័ញ្ចកម្លាំងពលកម្ម** ----------------------------------------- ៤២

មេរៀនទី១ សញ្ញាណនិងផលប៉ះពាល់នៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម--------------------------------------- ៤៣

មេរៀនទី២ កលល្បិចនៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម ---------------------------------------------------- ៤៨

មេរៀនទី៣ ការការពារខ្លួន និងការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម --------------------------- ៥៣

**ជំពូកទី៤ ការបង្ការ ទប់ស្កាត់អំពើដកហូតសរីរាង្គ** ------------------------------------------------------ ៦០

មេរៀនទី១ សញ្ញាណដំបូងនិងផលប៉ះពាល់នៃការដកហូតសរីរាង្គ---------------------------------------------- ៦១

មេរៀនទី២ កលល្បិចក្នុងអំពើដកហូតសរីរាង្គ --------------------------------------------------------------- ៦៦

មេរៀនទី៣ ការការពារ និងការបង្ការ ទប់ស្កាត់អំពើដកហូតសរីរាង្គ----------------------------------------- ៧១

**ជំពូកទី៥ ការបង្ការ ទប់ស្កាត់អំពើពពោះជំនួស** ---------------------------------------------------------- ៧៨

មេរៀនទី១ សញ្ញាណ និងផលប៉ះពាល់នៃអំពើពពោះជំនួស-------------------------------------------------------- ៧៩

មេរៀនទី២ ការការពារ និងបង្ការទប់ស្កាត់អំពើពពោះជំនួស ------------------------------------------------- ៨៥

**ជំពូកទី៦ ការបង្ការ ទប់ស្កាត់អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមអ៊ីនធឺណិតឬអនឡាញ** -------------------------------------------------------------------------------- ៩២

មេរៀនទី១ ការប្រឈមចំពោះហានិភ័យតាមអ៊ីនធឺណិតឬអនឡាញ----------------------------------------------- ៩៣

មេរៀនទី២ ការឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិតឬអនឡាញ ------------ ១០១

**ជំពូកទី៧ ការបង្ការ ទប់ស្កាត់ អំពើរត់ពន្ធមនុស្ស** -------------------------------------------------------- ១០៩

មេរៀនទី១ សញ្ញាណ និងការបង្ការទប់ស្កាត់ហានិភ័យបង្កដោយអំពើរត់ពន្ធមនុស្ស ------------------- ១១០

មេរៀនទី២ ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយភាពឈ្លាសវៃ ------------------------------------------ ១១៨

**ជំនួយស្មារតីសម្រាប់ការបង្រៀនស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស** ------- ១៣១

# ជំពូកទី ១ សិទ្ធិមនុស្ស




នៅសតវត្សទី២១នេះ ការគោរពសិទ្ធិ និងសេរីភាពរបស់មនុស្សមានការរីកចម្រើន និងរីកចម្រើនជឿនលឿនយ៉ាងខ្លាំង។ សេចក្ដីប្រកាស សន្ធិសញ្ញា និងកតិកាសញ្ញាអន្តរជាតិជាច្រើន ត្រូវបានបង្កើតឡើង ព្រមទាំងមានប្រទេសជាច្រើននៅលើសាកលលោកបានផ្តល់សច្ចាប័ន និងព្រមទទួលយកទៅអនុវត្ត។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានចែងយ៉ាងច្បាស់អំពីការទទួលស្គាល់សិទ្ធិ សេរីភាពរបស់មនុស្សដែលមានចែងនៅក្នុងអត្ថបទច្បាប់អន្តរជាតិផងដែរ។ ព្រះរាជាណាចក្រកម្ពុជា បានប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្សក្នុងដំណើរការគ្រប់គ្រងប្រទេស។ សិទ្ធិមនុស្ស និងសេរីភាពពលរដ្ឋបានក្លាយជាប្រធានបទពេញនិយមរបស់សង្គមស៊ីវិល អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសមាគមក្នុងស្រុក។ ការយល់ដឹងឱ្យបានច្បាស់អំពីអត្ថន័យសិទ្ធិនិងសេរីភាព ជាយន្តការនៃការប្រើប្រាស់សិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ ដើម្បីចៀសផុតពីការរំលោភបំពានគ្រប់ទម្រង់លើមនុស្ស ដូចជា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទ ការជួញដូរសរីរាង្គ ការពពោះជំនួស ការជួញដូរមនុស្ស។ល។ ដូចនេះ ក្នុងជំពូកស្ដីពីសិទ្ធិមនុស្ស យើងនឹងសិក្សាអំពីមេរៀនសំខាន់ៗដូចខាងក្រោម៖

- មេរៀនទី១ គោលការណ៍ទូទៅនៃសិទ្ធិមនុស្ស
- មេរៀនទី២ ព្រំដែននៃសេរីភាព
- មេរៀនទី៣ សិទ្ធិ និងករណីយកិច្ចរបស់ពលរដ្ឋ
- មេរៀនទី៤ សិទ្ធិចូលរួមក្នុងការអភិវឌ្ឍសង្គម។

មេរៀនទី ១

# គោលការណ៍ទូទៅនៃសិទ្ធិមនុស្ស

## ក- វត្ថុបំណង

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចរៀបរាប់បានអំពីប្រវត្តិនៃសិទ្ធិមនុស្ស អាចបែងចែកបានពីប្រភេទសិទ្ធិមនុស្ស ដើម្បីចូលរួមយ៉ាងសកម្មក្នុងការគោរព និងការពារសិទ្ធិមនុស្ស ចៀសផុតពីអំពើរំលោភបំពាន និងការជួញដូរមនុស្ស។

## ខ- សកម្មភាពផ្ដើម

ចូរពិនិត្យមើលរូបភាពខាងក្រោមតើអ្នកគិតថារូបភាពទាំងនោះពាក់ព័ន្ធទៅនឹងសិទ្ធិមនុស្សដូចម្ដេចខ្លះ?




## គ- ពាក្យគន្លឹះ

- *សិទ្ធិមនុស្ស:* សិទ្ធិមូលដ្ឋាន ជាអំណាចការពារស្របច្បាប់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សគ្រប់រូប។
- *សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ:* សិទ្ធិពីកំណើតដែលមនុស្សគ្រប់រូបមានដូចៗគ្នា មនុស្សត្រូវតែទទួលបានសិទ្ធិជាមូលដ្ឋានរួមមាន សិទ្ធិក្នុងការរស់នៅ សិទ្ធិទទួលនូវសេរីភាព (ជំនឿ ដើរហើរ ប្រកបរបរអាជីវកម្ម ការសិក្សា... សិទ្ធិសម្ដែងឆន្ទៈ ការធ្វើនយោបាយ...) សិទ្ធិទទួលនូវសុភមង្គល និងការប្រព្រឹត្តចំពោះគ្នាទៅវិញទៅមកដោយស្មើភាពគ្នានិងយុត្តិធម៌នៅក្នុងសង្គម។

- **សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌:** សិទ្ធិទទួលបានការងារសមស្រប មានការធានាសន្តិសុខសង្គម មានគ្រួសារ និងបានចូលរួមក្នុងជីវភាព សាសនា វប្បធម៌ ប្រពៃណី ដូចជាមានលំនៅដ្ឋាន ស្បៀងអាហារ ទឹក ការថែទាំសុខភាព និងការអប់រំដែលនាំឱ្យការរស់នៅមានសេចក្តីថ្លៃថ្នូរ។
- **រដ្ឋធម្មនុញ្ញ:** ច្បាប់កំពូលរបស់ប្រទេស។
- **សន្ធិសញ្ញា:** កិច្ចព្រមព្រៀងរវាងរដ្ឋនិងរដ្ឋ រដ្ឋនិងអង្គការអន្តរជាតិ អង្គការអន្តរជាតិនិងអង្គការអន្តរជាតិ លើកិច្ចការអ្វីមួយ ដើម្បីសម្រេចគោលបំណងរួមកម្រិតអន្តរជាតិ។
- **អនុសញ្ញា:** កិច្ចព្រមព្រៀងកម្រិតអន្តរជាតិដែលមានឋានានុក្រមភាពទាបជាងសន្ធិសញ្ញាអន្តរជាតិ មានចែងពីបទដ្ឋានដែលត្រូវបានទទួលស្គាល់ជាសកលក្នុងមជ្ឈដ្ឋាននៃប្រទេសជាសមាជិកនៅលើសាកលលោក។ អនុសញ្ញាមានវិសាលភាពខ្លាំងជាងកិច្ចព្រមព្រៀងអន្តរជាតិមួយប្រភេទហៅថាសេចក្តីប្រកាស។ នៅពេលដែលប្រទេសមួយផ្តល់សច្ចាប័នលើអនុសញ្ញា នោះអានុភាពភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ តម្រូវឱ្យមានការត្រួតពិនិត្យនិងវាយតម្លៃលើការប្រតិបត្តិក្នុងប្រទេសនោះ។

## ឃ- អត្ថបទអំណាន

សេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដោយមហាសន្និបាតអង្គការសហប្រជាជាតិ។ សេចក្តីប្រកាសនេះ ជាឧត្តមគតិរួមដែលប្រជាពលរដ្ឋគ្រប់ប្រទេសជាសមាជិក និងប្រជាជាតិទាំងអស់ត្រូវគោរពសិទ្ធិនិងសេរីភាពរបស់មនុស្ស ដោយមិនមានការរើសអើងតាមរយៈការបង្រៀននិងការអប់រំ ការទទួលស្គាល់និងការអនុវត្តជាសកលនូវវិធានការជាតិនិងអន្តរជាតិដែលមានលក្ខណៈរីកចម្រើនជាលំដាប់ក្នុងចំណោមប្រជាពលរដ្ឋនៃរដ្ឋសមាជិកទាំងអស់។

សម្រាប់ព្រះរាជាណាចក្រកម្ពុជា សិទ្ធិមនុស្សត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដែលមានកំណត់ក្នុងលិខិតូបករណ៍នៃអង្គការសហប្រជាជាតិ កតិកាសញ្ញា និងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ លើសពីនេះទៀតក៏បានកំណត់ថា ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់អ្នកដទៃឡើយ។

ដើម្បីចៀសផុតពីការរំលោភបំពានគ្រប់ទម្រង់លើមនុស្ស ជនគ្រប់រូបត្រូវមានការយល់ដឹងអំពីសិទ្ធិជាមូលដ្ឋានសំខាន់ៗមួយចំនួនដូចជា សិទ្ធិរស់រានមានជីវិត សិទ្ធិស្មើភាពចំពោះមុខច្បាប់ សិទ្ធិទទួលបានយុត្តិធម៌ សិទ្ធិឯកជន សិទ្ធិជ្រកកោន សិទ្ធិរៀបអាពាហ៍ពិពាហ៍និងបង្កើតគ្រួសារ សិទ្ធិជាម្ចាស់កម្មសិទ្ធិ សិទ្ធិចូលរួមក្នុងកិច្ចការសាធារណៈ សិទ្ធិទទួលបានសន្តិសុខសង្គម សិទ្ធិ

ការងារ សិទ្ធិសម្រាកនិងលំហែកម្សាន្ត សិទ្ធិទទួលបានការអប់រំ សិទ្ធិចូលរួមក្នុងជីវភាព (សាសនា វប្បធម៌ សិល្បៈ វិទ្យាសាស្ត្រនិងសេដ្ឋកិច្ច) និងសិទ្ធិរួចផុតពីអំពើជួញដូរមនុស្ស។

## ករណីសិក្សា

លោក **តុលា** និងអ្នកស្រី **បុប្ផា** បានរៀបការជាមួយគ្នាដោយស្របច្បាប់ មានកូនប្រុសម្នាក់ និងផ្ទះមួយខ្នង។ ដោយមានបំណុលច្រើន លោក **តុលា** បានសម្រេចចិត្តទៅធ្វើជាកម្មករនៅក្រៅប្រទេស ប៉ុន្តែមិនបានទៅតាមភ្នាក់ងារបញ្ជូនពលករស្របច្បាប់នោះទេ។ ក្នុងអំឡុងពេល៣ឆ្នាំនៃការងារនៅក្រៅប្រទេស លោក **តុលា** មិនបានទទួលប្រាក់កម្រៃពេញលេញ និងមិនអាចធ្វើទំនាក់ទំនងមកក្រុមគ្រួសារបានឡើយ។ អ្នកស្រី **បុប្ផា** និងកូន មានការលំបាកយ៉ាងខ្លាំងក្នុងការសងបំណុលគេ ហើយបានគិតថាប្តីនិងឪពុករបស់ខ្លួនបានស្លាប់នៅឯក្រៅប្រទេសបាត់ទៅហើយ។ រយៈពេល៣ឆ្នាំកន្លងផុតទៅ លោក **តុលា** បានសម្រេចចិត្តវិលត្រឡប់មកស្រុកកំណើតវិញ។ ពេលមកដល់ផ្ទះ លោកស្រី **បុប្ផា** មិនអនុញ្ញាតឱ្យប្តីចូលផ្ទះនោះទេ ព្រោះយល់ថា ទំនាក់ទំនងរបស់អ្នកទាំងពីរបានដាច់គ្នាទៅហើយ។ លោក **តុលា** មិនសុខចិត្តចំពោះការសម្រេចរបស់ប្រពន្ធទេ និងបានទៅប្តឹងលោកមេភូមិជួយដោះស្រាយ។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

- មាត្រា៣១... ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិ សេរីភាពរបស់បុគ្គលម្នាក់ៗ មិនត្រូវបំពានដល់សិទ្ធិ សេរីភាពអ្នកដទៃ។ ការប្រើសិទ្ធិ សេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌក្នុងច្បាប់កំណត់...។

### ២- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សៈ

- មាត្រា៣ សិទ្ធិរស់រានមានជីវិត ...បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន...។
- មាត្រា២២ សិទ្ធិទទួលបានសន្តិសុខសង្គមៈ... មនុស្សគ្រប់រូបក្នុងឋានៈជាសមាជិកមួយរូបនៃសង្គម មានសិទ្ធិទទួលបានសន្តិសុខសង្គម និងមានបុព្វសិទ្ធិក្នុងការ

សម្រេចបានសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដែលចាំបាច់មិនអាចអត់បាន សម្រាប់សេចក្តីថ្លៃថ្នូរ និងវឌ្ឍនកម្មដោយសេរីនៃបុគ្គលិកលក្ខណៈរបស់ខ្លួនតាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់ជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិស្របតាមការរៀបចំ និងតាមធនធានរបស់ប្រទេសនីមួយៗ...។

- មាត្រា២៣ សិទ្ធិការងារៈ ...មនុស្សគ្រប់រូបមានសិទ្ធិធ្វើការជ្រើសរើសការងារដោយសេរី និងធ្វើការងារក្នុងលក្ខខណ្ឌត្រឹមត្រូវនិងពេញលេញ ព្រមទាំងការពារប្រឆាំងនឹងភាពអត់ការងារធ្វើ...។ ... មនុស្សគ្រប់រូបមានសិទ្ធិទទួលប្រាក់បៀវត្សស្មើគ្នា ចំពោះការងារដូចគ្នា ដោយគ្មានការរើសអើង។ ...អ្នកធ្វើការងារមានសិទ្ធិទទួលបានលាភសក្ការៈដោយសមធម៌ និងពេញចិត្ត ដើម្បីធានាអាទិភាពរស់នៅរបស់ខ្លួននិងគ្រួសារឱ្យសមស្របទៅនឹងសេចក្តីថ្លៃថ្នូរនៃមនុស្ស និងត្រូវបានបំពេញបន្ថែមទៀតតាមមធ្យោបាយផ្សេងៗនៃការការពារផ្នែកសង្គមប្រសិនបើចាំបាច់។ ...មនុស្សគ្រប់រូបមានសិទ្ធិបង្កើត និងចូលរួមក្នុងការងារសហជីពដើម្បីការពារផលប្រយោជន៍របស់ខ្លួន។
- មាត្រា២៤ សិទ្ធិសម្រាកនិងលំហែកម្សាន្តៈ ...មនុស្សគ្រប់រូបមានសិទ្ធិសម្រាកនិងលំហែកម្សាន្តរួមបញ្ចូលទាំងកម្រិតម៉ោងការងារសមហេតុផលនិងការឈប់សម្រាកដោយបានប្រាក់បៀវត្សតាមពេលកំណត់...។
- មាត្រា២៥ សិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ៈ ...មនុស្សគ្រប់រូបមានសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ ដើម្បីធានាសុខភាព និងសុខុមាលភាពរបស់ខ្លួននិងគ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត។ មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការគាំពារនៅពេលគ្មានការងារធ្វើ មានជំងឺ ពិការ មេម៉ាយ ឬពោះម៉ាយ ចាស់ជរា ឬនៅពេលបាត់បង់មធ្យោបាយធានាជីវភាពដែលបណ្តាលមកពីកាលៈទេសៈផុតពីឆន្ទៈរបស់ខ្លួន...។
- មាត្រា៣០ សិទ្ធិមិនអាចលក់ ដូរ ផ្ទេរ ឬដកហូតបានៈ ...គ្មានបទប្បញ្ញត្តិណាមួយនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សអាចត្រូវបានបកស្រាយដែលបណ្តាលឱ្យរដ្ឋ ក្រុម ឬបុគ្គលណាមួយមានសិទ្ធិបែបណាមួយដើម្បីធ្វើសកម្មភាព ឬប្រព្រឹត្តអំពើអ្វីមួយសំដៅបំផ្លិចបំផ្លាញនូវសិទ្ធិ និងសេរីភាពទាំងឡាយដែលមានចែងក្នុងសេចក្តីប្រកាសនេះបានឡើយ...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១ -ហេតុអ្វីបានជាលោក តុលា ត្រូវចាកចេញទៅក្រៅប្រទេស?

២- តើករណីរបស់លោកតុលាអាចចាត់ទុកជាអំពើជួញដូរមនុស្សដែរ ឬទេ? ហេតុអ្វី?

៣- តើការប្តឹងទាមទារសិទ្ធិជាស្វាមី របស់លោក តុលា ពាក់ព័ន្ធការអនុវត្តសិទ្ធិមនុស្សដែរឬទេ? ហេតុអ្វី?

៤- ប្រសិនបើអ្នក ជាមេភូមិ តើអ្នកត្រូវដោះស្រាយករណីប្តឹងផ្តល់ រវាងប្តីនិងប្រពន្ធខាងលើនេះយ៉ាងដូចម្តេចដែរ?

## ច- កិច្ចការផ្ទះ

១- ចូរចាត់ប្រភេទសិទ្ធិមនុស្សខាងក្រោម តាមចំណាត់ថ្នាក់ ចង្កោមរបស់សិទ្ធិមនុស្ស រួមមានសិទ្ធិពលរដ្ឋនិងនយោបាយ និងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

| | |
|---|---|
| ១- សេរីភាពក្នុងការនិយាយស្តី | ៩- សិទ្ធិរៀបអាពាហ៍ពិពាហ៍ |
| ២- សេរីភាពក្នុងការផ្សាយព័ត៌មាន | ១០- សិទ្ធិសម្រាកលំហែកាយ |
| ៣- សេរីភាពក្នុងការប្រជុំ | ១១- សិទ្ធិដើម្បីមានសន្តិសុខសង្គម |
| ៤- សិទ្ធិក្នុងការបោះឆ្នោត | ១២- សិទ្ធិទទួលការអប់រំ |
| ៥- សិទ្ធិក្នុងការបង្កើតគណបក្សនយោបាយ | ១៣- សិទ្ធិទទួលព័ត៌មាន |
| ៦- សិទ្ធិមានកម្មសិទ្ធិផ្ទាល់ខ្លួន | ១៤- សិទ្ធិក្នុងការប្រើប្រាស់ភាសា |
| ៧- សិទ្ធិលក់ដូរទ្រព្យសម្បត្តិស្របច្បាប់ | ១៥- សិទ្ធិជំនឿសាសនា។ |
| ៨-សិទ្ធិជ្រើសរើសការងារតាមសមត្ថភាព | |

| **សិទ្ធិពលរដ្ឋនិងនយោបាយ** | **សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌** |
|---|---|
| - ........................................ | - ........................................ |
| - ........................................ | - ........................................ |
| - ........................................ | - ........................................ |
| - ........................................ | - ........................................ |
| - ........................................ | - ........................................ |
| - ........................................ | - ........................................ |

២- តើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សត្រូវបានប្រកាសឱ្យប្រើឆ្នាំណា?

៣- ដើម្បីចៀសឱ្យផុតពីអំពើកេងប្រវ័ញ្ចពលកម្មលើមនុស្ស តើអ្នកត្រូវមានការយល់ដឹងអំពីសិទ្ធិអ្វីខ្លះ?

៤- តើចំណុចត្រង់ណាខ្លះដែលបញ្ជាក់ថាប្រទេសកម្ពុជាព្រមគោរព និងអនុវត្តតាមគោលការណ៍សិទ្ធិមនុស្ស ដែលមានកំណត់ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស?

៥- តើមនុស្ស អាចជាកម្មវត្ថុនៃការលក់ ដូរ ដូចវត្ថុបានដែរឬទេ? ហេតុអ្វី?

មេរៀនទី ២

# ព្រំដែននៃសេរីភាព

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សានឹងអាចកំណត់បានពីអត្ថន័យនៃព្រំដែននៃសេរីភាពរបស់មនុស្សបានច្បាស់លាស់ និងអាចប្រើប្រាស់សេរីភាពរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ ដើម្បីចៀសផុតពីអំពើជួញដូរមនុស្ស ព្រមទាំងអាចបង្កើតបំណិនចូលរួមបង្ការ ទប់ស្កាត់គ្រោះថ្នាក់ទាំងនោះ។

## ខ- សកម្មភាពផ្ដើម

ចូរបកស្រាយសកម្មភាពពាក់ព័ន្ធនឹងការប្រើប្រាស់សេរីភាពក្នុងការស្វែងរកការងារធ្វើដែលបង្ហាញនៅក្នុងរូបខាងក្រោមនេះ។




## គ- ពាក្យគន្លឹះ

- **សេរីភាព:** ការប្រើប្រាស់សិទ្ធិក្នុងការប្រព្រឹត្តទង្វើអ្វីមួយដែលមិនប្រាសចាកពីដែនកំណត់នៃច្បាប់ និងមិនប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។ ឧទាហរណ៍: មនុស្ស អាចដើរហើរគ្រប់ទីកន្លែង អាចប្រកបមុខរបរគ្រប់ប្រភេទ អាចនិយាយអ្វីក៏បាន អាចមើលអ្វីក៏បាន អាចស្ដាប់អ្វីក៏បាន និងធ្វើអ្វីៗដែលមនុស្សចង់ធ្វើ ឱ្យតែស្របតាមច្បាប់ និងមិនរំខាន ឬប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ។

- **សិទ្ធិ:** អំណាចដែលមនុស្សមានពីកំណើត អ្វីៗដែលមនុស្សត្រូវការជាចាំបាច់ដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរជាមនុស្ស និងប្រើប្រាស់ជាឧបករណ៍សម្រាប់ការពារទប់ស្កាត់ការធ្វើទុក្ខបុកម្នេញពីអ្នកដទៃ។
- **ព្រំដែន:** ខណ្ឌសីមា ការកម្រិត ការកំណត់ ដែនកំណត់។
- **ច្រករបៀង:** គន្លងផ្លូវដែលមនុស្សអាចដើរឆ្លងកាត់ទៅវិញទៅមកនៅតាមព្រំដែន។ ច្រកទ្វារសម្រាប់ឆ្លងកាត់ព្រំដែនរវាងប្រទេសពីរ ដែលមិនទាន់មានការទទួលស្គាល់ជាផ្លូវការនៅឡើយ។

## ឃ- អត្ថបទអំណាន

សិទ្ធិនិងសេរីភាពរបស់មនុស្សមានការវិវត្ត និងរីកចម្រើនជឿនលឿនយ៉ាងខ្លាំង។ សេចក្តីប្រកាស សន្ធិសញ្ញា និងកតិកាសញ្ញាអន្តរជាតិជាច្រើនត្រូវបានបង្កើត ព្រមទាំងមានប្រទេសជាច្រើននៅលើពិភពលោកបានប្រកាសទទួលស្គាល់ និងព្រមទទួលយកទៅអនុវត្ត។ សេរីភាពទាំងនោះរួមមាន សេរីភាពរួចផុតពីទាសភាព សេរីភាពរួចផុតពីទារុណកម្ម សេរីភាពរួចផុតពីការឃុំខ្លួនដោយបំពាន សេរីភាពដើរហើរ សេរីភាពខាងសាសនា ឬជំនឿ សេរីភាពនៃការសម្តែងមតិ សេរីភាពជួបជុំ។ល។ ដោយហេតុថាការប្រើសេរីភាពរបស់មនុស្សម្នាក់ៗត្រូវចំណុះក្រោមលក្ខខណ្ឌសង្គម ការកំណត់អំណាចនៃការប្រើសេរីភាពត្រូវបានចែងក្នុងច្បាប់និងបទដ្ឋានគតិយុត្តនៃប្រទេសនីមួយៗ។ ទោះជាក្នុងសង្គមណាដែលប្រកាន់យកការគោរពសេរីភាពជាធំក៏ដោយ ក៏រដ្ឋមិនឱបដៃនៅស្ងៀមចំពោះការប្រើប្រាស់សេរីភាពហួសព្រំដែនរបស់សមាជិកសង្គមម្នាក់ៗឡើយ ព្រោះថាការប្រើប្រាស់សេរីភាពគ្មានព្រំដែនរបស់មនុស្សម្នាក់អាចប៉ះពាល់ដល់អ្នកដទៃ និងសង្គមទាំងមូល។ សម្រាប់ព្រះរាជាណាចក្រកម្ពុជា សិទ្ធិមនុស្ស និងសេរីភាពពលរដ្ឋត្រូវបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ពាក់ព័ន្ធជាច្រើន ដូចជា ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីការអប់រំ ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គមជាដើម ដែលជាវិធានសម្រាប់គ្រប់គ្រងការប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងនោះ។ ដូចនេះ នៅពេលមនុស្សមានការយល់ដឹងអំពីសេរីភាព និងព្រំដែននៃការប្រើប្រាស់សេរីភាពធ្វើឱ្យមនុស្សរស់នៅប្រកបដោយសេចក្តីសុខ សុវត្ថិភាព សុភមង្គល រួចចាកផុតពីអំពើអមនុស្សធម៌ផ្សេងៗ ដូចជា ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភបំពានផ្លូវភេទ ការជួញដូរសរីរាង្គ និងការពពោះជំនួស។ល។

### ករណីសិក្សា

ក្រោយពីបានបោះបង់ការសិក្សាត្រឹមថ្នាក់ទី៩ **ពិសិដ្ឋ** បានស្វះស្វែងរកការងារធ្វើដើម្បីបានប្រាក់កម្រៃមកផ្គត់ផ្គង់តម្រូវការរបស់ខ្លួន និងគ្រួសារដែលបាននិងកំពុងជួបការលំបាក។ ថ្ងៃមួយ **ពិសិដ្ឋ** បានជួបនឹងវិសាល ដែលជាមិត្តភក្តិ និងបានបបួលគ្នាធ្វើចំណាកស្រុកទៅរកការងារនៅ

ប្រទេសជិតខាង។ វិសាលបានរៀបរាប់ប្រាប់ **ពិសិដ្ឋ** អំពីស្ថានភាពនៃការធ្វើចំណាកស្រុក និងការធ្វើការងារនៅប្រទេសជិតខាងនោះ ថាមិនមានការរារាំង ឬបង្ខិតបង្ខំណាមួយឡើយ ព្រមទាំងទទួលបានប្រាក់ខែច្រើន ដែលអាចទ្រទ្រង់ជីវភាពគ្រួសារបានធូរធារដូចគ្រួសាររបស់អ្នកជិតខាងគាត់ម្នាក់នៅក្នុងភូមិ។

សប្តាហ៍បន្ទាប់ **ពិសិដ្ឋ** ក៏បានចាកចេញពីស្រុកកំណើតទៅរកការងារធ្វើតាមការណែនាំរបស់ **វិសាល** ដោយមិនមានឯកសារពាក់ព័ន្ធក្នុងការធ្វើដំណើរ។ អ្នកទាំងពីរបានណាត់គ្នាចេញដំណើរតាមរថយន្តឈ្នួល ទៅកន្លែងគោលដៅដែលត្រូវឆ្លងកាត់ច្រករបៀងតាមព្រំដែន។ ជាភ័ព្វសំណាង **ពិសិដ្ឋ** បានឆ្លងផុតទៅដល់កន្លែងគោលដៅដែល **វិសាល** បានណែនាំ ហើយបានចូលធ្វើការនៅកន្លែងមួយ។ អស់រយៈពេលពីរឆ្នាំ **ពិសិដ្ឋ** បានដាច់ទំនាក់ទំនងជាមួយក្រុមគ្រួសារ និងសាច់ញាតិ និងមិនបានដឹងថាគ្រួសារមានសុខទុក្ខយ៉ាងណាឡើយ។ ក្រោយមកក្រុមគ្រួសារបានទទួលដំណឹងថា **ពិសិដ្ឋ** ត្រូវបានចាញ់បោកគេ ដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម មិនទទួលបានប្រាក់កម្រៃ និងទទួលរងនូវអំពើហិង្សាពីថៅកែជាច្រើនលើកច្រើនសារហូតដល់មានពិការភាពដៃម្ខាងទៀតផង។ ដោយមានការគាំទ្រជួយយកអាសាពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច **ពិសិដ្ឋ** អាចមានវាសនាវិលត្រឡប់មកជួបជុំគ្រួសារនៅស្រុកកំណើតវិញ។

## ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ៖

### ១- រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣

- មាត្រា៣១ ... ការប្រើប្រាស់សិទ្ធិសេរីភាពដោយបុគ្គលម្នាក់ៗ មិនត្រូវប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។
- មាត្រា៣២ ...ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន  ហើយទោសប្រហារជីវិត មិនត្រូវឱ្យមានឡើយ...។
- មាត្រា៤០ ...សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋត្រូវបានគោរព។ ប្រជាពលរដ្ឋខ្មែរ អាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន...។
- មាត្រា៤១ ...ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ...។

## ២- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស

- មាត្រា២ សេរីភាពរួចផុតពីការរើសអើងៈ ...មនុស្សម្នាក់ៗអាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលបានប្រកាសក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀតដើមកំណើតជាតិឬសង្គម ទ្រព្យសម្បត្តិកំណើតឬស្ថានភាពដទៃទៀតឡើយ។ លើសពីនេះមិនត្រូវធ្វើការប្រកាន់បែងចែកណាមួយដោយសំអាងទៅលើឋានៈខាងនយោបាយ យុត្តាធិការ អន្តរជាតិរបស់ប្រទេស ឬដែនដីដែលបុគ្គលណាម្នាក់រស់នៅទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យ ក្រោមអាណាព្យាបាល ឬគ្មានស្វ័យគ្រប់គ្រងក្តី ឬស្ថិតក្រោមការដាក់កម្រិតផ្សេងទៀតណាមួយនៃអធិបតេយ្យភាពក្តី...។
- មាត្រា៤ សេរីភាពរួចផុតពីទាសភាពៈ ...គ្មានជនណាម្នាក់ ត្រូវស្ថិតក្នុងទាសភាព ឬស្ថិតក្នុងភាពជាអ្នកបម្រើដាច់ថ្លៃឡើយ។ ទាសភាព និងទាសពាណិជ្ជកម្ម តាមគ្រប់ទម្រង់ទាំងអស់ត្រូវហាមឃាត់...។
- មាត្រា៥ សេរីភាពរួចផុតពីទារុណកម្មៈ ...គ្មានជនណាម្នាក់ត្រូវទទួលរងការធ្វើទារុណកម្មប្រព្រឹត្តកម្មលើខ្លួន ឬទណ្ឌកម្មឯទៀតដែលឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ...។
- មាត្រា៩ សេរីភាពរួចផុតពីការឃុំខ្លួនដោយបំពានៈ ...គ្មានជនណាម្នាក់ ត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬនិរទេសខ្លួន ដោយបំពានឡើយ...។

# ខ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- ហេតុអ្វីបានជាពិសិដ្ឋធ្វើចំណាកស្រុក?

២- តើការធ្វើចំណាកស្រុករបស់ ពិសិដ្ឋ ត្រឹមត្រូវដែរ ឬទេ? ហេតុអ្វី?

៣- តើការប្រើប្រាស់សេរីភាពក្នុងការធ្វើដំណើរទៅរកការងារធ្វើរបស់**ពិសិដ្ឋ**ត្រឹមត្រូវដែរ ឬទេ? ហេតុអ្វី?

៤- តើបញ្ហាអ្វីខ្លះដែល**ពិសិដ្ឋ**បានជួបប្រទះក្នុងអំឡុងពេលប្រកបការងារនៅក្រៅប្រទេសកំណើត? ហេតុអ្វី?

៥- តើពិការភាពរបស់ **ពិសិដ្ឋ** អាចក្លាយជារបាំងសិទ្ធិសេរីភាពមនុស្សដែរឬទេ? ហេតុអ្វី?

៦- ប្រសិនបើអ្នកជា **ពិសិដ្ឋ** នៅពេលទទួលរងអំពើហិង្សាពីសំណាក់ថៅកែ តើអ្នកត្រូវដោះស្រាយយ៉ាងដូចម្តេច? ហេតុអ្វីបានជា ពិសិដ្ឋ មិនអាចដោះស្រាយដូចអ្នកបាន?

## ច- កិច្ចការផ្ទះ

១- ចូរផ្ទៀងផ្ទាត់សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សដែលមានចែងក្នុងច្បាប់និងបទដ្ឋានគតិយុត្តខាងលើរួចឆ្លើយសំណួរខាងក្រោម៖

- តើសេរីភាពជាអ្វី?
- តើព្រំដែននៃសេរីភាពត្រូវអនុវត្តយ៉ាងដូចម្តេចខ្លះ ដើម្បីធានាបានសន្តិសុខ និងជាសុកភាពសង្គម?

២- ចូរធ្វើការស្រាវជ្រាវ ជ្រើសរើស និងបរិយាយសកម្មភាពចំនួនបីដែលជាការប្រើប្រាស់សេរីភាពបានត្រឹមត្រូវ និងចំនួនបីទៀតមិនត្រឹមត្រូវសម្រាប់ការអភិវឌ្ឍសង្គម។

| ការប្រើប្រាស់សេរីភាពបានត្រឹមត្រូវ | ការប្រើប្រាស់សេរីភាពមិនបានត្រឹមត្រូវ |
|---|---|
| ១............................................. | ក................................................... |
| ២............................................. | ខ................................................... |
| ៣............................................. | គ................................................... |

## មេរៀនទី ៣ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋ

### ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចពណ៌នាបានអំពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍសហគមន៍ ដោយអនុវត្តសិទ្ធិ និងករណីយកិច្ចរបស់ខ្លួនស្របតាមច្បាប់កំណត់ ដើម្បីចៀសផុតពីអំពើជួញដូរមនុស្ស។

### ខ- សកម្មភាពផ្តើម

ចូរសង្កេតរូបភាពខាងក្រោម រួចបង្ហាញពីអត្ថន័យនៃរូបភាពទាំងនោះ ដែលពាក់ព័ន្ធទៅនឹងសិទ្ធិនិងករណីយកិច្ចរបស់ពលរដ្ឋចូលរួមអភិវឌ្ឍសង្គម។




### គ- ពាក្យគន្លឹះ

- **ករណីយកិច្ច:** កិច្ចការអ្វីមួយដែលគប្បីធ្វើឆ្លើយតបទៅនឹងទំនោរប្រពៃណី ឬទំនៀមទម្លាប់។
- **កាតព្វកិច្ច:** កិច្ចការដែលតម្រូវឱ្យបំពេញតាមច្បាប់កំណត់។
- **អំពើល្មើស:** ការប្រព្រឹត្តខុសប្រឆាំងនឹងច្បាប់កំណត់។

### ឃ- អត្ថបទអំណាន

ពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចនិងករណីយកិច្ចចូលរួមអភិវឌ្ឍសង្គមទៅតាមសមត្ថភាពនិងលទ្ធភាពរបស់ខ្លួន។ ពលរដ្ឋម្នាក់ៗ ត្រូវធ្វើខ្លួនឱ្យមានប្រយោជន៍ចំពោះសង្គមមានទំនួលខុសត្រូវចំពោះការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ត្រូវចេះអភិវឌ្ឍជំនាញធ្វើជាមនុស្សល្អ មិនបង្កភាពអសកម្មដល់សង្គម ។ ពលរដ្ឋគ្រប់រូបត្រូវគោរពច្បាប់ មិនគេចវេះពីកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ មិនបំផ្លាញសម្បត្តិសាធារណៈ និងមិនបង្កគ្រោះភ័យដល់សង្គម។ ពលរដ្ឋគ្រប់រូប ត្រូវចូលរួមសកម្មភាពផ្សេងៗទៀតនៅក្នុងសង្គមជីវភាពប្រចាំថ្ងៃ ដូចជាការលុបបំបាត់អំពើហិង្សា ការដាំដើមឈើបង្កើនប្រសិទ្ធភាព

គម្រប់បែតងឡើងវិញ ការថែរក្សាបរិស្ថាន ការថែរក្សាសម្បត្តិសាធារណៈ ការធានាសុខដុមនីយកម្ម ក្នុងគ្រួសារនិងសង្គម និងការលុបបំបាត់អំពើជួញដូរមនុស្ស។ល។ ករណីយកិច្ចដែលពលរដ្ឋម្នាក់ៗ ត្រូវបំពេញមាន ចំពោះខ្លួនឯង គ្រួសារ មាតាបិតា សហគមន៍ និងសង្គមជាតិ។

### ១- ករណីយកិច្ចចំពោះខ្លួនឯង

ពលរដ្ឋម្នាក់ៗ ត្រូវមានករណីយកិច្ចៈ

- ប្រឹងប្រែងសិក្សារៀនសូត្របង្កើតជំនាញធ្វើខ្លួនឱ្យក្លាយជាជនមានប្រយោជន៍ចំពោះ សង្គមជាតិ ជាមនុស្សល្អ មិនបង្កភាពអសកម្មដល់សង្គម មានការទទួលខុសត្រូវចំពោះ គ្រួសារ និងចំពោះមុខងារដែលខ្លួនទទួលបន្ទុក
- ចូលរួមកសាង និងអភិវឌ្ឍប្រទេសជាតិទៅតាមសមត្ថភាពនិងលទ្ធភាពរបស់ខ្លួន
- ថែទាំសុខភាព និងអនាម័យ បង្ការជំងឺឆ្លងគ្រប់ប្រភេទ
- បង្កើតកេរ្តិ៍ឈ្មោះល្អ មានកិត្តិយសនៅក្នុងគ្រួសារ សហគមន៍ និងសង្គមដែលខ្លួន ប្រាស្រ័យការងារ និងរស់នៅ
- មិនធ្វើឱ្យអ្នកដទៃរងការឈឺចាប់ ឬមានគ្រោះថ្នាក់ដោយសារខ្លួន។

### ២- ករណីយកិច្ចចំពោះគ្រួសារ

ពលរដ្ឋម្នាក់ៗ ត្រូវមានករណីយកិច្ចៈ

- កសាង និងផ្តល់សុភមង្គលដល់គ្រួសារ
- ធ្វើគំរូល្អដល់សមាជិកគ្រួសារ និងអ្នកជុំវិញខ្លួន
- ធ្វើឱ្យសមាជិកគ្រួសារម្នាក់ៗ ចេះគោរពស្រឡាញ់គ្នាទៅវិញទៅមក ចេះជួយយកអាសារ គ្នាទៅវិញទៅមក
- ចិញ្ចឹមបីបាច់ថែរក្សា ការពារ និងអប់រំកូនចៅឱ្យក្លាយជាមនុស្សល្អ ស្គាល់តួនាទីជាស្វាមី ភរិយា កូន បង ប្អូន ឬញាតិសន្តាន
- មាតាបិតា ឬអ្នកអាណាព្យាបាលត្រូវ ជ្រើសរើសកម្មវិធីអប់រំនិងគ្រឹះស្ថានសិក្សា ដែល សមស្របដល់កូនចៅៈ
  - ✓ ទទួលបានព័ត៌មាននិងរបាយការណ៍នៃការសិក្សាពីគ្រឹះស្ថានសិក្សារបស់កូន
  - ✓ ចូលរួមយ៉ាងសកម្មនិងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់សាលារៀន និងថ្នាក់ជាតិដោយផ្ទាល់ឬដោយតំណាង
  - ✓ នាំកូនដែលមានអាយុចាប់ពី៦ឆ្នាំឬយ៉ាងទាបបំផុត៧០ខែឡើង ទៅចុះឈ្មោះចូល សិក្សានៅថ្នាក់ទី១នៅសាលារៀន
  - ✓ ខិតខំឱ្យអស់លទ្ធភាព ដើម្បីគាំទ្រការសិក្សារបស់កូនជាពិសេសចំពោះការអប់រំកម្រិត មូលដ្ឋាន

✓ យកចិត្តទុកដាក់ផ្សារភ្ជាប់សាលារៀន គ្រួសារ សហគមន៍ដើម្បីចូលរួមជួយបណ្ដុះបណ្ដាល និងកែលម្អបរិស្ថានសិក្សា។

### ៣- កាតព្វកិច្ចចំពោះសហគមន៍ និងសង្គមជាតិ

ពលរដ្ឋម្នាក់ៗ មានកាតព្វកិច្ចត្រូវ៖

- គោរពតាមដោយការទទួលខុសត្រូវចំពោះច្បាប់របស់រដ្ឋ
- បំពេញតួនាទីការពារជាតិមាតុភូមិ
- អនុវត្តការបង់ពន្ធជូនរដ្ឋដើម្បីចូលរួមចំណែកកសាង អភិវឌ្ឍប្រទេសជាតិ
- ប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យស្របតាមសីលធម៌ និងច្បាប់សង្គមដោយមិនឱ្យប៉ះពាល់សិទ្ធិអ្នកដទៃ
- ចូលរួមលុបបំបាត់អំពើហិង្សាគ្រប់រូបភាព
- ចូលរួមសម្អាត ថែរក្សាបរិស្ថានគ្រប់ទីកន្លែង
- គោរពសិទ្ធិនិងផលប្រយោជន៍របស់អ្នកដទៃ
- ចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន
- គោរពសិទ្ធិជនពិការ និងជនជាតិផ្សេងៗ
- គោរពច្បាប់ចរាចរណ៍
- ចូលរួមរាយការណ៍ករណីជួបប្រទះឬឃើញ អំពើជួញដូរមនុស្ស អំពើជួញដូរ ដាំដុះ ដឹកជញ្ជូន រក្សាទុក ឬប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងអំពើវិទ្ធង្សនាបំផ្លិចបំផ្លាញជាតិ។

## ករណីសិក្សា

**សៅ** មានអាយុ១៤ឆ្នាំ បានបោះបង់ចោលការសិក្សា និងជឿតាមមេខ្យល់ចេញទៅរកការងារនៅប្រទេសជិតខាង តែបរាជ័យខាតទាំងប្រាក់កាសដែលបានផ្ដល់ឱ្យមេខ្យល់ ក៏សម្រេចចិត្តមកប្រកបមុខរបរជាជាងបាញ់ថ្នាំម៉ូតូវិញ។ ពេលខ្លះ **សៅ** បានចូលរួមធ្វើជាអ្នកបើកបរម៉ូតូប្រណាំងធុនធំ ដើម្បីបានកម្រៃបន្ថែម។ ជាទម្លាប់រាល់ពេលបើកបរម៉ូតូ **សៅ** តែងប្រើល្បឿនលឿន និងពេលខ្លះជិះបញ្ច្រាសទិសទៀតផង។ ថ្ងៃមួយ **សៅ** និងក្រុមមិត្តបានជួបគ្រោះថ្នាក់ចរាចរណ៍ដែលបណ្ដាលឱ្យ **សៅ** បាត់បង់ជីវិតភ្លាមៗនៅនឹងកន្លែងកើតហេតុ។ មិត្តរបស់**សៅ** ម្នាក់ទៀតបានបាត់បង់ជីវិតពេលដឹកទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកមួយ។ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នាពេលនោះ ក៏មានជនរងគ្រោះ២នាក់ផ្សេងទៀតបានបាត់បង់ជីវិតផងដែរ ហើយសពត្រូវបានក្រុមគ្រួសារដឹកយកទៅធ្វើបុណ្យតាមប្រពៃណីរៀងខ្លួន។ ដោយឡែកម៉ូតូទាំង២គ្រឿងរបស់ **សៅ** និងមិត្ត ត្រូវបានសមត្ថកិច្ចយកទៅរក្សាទុកនៅអធិការដ្ឋាននគរបាលស្រុក។

## ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ៖

### ១- រដ្ឋធម្មនុញ្ញ

ជំពូកទី៣ អំពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

- មាត្រា៤៩ ...ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញនិងគោរពច្បាប់។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ...។
- មាត្រា៥០ ...ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈនិងកម្មសិទ្ធិស្របច្បាប់របស់ឯកជន...។

### ២- ច្បាប់ស្តីពីការអប់រំ

- មាត្រា៣៥ ...បានកំណត់អំពីករណីយកិច្ចរបស់អ្នកសិក្សា... "ត្រូវគោរពបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សា តម្លៃខាងសមធម៌យេនឌ័រដោយអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងខិតខំសិក្សាអស់ពីលទ្ធភាពដើម្បីទទួលបានការអភិវឌ្ឍចំណេះដឹង ជំនាញ សមត្ថភាព បញ្ញា និងសេចក្តីថ្លៃថ្នូរ...។
- មាត្រា៣៦ ...កំណត់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់មាតាបិតា ឬអ្នកអាណាព្យាបាលក្នុងការចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិដោយផ្ទាល់ ឬតាមតំណាងរបស់ខ្លួន...។ ...ករណីយកិច្ចរបស់មាតាបិតា ឬអ្នកអាណាព្យាបាលចំពោះការអប់រំរបស់អនីតិជនដែលស្ថិតនៅក្នុងបន្ទុកដូចជា នាំកូនអាយុគ្រប់៦ (ប្រាំមួយ) ឆ្នាំ ឬទាបបំផុត៧០ (ចិតសិប) ខែឡើងទៅចុះឈ្មោះចូលរៀននៅថ្នាក់ទី១ នៃកម្មវិធីអប់រំចំណេះទូទៅ ខិតខំអស់លទ្ធភាពដើម្បីគាំទ្រការសិក្សារបស់អ្នកសិក្សាជាពិសេសចំពោះការអប់រំកម្រិតមូលដ្ឋាន យកចិត្តទុកដាក់ផ្សារភ្ជាប់សាលារៀន គ្រួសារ និងសហគមន៍ដើម្បីចូលរួមជួយបណ្តុះបណ្តាល និងកែលម្អបរិស្ថានសិក្សា...។
- មាត្រា៣៧ ...បានកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចបុគ្គលិកអប់រំ ដែលបុគ្គលិកអប់រំមានកាតព្វកិច្ចគោរពក្រមសីលធម៌វិជ្ជាជីវៈ បំពេញកាតព្វកិច្ចផ្សេងទៀតដែលមានចែងក្នុងច្បាប់ជាធរមាន និងអនុវត្តនិងអភិវឌ្ឍការងាររបស់ខ្លួនដោយយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

- តើការប្រើប្រាស់សិទ្ធិសេរីភាពរបស់ **សៅ** ពាក់ព័ន្ធទៅនឹងការសិក្សា ការស្វែងរកការងារ និងការរកកម្រៃបន្ថែម ត្រឹមត្រូវដែរឬទេ?

- តើការមិនគោរពកាតព្វកិច្ចជាពលរដ្ឋល្អរបស់សៅ បង្កគ្រោះថ្នាក់អ្វីខ្លះដល់អ្នកដទៃ និងសង្គម?
- តើគ្រោះថ្នាក់ចរាចរណ៍បណ្ដាលមកពីកត្តាអ្វីខ្លះ? តើកត្តាអ្វីខ្លះដែលបង្កឱ្យមានគ្រោះថ្នាក់ញឹកញាប់ជាងគេ? ចូរបកស្រាយ។
- តើមានបទល្មើសអ្វីខ្លះ ក្នុងអត្ថបទករណីសិក្សាខាងលើ?
- តើបទល្មើសទាំងនោះ មានផលប៉ះពាល់អ្វីខ្លះដល់សង្គម?
- ក្នុងនាមជាយុវជនវ័យក្មេង តើអ្នកត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីលុបបំបាត់បទល្មើសទាំងនោះ?

## ច- កិច្ចការផ្ទះ

១- តើកាកសំណល់សារធាតុគីមី ដែលបង្ហាញក្នុងរូបភាពខាងក្រោម អាចជះឥទ្ធិពលមកលើសង្គម មនុស្ស សត្វ និងបរិស្ថានដូចម្ដេចដែរ? ក្នុងនាមពលរដ្ឋម្នាក់ តើអ្នកត្រូវមានករណីយកិច្ចបែបណាខ្លះដើម្បីកាត់បន្ថយ ឬលុបបំបាត់ហានិភ័យពាក់ព័ន្ធទៅនឹងសារធាតុគីមី ឬកាកសំណល់ទាំងនោះ?







២- ចូរជ្រើសរើសកន្សោមពាក្យមកបំពេញតារាងខាងក្រោមទៅតាមសកម្មភាពនៃអំពើល្មើសការបំផ្លាញបរិស្ថាននិងការរំលោភច្បាប់ដែលកើតមានឡើងនៅក្នុងសហគមន៍។

| ការបំផ្លាញបរិស្ថាន | ការរំលោភច្បាប់ |
|---|---|
| ១- ............................................ | ១- ............................................ |
| ២- ............................................ | ២- ............................................ |
| ៣- ............................................ | ៣- ............................................ |
| ៤- ............................................ | ៤- ............................................ |
| ៥- ............................................ | ៥- ............................................ |

៣- ក្នុងនាមជាកូនល្អម្នាក់ក្នុងគ្រួសារ តើអ្នកត្រូវផ្ដល់សារដល់សមាជិកគ្រួសាររបស់អ្នកយ៉ាងដូចម្ដេចខ្លះដើម្បីលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ?

# មេរៀនទី ៤ សិទ្ធិចូលរួមក្នុងការអភិវឌ្ឍសង្គម

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចរៀបរាប់និងកំណត់បានពីសិទ្ធិរបស់ខ្លួននិងអ្នកដទៃក្នុងការចូលរួមអភិវឌ្ឍសង្គម ព្រមទាំងអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនឱ្យបានត្រឹមត្រូវក្នុងការចូលរួមអភិវឌ្ឍសង្គមជាតិឱ្យចៀសផុតពីអំពើជួញដូរមនុស្ស។

## ខ- សកម្មភាពផ្ដើម

ចូរសង្កេតមើលរូបភាពខាងក្រោម តើកុមារក្រុមណាមួយដែលបានអនុវត្តសិទ្ធិចូលរួមសិទ្ធិអភិវឌ្ឍសង្គមហេតុអ្វី?



## គ- ពាក្យគន្លឹះ

- **សិទ្ធិក្នុងការអភិវឌ្ឍៈ** សិទ្ធិដែលពលរដ្ឋម្នាក់ៗអាចចូលរួមតាមសមត្ថភាព និងលទ្ធភាពក្នុងការកសាង និងធ្វើឱ្យសង្គមមានការរីកចម្រើនរុងរឿង។
- **កោសិកាសង្គមៈ** ផ្នែកមួយដែលអាចចូលរួមបង្កើតបានជាបណ្ដុំរូបរាងមួយដែលមានជីវិតពិតប្រាកដ។ ឧទារណាហ៍ៈ កូនម្នាក់គឺជាកោសិការបស់គ្រួសារមួយ។ គ្រួសារមួយជាកោសិការបស់ សង្គមមួយ។
- **អាជីវកម្មៈ** ការប្រកបរបរចិញ្ចឹមជីវិត ការចាត់ចែងធ្វើសកម្មភាពតាមជំនាញដែលអាចរកផលចំណូលពីមុខរបរនោះ។ ឧទាហរណ៍ៈ អាជីវកម្មក្នុងវិស័យកសិកម្ម អាជីវកម្មលក់ផលិតផលតាមអ៊ិនធឺណិត ឬអនឡាញ។
- **ពេស្យាកម្មៈ** អំពើអាជីវកម្មផ្លូវភេទ។

- **អាសអាភាសៈ** សកម្មភាពដែលបង្ហាញពីកេរខ្មាសរបស់មនុស្ស។
- **ធនធានធម្មជាតិៈ** សម្បត្តិដែលមាននៅក្នុងធម្មជាតិ ដូចជាព្រៃ ទឹក ឧស្ម័ន។ល។
- **ទ្រព្យសម្បត្តិសាធារណៈ**: សម្បត្តិដែលគ្រប់គ្រងដោយរដ្ឋដើម្បីបម្រើឱ្យផលប្រយោជន៍រួម។ ឧទាហរណ៍ៈ សាលារៀន ផ្លូវថ្នល់ សួនសាធារណៈ។ល។

## ឃ- អត្ថបទអំណាន

ពលរដ្ឋម្នាក់ៗជាកោសិកាមួយរបស់សង្គម។ សង្គមល្អ សង្គមមានសុខដុមរមនា សង្គមរីកចម្រើន គឺកើតចេញពីយើងម្នាក់ៗនេះឯង។ ការចង់ឱ្យសង្គមមួយមានវឌ្ឍនភាពល្អប្រសើរ និងសុភមង្គល យើងម្នាក់ៗត្រូវចូលរួមចំណែកកសាងទាំងអស់គ្នា។ ក្នុងន័យនេះពលរដ្ឋម្នាក់ៗមានសិទ្ធិចូលរួមក្នុងសកម្មភាពផ្សេងៗ ដើម្បីអភិវឌ្ឍសង្គម។ សកម្មភាពទាំងនោះរួមមាន៖

- មិនប្រព្រឹត្តអំពើល្មើសច្បាប់ដែលបង្កផលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ជាពិសេសស្ត្រី និងកុមារ ដូចជា ការរត់ពន្ធមនុស្ស ការជួញដូរមនុស្ស ការធ្វើអាជីវកម្មខុសច្បាប់ ការផលិត លក់ដូរ ដឹកជញ្ជូន រក្សាទុក ឬប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ការរកស៊ីក្នុងអំពើពេស្យាកម្ម អំពើអាសអាភាស និងការលេងល្បែងស៊ីសង។
- ត្រូវចូលរួមថែរក្សាសម្បត្តិវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ជាតិ ធនធានធម្មជាតិ ទ្រព្យសម្បត្តិសាធារណៈគ្រប់ប្រភេទ
- ត្រូវមានស្មារតីស្រឡាញ់ជាតិមាតុភូមិ សាមគ្គីជាតិ គោរពច្បាប់យ៉ាងខ្ជាប់ខ្ជួនដើម្បីក្លាយជាពលរដ្ឋថ្លៃថ្នូរ។ មិនតែប៉ុណ្ណោះ ពលរដ្ឋគ្រប់រូបដែលគ្រប់អាយុត្រូវចូលរួមបោះឆ្នោត ឬអាចឈរឈ្មោះឱ្យគេបោះឆ្នោតតាមគោលការណ៍ច្បាប់ ដោយសេរី យុត្តិធម៌ និងប្រជាធិបតេយ្យ។

ការចូលរួមរបស់ពលរដ្ឋគ្រប់រូបក្នុងការអភិវឌ្ឍសង្គម ពិតជាមានសារៈសំខាន់ណាស់សម្រាប់ប្រទេសជាតិ ដូចជា ជ្រើសរើសបានអ្នកដឹកនាំល្អទាំងនៅមូលដ្ឋាននិងថ្នាក់ជាតិ សង្គមមានសណ្តាប់ធ្នាប់ សុខសុវត្ថិភាព សុខដុមនីយកម្ម និងមានសន្តិភាពទូទាំងប្រទេសដែលធ្វើឱ្យមានការអភិវឌ្ឍគ្រប់វិស័យ និងសេដ្ឋកិច្ចជាតិមានការរីកចម្រើន។ ពលរដ្ឋម្នាក់ៗត្រូវមានស្មារតីស្រឡាញ់ជាតិមាតុភូមិ គោរពច្បាប់ រក្សាបាននូវវប្បធម៌ ប្រពៃណីជាតិបានល្អប្រសើរនោះជាតិនឹងថ្កុំថ្កើង រុងរឿងក្លាយជាអារ្យប្រទេស។

### ករណីសិក្សា

**ឧត្តម** អាយុ១៥ឆ្នាំ រៀននៅអនុវិទ្យាល័យក្នុងខេត្ត។ **ឧត្តម** ស្រឡាញ់ផ្នែកកសិកម្ម និងចង់ក្លាយជា "មេដឹកនាំកសិករ"នាថ្ងៃអនាគត។ បំណងប្រាថ្នានេះ បានធ្វើឱ្យ**ឧត្តម** យកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើមេរៀនស្នេមដែលពាក់ព័ន្ធទៅនឹងបំណិនជីវិត។ **ឧត្តម** បានប្រាប់ពីមូលហេតុ

ដែលខ្លួនបានជ្រើសរើសការតម្រង់ទិសការសិក្សាទៅរកផ្នែកកសិកម្មថា "ខ្ញុំស្រឡាញ់ផ្នែកកសិកម្មខ្លាំងណាស់ ខ្ញុំចង់រៀនផ្នែកកសិកម្មព្រោះខ្ញុំគិតថា ខ្ញុំនឹងអាចជួយដល់កសិករឱ្យធ្វើកសិកម្មបានទិន្នផលច្រើន។ ខ្ញុំស្រឡាញ់ជនបទ ខ្ញុំចូលចិត្តការរស់នៅតាមជនបទជាងនៅទីក្រុង។ ពេលខ្ញុំមានជំនាញ និងបំណិនផ្នែកកសិកម្ម ខ្ញុំនឹងជួយដល់កសិករឱ្យដាំដុះដំណាំតាមបែបវិទ្យាសាស្ត្រត្រឹមត្រូវមិនប៉ះពាល់សុខភាព និងទទួលបានទិន្នផលខ្ពស់ និងទទួលបានប្រាក់ចំណេញច្រើន។ មិនតែប៉ុណ្ណោះ ខ្ញុំនឹងអាចជួយដល់ពលករក្នុងវិស័យកសិកម្មអាចរកកម្រៃក្នុងស្រុកបាន ដោយមិនចាំបាច់ធ្វើចំណាកស្រុក"។ លោកគ្រូ អ្នកគ្រូ និងគ្រួសារបានពេញចិត្តនិងគាំទ្រទស្សនៈរបស់**ឧត្តម** ព្រមទាំងផ្តល់ឱកាសឱ្យ**ឧត្តម** រៀបចំជាបទបង្ហាញពាក់ព័ន្ធទៅនឹងគំនិតរបស់ខ្លួននៅក្នុងថ្នាក់រៀនថែមទៀតផង។ **ឧត្តម** បានថ្លែងថា "ខ្ញុំគិតថា សុវត្ថិភាពចំណីអាហារ គឺជាកត្តាចាំបាច់បំផុតសម្រាប់ប្រជាជនពីបច្ចុប្បន្នទៅអនាគត។ មនុស្សយើង សំខាន់គឺសុខភាព ចុះបើអាហារដែលយើងហូបចុករាល់ថ្ងៃគ្មានសុវត្ថិភាពសម្រាប់យើងផងហ្នឹង! អីចឹង យើងហូបចូលទៅអាចប៉ះពាល់សុខភាព និងការលូតលាស់របស់មុស្ស។ ពេលមនុស្សធ្លាក់ខ្លួនមានជំងឺ នោះមនុស្សនឹងខាតបង់ពេលវេលា បាត់សុភមង្គលក្នុងគ្រួសារ និងត្រូវចំណាយលុយសម្រាប់ការព្យាបាលដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពគ្រួសារថែមទៀតផង។ សុវត្ថិភាពចំណីអាហារ គឺជាបញ្ហាមួយរបស់សង្គម ដែលយើងត្រូវរួមគ្នាដោះស្រាយ។ យើងអាចធ្វើជាម្ចាស់កសិដ្ឋានសរីរាង្គ ដើម្បីផ្គត់ផ្គង់កសិផលដែលប្រជាពលរដ្ឋទទួលទានទៅមានសុខភាពប្រសើរ។ ពេលសុខភាពល្អប្រសើរ ពលរដ្ឋយើងនឹងមិនចាំបាច់ចំណាយប្រាក់ព្យាបាលជំងឺ គឺដូចជាជួយឱ្យសេដ្ឋកិច្ចគ្រួសារអាចកើនឡើងដែរ។ សូមអរគុណលោកគ្រូ អ្នកគ្រូ ដែលបានខិតខំបង្រៀនយើងខ្ញុំ ព្រមទាំងបណ្តុះស្មារតីអភិវឌ្ឍសង្គមដល់យើងខ្ញុំ"។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- មាត្រា៣៤ថ្មី ...ប្រជាពលរដ្ឋទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោតឱ្យ...។
- មាត្រា៣៥ ...ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ...។
- មាត្រា៤៩ ...ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញនិងគោរពច្បាប់។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិនិងការពារមាតុភូមិ...។

- មាត្រា៥០ ...ប្រជាពលរដ្ឋទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិនិងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិសាធារណៈនិងកម្មសិទ្ធិស្របច្បាប់របស់ឯកជន...។

## ២- ច្បាប់ស្តីពីការអប់រំ

- មាត្រា៣៦ ...កំណត់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់មាតាបិតា ឬអ្នកអាណាព្យាបាលក្នុងការចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិដោយផ្ទាល់ ឬតាមតំណាងរបស់ខ្លួន...។ ...ករណីយកិច្ចរបស់មាតិបិតា ឬអ្នកអាណាព្យាបាលចំពោះការអប់រំរបស់ អនីតិជនដែលស្ថិតនៅក្នុងបន្ទុកដូចជា នាំកូនអាយុគ្រប់៦(ប្រាំមួយ)ឆ្នាំ ឬទាបបំផុត៧០(ចិតសិប)ខែឡើងទៅចុះឈ្មោះចូលរៀននៅថ្នាក់ទី១ នៃកម្មវិធីអប់រំចំណេះទូទៅ ខិតខំអស់លទ្ធភាពដើម្បីគាំទ្រការសិក្សារបស់អ្នកសិក្សាជាពិសេសចំពោះការអប់រំកម្រិតមូលដ្ឋាន យកចិត្តទុកដាក់ផ្សារភ្ជាប់សាលារៀន គ្រួសារ និងសហគមន៍ដើម្បីចូលរួមជួយបណ្តុះបណ្តាល និងកែលម្អបរិស្ថានសិក្សា...។
- មាត្រា៣៧ ...កំណត់អំពីសិទ្ធិនិងកាតព្វកិច្ចបុគ្គលិកអប់រំ ក្នុងការចូលរួមយ៉ាងសកម្មនិងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិដោយផ្ទាល់ ឬតាមតំណាងរបស់ខ្លួន...។

# ង- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

- តើហេតុអ្វីបានជា ឧត្តម មានបំណងចង់សិក្សាផ្នែកកសិកម្ម?
- តើបទបង្ហាញរបស់ឧត្តម មានទំនាក់ទំនងយ៉ាងដូចម្តេចទៅនឹងការអនុវត្តសិទ្ធិមនុស្សក្នុងការអភិវឌ្ឍសង្គម?
- តើសកម្មភាពរបស់ឧត្តម អាចចូលរួមបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សបានដែរឬទេ?

# ច- កិច្ចការផ្ទះ

១- ចូរផ្តល់ចម្លើយពាក់ព័ន្ធទៅនឹងសិទ្ធិក្នុងការអភិវឌ្ឍសង្គម តាមស្ថានភាពនីមួយៗដូចខាងក្រោម ៖

| ល.រ | ស្ថានភាព | ការបាត់បង់សិទ្ធិ | ការទទួលខុសត្រូវរបស់គ្រួសារ | ការទទួលខុសត្រូវរបស់សង្គម |
|---|---|---|---|---|
| ១ | កុមារធ្វើការ | សិទ្ធិទទួលការអប់រំ | បញ្ជូនកូនទៅសាលារៀន | សាលាសាធារណៈ (ឥតបង់ថ្លៃសិក្សា) |
| ២ | ការរងអំពើហិង្សាក្នុងគ្រួសារ | | | |
| ៣ | ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ | | | |
| ៤ | ស្ត្រីដែលគ្មានការងារធ្វើ | | | |
| ៥ | សង្គ្រាម | | | |

២- តើការអនុវត្តសិទ្ធិអភិវឌ្ឍសង្គមមានសារៈសំខាន់ដូចម្ដេចខ្លះឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍជាតិ?

៣- ដើម្បីចូលរួមអភិវឌ្ឍសង្គមឱ្យបានរីកចម្រើន និងមានសន្តិភាព តើយុវជនម្នាក់ៗត្រូវធ្វើអ្វីខ្លះ?

៤- ចូរស្វែងរកសកម្មភាពដែលប្រជាពលរដ្ឋនៅក្នុងសហគមន៍គប្បីធ្វើដើម្បីចូលរួមអភិវឌ្ឍសហគមន៍ឱ្យបានរីកចម្រើន និងអាចបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស។

## ការវាយតម្លៃ លទ្ធផលសិក្សាជំពូកទី១

១- ចូរគូសសញ្ញា(✓)នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

- និយោជកដែលកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់កុមារ ជានិយោជិត គឺពាក់ព័ន្ធនឹងការរំលោភៈ

 ☐ សិទ្ធិវប្បធម៌ ☐ សិទ្ធិពលរដ្ឋ ☐ សិទ្ធិសេដ្ឋកិច្ច ☐ សិទ្ធិនយោបាយ

- សិទ្ធិនិងករណីយកិច្ចរបស់ពលរដ្ឋចំពោះសង្គមជាតិគឺ

 ☐ ធ្វើពលកម្ម ☐ ថែរក្សាសុខភាព ☐ បង់ពន្ធដារ ☐ មានការទទួលខុសត្រូវ

- កុមារគ្រប់រូបត្រូវទទួលបានការអប់រំ បានកំណត់ក្នុងកម្រងសិទ្ធិ

 ☐ សិទ្ធិនិងសេរីភាព ☐ សិទ្ធិសេដ្ឋកិច្ច ☐ សិទ្ធិមនុស្ស ☐ សិទ្ធិវប្បធម៌

- ការប្រើប្រាស់សេរីភាពហួសព្រំដែនរបស់មនុស្សម្នាក់ៗនៅក្នុងសង្គម អាចប៉ះពាល់ដល់

 ☐ សេរីភាពខ្លួន ☐ អ្នកដទៃ ☐ សហគមន៍ ☐ ពេលវេលា

២- ចូរផ្គូផ្គងផ្នែក ក និងផ្នែក ខ ដោយការជ្រើសរើសឱ្យបានត្រឹមត្រូវ។

| ក | ខ | ចម្លើយ |
|---|---|---|
| ១- សិទ្ធិពលរដ្ឋ | ក- សិទ្ធិការពារមិនឱ្យគេយកទៅធ្វើជាទាសករឬធ្វើជាអ្នកបម្រើដាច់ថ្លៃ | ១ → .......... |
| ២- សិទ្ធិនយោបាយ | ខ- សិទ្ធិក្នុងការជ្រើសរើសមុខរបរដោយសេរី | ២ → .......... |
| ៣- សិទ្ធិសេដ្ឋកិច្ច | គ- សិទ្ធិក្នុងការបញ្ចេញមតិ និងសិទ្ធិចូលរួមបោះឆ្នោត | ៣ → .......... |
| ៤- សិទ្ធិសង្គមកិច្ច | ឃ-សិទ្ធិទទួលបានការការពារផ្នែកសុខភាព | ៤ → .......... |
| | ង- សិទ្ធិប្រកាន់ទំនៀមទម្លាប់ | |
| | ច- សិទ្ធិអាស្រ័យផលវប្បធម៌និងរក្សាសិទ្ធិ | |

៣- ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

- ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាង..............................និងការពារមាតុភូមិ។
- ការប្រើប្រាស់សិទ្ធិក្នុងការប្រព្រឹត្តទង្វើអ្វីមួយដែលមិនប្រាសចាកពីដែនកំណត់នៃច្បាប់និងមិនប៉ះពាល់ដល់សិទ្ធិអ្នកដទៃគឺ..............................។
- អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ គឺការរំលោភសិទ្ធិ................................។

៤- ឆ្លើយសំណួរខាងក្រោម៖

- តើកុមារអាចធ្វើអ្វីបានខ្លះដោយខ្លួនឯង ដើម្បីការពារខ្លួនពីអាជីវកម្មផ្លូវភេទឬការរំលោភបំពានផ្លូវភេទ?
- តើប្រជាពលរដ្ឋម្នាក់ៗ ត្រូវធ្វើយ៉ាងដូចម្ដេចដើម្បីចូលរួមអភិវឌ្ឍសហគមន៍ឱ្យបានរីកចម្រើន មានសន្តិភាព និងចៀសផុតពីអំពើជួញដូរមនុស្ស ?
- តើការគោរពសិទ្ធិសេរីភាពអ្នកដទៃ ការខិតខំរៀនសូត្រ ការមិនប្រព្រឹត្តអំពើល្មើសច្បាប់ អាចចាត់ទុកជាការចូលរួមអភិវឌ្ឍសង្គមបានដែរឬទេ ? ហេតុអ្វី ?

# ជំពូកទី ២

# ការបង្ការ ទប់ស្កាត់អំពើធ្វើអាជីវកម្មផ្លូវភេទ








អំពើអាជីវកម្មផ្លូវភេទអាចកើតមានចំពោះមនុស្សទូទៅ ជាពិសេសលើស្ត្រី និងកុមារ ដែលបង្កផលប៉ះពាល់ទៅលើសន្តិសុខសង្គម សុខភាពសាធារណៈ និងតម្លៃវប្បធម៌ប្រពៃណីជាតិ។ ជនខិលខូចឬជនសង្ស័យ មានកលល្បិចក្នុងការលួងលោម បោកបញ្ឆោត អូសទាញ ឬបង្ខិតបង្ខំជនរងគ្រោះឱ្យងាយធ្លាក់ទៅក្នុងអន្ទាក់នៃអំពើអាជីវកម្មផ្លូវភេទ។ ជំពូកទី២នេះ អ្នកសិក្សានឹងទទួលបានចំណេះដឹង បំណិនឆ្លើយតបទៅនឹងកលល្បិចរបស់ជនខិលខូចឬជនសង្ស័យ ដើម្បីបណ្ដុះបាននូវចរិយាសម្បត្តិសង្គមល្អប្រពៃ ដើម្បីចូលរួមបង្ការទប់ស្កាត់អំពើធ្វើអាជីវកម្មផ្លូវភេទនៅក្នុងសហគមន៍។ មេរៀនទាំងបីរួមមាន៖

មេរៀនទី១ សញ្ញាណនិងផលប៉ះពាល់នៃអំពើធ្វើអាជីវកម្មផ្លូវភេទ

មេរៀនទី២ ឧបាយកលជនខិលខូច ឬជនសង្ស័យ

មេរៀនទី៣ ការការពារខ្លួន និងការបង្ការទប់ស្កាត់អំពើធ្វើអាជីកម្មផ្លូវភេទ

## មេរៀនទី ១ សញ្ញាណនិងផលប៉ះពាល់នៃអំពើធ្វើអាជីវកម្មផ្លូវភេទ

### ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចប្រាប់បានពីសញ្ញាណ (ការសម្គាល់) និងទម្រង់នៃអំពើធ្វើអាជីវកម្មផ្លូវភេទ ហើយកំណត់បានពីផលប៉ះពាល់ ដែលបណ្ដាលមកពីអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីបង្កើនស្មារតីប្រុងប្រយ័ត្ន រិះរកវិធីការពារខ្លួនឯង និងអាចជួយដល់មនុស្សដែលនៅជុំវិញខ្លួនបាន។

### ខ- សកម្មភាពផ្ដើម

តើរូបភាពខាងក្រោម មានរូបភាពមួយណាដែលបង្ហាញពីសកម្មភាពនៃអំពើជួញដូរផ្លូវភេទ (ពេស្យាចារ)? ចូរបញ្ជាក់ហេតុផល ។





*រូបទី១....................* *រូបទី២.................................* *រូបទី៣............................*

### គ- ពាក្យគន្លឹះ

- **ការធ្វើអាជីវកម្មផ្លូវភេទ:** ការធ្វើជំនួញ ឬដោះដូរផ្លូវភេទ ដើម្បីទាញយក ឬទទួលបានផលប្រយោជន៍ ជាហិរញ្ញវត្ថុ ឬរបស់មានតម្លៃពីអំពើពេស្យាចារ។
- **អំពើពេស្យាចារ:** អំពើទាក់ទងទៅនឹងការរួមភេទជាមួយនរណាម្នាក់ ដើម្បីដោះដូរនឹងផលប្រយោជន៍អ្វីមួយ/វត្ថុមានតម្លៃ។
- **សញ្ចារកម្ម:** សកម្មភាពដកហូតយកប្រយោជន៍ ឬរបស់មានតម្លៃលើពេស្យាចារជនដទៃ។

### ឃ- អត្ថបទអំណាន

ការធ្វើអាជីវកម្មផ្លូវភេទ ជាការធ្វើជំនួញផ្លូវភេទដើម្បីទាញយកឬទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុ ឬរបស់មានតម្លៃពីអំពើពេស្យាចារជនដទៃ។ មនុស្សខ្លះ បានចាត់ទុកស្ត្រី និងកុមារដូចជាឧបករណ៍សម្រាប់បម្រើផ្លូវភេទនិងជាទំនិញសម្រាប់ធ្វើអាជីវកម្ម។ ស្ត្រីនិងកុមារអាចត្រូវគេប្រើឱ្យធ្វើជាពេស្យា ឬផលិតរូបភាពអាសអាភាស តាមរយៈមធ្យោបាយផ្សេងៗដូចជា លួងលោម បោក

បញ្ឆោត បង្ខំ ទិញ ឱ្យសម្ភារៈមានតម្លៃ ឬវិធីឱ្យខ្ចីប្រាក់។បច្ចុប្បន្នមិនត្រឹមតែស្ត្រីនិងកុមារីទេដែលត្រូវបានគេយកទៅធ្វើអាជីវកម្មផ្លូវភេទប៉ុន្តែបុរសនិងកុមារាក៏ត្រូវបានជនខិលខូចឬជនសង្ស័យប្រើប្រាស់មធ្យោបាយខាងលើដើម្បីយកពួកគេទៅធ្វើអាជីវកម្មផ្លូវភេទផងដែរ។

ការធ្វើអាជីវកម្មផ្លូវភេទ បានធ្វើឱ្យមនុស្សជាច្រើនបាត់បង់គោលដៅជីវិត បាត់បង់ការសិក្សា គ្រួសារ កិត្តិយសក្នុងសង្គម មានអារម្មណ៍ខ្មាសខ្លួនឯង ឯកា និងខ្លះធ្លាក់ខ្លួនមានជំងឺរហូតដល់ស្លាប់ក៏មាន។

## ករណីសិក្សា

**បុប្ផា** ជាក្មេងរស់នៅក្នុងគ្រួសារមួយដែលមានជីវភាពខ្សត់ខ្សោយ មានឪពុកជាកម្មករសំណង់ ម្ដាយជាកសិករ និងមានប្អូនតូចៗក្នុងបន្ទុកចំនួន៥នាក់។ ទោះបីជានាងជួបការលំបាកយ៉ាងណាក៏ដោយក៏ **បុប្ផា** មិនដែលត្អូញត្អែរ ឬបោះបង់ចោលការសិក្សានោះទេ។ នាងខិតខំរៀនសូត្ររហូតប្រឡងជាប់មធ្យមសិក្សាបឋមភូមិ និងទទួលបានអាហារូបករណ៍សិស្សក្រីក្រសម្រាប់ការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅទីរួមស្រុក។ ដោយសារជីវភាពខ្វះខាតកាន់តែធ្ងន់ធ្ងរ **បុប្ផា** បានឆ្លៀតរកការងារធ្វើក្រៅម៉ោងសិក្សា។ ថ្ងៃមួយ **បុប្ផា**បានជួបស្ត្រីម្នាក់ឈ្មោះ**នី** ដែលជាញាតិជិតខាងរបស់នាង។ **មីងនី** បានបបួលនាងទៅធ្វើការងារនៅហាងកាហ្វេមួយកន្លែងនៅពេលយប់ដែលមិនប៉ះពាល់ដល់ម៉ោងសិក្សារបស់នាង។ ក្រោយពេលនាងធ្វើការនៅហាងកាហ្វេនោះបានមួយរយៈពេល នៅថ្ងៃមួយនាងបានទទួលដំណឹងថាឪពុករបស់នាងរងគ្រោះថ្នាក់ចរាចរណ៍ ដែលត្រូវការប្រាក់សម្រាប់វះកាត់បន្ទាន់។ នាងមិនបានស្គាល់អ្នកណាផ្សេងដែលមានលទ្ធភាពអាចឱ្យនាងខ្ចីប្រាក់សម្រាប់ជួយសង្គ្រោះឪពុករបស់នាងក្រៅពីម្ចាស់ហាងឡើយ។ ភ្លាមនោះ នាងបានសម្រេចចិត្តសុំខ្ចីប្រាក់ពីម្ចាស់ហាងនោះចំនួន៤លានរៀល ដោយសន្យាថានឹងកាត់ប្រាក់ខែសងម្ចាស់ហាងវិញ។ ក្រោយពេល **បុប្ផា**កាត់ប្រាក់ខែបានចំនួនតែពីរខែប៉ុណ្ណោះ ម្ចាស់ហាងក៏បានទាមទារឱ្យនាងសងប្រាក់ដែលជំពាក់ទាំងអស់មកខ្លួនវិញ ដោយយកលេសថាខ្លួនត្រូវការប្រាក់បន្ទាន់។ **បុប្ផា** បានសុំម្ចាស់ហាងពន្យារពេលក្នុងការសងប្រាក់ ប៉ុន្តែម្ចាស់ហាងបដិសេធមិនយល់ព្រមនិងបាននិយាយថា “ **បើគ្មានប្រាក់សងទាន់ពេលខ្ញុំនឹងប្ដឹងសមត្ថកិច្ចឬក៏មានជម្រើសមួយទៀតសម្រាប់ឯង (បុប្ផា) គឺត្រូវតែទៅរួមភេទជាមួយភ្ញៀវ ដើម្បីរំលស់បំណុលដែលឯងជំពាក់យើង**”។

## ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា១៥ អំពើលក់-ដូរមនុស្សដោយមានគោលដៅ ...ជនណាដែលលក់-ដូរជនដទៃដោយមានគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់នៃការកេង

ប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំ ដល់១៥ (ដប់ប្រាំ) ឆ្នាំ ...។ ...ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ) ឆ្នាំដល់២០ (ម្ភៃ) ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង...។

- មាត្រា២៥ និយមន័យនៃសញ្ចារកម្ម ...អំពើសញ្ចារកម្ម នៅក្នុងច្បាប់នេះ មានន័យថា ទាញយកផលប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ ជួយ ឬការពារអំពើពេស្យាចាររបស់ជនដទៃ ជ្រើសរើស អូសទាញ ឬបណ្តុះបណ្តាលបុគ្គលណាមួយឱ្យធ្វើអំពើពេស្យាចារ ធ្វើការគាបសង្កត់លើបុគ្គលណាមួយដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ ...។...ត្រូវចាត់ទុកថា អំពើសញ្ចារកម្មមាន...អំពើធ្វើជាអន្តរការីរវាងបុគ្គលដែលធ្វើពេស្យាចារ និងបុគ្គលដែលប្រកបអាជីវកម្ម ឬឱ្យលាភការដល់ពេស្យាចារជនដទៃ អំពើរបស់ជនណាដែលបានជួយសម្រួល ឬបិទបាំងនូវធនធានដែលខ្លួនបានមកពីអំពើសញ្ចារកម្ម អំពើរារាំងដល់ការបង្ការ ការជួយ ឬការអប់រំជាថ្មី ដោយទីភ្នាក់ងារសាធារណៈ ឬដោយអង្គការឯកជនដែលមាននីតិសម្បទាដែលធ្វើឡើងដើម្បីគុណប្រយោជន៍ដល់បុគ្គលប្រព្រឹត្តពេស្យាចារ ឬកំពុងមានគ្រោះដោយការធ្វើពេស្យាចារ...។
- មាត្រា២៦ សញ្ចារកម្ម...ជនណាដែលប្រព្រឹត្តសញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ) ឆ្នាំ ដល់៥(ប្រាំ)ឆ្នាំ...។
- មាត្រា២៧ ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម... ជនណាប្រព្រឹត្តសញ្ចារកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំដល់១០(ដប់) ឆ្នាំ ក្នុងករណី៖ កាលបើសញ្ចារិក សញ្ចារិកា ឬជនជាមេពេស្យាជាបុព្វញាតិ ឬបច្ឆាញាតិមានខាន់ស្លា អត់ខាន់ស្លា ឬសាច់បង្កើត ឬចិញ្ចឹមរបស់បុគ្គលដែលធ្វើពេស្យា។ កាលបើសញ្ចារិក សញ្ចារិកា ឬជនជាមេពេស្យារំលោភអំណាចដែលមុខងាររបស់ខ្លួនបានផ្តល់ឱ្យទៅលើបុគ្គលដែលធ្វើពេស្យាចារ។ កាលបើសញ្ចារិក សញ្ចារិកា ឬជនជាមេពេស្យាប្រើហិង្សា ឬការបង្ខិតបង្ខំចំពោះបុគ្គលដែលធ្វើពេស្យាចារ។ កាលបើសញ្ចារកម្មត្រូវបានប្រព្រឹត្តលើកុមារមានការចាត់តាំង។ កាលបើសញ្ចារកម្មត្រូវបានប្រព្រឹត្តលើបុគ្គលច្រើននាក់ធ្វើពេស្យាចារ...។
- មាត្រា៣៤ ការទិញពេស្យាចារកុមារ ...ជនណារួមភេទ ឬធ្វើអំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទជាមួយអនីតិជន ដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅដោយផ្តល់ ឬសន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយទៅឱ្យអនីតិជននោះ ឬទៅឱ្យអន្តរការី ឪពុកម្តាយ អ្នកអាណាព្យាបាល ឬជនដទៃទៀតដែលគ្រប់គ្រង ឬត្រួតពិនិត្យលើអនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ដល់៥ (ប្រាំ) ឆ្នាំ។ ជនណាដែលប្រព្រឹត្តបទល្មើស

ខាងលើជាមួយអនីតិជនដែលមានអាយុតិចជាង១៥ ឆ្នាំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ...។

- មាត្រា៣៥ អំពើអូសទាញពេស្យាកុមារ ...ជនណាអូសទាញជនដទៃសម្រាប់អំពើពេស្យាចារកុមារ ឬ ផ្សាយពាណិជ្ជកម្មនូវអំពើពេស្យាចារកុមារក្នុងគោលដៅធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារនោះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ដល់៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ដល់ ១០ ០០០ ០០០ (ដប់លាន) រៀល។ ជនណាប្រព្រឹត្តបទល្មើសខាងលើធ្វើជាមុខរបរ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ដល់១០ (ដប់) ឆ្នាំ...។
- មាត្រា៣៦ ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌទាក់ទងទៅនឹងអំពើពេស្យាចារកុមារ ... ជនណាឱ្យជនដទៃខ្ចីប្រាក់ ឬវត្ថុមានតម្លៃអ្វីមួយដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឱ្យអនីតិជន ប្រកបរបរពេស្យាចារ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ដល់១០ (ដប់) ឆ្នាំ។ ជនណាឱ្យអនីតិជនខ្ចីប្រាក់ឬវត្ថុមានតម្លៃអ្វីមួយដោយភ្ជាប់ទៅនឹងលក្ខខណ្ឌដែលតម្រូវឱ្យអនីតិជន ប្រកបរបរពេស្យាចារ ត្រូវផ្ដន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ នៃមាត្រានេះ...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរប្អូនឆ្លើយសំណួរខាងក្រោម៖

១- តើក្នុងអត្ថបទករណីសិក្សាមានតួអង្គប៉ុន្មាននាក់ដែលពាក់ព័ន្ធទៅនឹងអំពើធ្វើអាជីវកម្មផ្លូវភេទ?

២- តើម្ចាស់ហាងបានប្រើល្បិចកលដូចម្ដេចខ្លះ ក្នុងបទសញ្ជារកម្ម?

៣- តើម្ចាស់ហាង អាចប្រឈមនឹងការទទួលទោសទណ្ឌដូចម្ដេចខ្លះ?

៤- ប្រសិនបើអ្នក ជាបុប្ផា តើអ្នកត្រូវដោះស្រាយបែបណាដើម្បីចៀសផុតពីអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបង្កដោយម្ចាស់ហាងបែបនោះ?

## ច- កិច្ចការផ្ទះ

១- ចូរអានសកម្មភាពខាងក្រោមដោយយកចិត្តទុកដាក់ រួចឆ្លើយថា "ទេ" ចំពោះសកម្មភាពទាំងឡាយណាដែលអាចនាំអ្នកឱ្យក្លាយជាជនរងគ្រោះដោយអំពើធ្វើអាជីវកម្មផ្លូវភេទ និងឆ្លើយថា "បាទ ឬចា" ចំពោះសកម្មភាពណាដែលនាំអ្នកឱ្យមានឱកាសអភិវឌ្ឍ៖

| សកម្មភាព | ចម្លើយ | ហេតុផលដែលអ្នកឆ្លើយបដិសេធ |
|---|---|---|
| ១- មិត្តភក្តិបបួលអ្នកឱ្យចូលរួមក្នុងក្លឹបសិក្សា។ | | |
| ២- មិត្តភក្តិនាំទៅអានសៀវភៅនៅបណ្ណាល័យ។ | | |
| ៣- ញាតិជិតខាងបបួលអ្នកឱ្យទៅធ្វើការនៅកន្លែងឆ្ងាយពីផ្ទះ ដែលអ្នកមិនធ្លាប់ស្គាល់។ | | |
| ៤- មនុស្សដែលអ្នកមិនធ្លាប់ស្គាល់យករបស់មានតម្លៃមកឱ្យអ្នកដើម្បី បបួលអ្នកទៅកន្លែងស្ងាត់ (ទីកំបាំង)។ | | |
| ៥- មិត្តភក្តិបបួលអ្នកប្រើប្រាស់សារធាតុអ្វីមួយដែលអ្នកមិនធ្លាប់បានស្គាល់ពីមុនមក។ | | |
| ៦- មនុស្សដែលអ្នកមិនធ្លាប់ស្គាល់ប្រវត្តិមកប្រាប់អ្នកឱ្យបបួលមិត្តភក្តិរបស់អ្នកទៅដើរលេងកម្សាន្តក្នុង ឬក្រៅម៉ោងសិក្សា។ | | |
| ៧- មិត្តភក្តិបបួលអ្នកឱ្យចូលរួមក្នុងសកម្មភាពច្រៀងរាំកម្សាន្តដោយមានទទួលទានគ្រឿងស្រវឹងតិចតួច។ | | |

២- ចូរិះរកពីវិធីសាស្ត្រនៃការបង្កើនស្មារតីប្រុងប្រយ័ត្នដល់មិត្តរួមថ្នាក់ និងប្រជាពលរដ្ឋនៅក្នុងសហគមន៍ ដើម្បីចៀសផុតពីអំពីជួញដូរផ្លូវភេទ។

## មេរៀនទី ២ ឧបាយកលជនខិលខូចឬជនសង្ស័យ

### ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចប្រាប់បានពីលក្ខណៈឬអាកប្បកិរិយារបស់ជនខិលខូចឬជនសង្ស័យដែលប្រើកលល្បិច ការលួងលោម អូសទាញកុមារឱ្យធ្លាក់ទៅក្នុងអំពើធ្វើអាជីវកម្មផ្លូវភេទ និងអាចបង្កើតបំណិនបង្កើនស្មារតីប្រុងប្រយ័ត្នការពារខ្លួនឯង និងមនុស្សជុំវិញខ្លួនឱ្យចៀសផុតពីការធ្លាក់ក្នុងអន្ទាក់កលល្បិចជនខិលខូចឬជនសង្ស័យ។

### ខ- សកម្មភាពផ្តើម

ចូរសង្កេតមើលរូបភាពខាងក្រោម តើមានសកម្មភាពណាដែលអាចសន្និដ្ឋានបានថាជាទង្វើអាជីវកម្មផ្លូវភេទ?




### គ- ពាក្យគន្លឹះ

- **ជនខិលខូចឬជនសង្ស័យ**: មនុស្សដែលមានគំនិតទុច្ចរិត មិនស្មោះត្រង់ ឬមានបំណងប្រព្រឹត្តអំពើខុសច្បាប់។
- **កលល្បិច**: វិធី មធ្យោបាយអូសទាញជនណាម្នាក់ដើម្បីទាញយកផលប្រយោជន៍។
- **ទំនោរសង្គម**: បរិបទនៃការវិវត្តរបស់សម័យកាលមួយ ចំណង់តាមសង្គម។

## ឃ- អត្ថបទអំណាន

ក្រុមជនខិលខូច/ជនសង្ស័យ មានកលល្បិចបោកប្រាស់កាន់តែប្លែកៗ ក្នុងការអូសទាញឱ្យជនរងគ្រោះជឿងប់ងល់ និងសុខចិត្តធ្វើតាម។ កលល្បិចរបស់ជនខិលខូចឬជនសង្ស័យមាន៖



លួងលោមចិត្តជនរងគ្រោះ ឬក្រុមគ្រួសារឱ្យជឿជាក់ធ្លាក់ក្នុងឧបាយកលរបស់ពួកគេដូចជា ជួយធានារកការងារឱ្យធ្វើដែលទទួលបានប្រាក់កម្រៃខ្ពស់ ជួយរត់ការឱ្យឆាប់បានទៅបរទេសធ្វើជាមានចិត្តល្អ ទិញគ្រឿងអលង្ការឱ្យ ទិញសម្លៀកបំពាក់ល្អៗឱ្យ ឱ្យលុយច្រើន ធ្វើជាធ្លាក់ទាក់ទាញចិត្តជនរងគ្រោះ ឱ្យខ្ចីប្រាក់កាសធ្វើដើមទុនរកស៊ី លួងលោមសុំធ្វើជាសង្សារឬប្រើល្បិចស្ដីដណ្ដឹងមុនរួចរៀបការជាក្រោយ បន្ទាប់មកនាំយកទៅលក់ សុំធ្វើជាកូនធម៌ឬបងប្អូនធម៌ ហើយនាំយកទៅលក់ ដាក់ថ្នាំញៀនឬថ្នាំសណ្ដំស្មារតីក្នុងអាហារឬភេសជ្ជៈ ហើយឱ្យជនរងគ្រោះទទួលទាន ប្រើអាវុធដើម្បីគំរាមកំហែងដល់អាយុជីវិតជនរងគ្រោះឬសាច់ញាតិជនរងគ្រោះ នាំទៅដើរលេងកម្សាន្ត និងស្នាក់នៅកន្លែងដែលមានភាពទាក់ទាញតាមទំនោរស្រើបស្រាល។

សកម្មភាពមនុស្សដែលអាចនាំឱ្យអ្នកក្លាយជាជនរងគ្រោះ នៅក្នុងអំពើធ្វើអាជីវកម្មផ្លូវភេទ គឺអាចកើតចេញពីមនុស្សនៅជុំវិញខ្លួន ដែលអាចជាមិត្តភក្តិ ញាតិមិត្តជិតខាង បងប្អូន មនុស្សដែលអ្នកមិនធ្លាប់ស្គាល់ដោយសន្យាយ៉ាងមុតមាំរហូតប្រើពាក្យសម្បថដាក់អាយុជីវិតក៏មាន ។

ប្រការនេះ យើងគប្បីបង្កើនការសង្កេតនិងប្រុងប្រយ័ត្នទ្វេដង ជាពិសេសការធ្វើទំនាក់ទំនងជាមួយមនុស្សមិនស្គាល់មុខតាមអ៊ិនធឺណិតឬអនឡាញ ការប្រាស្រ័យទាក់ទងតាមបណ្ដាញសង្គមនានា ការចូលរួមក្នុងកម្មវិធីសង្គមជាមួយមិត្តភក្តិ ជាដើម។ ត្រូវដើរចេញឱ្យឆ្ងាយពីក្រុមមនុស្សឬជនសង្ស័យទាំងនោះ ដើម្បីកុំឱ្យធ្លាក់ខ្លួនឬក្លាយជាជនរងគ្រោះ។

## ករណីសិក្សា

**សុខា**ជាក្មេងស្រីទើបចូលវ័យជំទង់ និងជាកូនទោលក្នុងគ្រួសារមានជីវភាពមធ្យមមួយនៅទីរួមខេត្ត។ ឪពុករបស់**សុខា** ជាមន្ត្រីរាជការ និងម្ដាយជាអាជីវករលក់ដូរសម្លៀកបំពាក់ក្នុងផ្សារ។ **សុខា**មិនឧស្សាហ៍រៀនសូត្រដូចមិត្តភក្តិឯទៀតទេ។ នាងតែងតែលួចចេញទៅដើរលេងជាមួយមិត្តភក្តិប្រុសស្រីជាកូនអ្នកជំនួញ និងជាកូនអ្នកមានទ្រព្យធនមួយចំនួនទៀតនៅក្នុងខេត្ត។ ថ្ងៃមួយ **សុខា**បានជួបនឹងបុរសសង្ហាម្នាក់នៅក្នុងហាងកាហ្វេទំនើបមួយកន្លែង។ បុរសនោះបានសម្លឹងមក**សុខា**ជារឿយៗ ចំណែកនាងក៏ចាប់អារម្មណ៍ជាមួយបុរសនោះដែរ។ ថ្ងៃបន្ទាប់ **សុខា**និងមិត្តរួមថ្នាក់

បានលួចគេចសាលារៀនទៅដើរលេងនៅរមណីយដ្ឋាន ហើយក៏បានជួបបុរសសង្ហានោះម្តងទៀត ដោយ**សុខា**មិនបានដឹងថាបុរសនោះលួចតាមដាននាងជាច្រើនថ្ងៃមកហើយទេ។ ពេលជួបគ្នាលើកនេះ បុរសនោះមិនបានបង្អង់យូរ ក៏បានដើរសំដៅមករកនាង ដោយពោលពាក្យជាច្រើនដែលជាភាសាផ្អែមល្ហែម ដើម្បីសុំនាងរាប់អានជាមិត្ត។ **សុខា**និងមិត្តភក្តិ រួមទាំងបុរសនោះបាននៅកម្សាន្តក្នុងរមណីយដ្ឋានរហូតដល់ម៉ោង៣រសៀលទើបពួកគេបបួលគ្នាបន្តទៅលេងនៅក្លឹបកម្សាន្តមួយកន្លែងនៅក្នុងក្រុង។ ពេលពួកគេទៅដល់ក្នុងក្លិបកម្សាន្ត បុរសនោះបានព្យាយាមលួងលោម**សុខា** និងមិត្តភក្តិឱ្យសេពគ្រឿងស្រវឹង និងម្សៅអ្វីម្យ៉ាងដែលនាងមិនធ្លាប់បានស្គាល់ពីមុនមកឡើយ។ បន្ទាប់ពីប្រើម្សៅនោះហើយ **សុខា**ចាប់ផ្តើមគ្រប់គ្រងអារម្មណ៍ខ្លួនឯងលែងបាន រវើរវាយលែងដឹងខ្លួន។ ពេល**សុខា**ដឹងខ្លួនឡើង អ្វីៗបានហួសពេលអស់ទៅហើយ នាងមានអារម្មណ៍វិលវល់ និងមានការសោកស្តាយយ៉ាងខ្លាំង។ ប៉ុន្តែបុរសនោះនៅតែព្យាយាមលួងលោមនាង និងបានឱ្យទូរស័ព្ទទំនើបថ្មី១គ្រឿង ដែលគេបានត្រៀមទុកជាស្រេចសម្រាប់ឱ្យនាង។ បុរសនោះបានបន្តបញ្ចុះបញ្ចូល**សុខា**ថា បើនាងបន្តរស់នៅជាមួយគ្រួសារទៀត នាងនឹងត្រូវខ្មាសគេ ព្រោះមិត្តភក្តិពិតជាបានដឹងរឿងនេះ និងដើរនិយាយប្រាប់គេឯងមិនខាន។ បុរសនោះបានបបួល**សុខា**ទៅរស់នៅជាមួយដោយសន្យាថានឹងរកការងារល្អៗឱ្យធ្វើ។ ដោយភាពឆោតល្ងង់មិនបានគិតគូរវែងឆ្ងាយ **សុខា**ក៏យល់ព្រមទៅជាមួយបុរសនោះ។ លុះបានរស់នៅជាមួយបុរសនោះមួយរយៈពេលខ្លី នាងត្រូវបានគេលក់ទៅឱ្យបុរសម្នាក់ទៀត។ ភាពរសាត់អណ្តែតពីបុរសម្នាក់ទៅបុរសម្នាក់ទៀត ធ្វើឱ្យ**សុខា**ឈឺចាប់យ៉ាងខ្លាំង និងបានសម្រេចចិត្តពឹងពាក់អ្នកជិតខាងផ្តល់ព័ត៌មានទៅម្តាយឪពុកនៅស្រុកដើម្បីជួយស្វែងរកជំនួយរំដោះនាងចេញពីស្ថានភាពជួញដូរមនុស្សនេះ។

## ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា១០ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ...ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ស្មុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ) ឆ្នាំ ដល់១៥(ដប់ប្រាំ) ឆ្នាំ..។ ...ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ) ឆ្នាំ ទៅ២០(ម្ភៃ) ឆ្នាំ ក្នុងករណីៈ ជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង...។...ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត នៅក្នុងមាត្រានេះ និងមាត្រា១២ មាត្រា១៥ មាត្រា១៧ និងមាត្រា១៩ នៃច្បាប់នេះ រួមមាន

ការកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ រូបភាព និងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវា ឬពលកម្មដោយបង្ខំទាសភាព ឬការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុលសេរីភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬការដកហូតសរីរាង្គ។ ការយល់ព្រមរបស់ជនរងគ្រោះចំពោះគោលដៅដែលមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ មិនទាក់ទងនឹងមធ្យោបាយណាមួយដែលមានចែងក្នុងកថាខណ្ឌទី១ មាត្រា៨នៃច្បាប់នេះដែលត្រូវបានប្រើនោះទេ។ ករណីនេះត្រូវយកទៅអនុវត្តផងដែរ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា១៥ មាត្រា១៧ និងមាត្រា១៩ នៃច្បាប់នេះ...។

- មាត្រា៣៤ ការទិញពេស្យាចារកុមារ ...ជនណារួមភេទ ឬធ្វើអំពើគ្រប់រូបភាពផ្សេងទៀតដែលទាក់ទងនឹងភេទជាមួយអនីតិជន ដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅដោយផ្តល់ ឬសន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយទៅឱ្យអនីតិជននោះ ឬទៅឱ្យអន្តរការី ឪពុកម្តាយ អ្នកអាណាព្យាបាល ឬជនដទៃទៀតដែលគ្រប់គ្រង ឬត្រួតពិនិត្យលើអនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ដល់៥ (ប្រាំ) ឆ្នាំ។ ជនណាដែលប្រព្រឹត្តបទល្មើសខាងលើជាមួយអនីតិជនដែលមានអាយុតិចជាង១៥ ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ...។
- មាត្រា៣៥ អំពើអូសទាញពេស្យាកុមារ ...ជនណាអូសទាញជនដទៃសម្រាប់អំពើពេស្យាចារកុមារ ឬ ផ្សាយពាណិជ្ជកម្មនូវអំពើពេស្យាចារកុមារក្នុងគោលដៅធ្វើជាអន្តរការីនៃអំពើពេស្យាចារកុមារនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ដល់៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ដល់ ១០ ០០០ ០០០ (ដប់លាន) រៀល។ ជនណាប្រព្រឹត្តបទល្មើសខាងលើធ្វើជាមុខរបរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ដល់១០ (ដប់) ឆ្នាំ...។
- មាត្រា៣៧ កិច្ចសន្យានៃអំពើពេស្យាចារកុមារ ...ជនណាធ្វើកិច្ចសន្យាជាមួយជនដទៃដែលក្នុងកិច្ចសន្យានោះតម្រូវឱ្យអនីតិជនប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ដល់១០ (ដប់) ឆ្នាំ។ ជនណាធ្វើកិច្ចសន្យាជាមួយអនីតិជនដែលក្នុងកិច្ចសន្យានោះតម្រូវឱ្យអនីតិជនប្រកបរបរពេស្យាចារ ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១នៃមាត្រានេះ...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើសុខាជាក្មេងដូចម្តេច ? ហេតុអ្វី?

២- តើសិស្សដែលគេចសាលារៀន អាចនឹងជួបលទ្ធផលដូចម្តេចខ្លះ?

៣- តើកលល្បិចអ្វី ដែលធ្វើឱ្យ សុខា ធ្លាក់ក្នុងអំពើជួញដូរមនុស្ស?

៤- តើបុរសដែលបានបោកបញ្ឆោត សុខា ត្រូវទទួលទោសទណ្ឌដូចម្តេច?

៥- តើបុរសបន្តបន្ទាប់ដែលបានទិញ សុខា ត្រូវទទួលទោសទណ្ឌដូចម្តេច?

## ច- កិច្ចការផ្ទះ

១- ចូររៀបរាប់ពីកលល្បិចរបស់ជនខិលខូចឬជនសង្ស័យ ដែលអាចអូសទាញកុមារធ្លាក់ក្នុងអំពើជួញដូរផ្លូវភេទ។

២- ចូររៀបចំបទបង្ហាញសម្រាប់ចែករំលែកព័ត៌មានស្តីពីកលល្បិចជនខិលខូចឬជនសង្ស័យពាក់ព័ន្ធករណីអំពើជួញដូរផ្លូវភេទដើម្បីអប់រំដល់មិត្តក្នុងថ្នាក់ឱ្យចៀសផុតពីគ្រោះថ្នាក់បង្កដោយជនខិលខូចឬជនសង្ស័យទាំងនោះ។

# មេរៀនទី ៣ ការការពារខ្លួន និងការបង្ការទប់ស្កាត់អំពើធ្វើអាជីវកម្មផ្លូវភេទ

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សានឹងរៀបរាប់បានពីមធ្យោបាយ យុទ្ធវិធី វិធីការពារខ្លួននិងបង្ការទប់ស្កាត់អំពើធ្វើអាជីវកម្មផ្លូវភេទមកលើខ្លួន និងអាចចូលរួមបង្ការ ទប់ស្កាត់អំពើធ្វើអាជីវកម្មផ្លូវភេទ ការពារមនុស្សជុំវិញខ្លួន ដើម្បីសហគមន៍មានសុវត្ថិភាព។

## ខ- សកម្មភាពផ្តើម

តើសកម្មភាពខាងក្រោម សកម្មភាពណាជាសកម្មភាពបង្ការទប់ស្កាត់អំពើធ្វើអាជីវកម្មផ្លូវភេទ?

- ☐ ក- ការបង្កើតនិងដាក់ចេញឱ្យអនុវត្តក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុង
- ☐ ខ- ការបង្កើតប្រព័ន្ធរាយការណ៍ទាន់ហេតុការណ៍ពីបទល្មើស
- ☐ គ- ការតម្រូវឱ្យសិស្សស្លៀកពាក់ឯកសណ្ឋានសិស្ស
- ☐ ឃ- ការប្រើសេរីភាពគ្រប់ពេលវេលា
- ☐ ង- ការសុំការអនុញ្ញាតពីអ្នកគ្រប់គ្រង មុនធ្វើអ្វីមួយ
- ☐ ច- ការមិនទទួលយកប្រាក់កាស វត្ថុមានតម្លៃដែលមិនមែនជាថ្នូរនឹងកម្លាំងពលកម្ម
- ☐ ឆ- ការដើរលេងកម្សាន្តគ្រប់ពេលវេលា
- ☐ ជ- ការហាមមិនឱ្យទៅទីកន្លែងស្ងាត់និងទៅតែម្នាក់ឯង
- ☐ ឈ- ការធ្វើដំណើរនិងស្នាក់នៅសណ្ឋាគារទំនើបៗជាមួយមិត្តភក្តិនិងអ្នកដទៃ
- ☐ ញ- ការផ្តល់ព័ត៌មានទៅអាជ្ញាធរ កងកម្លាំងមានសមត្ថកិច្ច ពេលឃើញមនុស្សចម្លែក ឬជនសង្ស័យ។

## គ- ពាក្យគន្លឹះ

- **ការបង្ការទប់ស្កាត់:** វិធីសាស្ត្រ ឬមធ្យោបាយក្នុងការរារាំង ឬបង្ការទុកជាមុននូវភាពរងគ្រោះនានាឱ្យបានទាន់ពេលវេលា ជាពិសេសអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។
- **រដ្ឋអំណាចមូលដ្ឋាន:** ប្រព័ន្ធរដ្ឋបាលគ្រប់គ្រងដែនដីថ្នាក់រាជធានី ខេត្ត ខណ្ឌ ក្រុង ស្រុក សង្កាត់ ឃុំ ភូមិ ដែលមានតួនាទីគ្រប់គ្រង ដឹកនាំ និងរៀបចំដំណើរការអភិវឌ្ឍមូលដ្ឋានឱ្យមានសណ្តាប់ធ្នាប់ សន្តិសុខ សុវត្ថិភាព។

- **អាជ្ញាធរមានសមត្ថកិច្ចៈ** រចនាសម្ព័ន្ធគ្រប់គ្រងសាធារណៈដែលមានអំណាចតួនាទីចាត់ចែង ត្រួតពិនិត្យសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមនៅតាមមូលដ្ឋាន។
- **ក្រុមប្រឹក្សាកុមារៈ** រចនាសម្ព័ន្ធក្រុមការងារកុមារនៅតាមគ្រឹះស្ថានសិក្សា ដែលមានតួនាទីជាជំនួយការជូនដល់គណៈគ្រប់គ្រងសាលាលើផ្នែកជំរុញការងារសិក្សារបស់សិស្ស ការគ្រប់គ្រងបរិស្ថានសាលារៀន សន្តិសុខ សណ្តាប់ធ្នាប់ វិន័យ និងការអភិវឌ្ឍនានានៅក្នុងសាលារៀន។
- **យុទ្ធភ័ណ្ឌៈ** សម្ភារៈ សព្វាវុធ ដែលប្រើប្រាស់សម្រាប់ធ្វើសង្គ្រាម។
- **អំពើហិង្សាៈ** ការប្រើកាយវិការ ឬសម្តី ឬសម្ភារៈដែលបំពានទៅលើរាងកាយ អារម្មណ៍របស់អ្នកដទៃ បង្កើតជាសោកនាដកម្ម ឬរបួសស្នាមដល់ជនរងគ្រោះ។
- **យុទ្ធនាការៈ** សកម្មភាពឯកភាពក្នុងចំណោមមនុស្សជាច្រើននាក់កម្រិតអន្តរជាតិ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិដើម្បីប្រយុទ្ធប្រឆាំងទៅនឹងអំពើអមនុស្សធម៌ណាមួយ ឬដើម្បីលើកកម្ពស់ការអនុវត្តជាប្រយោជន៍មនុស្សជាតិ ប្រយោជន៍ជាតិ។
- **អនីតិជនៈ** មនុស្សដែលមានអាយុក្រោម១៨ឆ្នាំ។
- **នីតិវិធីៈ** ការអនុវត្តកិច្ចការតាមបែបបទដែលកំណត់ដោយច្បាប់ជាធរមាន។
- **វិធានការៈ** បែបផែននៃការអនុវត្ត ឬមធ្យោបាយសម្រាប់ការការពារ និងប្រុងប្រយ័ត្ន។

## ឃ- អត្ថបទអំណាន

### របៀបបង្ការទប់ស្កាត់អំពើធ្វើអាជីវកម្មផ្លូវភេទ



អំពើធ្វើអាជីវកម្មផ្លូវភេទ អាចកើតមានចំពោះមនុស្សទូទៅគ្រប់កម្រិតជីវភាព ជាពិសេសលើស្ត្រីនិងកុមារ។ ជនខិលខូចឬជនសង្ស័យ អាចជាមនុស្សដែលនៅជុំវិញខ្លួនដូចជា សាច់ញាតិ មិត្តភក្តិ អ្នកជិតខាង មនុស្សជិតស្និត ។ល។ មនុស្សទាំងនោះមានកលល្បិចខ្ពស់ និងថ្មីៗក្នុងការល្បួងលោម បោកបញ្ឆោត អូសទាញអ្នកឱ្យក្លាយជាជនរងគ្រោះ។

ដូចនេះ កុមារគ្រប់រូបត្រូវតែចេះសង្កេត វិភាគនូវរាល់សកម្មភាព ដែលសង្ស័យថាជាទង្វើដែលមានទំនោរទៅរកអំពើធ្វើអាជីវកម្មផ្លូវភេទ។



ប្រសិនបើមានការសង្ស័យ កុមារត្រូវចេញឱ្យឆ្ងាយពីជនខិលខូចឬជនសង្ស័យទាំងនោះ រួចត្រូវរួសរាន់ស្វែងរកកន្លែងសុវត្ថិភាព និងត្រូវរាយការណ៍ទៅចាស់ទុំ អាជ្ញាធរមូលដ្ឋាន ឬ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត។ កុមារក៏អាចចូលរួមចែករំលែកព័ត៌មានដែលបានដឹង និងអាចចូលរួមផ្សព្វផ្សាយពីវិធីសាស្ត្រនៃការបង្ការទប់ស្កាត់អំពើជួញដូរផ្លូវភេទ តាមរយៈមធ្យោបាយផ្សេងៗដូចជា មិត្តអប់រំមិត្ត ក្លឹបសិក្សា ក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សាកុមារ និងសកម្មភាពអប់រំផ្សេងៗទៀតនៅក្នុងសហគមន៍។ល។

ដើម្បីចូលរួមបង្ការទប់ស្កាត់អំពើធ្វើអាជីវកម្មផ្លូវភេទ រាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងសកម្មភាពអសន្តិសុខសង្គមផ្សេងទៀត កន្លងមករាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដែលមានលក្ខណៈសម្បត្តិ៩យ៉ាង រួមមាន៖

១- គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយនិងការប្រើប្រាស់ គ្រឿងញៀនខុសច្បាប់

៣- គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤- គ្មានក្មេងទំនើង

៥- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់និងបទល្មើសគ្រប់ប្រភេទ

៦- គ្មានគ្រោះថ្នាក់ចរាចរណ៍

៧- គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៨- មានវិធានការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព

៩- គ្មានការត្រួតពិនិត្យខុសច្បាប់ ។

## ករណីសិក្សា

ដោយសារជីវភាពខ្វះខាត **សំណាង** អាយុ១២ឆ្នាំ បានទៅតាមអ្នកជិតខាងដើម្បីរកការងារធ្វើដើម្បីបានកម្រៃមកជួយគ្រួសារ។ ប៉ុន្តែជាអកុសល អ្នកជិតខាងនោះបានយកនាងទៅបម្រើនៅតាមផ្ទះរបស់បុរសម្នាក់នៅទីក្រុង។ បុរសជាម្ចាស់ផ្ទះនោះ បាននាំនាងទៅបម្រើការនៅក្នុងសណ្ឋាគាររយៈពេលមួយសប្តាហ៍។ ឆ្លៀតពេលទំនេរពីការងារអនាម័យក្នុងសណ្ឋាគារ **សំណាង**បានលបចូល

ទៅក្នុងបន្ទប់ធំមួយនៅផ្នែកខាងក្រោយនៃសណ្ឋាគារ និងបានឃើញស្ត្រីវ័យក្មេងៗជាច្រើននាក់ មានរូបរាងស្អាតៗនៅកំដរជាមួយបុរសៗជាអតិថិជន។ ដោយយល់ពីស្ថានការណ៍មិនល្អ **សំណាង**ក៏បានលបរត់គេចខ្លួន ហើយទៅរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចដែលនៅក្បែរសណ្ឋាគារពីដំណើររឿងដែលនាងបានឃើញនៅក្នុងសណ្ឋាគារ។

ដោយទទួលបានព័ត៌មានពី**សំណាង** សមត្ថកិច្ចនគរបាលបានឆ្មក់ចូលទៅបង្ក្រាបទីតាំងលួចលាក់បើកអាជីវកម្មជួញដូរផ្លូវភេទ និងបានឃាត់ខ្លួនអ្នកពាក់ព័ន្ធជាច្រើននាក់។ លោកអធិការនគរបាលបានប្រាប់ឱ្យដឹងថា ប្រតិបត្តិការខាងលើនេះ បានសហការចូលរួមពីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលរាជធានី ព្រមទាំងកម្លាំងនគរបាលមូលដ្ឋាន ដែលដឹកនាំសម្របសម្រួលផ្លូវច្បាប់ពីព្រះរាជអាជ្ញារងអមសាលាដំបូងផងដែរ ។ ប្រតិបត្តិការនេះ ក្រៅពីបានឃាត់ខ្លួនជនសង្ស័យពាក់ព័ន្ធជាង៣០នាក់។ សមត្ថកិច្ចនគរបាល ក៏បានដកហូតវត្ថុតាងមួយចំនួនពីទីតាំងអាជីវកម្មជួញដូរផ្លូវភេទខាងលើនេះ និងត្រូវបានបញ្ជាឱ្យបិទអាជីវកម្មសណ្ឋាគារជារៀងរហូត ព្រមទាំងត្រូវពិន័យជាប្រាក់តាមច្បាប់កំណត់។

## ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា៣០ ជនណាដឹកនាំធ្វើអាជីវកម្ម ធ្វើប្រតិបត្តិការ ឬចេញប្រាក់ឱ្យគ្រឹះស្ថានពេស្យាចារដោយផ្ទាល់ ឬតាមរយៈអន្តរការី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ) ឆ្នាំទៅ៥(ប្រាំ) ឆ្នាំ។
- មាត្រា៣១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ) ឆ្នាំទៅ៥(ប្រាំ) ឆ្នាំ កាលបើបានយល់ព្រម ឬបានអនុគ្រោះ៖
  - ១- ឱ្យបុគ្គលណាម្នាក់ប្រព្រឹត្តពេស្យាចារនៅក្នុងគ្រឹះស្ថាន ឬនៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាន ឬ
  - ២- ឱ្យបុគ្គលណាម្នាក់រកភ្ញៀវ ដើម្បីធ្វើពេស្យាចារ្យនៅក្នុងគ្រឹះស្ថាន ឬនៅក្នុងឧបសម្ព័ន្ធរបស់គ្រឹះស្ថាននេះ។
- មាត្រា៣២ ជនណាលក់ ឬដាក់ឱ្យបុគ្គលណាម្នាក់ប្រើប្រាស់ទីកន្លែង ដែលមិនមែនប្រើប្រាស់ដោយសាធារណជន ដោយដឹងថាបុគ្គលនោះនឹងប្រើប្រាស់ទីកន្លែងនោះសម្រាប់ធ្វើសកម្មភាពធ្វើពេស្យាចារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ) ឆ្នាំទៅ ៥(ប្រាំ) ឆ្នាំ។

## ឆ- សកម្មភាពប្រតិបត្តិ

១- ចូរឆ្លើយសំណួរខាងក្រោម ៖

- តើអំពើធ្វើអាជីវកម្មផ្លូវភេទប៉ះពាល់អ្វីខ្លះដល់មនុស្ស និងសង្គម?
- តើហេតុអ្វីបានជាសំណាងត្រូវចេញរកការងារធ្វើទាំងនៅវ័យសិក្សា?តើការសម្រេចរបស់នាងត្រឹមត្រូវដែរឬទេ?
- តើបុរសជាម្ចាស់ផ្ទះ យកសំណាង ទៅបម្រើការក្នុងសណ្ឋាគារ មានបំណងយ៉ាងដូចម្ដេច?
- តើការដែលសំណាងយករឿងរ៉ាវដែលមើលឃើញនៅក្នុងសណ្ឋាគារទៅរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចត្រឹមត្រូវដែរឬទេ? ហេតុអ្វី?

២- ចូរសម្ដែងធ្វើជាជនបង្គោលក្នុងការផ្សព្វផ្សាយព័ត៌មាន ដើម្បីបង្ការ ទប់ស្កាត់ភាពរងគ្រោះ ដោយអំពើធ្វើអាជីវកម្មផ្លូវភេទ ទៅកាន់មិត្តរួមថ្នាក់។

## ជ- កិច្ចការផ្ទះ

ចូររៀបចំធ្វើយុទ្ធនាការផ្សព្វផ្សាយ ស្ដីពីការបង្ការ ទប់ស្កាត់អំពើធ្វើអាជីកម្មផ្លូវភេទដល់មិត្តរួមសាលារៀន ដល់សាលារៀនដទៃ និងដល់សហគមន៍ដោយរៀបចំធ្វើបដា ឬប័ណ្ណផ្ទត់។

# ការវាយតម្លៃ លទ្ធផលសិក្សាជំពូកទី២

១- ចូរគូសសញ្ញា(✓)នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

- ផលប៉ះពាល់ចំពោះសុខភាពរាងកាយកុមារដែលធ្លាប់រងគ្រោះដោយអំពើធ្វើអាជីវកម្មផ្លូវភេទមាន៖

  □ ជំងឺផ្លូវចិត្ត □ ជំងឺឆ្លងផ្សេងៗ □ ជំងឺអស់សង្ឃឹម □ ជំងឺតពូជ

- ការធ្វើអាជីវកម្មផ្លូវភេទជាការធ្វើជំនួញផ្លូវភេទពីអំពើពេស្យាចារជនដទៃដើម្បីទទួលបានរបស់មានតម្លៃឬ

  □ កបិលវត្ថុ □ ទេយ្យវត្ថុ □ ហិរញ្ញវត្ថុ □ ស្វាធ្យាយវត្ថុ

- មូលហេតុដែលអាចនាំឱ្យកុមារធ្លាក់ខ្លួនជាជនរងគ្រោះនៃអំពើធ្វើអាជីវកម្មផ្លូវភេទគឺ

  □ ខ្វះសុភមង្គលគ្រួសារ □ ទំហំគ្រួសារ □ អាជីវកម្មគ្រួសារ □ បុគ្គលនិងគ្រួសារ

- មនុស្សដែលអាចនាំឱ្យកុមារក្លាយខ្លួនជាជនរងគ្រោះនៃអំពើធ្វើអាជីវកម្មផ្លូវភេទ គឺ

  □ គ្រូបាអាចារ្យ □ ញាតិជិតខាងឬមិត្តភក្តិ

  □ ក្រឡាបញ្ជី □ មនុស្សទាំងអស់នៅជុំវិញខ្លួន

២- ចូរផ្គូផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| ១- កលល្បិចជនខិលខូចឬជនសង្ស័យ | ក- បដិសេធមិនព្រមទទួលរបស់ដែលគេផ្តល់ឱ្យ | ១ → ....... |
| | ខ- យកចិត្តទុកដាក់ថែទាំសុខភាព | ២ → ....... |
| ២- មធ្យោបាយ ជនរងគ្រោះ | គ- ឃ្លាំមើលសកម្មភាពនិងប្រមូលភស្តុតាង | ៣ → ....... |
| ៣- មធ្យោបាយ កងកម្លាំងសមត្ថកិច្ច | ឃ- លួងលោម ធ្វើជាចិត្តល្អ ឱ្យខ្ចីប្រាក់ | ៤ → ....... |
| | ង- បង្កើតអនុសញ្ញាអង្គការសហប្រជាជាតិ | |
| ៤- មធ្យោបាយ របស់ខ្ញុំ | ច- ចាកចេញពីជនសង្ស័យដោយប្រាប់ថា មានការរវល់ | |

៣- ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

- មូលហេតុដែលជំរុញឱ្យស្ត្រីភាគច្រើនងាយធ្លាក់ក្នុងកលល្បិចរបស់ជនខិលខូចឬជនសង្ស័យ គឺ កត្តាបុគ្គលនិងគ្រួសារ ............................ និងកត្តាធម្មជាតិ។
- វិធី ឬមធ្យោយបាយដ៏ប៉ិនប្រសប់ក្នុងការអូសទាញជនណាម្នាក់ដើម្បីទាញយកផលប្រយោជន៍ហៅថា ............................។

- វិធីសាស្ត្រ ឬមធ្យោបាយក្នុងការកាត់បន្ថយ ឬលុបបំបាត់ភាពរងគ្រោះនានាឱ្យទាន់ពេលវេលា ជាពិសេសអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារគឺ ................................។

៤- ឆ្លើយសំណួរ

ក- តើជនដែលធ្វើអាជីវកម្មផ្លូវភេទមានទោសដូចម្តេចខ្លះ ?

ខ- តើកុមារអាចធ្វើអ្វីបានខ្លះដោយខ្លួនឯង ដើម្បីការពារខ្លួនពីការធ្វើអាជីវកម្មផ្លូវភេទ ឬការរំលោភបំពានផ្លូវភេទ?

# ជំពូកទី ៣ ការបង្ការ ទប់ស្កាត់អំពើកេងប្រវ័ញ្ច កម្លាំងពលកម្ម



ការកេងប្រវ័ញ្ចកម្លាំងពលកម្មអាចកើតមានចំពោះបុគ្គលគ្រប់រូបដែលធ្វើការងារដើម្បីបំពេញតម្រូវការជីវភាពខ្លួនឯងនិងគ្រួសារ។ អំពើនេះ អាចកើតលើទាំងអ្នកធ្វើការងារមានកិច្ចសន្យាការងារស្របតាមច្បាប់ការងារ និងទាំងអ្នកធ្វើការងារមិនមានកិច្ចសន្យាការងារច្បាស់លាស់ ដូចជាប្រភេទការងារសំណង់ ការងារបម្រើតាមផ្ទះ ការងារក្នុងកសិដ្ឋាន ការងារនេសាទ..។ល។

យើងសង្កេតឃើញថាការងារដែលមិនមានកិច្ចសន្យាច្បាស់លាស់ ជាប្រភេទការងារប្រើកម្លាំងប្តូរយកកម្រៃ ជាប្រភេទការងារដែលមានហានិភ័យខ្ពស់ និងពិបាកទទួលបានការគោរពសិទ្ធិការងារបានពេញលេញពីសំណាក់ថៅកែ។

កុមារមិនអាចធ្វើការងារណាដែលមានគ្រោះថ្នាក់ទេ ទោះបីជាការងារស្រាលឬធ្ងន់ក្តី ដូចជាការធ្វើការងារច្រើនម៉ោងគ្មានពេលសម្រាក មិនបានទៅរៀន ទទួលបានកម្រៃតិចតួច គ្មានការព្យាបាលពេលមានជំងឺ មានគ្រោះថ្នាក់ដល់រាងកាយនិងសុខភាព ឱ្យធ្វើការងារខុសច្បាប់។ល។ ព្រោះការងារទាំងនោះ ផ្តល់ផលប៉ះពាល់ជាខ្លាំងដល់ការអភិវឌ្ឍផ្នែករាងកាយ សុខភាព បញ្ញាស្មារតី និងអារម្មណ៍របស់កុមារ។ នៅក្នុងជំពូកនេះ អ្នកសិក្សានឹងសិក្សាស៊ីជម្រៅពីប្រធានបទនេះ តាមរយៈមេរៀនទាំងបី រួមមាន ៖

មេរៀនទី១ សញ្ញាណនិងផលប៉ះពាល់នៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម

មេរៀនទី២ ឧបាយកលនៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម

មេរៀនទី៣ ការការពារខ្លួន និងការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម

**មេរៀនទី ១**

# សញ្ញាណនិងផលប៉ះពាល់នៃការកេងប្រវ័ញ្ច កម្លាំងពលកម្ម

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចប្រាប់បានពីអត្ថន័យនៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម ព្រមទាំងមានបំណិនឈ្លាសវៃក្នុងការវិនិច្ឆ័យពីផលប៉ះពាល់នៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអាចពង្រឹងភាពក្លាហានក្នុងការសួរឬផ្តល់មតិទៅអ្នកដែលមានបំណងកេងប្រវ័ញ្ចកម្លាំងពលកម្ម ដើម្បីចូលរួមលុបបំបាត់អំពើកេងប្រវ័ញ្ចទាំងនោះ។

## ខ- សកម្មភាពផ្តើម

ចូរពិនិត្យមើលរូបភាពខាងក្រោម តើរូបភាពណាខ្លះបង្ហាញ "ការងារមានកិច្ចសន្យា" និងរូបភាពណាខ្លះបង្ហាញ "ការងារគ្មានកិច្ចសន្យាច្បាស់លាស់" ដោយបញ្ជាក់ហេតុផល៖






១- ........................ ២- ........................ ៣- ........................ ៤- ........................

## គ- ពាក្យគន្លឹះ

- **ការកេងប្រវ័ញ្ចកម្លាំងពលកម្ម:** ការកេងចំណេញ ឬការទាញយកប្រយោជន៍ពីការងាររបស់ជនដទៃដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ដោយមិនស្របទៅតាមលក្ខខណ្ឌ ឬច្បាប់ការងារ និងផ្ទុយពីអនុសញ្ញា ឬសន្ធិសញ្ញារបស់អង្គការពលកម្មអន្តរជាតិ (ILO)។
- **សហគ្រាស:** គ្រឹះស្ថាន ឬអង្គការរបស់រដ្ឋ ឬឯកជនសម្រាប់ធ្វើសកម្មភាពពាណិជ្ជកម្ម ឬផលិតកម្មដែលស្វែងរកប្រាក់ចំណេញ មានដូចជា ក្រុមហ៊ុន រោងចក្រ សិប្បកម្ម កសិដ្ឋាន...។
- **និយោជក:** អ្នកជួលគេធ្វើការងារឱ្យ ឬថៅកែ។
- **និយោជិត:** អ្នកធ្វើការងារឱ្យគេ ឬកម្មករ។

## ឃ- អត្ថបទអំណាន

មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពទទួលបានការងារសមស្របទៅនឹងសមត្ថភាព ជំនាញវិជ្ជាជីវៈ ហើយទទួលបានប្រាក់កម្រៃពីការងារតាមគោលការណ៍របស់ក្រុមហ៊ុនឬសហគ្រាស និងតាមថិរវេលាដែលមានកំណត់ក្នុងច្បាប់ជាពិសេសច្បាប់ស្តីពីការងារ។ ការងារដែលមានលក្ខណៈត្រឹមត្រូវ គឺកើតចេញពីកិច្ចសន្យាការងារ ដែលបានផ្តល់កម្រៃ និងអត្ថប្រយោជន៍ផ្សេងៗ ស្របទៅនឹងការបំពេញការងារ ហើយកិច្ចសន្យានេះ បានការពារផលប្រយោជន៍ ទាំងនិយោជក និងនិយោជិត ដោយស្ថិតក្រោមច្បាប់ស្តីពីការងារ។

ចំពោះអ្នកធ្វើការងារមួយចំនួនដែលធ្វើដោយប្រើកម្លាំងក្នុងការដោះដូរកម្រៃប្រចាំថ្ងៃ (ការងារគ្មានកិច្ចសន្យា) ក៏ត្រូវទទួលអត្ថប្រយោជន៍ កម្រៃសមស្របទៅនឹងសមត្ថភាពនិងថិរវេលាដែលពួកគេបំពេញប្រចាំថ្ងៃផងដែរ។ ការងារប្រភេទនេះបង្កភាពងាយស្រួលដល់និយោជកឬថៅកែ ឬអ្នកគ្រប់គ្រង អាចឆ្លៀតឱកាសកេងប្រវ័ញ្ចកម្លាំងពលកម្ម ពីព្រោះគ្មានកិច្ចសន្យាការងារច្បាស់លាស់ដែលកំណត់អំពីប្រាក់កម្រៃ ថិរវេលាធ្វើការ និងទទួលបានការគោរពសិទ្ធិតាមច្បាប់ស្តីពីការងារ។ ការងារភាគច្រើន ដែលគ្មានកិច្ចសន្យាការងារ រួមមានការងារសំណង់ ការងារកសិដ្ឋាន ការងារក្រៅម៉ោងនៅតាមរង្គសាល អាហារដ្ឋាន ភោជនីយដ្ឋាន ខារ៉ាអូខេ ឧស្សាហកម្ម នេសាទ។ល។ ការងារប្រើកម្លាំងទាំងអស់នោះងាយស្រួលនឹងឱ្យនិយោជក ថៅកែ ឬអ្នកគ្រប់គ្រងកេងប្រវ័ញ្ចកម្លាំងពលកម្ម ព្រោះជាការងារដែលគ្មានកិច្ចសន្យាការងារច្បាស់លាស់។ អ្នកធ្វើការងារប្រភេទនេះ អាចនឹងត្រូវបានគេកាត់ប្រាក់ខែ បញ្ឈប់ពីការងារដោយគ្មានមូលហេតុ និងមិនអាចទាមទារសំណងជំងឺចិត្តពីនិយោជក។

### ១- ការងារមានកិច្ចសន្យា

ជនរងគ្រោះអាចបាត់បង់ផលប្រយោជន៍ មិនទទួលបានប្រាក់កម្រៃសមស្របទៅនឹងការបំពេញការងារជាក់ស្តែង។ និយោជកឬថៅកែ ឬអ្នកគ្រប់គ្រងលួងលោមបោកបញ្ឆោត ឬបង្ខំឱ្យធ្វើការលើសកម្លាំង ឬលើសម៉ោងកំណត់ដោយបានសន្យាថានឹងផ្តល់ឱ្យផលប្រយោជន៍អ្វីមួយដល់ជនរងគ្រោះ។ ជាក់ស្តែងជនរងគ្រោះ មិនទទួលបានដូចការសន្យានោះទេ។ ថៅកែឬអ្នកគ្រប់គ្រងតែងតែប្រើវិធីសាស្ត្ររកលេសដោះសារដោយមូលហេតុផ្សេងៗដូចជា ការគំរាមកំហែងដោយប្រើអំណាចឋានានុក្រមទៅលើជនរងគ្រោះ មិនឱ្យជនរងគ្រោះតបតបាន ដូចជា ការដកហូតតំណែង បញ្ចុះតំណែង ឬបញ្ឈប់ពីការងារ។

### ២- ការងារគ្មានកិច្ចសន្យា

ជនរងគ្រោះមិនទទួលបានការគាំពារគ្រប់គ្រាន់ផ្នែកអាហារូបត្ថម្ភ ការថែទាំផ្នែកសុខុមាលភាពសង្គម និងការព្យាបាលនៅពេលជនរងគ្រោះជួបគ្រោះថ្នាក់ក្នុងពេលបំពេញការងារ។ ជនរងគ្រោះនឹងមិនទទួលបានសំណង ដូចអ្នកដែលធ្វើការងារមានកិច្ចសន្យាស្របតាមច្បាប់ការងារនោះទេ។ ពេលខ្លះត្រូវបាននិយោជកឬថៅកែ ឬអ្នកគ្រប់គ្រងធ្វើបាប ដោយគំរាមកំហែងតាមវិធីផ្សេងៗ ដើម្បីបំបាក់ស្មារតីជនរងគ្រោះ។ លើសពីនេះ ជនរងគ្រោះ អាចត្រូវបានគេលក់បន្តទៅថៅកែផ្សេង ក្រោមរូបភាពផ្លាស់ប្តូរទីកន្លែងការងារ ដោយពេលខ្លះ ជនរងគ្រោះអាចធ្លាក់ចូលក្នុងស្ថានភាពកាន់តែអាក្រក់ជាងមុន ដោយរងទារុណកម្ម ឬការរំលោភបំពានផ្សេងទៀត។

## ករណីសិក្សា

**ស៊ីណា**មានអាយុ១៤ឆ្នាំ បានបោះបង់ការសិក្សាដើម្បីទៅធ្វើការនៅក្នុងសិប្បកម្មកាត់ដេរមួយកន្លែង។ ការងារដែលនាងធ្វើគឺមិនមានកិច្ចសន្យាត្រឹមត្រូវនោះទេ។ រៀងរាល់ថ្ងៃ **ស៊ីណា** ត្រូវធ្វើការ៨ម៉ោង ហើយពេលខ្លះ នាងត្រូវធ្វើការបន្ថែមម៉ោងនៅពេលយប់ថែមទៀតផង។ ការបំពេញការងារនៅក្នុងសិប្បកម្មកាត់ដេរនោះ នាងត្រូវបានថៅកែហៅអប់រំជាច្រើនលើកពីសកម្មភាពអ៊ុតផ្ទាំងក្រណាត់ធំៗមិនរាបស្មើល្អ។ កំហុសដែលនាងបានប្រព្រឹត្តត្រូវបានអ្នកគ្រប់គ្រងផ្នែកស្តីបន្ទោស និងគំរាមថានឹងត្រូវបណ្តេញចេញនៅថ្ងៃណាមួយ។ **ស៊ីណា** មានការបារម្ភនិងភ័យខ្លាចយ៉ាងខ្លាំង។ ការបារម្ភបានក្លាយជាការពិត នាងត្រូវគេផ្លាស់ប្តូរឱ្យទៅធ្វើការនៅផ្នែក ជ្រលក់ពណ៌ ដែលត្រូវធ្វើការជាមួយសារធាតុគីមី និងចំហាយឧស្ម័នក្តៅជារៀងរាល់ថ្ងៃ រហូតដល់នាងធ្លាក់ខ្លួនមានជំងឺរលាកសួត និងឡើងកម្តៅពងបែកពេញផ្ទៃមុខ។ ដោយទ្រាំការឈឺចាប់មិនបាន **ស៊ីណា** បានសុំអនុញ្ញាតច្បាប់ឈប់សម្រាកពីការងារ១សប្តាហ៍ដើម្បីព្យាបាលខ្លួន ប៉ុន្តែអ្នកគ្រប់គ្រងផ្នែកជ្រលក់ពណ៌មិនអនុញ្ញាតច្បាប់ឱ្យទេ ព្រមទាំងរាយការណ៍ទៅថៅកែឱ្យលុបឈ្មោះនិងបណ្តេញនាងចេញពីការងារទៀតផង។

មូលហេតុដោយ**ស៊ីណា**ចូលធ្វើការគ្មានកិច្ចសន្យាស្របច្បាប់ការងារ នាងត្រូវបានគេបញ្ឈប់ដោយមិនទទួលបានប្រាក់សំណងដូចអ្នកដទៃឡើយ។

## ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ១- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាលេខ១៣៨ (ឆ្នាំ១៩៩៩)

- មាត្រា៣ ...ចំពោះមុខរបរ និងការងារណាដោយសារប្រភេទ និងស្ថានភាពនៃមុខរបរ ឬការងារ នោះនៅពេលដែលធ្វើទៅនាំឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬសតិបញ្ញារបស់ក្មេង អាយុអប្បបរមាដែលអាចឱ្យចូលបម្រើក្នុងមុខរបរ ការងារទាំងនោះត្រូវកម្រិតមិនឱ្យតិចជាង១៨ឆ្នាំឡើយ...។ ... ច្បាប់ឬបទបញ្ជានានារបស់ជាតិ

ឬអាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យមានមុខរបរ ឬការងារសម្រាប់ក្មេងអាយុត្រឹម១៦ឆ្នាំ ក្នុងលក្ខខណ្ឌដែលថាក្មេងទាំងនោះ ត្រូវទទួលបានការការពារយ៉ាងពេញលេញខាងផ្នែកសុខភាព សុវត្ថិភាព ឬសតិបញ្ញា ព្រមទាំងទទួលនូវការហ្វឹកហ្វឺនយ៉ាងត្រឹមត្រូវចំពោះវិជ្ជាជីវៈដែលពាក់ព័ន្ធ...។

## ២- ច្បាប់ស្តីពីការងារ

- មាត្រា១៥ ...ការងារដោយបង្ខំ ឬជាកាតព្វកិច្ចត្រូវហាមឃាត់ដាច់ខាត...។...មាត្រានេះត្រូវអនុវត្តទៅលើបុគ្គលទាំងអស់គិតទាំងអ្នកបម្រើក្នុងផ្ទះនិងកម្មករនិយោជិតក្នុងសហគ្រាសកសិកម្មទាំងឡាយ...។
- មាត្រា១៦ ...ការជួលមនុស្សឱ្យធ្វើការដើម្បីកាត់ជំពាក់ត្រូវហាមឃាត់...។
- មាត្រា១៣៧ ...ថិរវេលានៃការធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពី៨ (ប្រាំបី) ម៉ោងក្នុងមួយថ្ងៃ ឬ៤៨ (សែសិបប្រាំបី) ម៉ោងក្នុងមួយអាទិត្យ...។
- មាត្រា១៣៩ថ្មី ... ករណីមានកិច្ចការប្រញាប់ខុសពីធម្មតា តម្រូវឱ្យកម្មករនិយោជិតធ្វើការបន្ថែមក្រៅម៉ោងពេលធម្មតា ម៉ោងពេលបន្ថែមនេះត្រូវឱ្យឈ្នួល តាមអត្រាដំឡើង៥០% (ហាសិបភាគរយ)។ ប្រសិនបើធ្វើការបន្ថែមចន្លោះម៉ោង២២.០០ ដល់ម៉ោង៥.០០ភ្លឺ ឬនៅក្នុងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវផ្តល់ប្រាក់បន្ថែមតាមអត្រាដំឡើង១០០% (មួយរយភាគរយ)...។

## ៣- ក្រមព្រហ្មទណ្ឌ

- មាត្រា៣៣៩ បទដាក់អនីតិជនឱ្យស្ថិតក្នុងលក្ខខណ្ឌនៃការងារដែលបណ្តាលឱ្យខូចសុខភាព... អំពើដែលដាក់អនីតិជនឱ្យស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារបណ្តាលឱ្យខូចដល់សុខភាព ឬការលូតលាស់ដល់រាងកាយរបស់អនីតិជននោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ) ឆ្នាំ ទៅ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល...។
- មាត្រា៣៤០ ស្ថានទម្ងន់ទោសដោយសារមរណភាពនៃអនីតិជន ...បទល្មើសដែលមានចែងក្នុងមាត្រា៣៣៩ (បទដាក់អនីតិជនឱ្យស្ថិតក្នុងលក្ខខណ្ឌនៃការងារដែលបណ្តាលឱ្យខូចសុខភាព) នៃក្រមនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំទៅ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនោះនាំឱ្យជនរងគ្រោះស្លាប់...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរប្អូនឆ្លើយសំណួរខាងក្រោម៖

១- តើហេតុអ្វីបានជាស៊ីុណាបោះបង់ការសិក្សា ហើយទៅរកការងារធ្វើ?

២- តើមានមូលដ្ឋានអ្វីខ្លះ ដើម្បីកំណត់ថាមានការកេងប្រវ័ញ្ចកម្លាំងពលកម្មលើស៊ីុណា?

៣- តើការងារដែលស៊ីុណាធ្វើសមស្របនឹងអាយុរបស់នាងដែរឬទេ? ហេតុអ្វី?

៤- តើការបណ្តេញស៊ីុណាចេញឈប់ឱ្យធ្វើការត្រឹមត្រូវដែរឬទេ?

៥- តើសិប្បកម្មដែលស៊ីុណាធ្វើការ ស្របច្បាប់ឬទេ? មូលហេតុអ្វី?

៦- តើស៊ីុណាបាត់បង់សិទ្ធិអ្វីខ្លះ?

៧- ដើម្បីកុំឱ្យមានការកេងប្រវ័ញ្ចកម្លាំងពលកម្ម តើការស្វែងរកការងារធ្វើត្រូវពិចារណាលើចំណុចអ្វីខ្លះ?

៨- តើមូលហេតុអ្វីខ្លះដែលធ្វើឱ្យមានការកេងប្រវ័ញ្ចកម្លាំងពលកម្មកើតមាន? ចូរបកស្រាយ។

## ច- កិច្ចការផ្ទះ

១- ចូរស្វែងរកប្រភេទការងារដែលអ្នកគិតថា ងាយត្រូវបានថៅកែឬអ្នកគ្រប់គ្រងកេងប្រវ័ញ្ចកម្លាំងពលកម្មឱ្យបានចំនួន៣ និងបញ្ជាក់ពីអំណះអំណាង?

២- ចូរស្វែងរកប្រភេទការងារដែលអ្នកគិតថាជាការងារមានលក្ខខណ្ឌនិងមានកិច្ចសន្យាការងារស្របទៅតាមច្បាប់ចំនួន៥? (មិនរាប់បញ្ចូលការងារជាមន្ត្រីរាជការ)

មេរៀនទី ២

# កលល្បិចនៃការកេងប្រវ័ញ្ចកម្លាំងពលកម្ម

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចរៀបរាប់បានអំពីកលល្បិចរបស់និយោជក ឬថៅកែឬអ្នកគ្រប់គ្រងក្នុងការរកវិធីកេងប្រវ័ញ្ចកម្លាំងពលកម្មលើបុគ្គលិក កម្មករ និយោជិត និង អាចប្រើបំណិនវិនិច្ឆ័យបានច្បាស់លាស់ពីអត្តចរិតរបស់និយោជកឬថៅកែឬអ្នកគ្រប់គ្រងដែលមាន បំណងប្រើកលល្បិចដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្ម ហើយចូលរួមសម្តែងមតិទាមទារឱ្យនិយោជក គោរពច្បាប់ការងារ។

## ខ- សកម្មភាពដើម

ចូរពិនិត្យមើលរូបភាពខាងក្រោម តើរូបភាពការងារណាមួយដែលនិយោជិតឬកម្មករ ងាយរងគ្រោះក្នុងការកេងប្រវ័ញ្ចកម្លាំងពលកម្មជាងគេ? ហេតុអ្វី?





## គ- ពាក្យគន្លឹះ

- **សិប្បកម្ម:** សកម្មភាពអាជីវកម្មដែលប្រើជំនាញដោយដៃរបស់កម្មករជំនាញឬដោយម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិដើម្បីបង្កើតជាផលិតផលកែច្នៃសម្រាប់ដាក់លក់។ ឧទាហរណ៍: សិប្បកម្មឡឥដ្ឋ សិប្បកម្មស្លឆ្នាំង...។
- **ឧស្សាហកម្ម:** សកម្មភាពអាជីវកម្ម ឬសេវាកម្មដ៏ធំទូលាយនៃវិស័យសេដ្ឋកិច្ច និងដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញសេដ្ឋកិច្ចជាតិឱ្យមានការអភិវឌ្ឍន៍ឬការផលិតរបស់ប្រើប្រាស់តាមសម័យនិយម ដែលប្រើកម្មករច្រើន។ ឧទាហរណ៍: ឧស្សាហកម្មកាត់ដេរ...។
- **ការដ្ឋាន:** កន្លែងធ្វើការ ទីនៃការងារ។ ឧទាហរណ៍: ការដ្ឋានសំណង់ ការដ្ឋានអណ្តូងរ៉ែ...។
- **បរិស្ថានការងារ:** ស្ថានភាពនៃការគ្រប់គ្រងការងារនៅតាមទីកន្លែងការងារតូចធំ។
- **ផលវិបាក:** លទ្ធផលការងារដែលនាំមកនូវទុក្ខលំបាក វេទនា ទាំងផ្លូវកាយ ផ្លូវចិត្ត និងអារម្មណ៍។
- **វិនិយោគ:** ការបោះទុនបង្កើតអាជីវកម្មនានា ដើម្បីផលចំណេញ។

## ឃ- អត្ថបទអំណាន

ប្រទេសកម្ពុជាមានប្រជាជនប្រហែលជាង១៦លាននាក់ ភាគច្រើនមានអាយុក្រោយ៤៥ឆ្នាំ។ ជារៀងរាល់ឆ្នាំ មានមនុស្សប្រហែល២៥០ ០០០នាក់បានចូលរកទីផ្សារការងារ។ បើទោះបីមានកំណើនផលិតផលក្នុងស្រុកសរុបជាមធ្យមប្រមាណ៧ភាគរយក្នុងមួយឆ្នាំនាទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏ភាពអត់ការងារធ្វើនៅតែជាកត្តាព្រួយបារម្ភក្នុងចំណោមប្រជាជនវ័យក្មេង។ កម្លាំងពលកម្មនៅតាមជនបទ ភាគច្រើនត្រូវបានស្រូបយកដោយវិស័យកសិកម្ម។ ក្រៅពីវិស័យកសិកម្ម ក៏មានវិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និងវិស័យឧស្សាហកម្មទេសចរណ៍ផងដែរ ដែលត្រូវបានរាជរដ្ឋាភិបាលមើលឃើញថា ជាគន្លឹះសម្រាប់ការបង្កើតការងារ។ វិស័យឧស្សាហកម្មទាំងពីរនេះត្រូវបានរំពឹងទុកថានឹងចូលរួមបង្កើតការងារសម្រាប់ប្រជាជនកម្ពុជាវ័យក្មេងជាច្រើនបន្ថែមទៀត។

រាជរដ្ឋាភិបាលនៅតែមានការបារម្ភពាក់ព័ន្ធទៅនឹងសុវត្ថិភាពនិងសុខភាពរបស់កម្មករនិយោជិត ដែលអាចទទួលរងការគំរាមកំហែងដោយលក្ខខណ្ឌនិងបរិស្ថានការងារមួយចំនួន ដែលបង្កគ្រោះថ្នាក់ប៉ះពាល់សុខភាព សុវត្ថិភាពការងារ និងបញ្ហាប្រាក់ឈ្នួល ដែលត្រូវការដំណោះស្រាយឱ្យបានទាន់ពេលវេលា។ ក្នុងស្ថានភាពប្រកួតប្រជែងជាមួយនឹងប្រទេសជិតខាងសម្រាប់ការវិនិយោគនិងការនាំចេញផលិតផល ទោះបីមានការប្តេជ្ញាចិត្តក្នុងការគោរពសិទ្ធិកម្មករនិយោជិតស្របតាមនិយាមអន្តរជាតិក៏ដោយ ផលវិបាកដោយផ្ទាល់នៃការធ្វើចំណាកស្រុកនៅតែចោទជាបញ្ហាជារឿយៗនៅក្នុងការងារគ្រប់គ្រងមូលដ្ឋាន។ មិនតែប៉ុណ្ណោះ បញ្ហាពលកម្មកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការកេងប្រវ័ញ្ចផ្សេងទៀតនៅតែមាននៅតាមបណ្តាឧស្សាហកម្មនិងសិប្បកម្ម ដែលជាបញ្ហាត្រូវដោះស្រាយជាបន្តបន្ទាប់។

ថៅកែឬអ្នកគ្រប់គ្រងខិលខូចមួយចំនួន មានកលល្បិចយ៉ាងច្រើនដើម្បីទាក់ទាញ លួងលោម បោកបញ្ឆោត តាមវិធីសាស្ត្រទន់ភ្លន់ ប្រាប់ដល់ជនរងគ្រោះពីហេតុផលសមស្រប ដើម្បីបម្រើមហិច្ឆតាកេងប្រវ័ញ្ចទាញយកផលប្រយោជន៍ណាមួយពីជនរងគ្រោះ។ ទន្ទឹមនេះ ក៏មានអ្នកខ្លះបានប្រើប្រាស់វិធីគំរាមកំហែងទៅលើជនរងគ្រោះណាដែលពួកគេមើលឃើញថា មិនសូវមានចំណេះដឹង មានកម្រិតវប្បធម៌ទាប និងមិនសូវមានការយល់ដឹងផ្នែកច្បាប់និងគោលនយោបាយពាក់ព័ន្ធទៅនឹងសិទ្ធិក្នុងការបំពេញការងារក្នុងវិស័យសាធារណៈ ឬវិស័យឯកជនបានស៊ីជម្រៅពិសេសច្បាប់ស្តីពីការងារ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

### ករណីសិក្សា

គ្រួសារ **វណ្ណៈ** មានសមាជិក៣នាក់រស់នៅក្នុងខ្ទមស្បូវតូចមួយក្បែរមាត់ទន្លេនៃខេត្តមួយ។ គ្រួសារគាត់មានជីវភាពខ្សត់ខ្សោយជាខ្លាំង។ ដោយមានបន្ទុកគ្រួសារត្រូវរ៉ាប់រងការរស់នៅនិងសិក្សា

របស់កូនតូចអាយុ៦ឆ្នាំម្នាក់ ព្រមទាំងភរិយាដែលមានផ្ទៃពោះ៧ខែផងនោះ **វណ្ណៈ** ត្រូវបង្ខំចិត្តចេញស្វែងរកការងារដើម្បីត្រៀមថវិកាសម្រាប់ភរិយាសម្រាលបុត្រ និងផ្គត់ផ្គង់ជីវភាពទៅថ្ងៃក្រោយ។

**វណ្ណៈ** បានធ្វើដំណើរតាមរថយន្តឈ្នួល ចាកចេញពីភូមិកំណើតទៅទីក្រុងដើម្បីរកការងារធ្វើ។ តាមផ្លូវគាត់បានជួបជាមួយបុរសម្នាក់ ដែលបានសួរគាត់ថា "បងទៅទីក្រុងធ្វើអ្វី?"។ **វណ្ណៈ** តបវិញថា "ខ្ញុំចង់ទៅរកការងារធ្វើ"។ បុរសនោះក៏បន្ថែមដោយបំណងបញ្ចុះបញ្ចូលថា "នៅទីក្រុងមិនសូវសម្បូរការងារទេ បើចង់រកការងារធ្វើ គួរឆ្លងចូលទៅប្រទេសជិតខាងទៅមិនខ្វះទេ ហើយបានប្រាក់កម្រៃច្រើនទៀត"។ **វណ្ណៈ** ស្តាប់ឮហើយសប្បាយចិត្តណាស់ ក៏សួរព័ត៌មានបន្ថែមថា "បានកម្រៃពលកម្មច្រើនមែនឬបង? ហើយនៅទីនោះគេឱ្យធ្វើអីខ្លះទៅបង?"។ ដោយឃើញ **វណ្ណៈ** ចាប់អារម្មណ៍បុរសនោះក៏និយាយថា "ការងារស្រួលៗទេ! គេឱ្យយើងហាលត្រីដែលគេទម្លាក់ពីទូកនេសាទហ្នឹងណា!"។ ដោយឮថាធ្វើការងារស្រួលៗ **វណ្ណៈ** ក៏សុំពឹងឱ្យបុរសនោះជូនខ្លួនទៅរកការងារនៅទីកន្លែងនោះ ជាថ្នូរនឹងសាគុណ១០ម៉ឺនរៀល។

ពេលឆ្លងចូលដល់ប្រទេសគោលដៅ បុរសនោះក៏បាននាំ**វណ្ណៈ**ទៅប្រគល់ឱ្យបុរសជាមេខ្យល់ម្នាក់ ហើយក៏បានចាកចេញទៅបាត់។ បន្ទាប់មកបុរសមេខ្យល់នោះ តម្រូវឱ្យ**វណ្ណៈ** បង់ថ្លៃនាំចូលការងារជារូបិយវត្ថុបរទេសមួយចំនួន រួចហើយទើបនាំ**វណ្ណៈ**ទៅកាន់ទូកនេសាទធំមួយដែលចតនៅក្បែរមាត់សមុទ្រ ហើយចង្អុលជាសញ្ញាប្រាប់ឱ្យ **វណ្ណៈ**ឡើងទៅលើទូកនោះ។ **វណ្ណៈ** មិនយល់មូលហេតុអ្វីទើបគាត់ត្រូវឡើងលើទូកនោះទេ ប៉ុន្តែដោយមិនចេះភាសាគេ មិនអាចប្រកែកអ្វីបាន គាត់ក៏បានឡើងទៅលើទូកនេសាទនោះ។ ពេលព្រលប់មកដល់ ទូកនេសាទដែលមានមនុស្សចំនួន១៥នាក់រួមទាំង**វណ្ណៈ**ផងនោះ បានចាកចេញពីផែធ្វើដំណើរទៅកណ្តាលសមុទ្រដើម្បីនេសាទត្រី។ ទិដ្ឋភាពនៅកណ្តាលមហាសមុទ្រ គឺងងឹតសូន្យមើលអ្វីមិនយល់ ខ្យល់បក់ខ្លាំង មានរលកធំៗបណ្តាលឱ្យទូកមុជងើបៗឥតឈប់ឈរ បូករួមទាំងមិនទាន់បានទទួលទានអាហារផងនោះ ធ្វើឱ្យ**វណ្ណៈ** មានអារម្មណ៍ធីងធោង ឈឺក្បាលចង់ក្អួត និងទន់ដៃទន់ជើងឈរមិននឹង។ ប៉ុន្តែជាអកុសល**វណ្ណៈ** គ្មានពេលដើម្បីសម្រាកទេ គាត់ត្រូវបានគេបង្ខំឱ្យធ្វើការឥតឈប់ ដោយមិនខ្វល់ថាគាត់មិនស្រួលខ្លួន ឬទោះបីសកម្មភាពការងារនោះគ្រោះថ្នាក់យ៉ាងណាក៏ដោយ។ គេបង្ខំឱ្យ **វណ្ណៈ** និងកម្មករដទៃធ្វើការមួយថ្ងៃលើសពី១៨ម៉ោង ដោយគ្មានអាហារហូបចុកគ្រប់គ្រាន់ គ្មានថ្នាំព្យាបាលពេលឈឺថ្កាត់ និងមិនបានទទួលប្រាក់កម្រៃអ្វីឡើយ។ មានអ្នកខ្លះបានធ្លាក់ចូលក្នុងសមុទ្រដោយសារអស់កម្លាំងពេក អ្នកខ្លះត្រូវដោតជាប់ដោយផ្លែសន្ទូចធំៗ បណ្តាលឱ្យរបួស ឬស្លាប់ក៏មាន។ គ្មានអ្នកណាខ្វល់ពីការស្លាប់របស់កម្មករនៅលើទូកនេសាទក្នុងសមុទ្រនេះឡើយ។ កម្មករលើទូកនេសាទម្នាក់ៗទោះបីមានភាសាកំណើតផ្សេងគ្នាក៏ដោយក៏ពួកគេតែងតែទន្ទេញជាប់ក្នុងចិត្តថា "កុំតក់ស្លុត ថ្ងៃណាមួយគង់តែដល់វេនអញមិនខានឡើយ!"។ ជីវិតកម្មករនៅលើទូកនោះ គឺរស់ដោយមានសង្ឃឹមតិចតួច មិនមានសេរីភាព និងបានត្រឹមតែមានការលួចស្រមៃថាអាចត្រឡប់ទៅជួបជុំគ្រួសារវិញបានតែប៉ុណ្ណោះ។

ដោយមានការត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ចតាមដែនសមុទ្រ ទូកនេសាទនោះត្រូវបានអាជ្ញាធរចាប់ឃាត់ និងជួយសង្គ្រោះកម្មករលើទូករួចបញ្ជូនទៅប្រទេសកំណើតរៀងៗខ្លួន។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

១- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា៨ ការនាំចេញដោយមិនស្របច្បាប់ ... ការនាំចេញមិនស្របច្បាប់ជាការធ្វើឱ្យមនុស្សម្នាក់ផ្លាស់ទីពីកន្លែងដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬរបស់តតិយជនតាមមធ្យោបាយបង្ខិតបង្ខំ គំរាមកំហែង បោកបញ្ឆោត បំពានអំណាច ឬលួងលោម...។
- មាត្រា១០ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ... ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ) ឆ្នាំ ដល់១៥(ដប់ប្រាំ) ឆ្នាំ..។...ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ) ឆ្នាំទៅ២០(ម្ភៃ) ឆ្នាំ ក្នុងករណីៈ ជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង...។
- មាត្រា១១ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ...ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ក្នុងគោលដៅប្រគល់ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំដល់១៥ (ដប់ប្រាំ) ឆ្នាំ។ ...ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅប្រគល់ ឬនាំជននោះទៅប្រទេសផ្សេងទៀត ត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌខាងលើ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំដល់២០(ម្ភៃ) ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តដោយមានក្រុមចាត់តាំង...។
- មាត្រា១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់ការកេងប្រវ័ញ្ច ...ការបញ្ចុះបញ្ចូល ការជួល ឬការឱ្យជនណាមួយបម្រើការក្រោមទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត តាមមធ្យោបាយបោកបញ្ឆោត បំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគម្រាមកំហែង ឬមធ្យោបាយបង្ខិតបង្ខំផ្សេងទៀត...។...ជនណា

ដែលជ្រើសរើសជនដទៃដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំដល់១៥(ដប់ប្រាំ)ឆ្នាំ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ដល់២០ (ម្ភៃ)ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះនិង អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង...។

### ១- ច្បាប់ស្តីពីការងារ

- មាត្រា១៥ ការងារដោយបង្ខំ ឬកាតព្វកិច្ចត្រូវហាមឃាត់ដាច់ខាត... មាត្រានេះត្រូវ អនុវត្តទៅលើបុគ្គលទាំងអស់គិតទាំងអ្នកបម្រើក្នុងផ្ទះនិងកម្មករនិយោជិតក្នុងសហ គ្រាសកសិកម្មទាំងឡាយ...។
- មាត្រា១៣៧ ...ថិរវេលានៃការធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវ ឱ្យលើសពី៨(ប្រាំបី) ម៉ោងក្នុងមួយថ្ងៃឬ៤៨(សែសិបប្រាំបី) ម៉ោងក្នុងមួយសប្តាហ៍...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើមានកត្តាអ្វីខ្លះដែលជំរុញឱ្យ វណ្ណៈ ធ្លាក់ចូលក្នុងការកេងប្រវ័ញ្ចកម្លាំងពលកម្ម?

២- តើនរណាខ្លះដែលពាក់ព័ន្ធទៅនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងអត្ថបទករណី សិក្សាខាងលើ?

៣- តើអ្វីខ្លះដែលបង្ហាញថាការកេងប្រវ័ញ្ចកម្លាំងពលកម្ម គឺជាអំពើឃោរឃៅ អមនុស្សធម៌ ប្រៀបដូចជាទាសភាពសម័យទំនើប?

៤- តើការកេងប្រវ័ញ្ចកម្លាំងពលកម្មប៉ះពាល់ដល់ផ្លូវចិត្ត ផ្លូវកាយ ផ្លូវអារម្មណ៍របស់ជនរង គ្រោះដូចម្តេចខ្លះ ?

៥- ដើម្បីកុំឱ្យធ្លាក់ចូលក្នុងកលល្បិចកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់ជនខិលខូចឬជន សង្ស័យ តើនៅពេលស្វែងរកការងារធ្វើ មនុស្សម្នាក់ៗត្រូវធ្វើយ៉ាងដូចម្តេចខ្លះ?

## ច- កិច្ចការផ្ទះ

១- ចូរស្រាវជ្រាវរកព័ត៌មានពិតពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដែលកើតមាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមអប់រំផ្សព្វផ្សាយការបង្ការទប់ស្កាត់ទង្វើ ទាំងនោះ។

២- ក្នុងនាមជាយុវជនម្នាក់ តើមានវិធីអ្វីខ្លះដើម្បីផ្សព្វផ្សាយចំណេះដឹងពាក់ព័ន្ធការកេង ប្រវ័ញ្ចកម្លាំងពលកម្មដល់មិត្តភក្តិរបស់អ្នក និងមនុស្សនៅក្នុងសហគមន៍របស់អ្នក ដើម្បីចៀសផុតពីគ្រោះថ្នាក់ទាំងនោះ?

**មេរៀនទី ៣**

# ការការពារខ្លួន និងការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចរៀបរាប់បានពីវិធីការពារខ្លួន និងការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្មមកលើខ្លួននិងមនុស្សជុំវិញខ្លួន ព្រមទាំងអាចប្រើបំណិនសមស្របអនុវត្តវិធីទាំងនោះឱ្យមានប្រសិទ្ធភាពដើម្បីចូលរួមសម្តែងមតិទាមទារឱ្យនិយោជកគោរពច្បាប់ការងារ។

## ខ- សកម្មភាពផ្តើម

ចូរពិនិត្យ និងបង្ហាញពីអត្ថន័យនៃរូបខាងក្រោមនេះ។




## គ- ពាក្យគន្លឹះ

- **លក្ខខណ្ឌការងារ:** ការកំណត់ពីគោលការណ៍សម្រាប់ការជ្រើសរើសបុគ្គលិក និងការតម្រង់ទិស ការងារដែលត្រូវអនុវត្តតាមទាំងនិយោជក និងនិយោជិត។
- **បុគ្គលិកឆ្នើម:** បុគ្គលិក ឬកម្មករដែលបំពេញការងារបានល្អតាមលក្ខខណ្ឌការងារតម្រូវ។
- **អត្រាប្រាក់កម្រៃ:** កម្រិតនៃចំនួនទឹកប្រាក់ដែលទទួលបានពីការបំពេញការងារតាមតួនាទី។

- **ប្រាក់បំណាច់**: ចំនួនប្រាក់កម្រៃ ឬប្រាក់រង្វាន់ដែលទទួលបានពីការងារប្រចាំឆ្នាំ។
- **សោហ៊ុយជំងឺចិត្ត**: ប្រាក់សំណងដែលទទួលបាន ក្រោយត្រូវបានបញ្ឈប់ ឬគ្រោះថ្នាក់នានាក្នុងពេលបំពេញការងារ។

## ឃ- អត្ថបទអំណាន

ការកេងប្រវ័ញ្ចកម្លាំងពលកម្ម អាចកើតមានចំពោះមនុស្សទូទៅ គ្រប់កម្រិតជីវភាព ទាំងបុរស ទាំងស្ត្រី ឬពេលខ្លះក៏អាចកើតលើអនីតិជនផងដែរ។ ថៅកែឬអ្នកគ្រប់គ្រងមួយចំនួន មានកលល្បិចខ្ពស់និងថ្មីៗ ក្នុងការលួងលោម បោកបញ្ឆោត បង្ខិតបង្ខំ គំរាមកំហែង ជាមធ្យោបាយក្នុងការកេងប្រវ័ញ្ចកម្លាំងពលកម្មទៅលើមនុស្សនៅក្រោមឱវាទ ឬក្រោមបង្គាប់របស់ពួកគេដើម្បីកេងយកប្រាក់កម្រៃមកធ្វើប្រយោជន៍ផ្ទាល់ខ្លួន។ ដូចនេះយើងទាំងអស់គ្នាត្រូវតែចេះសង្កេត និងវិភាគលើរាល់សកម្មភាពដែលថៅកែឬអ្នកគ្រប់គ្រងកំពុងធ្វើសកម្មភាពដែលមានទំនោរទៅរកការប្រព្រឹត្តអំពើកេងប្រវ័ញ្ចកម្លាំងពលកម្ម។

ប្រសិនបើសង្កេតឃើញថា ថៅកែឬអ្នកគ្រប់គ្រង កំពុងតែប្រព្រឹត្តសកម្មភាពកេងប្រវ័ញ្ចកម្លាំងពលកម្មទៅលើជនណាម្នាក់ ចាំបាច់ត្រូវចេះណែនាំពួកគេឱ្យចេះការពារខ្លួន និងចេះសួរនាំទៅថៅកែឬអ្នកគ្រប់គ្រងអំពីលក្ខខណ្ឌការងារ ថិរវេលាបំពេញការងារ ប្រាក់កម្រៃដែលត្រូវទទួលបានសមស្របតាមកិច្ចសន្យាការងារ និងការសន្យារបស់ថៅកែឬអ្នកគ្រប់គ្រងឱ្យបានល្អិតល្អន់ច្បាស់លាស់។ ប្រសិនបើនៅតែមិនទទួលបានដំណោះស្រាយសមស្របពីសំណាក់ថៅកែឬអ្នកគ្រប់គ្រង នោះត្រូវស្គាល់គោលដៅត្រូវរាយការណ៍ ឬទាក់ទងទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលនៅជិតបំផុត ដើម្បីជួយសម្របសម្រួលឬជួយដោះស្រាយតាមផ្លូវច្បាប់។ អ្នកសិក្សាគ្រប់រូបអាចចូលរួមចែករំលែកផ្តល់ព័ត៌មានដែលបានដឹង និងចូលរួមផ្សព្វផ្សាយបន្តស្តីពីការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្មតាមរយៈមធ្យោបាយផ្សេងៗទៅដល់បងប្អូនសាច់ញាតិ មិត្តភក្តិនៅជុំវិញខ្លួនអ្នក និងមនុស្សឯទៀតនៅក្នុងសហគមន៍របស់អ្នក។

### ករណីសិក្សា

លោក **បូរា** មានបុត្រ២នាក់រៀននៅអនុវិទ្យាល័យមួយក្នុងទីរួមស្រុក។ គាត់ជាអ្នកគ្រប់គ្រងផ្នែករដ្ឋបាល និងជាអ្នកគ្រប់គ្រងកម្មករនៅរោងចក្រចំណីសត្វមួយកន្លែង។ លោក **បូរា** បានធ្វើការងារនៅទីនោះជាង១០ឆ្នាំកន្លងមកហើយ។ តាំងពីថៅកែទីមួយរហូតមកដល់ថៅកែទីបី គឺសុទ្ធតែទទួលស្គាល់ថា គាត់ជាបុគ្គលិកឆ្នើមប្រចាំក្រុមហ៊ុននេះ និងបានផ្តល់ការអាណិតស្រឡាញ់ពីថៅកែគ្រប់ជំនាន់។ ប៉ុន្តែថៅកែទីបីចុងក្រោយនេះជាមនុស្សនិយមគិតតែផលចំណេញសម្រាប់ក្រុមហ៊ុនមួយមុខប៉ុណ្ណោះ មិនសូវយកចិត្តទុកដាក់អំពីសុខទុក្ខរបស់បុគ្គលិកក្រោមឱវាទឬកម្មករប៉ុន្មានទេ។ ថៅកែនោះថែមទាំងប្រាប់ទៅលោក**បូរា**ឱ្យចូលរួមលួងលោមដល់កម្មករឱ្យធ្វើការលើស

ម៉ោងកំណត់ប្រចាំថ្ងៃ ដោយប្រើការសន្យាផ្ទាល់មាត់ជាមួយកម្មករថា ពេលក្រុមហ៊ុនរកស៊ីចំណេញនឹងផ្តល់ជាប្រាក់រង្វាន់នៅចុងឆ្នាំនីមួយៗ។ ជាក់ស្តែងដល់ពេលចុងឆ្នាំម្តងៗ លោក**បូរា**សង្កេតឃើញថា ថៅកែនោះបានចំណេញប្រាក់យ៉ាងច្រើន ប៉ុន្តែថៅកែបានប្រាប់**បូរា**ថាត្រូវប្រកាសថាក្រុមហ៊ុនរកស៊ីខាត។ ពេលខ្លះថៅកែនោះបានប្រើប្រាស់អំណាចរបស់ខ្លួន បញ្ឈប់កម្មករដោយគ្មានមូលហេតុច្បាស់លាស់ ដើម្បីគំរាមដល់កម្មករដទៃទៀតដែលចង់ប្រឆាំងនឹងគាត់។ នាអំឡុងខែចុងក្រោយនេះ ថៅកែបានបញ្ជាឱ្យលោក**បូរា** ប្រាប់ទៅផ្នែកសន្តិសុខរោងចក្រឱ្យបិទទ្វាររោងចក្រមិនអនុញ្ញាតឱ្យកម្មករចេញទៅផ្ទះមុនម៉ោង៧យប់ជាដាច់ខាត។ ករណីកម្មករណាបំពានបំរាមខាងលើនោះនឹងមិនទទួលបានប្រាក់កម្រៃសម្រាប់ការធ្វើការលើសម៉ោងនោះទេ។ មិនតែប៉ុណ្ណោះ នឹងត្រូវកាត់ប្រាក់ខែថែមទៀតផង។ ក្រោយមកដោយសារ**បូរា**មើលឃើញការកេងប្រវ័ញ្ចរបស់ថៅកែនោះហួសហេតុពេក គាត់ក៏បានដាក់ពាក្យបណ្តឹងទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធដើម្បីរកវិធីតវ៉ាទាមទាររកអត្ថប្រយោជន៍ផ្សេងៗដែលកម្មករ ឬក្រុមការងារសន្តិសុខគួរតែទទួលបានឱ្យសមស្របទៅនឹងលក្ខខណ្ឌការងារ និងថិរវេលាក្នុងការបំពេញការងារទៅតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា។ ក្រោយពេលទទួលបានពាក្យបណ្តឹង សមត្ថកិច្ចពាក់ព័ន្ធបានចុះទៅធ្វើអន្តរាគមន៍ ដើម្បីទាមទារសោហ៊ុយជំងឺចិត្តជូនដល់កម្មករ និងសន្តិសុខរោងចក្រ ព្រមទាំងចាត់វិធានការទៅលើថៅកែរោងចក្រនោះតាមច្បាប់កំណត់។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ១- ច្បាប់ស្តីពីការងារ

- មាត្រា៨៩ ...ប្រសិនបើកិច្ចសន្យាការងារត្រូវបញ្ឈប់ដោយឆន្ទៈរបស់និយោជកតែម្ខាង វៀរលែងតែក្នុងករណីដែលកម្មករនិយោជិតមានកំហុសធ្ងន់ និយោជកត្រូវតែឱ្យកម្មករនិយោជិត ដែលខ្លួនបញ្ឈប់ក្រៅពីអត្ថប្រយោជន៍នៃការឱ្យដំណឹងមុនដូចមានចែងក្នុងផ្នែកនេះស្រាប់ នូវប្រាក់បំណាច់បណ្តេញចេញ...។
- មាត្រា៩០...ប្រាក់បំណាច់នៃការបណ្តេញចេញត្រូវតែបើកឱ្យកម្មករនិយោជិត ហើយកម្មករនិយោជិតនោះក៏អាចទាមទារជំងឺចិត្តបាន ទោះបីការផ្តាច់កិច្ចសន្យាមិនមែនធ្វើដោយនិយោជកក្តីក៏ប៉ុន្តែនិយោជកនេះបានជំរុញឱ្យអំពើអាក្រក់របស់ខ្លួន ឱ្យឃើញថាកម្មករនិយោជិតបានផ្តាច់កិច្ចសន្យាដោយខ្លួនឯង...។
- មាត្រា៩១ ...ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈផ្ទាល់នៃភាគីណាមួយ ដោយគ្មានហេតុផលត្រឹមត្រូវ នោះអាចបើកសិទ្ធិឱ្យភាគីម្ខាងទៀតទាមទារសោហ៊ុយជំងឺចិត្តបាន។ សោហុយជំងឺចិត្ត មិនត្រូវច្រឡំគ្នាជាមួយនឹងប្រាក់បំណាច់ទូទាត់ជួសការឱ្យដំណឹងមុន ឬជាមួយនឹងប្រាក់បំណាច់បណ្តេញចេញទេ។ កម្មករនិយោជិតអាច

ទាមទារប្រាក់បើកផ្តាច់ដែលមានចំនួនស្មើនឹងប្រាក់បំណាច់បណ្តេញចេញ។ ក្នុងករណីនេះកម្មករនិយោជិតត្រូវបានរួចផុតពីកាតព្វកិច្ចដែលត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីការខូចខាតរបស់ខ្លួន...។

- មាត្រា១៣៧ ...ចិរវេលានៃការធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទ មិនត្រូវឱ្យលើសពី៨ (ប្រាំបី) ម៉ោងក្នុងមួយថ្ងៃ ឬ៤៨ (សែសិបប្រាំបី) ម៉ោងក្នុងមួយអាទិត្យ...។
- មាត្រា១៣៩ថ្មី ... ករណីមានកិច្ចការប្រញាប់ខុសពីធម្មតា តម្រូវឱ្យកម្មករនិយោជិតធ្វើការបន្ថែមក្រៅម៉ោងពេលធម្មតា ម៉ោងពេលបន្ថែមនេះត្រូវឱ្យឈ្នួល តាមអត្រាដំឡើង៥០% (ហាសិបភាគរយ)។ ប្រសិនបើធ្វើការបន្ថែមចន្លោះម៉ោង២២.០០ ដល់ម៉ោង៥.០០ភ្លឺ ឬនៅក្នុងថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ ត្រូវផ្តល់ប្រាក់បន្ថែមតាមអត្រាដំឡើង១០០% (មួយរយភាគរយ)...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរប្អូនឆ្លើយសំណួរខាងក្រោម៖

១- តើលោកបូរាជាអ្នកណា?

២- តើសកម្មភាពអ្វីខ្លះនៅក្នុងករណីសិក្សាខាងលើជាការកេងប្រវ័ញ្ចកម្លាំងពលកម្ម? ចូរបង្ហាញ។

៣- តើលោកបូរា បានចូលរួមធ្វើអ្វីខ្លះតាមបញ្ជារបស់ថៅកែ?

៤- តើការកេងប្រវ័ញ្ចកម្លាំពលកម្មនៅក្នុងរោងចក្រខាងលើ ចាត់ថាជាកំហុសរបស់បូរាបានដែរឬទេ?

៥- តើបូរា និងកម្មករដ៏ទៃទៀត អាចទាមទារសំណងពីក្រុមហ៊ុនបានដែរឬទេ ក្នុងករណីបញ្ឈប់ពួកគាត់ពីការងារដោយគ្មានមូលហេតុ? ចូរបង្ហាញអំណះអំណាងតាមផ្លូវច្បាប់។

៦- តើព័ត៌មានពាក់ព័ន្ធករណី លោកបូរា អាចត្រូវបានបង្ហាញទៅក្នុងសាលារៀនតាមរយៈអ្នកណា? តើសកម្មភាពនោះ អាចចាត់ទុកជាទង្វើចូលរួមបង្ការទប់ស្កាត់អំពើកេងប្រវ័ញ្ចកម្លាំងពលកម្មឬទេ?

## ច- កិច្ចការផ្ទះ

ចូរជ្រើសរើសដៃគូពិភាក្សាគ្នាចំនួន២ក្រុម ដើម្បីរកវិធីផ្សព្វផ្សាយអប់រំ ដើម្បីការពារខ្លួនពីកលល្បិចជនខិលខូចឬជនសង្ស័យពាក់ព័ន្ធការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដើម្បីធ្វើការផ្សព្វផ្សាយអប់រំទៅដល់សិស្សនៅក្នុងសាលារៀននិងប្រជាពលរដ្ឋនៅក្នុងសហគមន៍របស់អ្នក។

ខ្លឹមសារអប់រំអាចពាក់ព័ន្ធទៅនឹងសំណួរខាងក្រោម៖

- តើអ្នកគួរតែចូលរួមផ្សព្វផ្សាយពីកលល្បិចជនខិលខូចឬជនសង្ស័យនៅសហគមន៍របស់អ្នក ដើម្បីបង្ការ ទប់ស្កាត់ ភាពរងគ្រោះនៃការកេងប្រវ័ញ្ចកម្លាំងពលកម្មដែរឬទេ? ហេតុអ្វី?
- តើអ្នកណាខ្លះត្រូវចូលរួមទាមទារឱ្យនិយោជក គោរពច្បាប់ការងារ ?
- តើនិយោជកដែលកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់និយោជិត ត្រូវមានទោសដែរឬទេ? ហេតុអ្វី?
- តើមានវិធីអ្វីខ្លះ ដើម្បីទប់ស្កាត់កុំឱ្យកើតមានការកេងប្រវ័ញ្ចកម្លាំងពលកម្ម ?
- តើមានចំណុចណាខ្លះ ដែលអ្នកគិតថាជាសកម្មភាពកេងប្រវ័ញ្ចកម្លាំងពលកម្ម? តើអ្នកគួរចូលរួមធ្វើអ្វីខ្លះ ដើម្បីជួយបង្ការ ទប់ស្កាត់ការរងគ្រោះរបស់ពួកគេ?

## ការវាយតម្លៃ លទ្ធផលសិក្សាជំពូកទី៣

១- ចូរគូសសញ្ញា (✓) នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

- សញ្ញាណដែលអាចបង្ហាញពីការប្រឈមទៅនឹងអំពើកេងប្រវ័ញ្ចកម្លាំងពលកម្មគឺ
  - □ គ្រប់ម៉ោងធ្វើការ □ ធ្វើការពេញម៉ោង
  - □ ធ្វើការគ្មានម៉ោងសម្រាក □ ចំនួនម៉ោងកំណត់
- ផលប៉ះពាល់ឬផលអាក្រក់ចំពោះអ្នកធ្វើការមិនមានកិច្ចសន្យាការងារច្បាស់លាស់គឺ
  - □ ប្រាក់កម្រៃសមស្រប □ ប្រាក់កម្រៃបន្ថែម
  - □ ប្រាក់កម្រៃតិច □ ប្រាក់កម្រៃមិនច្បាស់លាស់
- ជនរងគ្រោះក្នុងអំពើកេងប្រវ័ញ្ចកម្លាំងពលកម្មជួបប្រទះបញ្ហា
  - □ សុវត្ថិភាពការងារ □ ទទួលបានការមើលថែទាំសុខភាព
  - □ ការទទួលបានអាហារ □ ការសន្យាផ្តល់កម្រៃច្រើន
- ដើម្បីកេងប្រវ័ញ្ចកម្លាំងពលកម្មបាន អ្នកគ្រប់គ្រងប្រើវិធីសាស្ត្រគំរាមកំហែងលើជនរងគ្រោះដែល
  - □ មានចំណេះដឹងខ្ពស់ □ មានកម្រិតវប្បធម៌ទាប
  - □ មានចំណេះដឹងផ្នែកច្បាប់ □ ដឹងពីសិទ្ធិធ្វើការងារ

២- ចូរផ្គូផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| ១- ការកេងប្រវ័ញ្ចកម្លាំងពលកម្ម<br>២- ការទប់ស្កាត់ការកេងប្រវ័ញ្ចកម្លាំងពលកម្ម<br>៣- កលល្បិចរបស់ថៅកែ/អ្នកគ្រប់គ្រង<br>៤- ជនធ្វើការងារគ្មានកិច្ចសន្យា | ក- ការពារខ្លួន បងប្អូនសាច់ញាតិ មិត្តភក្តិនៅជុំវិញខ្លួន និងមនុស្សនៅក្នុងសហគមន៍។<br>ខ- ការទាញយកប្រយោជន៍ពីការងាររបស់ជនដទៃដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។<br>គ- ការលួងលោម បោកបញ្ឆោតតាមវិធីសាស្ត្រទន់ភ្លន់ ធ្វើជាចិត្តល្អ ឱ្យខ្ចីប្រាក់។<br>ឃ-អ្នករងគ្រោះមិនទទួលបានគ្រប់គ្រាន់ផ្នែកអាហារូបត្ថម្ភ ការថែទាំសុខភាព និងការថែទាំព្យាបាលពេលជួបគ្រោះថ្នាក់ការងារ។<br>ច- ការងារមានកិច្ចសន្យាខុសពីការងារគ្មានកិច្ចសន្យា។ | ១ → .......<br>២ → .......<br>៣ → .......<br>៤ → ....... |

៣- ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

- ការកេងប្រវ័ញ្ចកម្លាំងពលកម្មគឺការទាញយកប្រយោជន៍ពីការងាររបស់ជនដទៃដែលស្ថិតនៅក្រោម ........................របស់ខ្លួន ដោយមិនស្របទៅតាមលក្ខខណ្ឌ ឬច្បាប់ការងារ។
- ជនដែលប្រព្រឹត្តបទល្មើសកេងប្រវ័ញ្ចកម្លាំងពលកម្មជា.........................ទៅលើបុគ្គលិក ឬអ្នកបម្រើការងារនៅក្នុងក្រុមហ៊ុន ឬនៅក្នុងសហគ្រាស។

៤- ឆ្លើយសំណួរ៖

តើថៅកែឬអ្នកគ្រប់គ្រងដែលកេងប្រវ័ញ្ចកម្លាំងពលកម្មត្រូវមានទោសដូចម្តេចខ្លះ ?

# ជំពូកទី ៤
# ការបង្ការទប់ស្កាត់អំពើដកហូតសរីរាង្គ





រាងកាយមនុស្ស ជារចនាសម្ព័ន្ធដែលផ្គុំឡើងដោយសរីរាង្គផ្សេងៗជាច្រើន។ សរីរាង្គនីមួយៗមានមុខងារនិងតួនាទីរៀងៗខ្លួនសម្រាប់គាំទ្រដំណើរការលូតលាស់នៃរាងកាយ សតិបញ្ញា អាយុជីវិតរបស់មនុស្ស។ សរីរាង្គនីមួយៗមានទំនាក់ទំនងគ្នាទៅវិញទៅមក និងធ្វើការជាមួយគ្នាដោយផ្ទាល់ឬដោយប្រយោល ក្នុងខ្លួនមនុស្ស។ រាងកាយរបស់មនុស្សមិនអាចមានសុខភាពល្អបានទេ បើសរីរាង្គណាមួយមិនដំណើរការ ឬខូច។ បច្ចុប្បន្ន វេជ្ជសាស្ត្រមានភាពជឿនលឿនរហូតដល់មានការជួយព្យាបាលអ្នកជំងឺតាមរយៈការយកសរីរាង្គពីមនុស្សម្នាក់ទៅដូរសរីរាង្គដែលខូចមិនដំណើរការរបស់អ្នកជំងឺ។ ដោយសារមូលហេតុនេះហើយ ទើបមានជនខិលខូចឬជនសង្ស័យប្រើកលល្បិច ស្វះស្វែងរកសរីរាង្គរបស់មនុស្សដើម្បីយកទៅលក់ឱ្យអ្នកជំងឺ ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន។ នៅក្នុងជំពូកនេះ អ្នកសិក្សានឹងបានយល់អំពីបញ្ហាពាក់ព័ន្ធការដកហូតសរីរាង្គ ដែលត្រូវបានចាត់ទុកជាអំពើជួញដូរមនុស្ស ។ មេរៀនចំនួន៣ រួមមាន៖

មេរៀនទី១ សញ្ញាណដំបូងនិងផលប៉ះពាល់នៃការដកហូតសរីរាង្គ

មេរៀនទី២ កលល្បិចជនខិលខូចឬជនសង្ស័យក្នុងអំពើដកហូតសរីរាង្គ

មេរៀនទី៣ ការការពារ និងការបង្ការ ទប់ស្កាត់អំពើដកហូតសរីរាង្គ

## មេរៀនទី ១ សញ្ញាណដំបូងនិងផលប៉ះពាល់នៃការដកហូតសរីរាង្គ

### ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចប្រាប់បានអំពីសញ្ញាណ និងផលប៉ះពាល់នៃការដកហូតសរីរាង្គ និងអាចស្វែងយល់ពីគោលបំណងនៃការដកហូតសរីរាង្គ ព្រមទាំងមានបំណិនចូលរួមប្រកបដោយឆន្ទៈទទួលខុសត្រូវប្រយុទ្ធប្រឆាំងការដកហូតសរីរាង្គដោយផ្តល់ព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីសុវត្ថិភាពគ្រួសារនិងសហគមន៍។

### ខ- សកម្មភាពផ្តើម




ចូរឆ្លើយសំណួរខាងក្រោម៖

- តើសរីរាង្គរបស់មនុស្សគឺជាអ្វី?
- ចូរសង្កេតរូបខាងលើ រួចបរិយាយពីតួនាទីរបស់សរីរាង្គនីមួយៗដែលមានមុខងារគាំទ្រដំណើរការលូតលាស់រាងកាយ សុខភាព និងសតិបញ្ញារបស់មនុស្ស។
- តើការដកហូតសរីរាង្គណាមួយរបស់មនុស្សមានផលប៉ះពាល់ដូចម្តេចខ្លះ ?

## គ- ពាក្យគន្លឹះ

- **សរីរាង្គ** (មនុស្ស): ចំណែកនៃសារពាង្គកាយរបស់មនុស្ស ដូចជាបេះដូង ក្រពះ ថ្លោក នោម ពោះវៀន ក្រលៀន តម្រងនោម ថ្លើម សួត...។
- **ការដកហូតយកសរីរាង្គ**: ការវះកាត់ ដោយបង្ខំ ឬសម្លាប់វះកាត់យកសរីរាង្គ ជនណាម្នាក់ ដើម្បីធ្វើអាជីវកម្មឬដើម្បីដោះដូរទៅឱ្យជនណាម្នាក់ទៀត ក្នុងគោលបំណងស្វែងរកប្រយោជន៍។
- **ការជួញដូរសរីរាង្គ**: ការយល់ព្រមពីជនណាម្នាក់ឱ្យវះកាត់យកសរីរាង្គ ដើម្បីដោះដូរទៅឱ្យជនដទៃក្នុងគោលបំណងស្វែងរកប្រយោជន៍។
- **សរីសាស្ត្រ**: វិទ្យាសាស្ត្រទាក់ទងនឹងសរីរាង្គរបស់មនុស្ស។
- **សុខភាពផ្លូវកាយ**: ស្ថានភាពនៃរាងកាយដោយរាប់បញ្ចូលទាំងអ្វីៗគ្រប់យ៉ាងពាក់ព័ន្ធសុខុមាលភាព និងកាយសម្បទា។
- **សុខភាពផ្លូវចិត្ត**: ស្ថានភាពនៃផ្លូវចិត្តរបស់មនុស្ស ដែលរាប់បញ្ចូលការគិត ឥរិយាបថ សុខភាព និងអារម្មណ៍។

## ឃ- អត្ថបទអំណាន

បច្ចុប្បន្ន ពិភពលោកមានការរីកចម្រើនខ្លាំងលើគ្រប់វិស័យ ក្នុងនោះ វិស័យវេជ្ជសាស្ត្រសុខាភិបាលបានទទួលស្គាល់ថាមានការវិវត្តជឿនលឿនយ៉ាងខ្លាំងសម្រាប់បម្រើដល់ការរស់នៅរបស់មនុស្ស។វិស័យវេជ្ជសាស្ត្រ បានស្រាវជ្រាវរកឃើញថ្នាំដែលអាចព្យាបាល និងបង្ការជំងឺផ្សេងៗ រហូតដល់អាចធ្វើការវះកាត់ផ្លាស់ប្តូរសរីរាង្គមនុស្សបានទៀតផង។ អាស្រ័យដោយសរីរាង្គក្លាយជាតម្រូវការសំខាន់ក្នុងវិស័យវេជ្ជសាស្ត្រ និងដើម្បីការពារការជួញដូរសរីរាង្គ ច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាក ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស នេះ ត្រូវបានប្រកាសឱ្យប្រើ ដោយកំណត់ថា សរីរាង្គរបស់មនុស្សត្រូវផ្តល់ជូនវិស័យវេជ្ជសាស្ត្រតាមរយៈការបរិច្ចាគមនុស្សធម៌តែប៉ុណ្ណោះ មិនអាចដកហូតយកសរីរាង្គរបស់មនុស្សតាមរយៈការឱ្យជាប្រាក់ របស់មានតម្លៃ ឬអត្ថប្រយោជន៍អ្វីផ្សេងបានឡើយ។ ដោយសារតែសរីរាង្គមនុស្សមានតម្រូវការកាន់ខ្ពស់ក្នុងការជួយសង្គ្រោះជីវិតអ្នកជំងឺនៅលើសាកលលោកនិងលំបាកក្នុងការស្វែងរកអ្នកបរិច្ចាគដោយស្ម័គ្រចិត្ត ទើបជនខិលខូចឬជនសង្ស័យ ប្រើប្រាស់មធ្យោបាយតាមគ្រប់រូបភាពក្នុងការដកហូតយកសរីរាង្គមនុស្ស ដើម្បីផលប្រយោជន៍របស់ខ្លួន។ ជាទូទៅ អ្នកជំងឺមួយចំនួនដែលមានតម្រូវការ និងមានលទ្ធភាពខ្ពស់ក្នុងការចំណាយទៅលើការផ្លាស់ប្តូរសរីរាង្គតាមបែបវេជ្ជសាស្ត្រ ដើម្បីព្យាបាលជំងឺរបស់ពួកគេ ហេតុនេះពួកគេមិនដែលខ្វាយខ្វល់ពីជីវិតអ្នកដទៃដែលត្រូវបានពួកគេចំណាយប្រាក់ក្នុងការទិញយក ឬដកហូតយកសរីរាង្គនឹងត្រូវជួបបញ្ហាប្រឈមអ្វីខ្លះនៅក្នុងការបន្តជីវិតរស់នៅទៅថ្ងៃមុខនោះឡើយ។ ទង្វើដកហូតយកសរីរាង្គក្នុងគោលបំណងជួញដូរត្រូវផ្តន្ទាទោសទៅតាមច្បាប់។

## ករណីសិក្សា

**កំសត់** ជាបុរសពោះម៉ាយមានវ័យប្រហែល៣០ឆ្នាំ ត្រូវទទួលបន្ទុកចិញ្ចឹមគ្រួសារមានសមាជិកបីនាក់ យ៉ាងលំបាកមួយដែលរកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក។ ម្ដាយរបស់**កំសត់**មានជំងឺប្រចាំកាយ និងត្រូវរកស៊ីបោកគក់ខោអាវឱ្យគេ ដើម្បីបានកម្រៃជួយកូនដែលជាកម្មកររោងម៉ាស៊ីនកិនស្រូវមួយកន្លែង និងចិញ្ចឹមចៅប្រុសកំសត់ម្នាក់អាយុ៧ឆ្នាំ ដែលម្ដាយបានស្លាប់ចោលក្នុងពេលសម្រាលឱ្យបានចូលរៀនដូចគេឯង។ មិនយូរប៉ុន្មាន ម្ដាយរបស់**កំសត់**ធ្លាក់ខ្លួនមានជំងឺកាន់តែធ្ងន់ធ្ងរមិនអាចជួយរកចំណូលបន្ថែមសម្រាប់គ្រួសារបាន។ ទោះជា**កំសត់**ខិតខំធ្វើការងារយ៉ាងណាក៏ដោយ ក៏ចំណូលរបស់គាត់មិនអាចបំពេញតម្រូវការក្នុងការចំណាយទៅលើថ្លៃព្យាបាលជំងឺរបស់ម្ដាយគាត់បានឡើយ។

ថៅកែរោងម៉ាស៊ីនកិនស្រូវជាមនុស្សគោរពស្រឡាញ់ក្រុមគ្រួសារខ្លាំងណាស់ តែជាអកុសលឪពុករបស់គាត់មានជំងឺតម្រងនោមធ្ងន់ធ្ងរ ដែលត្រូវព្យាបាលជាបន្ទាន់។ វេជ្ជបណ្ឌិតបានប្រាប់មកថៅកែម៉ាស៊ីនកិនស្រូវថា ឪពុករបស់គាត់មិនអាចជាសះស្បើយឡើយ ប្រសិនបើមិនអាចស្វែងរកសរីរាង្គក្រលៀន (តម្រងនោម) មកប្ដូរជូនគាត់ទាន់ពេលទេ នោះគាត់នឹងមានគ្រោះថ្នាក់ដល់អាយុជីវិត ប៉ុន្តែការវះកាត់ប្ដូរតម្រងនោមត្រូវធ្វើនៅបរទេស។ បន្ទាប់ពីត្រឡប់មកពីមន្ទីរពេទ្យវិញ ថៅកែម៉ាស៊ីនកិនស្រូវមានក្ដីបារម្ភយ៉ាងខ្លាំង។ ពេលមកដល់ផ្ទះ ថៅកែម៉ាស៊ីនកិនស្រូវបានយករឿងជំងឺឪពុករបស់គាត់មកពិភាក្សាជាមួយប្រពន្ធ។ ប្រពន្ធរបស់គាត់បានផ្ដល់យោបល់ថា "គួរលួងលោមសុំទិញក្រលៀន(តម្រងនោម)របស់កំសត់ទៅ ព្រោះ**កំសត់**កំពុងត្រូវការលុយជាចាំបាច់ក្នុងការព្យាបាលជំងឺម្ដាយ"។ ថ្ងៃបន្ទាប់មក ថៅកែម៉ាស៊ីនកិនស្រូវបានហៅ**កំសត់**មកជួប ហើយបាននិយាយលួងលោមទៅកាន់**កំសត់**ថា "ប្រសិនបើឯងត្រូវការលុយ យើងមានវិធីអាចឱ្យឯងរកលុយបានរាប់ពាន់ដុល្លារ"។ ថៅកែម៉ាស៊ីនស្រូវក៏បានបន្តថា "ឪពុករបស់យើងឈឺធ្ងន់ ត្រូវការសរីរាង្គរបស់ឯងមួយចំហៀង ដើម្បីយកទៅប្ដូរឱ្យគាត់។ យើងបានសួរពេទ្យហើយ ពេទ្យថាមិនមានផលប៉ះពាល់ដល់សុខភាពរបស់ឯងទេ ព្រោះឯងនៅក្មេង ណាមួយយើងកាត់យកក្រលៀន (តម្រងនោម) របស់ឯងតែម្ខាងប៉ុណ្ណោះ ឯងអាចសម្រាកនៅផ្ទះតែ២-៣សប្ដាហ៍ ឯងនឹងអាចមកធ្វើការងារឱ្យយើងបានធម្មតា។ ឯងនៅក្មេងកោសិកាលូតលាស់លឿន បើឯងសុខចិត្តយើងនឹងឱ្យឯង៥០០០ដុល្លារសហរដ្ឋអាមេរិក"។ ឮដូច្នេះ **កំសត់**មានចិត្តត្រេកអរយ៉ាងខ្លាំង ហើយបានឆ្លើយយល់ព្រមភ្លាមៗតែម្ដង។ ថៅកែម៉ាស៊ីនស្រូវបន្តថា "ឯងមិនចាំបាច់ប្រាប់ម្ដាយឬអ្នកណាផ្សេងទេ គ្រាន់តែប្រាប់គាត់ទៅថា យើងនាំឯងទៅដើរលេងនៅបរទេស។ ត្រៀមទៅសប្ដាហ៍ក្រោយយើងនឹងនាំឯងទៅហើយ"។

សប្តាហ៍បន្ទាប់ ថៅកែម៉ាស៊ីនស្រូវបានជួលយន្តហោះឯកជនមួយដើម្បីនាំយកឪពុករបស់គាត់ និង**កំសត់** ទៅវះកាត់នៅបរទេស។ ការវះកាត់ប្រកបដោយជោគជ័យ ឪពុករបស់ថៅកែម៉ាស៊ីនស្រូវ និង**កំសត់**ត្រូវបានដាក់ឱ្យសម្រាកនៅមន្ទីរពេទ្យរយៈពេលមួយខែ។ ពេលត្រឡប់មកពីការវះកាត់នៅបរទេសវិញ **កំសត់**ហាក់មិនបានធូរស្រាលដូចថៅកែម៉ាស៊ីនស្រូវប្រាប់ឡើយ។ ពីមួយថ្ងៃទៅមួយថ្ងៃ កំសត់មានការឈឺចាប់ខ្លាំងឡើងៗនៅក្នុងរាងកាយត្រង់ចំណុចដែលគេកាត់យកសរីរាង្គរបស់គាត់ ហើយកម្លាំងក៏ចុះខ្សោយទៅៗជាលំដាប់។ បួនខែក្រោយ **កំសត់**ដើរដើរខ្លួនឯងលែងរួច និងត្រូវក្លាយជាជនពិការជារៀងរហូត។ ដោយបន្ទុកគ្រួសារ កុមារាដែលជាកូនរបស់**កំសត់**ក៏ត្រូវឈប់រៀនទាំងវ័យក្មេងខ្ចី ដើម្បីទៅស៊ីឈ្នួលលាងចានរកកម្រៃមកជួយគ្រួសារ។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ១- ច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស

- មាត្រា៦ ...ការបរិច្ចាគ និងការទទួលសរីរាង្គមនុស្សត្រូវគោរពតាមលក្ខខណ្ឌ ដូចជាតាមការស្ម័គ្រចិត្តពីអ្នកបរិច្ចាគនិងអ្នកទទួល ឬគោលបំណងសប្បុរសធម៌ និងមនុស្សធម៌។ មិនធ្វើពាណិជ្ជកម្ម និងមិនមានការផ្សាយពាណិជ្ជកម្ម។ សុវត្ថិភាពសុខភាពរបស់អ្នកបរិច្ចាគនិងអ្នកទទួល និងរក្សាការសម្ងាត់របស់អ្នកបរិច្ចាគ និងអ្នកទទួល លើកលែងតែមានការឯកភាពគ្នាពីភាគីពាក់ព័ន្ធ ឬកំណត់ដោយច្បាប់ជាធរមាន...។
- មាត្រា៧ ...អ្នកបរិច្ចាគត្រូវមានអាយុយ៉ាងតិច១៨ឆ្នាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសេចក្តីសម្រេចចិត្តហើយវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន។ ចំពោះជនវិកលចរិត ឬជនវិបល្លាសស្មារតី ការបរិច្ចាគកោសិកា ជាលិកា និងសរីរាង្គត្រូវហាមឃាត់ ទោះជាមានការយល់ព្រមពីឪពុកម្តាយ ឬអ្នកអាណាព្យាបាលក៏ដោយ...។
- មាត្រា៨ ...អ្នកបរិច្ចាគមានសិទ្ធិ ឬអនុញ្ញាតឱ្យមានការដកចេញនូវកោសិកា ជាលិកា និងសរីរាង្គណាមួយរបស់ខ្លួនតាមរយៈការបរិច្ចាគដោយស្ម័គ្រចិត្តក្នុងគោលបំណងព្យាបាលជំងឺ និងមិនធ្វើពាណិជ្ជកម្ម...។
- មាត្រា១០ ...អ្នកបរិច្ចាគត្រូវទទួលបាននូវការថែទាំសុខភាព សុខុមាលភាពមុនពេល ក្នុងអំឡុងពេល និងក្រោយពេលបរិច្ចាគពីមន្ទីរពេទ្យដែលធ្វើការផ្សាំកោសិកា ជាលិកា និងសរីរាង្គ។ រាល់ការចំណាយលើការថែទាំសុខភាព សុខុមាលភាពដែលទាក់ទងនឹងការផ្សាំកោសិកា ជាលិកា និងសរីរាង្គ មុនពេល ក្នុងអំឡុងពេល និងក្រោយពេលបរិច្ចាគ ជាបន្ទុករបស់មន្ទីរពេទ្យដែលធ្វើការផ្សាំកោសិកា ជាលិកា និងសរីរាង្គ...។

- មាត្រា១៧ ...ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស មិនត្រូវអនុញ្ញាតឱ្យធ្វើឡើងក្នុងគោលបំណងធ្វើការផ្សាយពាណិជ្ជកម្មឡើយ។ ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជកម្មទាក់ទងទៅនឹងការទិញលក់សរីរាង្គមនុស្សត្រូវហាមឃាត់ជាដាច់ខាត...។

## ង- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើមូលហេតុអ្វី ដែលបណ្ដាលឱ្យកំសត់សម្រេចចិត្តលក់ដូរសរីរាង្គរបស់ខ្លួន?

២- តើថៅកែម៉ាស៊ីនស្រូវបានលួងលោម និងឆបោកកំសត់ដូចម្ដេចខ្លះ?

៣- តើប្រាក់ដែលកំសត់ទទួលបានពីការលក់សរីរាង្គរបស់គាត់អាចជួយដល់ជីវភាពគ្រួសារគាត់ដូចការគិតរបស់គាត់ដែរឬទេ?

៤- តើកំសត់ក្លាយជាមនុស្សមានសុខភាពបែបណាក្រោយពេលលក់សរីរាង្គ?ហេតុអ្វី?

៥- តើផលប៉ះពាល់នៃការលក់ដូរសរីរាង្គរបស់កំសត់ បន្សាយផលអវិជ្ជមានដល់អ្នកណាខ្លះ? ហេតុអ្វី?

៦- បើមាននរណាម្នាក់សុំឱ្យអ្នក ឬសមាជិកណាម្នាក់ក្នុងគ្រួសារអ្នក ឱ្យបរិច្ចាគសរីរាង្គ ជាថ្នូរនឹងប្រាក់កាស តើអ្នកយល់ព្រមដែរឬទេ? ហេតុអ្វី?

៧- ក្នុងករណីដែលអ្នកបានដឹងឮថាមានការលក់ដូរសរីរាង្គរបស់ជនណាម្នាក់ តើអ្នកគួរត្រូវធ្វើដូចម្ដេច?

## ច- កិច្ចការផ្ទះ

ការដកហូតសរីរាង្គជាសកម្មភាពខុសច្បាប់ និងមានផលវិបាកជាច្រើនចំពោះជនរងគ្រោះ។ ចូររកមធ្យោបាយផ្ទាល់ខ្លួនដើម្បីធ្វើការផ្សព្វផ្សាយបន្តដល់មិត្តភក្តិ និងសហគមន៍របស់អ្នកក្រោមប្រធានបទ **“ចូរនិយាយថាទេ ចំពោះការជួញដូរសរីរាង្គ”**។

## មេរៀនទី ២ កលល្បិចក្នុងអំពើជួញដូរសរីរាង្គ

### ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សានឹងអាចពន្យល់បានពីមូលហេតុដែលនាំឱ្យមានការដកហូតសរីរាង្គពីមនុស្សម្នាក់ទៅឱ្យមនុស្សម្នាក់ទៀត និងធ្វើកំណត់សម្គាល់បានពីមុខសញ្ញានិងកលល្បិចជនខិលខូចឬជនសង្ស័យដែលប្រើការលួងលោមឬគំរាមកំហែងជនរងគ្រោះឱ្យផ្តល់សរីរាង្គជាថ្នូរនឹងប្រាក់កាស វត្ថុមានតម្លៃផ្សេងៗ ព្រមទាំងអាចបង្កើនឆន្ទៈប្រុងប្រយ័ត្ន និងចូលរួមប្រយុទ្ធប្រឆាំងការដកហូតសរីរាង្គដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន និងមនុស្សជុំវិញខ្លួន។

### ខ- សកម្មភាពផ្តើម

ចូរពិនិត្យរូបភាពខាងក្រោម រួចបង្ហាញពីទស្សនៈតាមការយល់ឃើញ។




### គ- ពាក្យគន្លឹះ

- **ជនងាយរងគ្រោះ:** ក្រុមមនុស្សដែលងាយត្រូវបានគេកេងប្រវ័ញ្ច និងធ្លាក់ក្នុងគ្រោះថ្នាក់ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត។
- **ទីផ្សារងងឹត:** ទីប្រជុំសកម្មភាពលក់ដូរឬទិញសរីរាង្គឬវត្ថុផ្សេងៗដែលមិនស្របច្បាប់ឬដោយលួចលាក់។

### ឃ- អត្ថបទអំណាន

បច្ចុប្បន្ន មនុស្សគ្រប់វ័យនៅលើសាកលលោកបាននិងកំពុងជួបការប្រឈមទៅនឹងបញ្ហាសុខភាព។ អ្នកជំងឺខ្លះទាមទារការព្យាបាលដោយការវះកាត់ដោះដូរសរីរាង្គដោយវិទ្យាសាស្ត្រវេជ្ជសាស្ត្រទំនើប។ បច្ចេកវិទ្យានៃការព្យាបាលនេះបាននាំឱ្យសរីរាង្គរបស់មនុស្សក្លាយទៅជាតម្រូវការ

របស់អ្នកមានជំងឺ និងបានបង្កឱ្យកើតមានជាទីផ្សារងងឹតនៅតាមប្រទេសមួយចំនួន ជាពិសេសប្រទេសដែលមានកម្រិតជីវភាពប្រជាជនក្រីក្រច្រើន។ ក្នុងនោះជនខិលខូចឬជនសង្ស័យ បានរៀបចំរចនាសម្ព័ន្ធយ៉ាងសម្ងាត់ដើម្បីទិញ លក់សរីរាង្គមនុស្សក្នុងទីផ្សារងងឹតជុំវិញពិភពលោកដើម្បីទាញយក ផលចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់។ ពេលខ្លះជនខិលខូចឬជនសង្ស័យប្រើវិធីអូសទាញជនរងគ្រោះដោយផ្តល់សម្ភារៈមានតម្លៃឬប្រាក់យ៉ាងច្រើនលើសលប់ដើម្បីទិញសរីរាង្គ។ ពេលខ្លះជនខិលខូចឬជនសង្ស័យទាំងនោះ តែងតែធ្វើសកម្មភាពអមនុស្សធម៌ក្នុងការស្វែងរកសរីរាង្គមនុស្សគ្រប់វ័យដើម្បីបំពេញតម្រូវការ និងប្រយោជន៍របស់ពួកគេ។ ការដកហូតយកសរីរាង្គក៏អាចកើតលើមនុស្សគ្រប់រូបតាមរយៈការលួងលោម បោកបញ្ឆោត ការចាប់ពង្រត់ ឬករណីខ្លះរហូតដល់មានការសម្លាប់ដើម្បីដកហូតយកសរីរាង្គទៀតផង។

## ករណីសិក្សា

**សុភ័ក្ត្រ**ជាអ្នកបកប្រែភាសាបរទេសនៅក្នុងមន្ទីរពេទ្យមួយនៅក្រៅប្រទេស។ មន្ទីរពេទ្យនោះមានអ្នកគ្រូពេទ្យជំនាញឯកទេសផ្នែកវះកាត់ផ្លាស់ប្តូរសរីរាង្គមនុស្សយ៉ាងចំណាន។ ជារៀងរាល់ខែមន្ទីរពេទ្យនោះ មានអ្នកជំងឺដែលបានទៅធ្វើការវះកាត់ផ្លាស់ប្តូរសរីរាង្គជាច្រើននាក់ ទាំងក្នុងរូបភាពមនុស្សធម៌ ទាំងការវះកាត់បែបទិញ លក់សរីរាង្គក៏មានច្រើនដែរ។ ការផ្លាស់ប្តូរសរីរាង្គមនុស្សកាន់តែមានតម្រូវការខ្ពស់ ធ្វើឱ្យ**សុភ័ក្ត្រ**គិតថាវាអាចជាមុខរបរមួយថ្មីដែលងាយរកប្រាក់បានច្រើន ពីព្រោះគាត់ស្គាល់មនុស្សដែលមានជីវភាពខ្វះខាតច្រើនដែលរស់នៅក្នុងភូមិកំណើតរបស់គាត់។ **សុភ័ក្ត្រ** ធ្លាប់បានឮគ្រូពេទ្យនិយាយថា បើគាត់អាចរកអ្នកណាម្នាក់ដែលព្រមឱ្យពេទ្យកាត់យកសរីរាង្គដើម្បីផ្លាស់ប្តូរឱ្យអ្នកជំងឺ នោះគាត់នឹងទទួលបានកម្រៃជើងសារជាប្រាក់ចំនួនពីរពាន់ដុល្លាសហរដ្ឋអាមេរិកសម្រាប់មួយករណី។

ថ្ងៃមួយមានអ្នកជំងឺចំណាស់ម្នាក់ជាជនជាតិបរទេស មានជំងឺក្រិនថ្លើមធ្ងន់ធ្ងរហើយត្រូវការផ្លាស់ប្តូរជាចាំបាច់។ មន្ទីរពេទ្យនោះ មិនអាចរកសរីរាង្គមកផ្លាស់ប្តូរជូនអ្នកជំងឺបានឡើយ ទើបប្រពន្ធអ្នកជំងឺបានប្រាប់ឱ្យ**សុភ័ក្ត្រ**ជួយរកអ្នកណាម្នាក់ដែលអាចផ្តល់ថ្លើមមួយផ្នែកដើម្បីផ្លាស់ប្តូរជូនប្តីរបស់គាត់ គាត់នឹងផ្តល់ជាសគុណចំនួន ៣ពាន់ដុល្លារអាមេរិក។ **សុភ័ក្ត្រ**បានធ្វើដំណើរមកស្រុកកំណើតដើម្បីស្វែងរកនិងបញ្ចុះបញ្ចូលមនុស្សម្នាក់ដែលរស់នៅក្នុងសហគមន៍របស់គាត់។ ពេលមកដល់ស្រុកភ្លាម**សុភ័ក្ត្រ**បានទៅជួប**ពូសំ**ដែលមានជីវភាពខ្វះខាត និងមានកូន៦នាក់ក្នុងបន្ទុក។ ដោយមើលឃើញឱកាសល្អបែបនេះ **សុភ័ក្ត្រ**បានប្រើកលល្បិចលួងលោម បញ្ចុះបញ្ចូល**ពូសំ**ថា "ខ្លួនជាអ្នកជំនាញក្នុងការជួយសង្គ្រោះដល់អ្នកមានជំងឺធ្ងន់ធ្ងរ ដែលត្រូវការវះកាត់ប្តូរសរីរាង្គដើម្បីសង្គ្រោះជីវិត និងជួយដល់អ្នកក្រីក្រក្នុងសហគមន៍ដែលចង់បានប្រាក់ច្រើនមកគាំទ្រជីវភាព។ ការដកយកសរីរាង្គថ្លើមមួយផ្នែក នោះមិនប៉ះពាល់ដល់សុខភាពឡើយ ហើយក៏ជារឿងមនុស្សធម៌

ទៀតផង ដូចបានសាងកុសលបុណ្យសង្គ្រោះជីវិតសត្វលោក”។ សុភ័ក្ត្របានប្រាប់ថា “ បើពូព្រម កាត់ថ្លើមរបស់ពូមួយចំណែកដើម្បីជួយសង្គ្រោះដល់អ្នកជំងឺម្នាក់នោះ ពូនឹងទទួលបានប្រាក់ចំនួន ១ម៉ឺនដុល្លារអាមេរិក ហើយខ្ញុំធានាថា នឹងមិនប៉ះពាល់ដល់សុខភាពរបស់ពូឡើយ”។ ពូដូច្នេះ និង ស្របពេលដែលគ្រួសារកំពុងមានតម្រូវការថវិកាក្នុងការផ្គត់ផ្គង់ជីវភាពផងនោះ ពូសំក៏បានឆ្លើយ យល់ព្រមដោយមិនបានពិចារណាវែងឆ្ងាយ។ក្រោយពេលពូសំយល់ព្រម សុភ័ក្ត្រប្រាប់ពូសំថា “ពីរ ថ្ងៃទៀតខ្ញុំនឹងនាំពូទៅបរទេស ដើម្បីធ្វើការវះកាត់ជួយដល់អ្នកជំងឺតែម្តងព្រោះគាត់ស្ថិតក្នុងស្ថាន ភាពធ្ងន់ធ្ងរ រីឯថវិកាខ្ញុំនឹងជូនទៅប្រពន្ធពូពាក់កណ្តាលសិន និងពាក់កណ្តាលទៀតខ្ញុំនឹងជូនពូ ក្រោយការវះកាត់រួចរាល់”។ ពីរថ្ងៃបន្ទាប់ សុភ័ក្ត្របានមកនាំពូសំ ចេញទៅបរទេសដើម្បីធ្វើការវះ កាត់។ ក្រោយពេលវះកាត់ផ្លាស់ប្តូរសរីរាង្គ(ថ្លើម) អ្នកជំងឺក៏មានសភាពធូរស្រាល ចំណែកពូសំបែរ ជាមានអាការៈធ្ងន់ធ្ងរដែលគ្រូពេទ្យមិនអាចជួយសង្គ្រោះបាន។ ប៉ុន្មានថ្ងៃក្រោយមកពូសំបានស្លាប់ បាត់បង់ជីវិតនៅទីនោះ ហើយចំណែកប្រាក់ដែលនៅសល់ពាក់កណ្តាលពីការលក់ថ្លើមរបស់គាត់ នោះ បានត្រឹមតែចំណាយក្នុងការបំពេញបែបបទដើម្បីបញ្ជូនសពរបស់គាត់ត្រឡប់មកស្រុក កំណើតវិញប៉ុណ្ណោះ។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

### ១- ច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស

- មាត្រា១៧... ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្សមិនត្រូវអនុញ្ញាតឱ្យធ្វើឡើង ក្នុងគោលបំណងធ្វើការផ្សាយពាណិជ្ជកម្មឡើយ។ ការផ្សព្វផ្សាយជាលក្ខណៈពាណិជ្ជ កម្មទាក់ទងទៅនឹងការទិញលក់សរីរាង្គមនុស្សត្រូវហាមឃាត់ជាដាច់ខាត...។
- មាត្រា២១...អំពើដកយកកោសិកា ជាលិកា ឬសរីរាង្គមនុស្សពីជនដែលត្រូវបានហាម ឃាត់ការបរិច្ចាគដូចមានចែងក្នុងមាត្រា៧នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី៧ (ប្រាំពីរ) ឆ្នាំទៅ១៥ (ដប់ប្រាំ) ឆ្នាំ។ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ (ដប់) ឆ្នាំទៅ២០ (ម្ភៃ) ឆ្នាំ កាលបើអំពើខាងលើនេះ នាំឱ្យមានការកាត់អវយវៈ ឬនាំឱ្យមាន ពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ឬបណ្តាលឱ្យជនរងគ្រោះស្លាប់ដោយគ្មាន ចេតនាសម្លាប់។
- មាត្រា២២...អំពើដកយកកោសិកា ជាលិកា ឬសរីរាង្គមនុស្សដែលគ្មានការបង្ហាញឆ ន្ទៈយល់ព្រមបរិច្ចាគពីអ្នកបរិច្ចាគត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ) ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំ។ ត្រូវផ្តន្ទាទោសដូចកថាខណ្ឌទី១ខាងលើ ចំពោះអំពើអូសទាញ លួងលោម បោកបញ្ឆោត ឬប្រើឧបាយកលទុច្ចរិតផ្សេងទៀតដើម្បីទទួលបានការ យល់ព្រមបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្សពីអ្នកបរិច្ចាគ។ ត្រូវចាត់ទុកថា

គ្មានការយល់ព្រមពីអ្នកបរិច្ចាគចំពោះករណីដែលការព្រមព្រៀងរវាងអ្នកបរិច្ចាគនិងអ្នកទទួលមិនបានធ្វើជាលាយលក្ខណ៍អក្សរ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់)ឆ្នាំ ទៅ២០(ម្ភៃ)ឆ្នាំ កាលបើអំពើខាងលើនេះនាំឱ្យមានការកាត់អវយវៈ ឬនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ឬបណ្តាលឱ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់...។

- មាត្រា២៣...អំពើផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្សក្នុងគោលបំណងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់) ឆ្នាំទៅ២០(ម្ភៃ) ឆ្នាំ...។
- មាត្រា២៦...អំពើមិនផ្តល់ព័ត៌មានអំពីដំណើរការនៃការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្សនិងផលប៉ះពាល់ ឬផលវិបាក ឬគ្រោះថ្នាក់ដែលអាចកើតមានឡើងដល់អ្នកបរិច្ចាគមុននឹងសុំការយល់ព្រមត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ)ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០ (មួយលាន) រៀលទៅ ៤ ០០០ ០០០ (បួនលាន) រៀល...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើសុភ័ក្រ្តប្រើប្រាស់កលល្បិចអ្វីខ្លះដើម្បីបញ្ឆោះបញ្ចូលពូសំឱ្យកាត់ដូរសរីរាង្គ?

២- តើមូលហេតុអ្វីដែលបណ្តាលឱ្យពូសំយល់ព្រមជាមួយសុភ័ក្រ្តដោយមិនបានពិចារណា?

៣- តើមូលហេតុអ្វីដែលបណ្តាលឱ្យពូសំស្លាប់?

៤- តើលុយដែលពូសំទទួលបានពិតជាបានជួយសម្រាលបន្ទុកគ្រួសារដូចអ្វីដែលគាត់បានរំពឹងទុកដែរឬទេ?

៥- តើករណី សុភ័ក្រ អាចត្រូវប្រឈមមុខទៅនឹងការផន្ទាទោសដែរឬទេ? ហេតុអ្វី?

៦- បើអ្នកជាសមាជិកគ្រួសាររបស់ពូសំ តើត្រូវធ្វើដូចម្តេចដើម្បីចៀសផុតពីអំពើដកហូតសរីរាង្គ?

៧- បើអ្នកជាសមាជិកគ្រួសាររបស់ពូសំ តើត្រូវធ្វើដូចម្តេចបន្ទាប់ពីមរណភាពរបស់ពូសំ?

## ច- កិច្ចការផ្ទះ

១- ចូរបកស្រាយប្រយោគប្រាក់ក៏បង់ ចង់ក៏ដាច់ដោយភ្ជាប់សាច់រឿងជាមួយករណីសិក្សាខាងលើ។

២- ចូរប្អូនបំពេញក្នុងតារាងខាងក្រោមអំពីផលប៉ះពាល់នៃជីវិតរបស់មនុស្សម្នាក់ ប្រសិនបើសរីរាង្គរបស់ខ្លួនមានជំងឺ ឬបាត់បង់។

| ល.រ | ប្រធានបទ | ផលប៉ះពាល់ដល់រាងកាយ អារម្មណ៍របស់មនុស្ស |
|---|---|---|
| ១ | រាងកាយ | *ឧទាហរណ៍ៈ រាងកាយទ្រុឌទ្រោម ការលំបាកក្នុងការធ្វើចលនា នៅ១កន្លែង។* |
| ២ | សុខភាព | |
| ៣ | ការរស់នៅ | |
| ៤ | ការសិក្សា | |
| ៥ | ការងារ | |
| ៦ | ជីវិកា | |
| ៧ | កិត្តិយស | |
| ៨ | ផ្លូវចិត្ត | |
| ៩ | ទំនាក់ទំនងគ្រួសារ | |
| ១០ | សេវាកម្មសង្គម | |

៣- តើសុភាសិត ពុទ្ធោវាទ និងពាក្យស្លោកខាងក្រោមមានអត្ថន័យដូចម្ដេចពាក់ព័ន្ធទៅនឹងករណីដកហូតសរីរាង្គ ?

- កុកតែងតែភ្លេចជុង តែជុងមិនដែលភ្លេចកុក
- ចិត្តជាចំណង់ សតិតម្រង់ ប្រាជ្ញាជាដំណោះស្រាយ
- គិតមុនគូរ
- ដំបៅមិនឈឺ យកឈើទៅចាក់
- បើក្រទ្រព្យក៏ក្រចុះ កុំឱ្យតែទាល់គំនិត។

## មេរៀនទី ៣ ការការពារ និងការបង្ការ ទប់ស្កាត់អំពើជួញដូរសរីរាង្គ

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សានឹងរៀបរាប់បានពីវិធីបង្ការទប់ស្កាត់ទុកជាមុនពីភាពរងគ្រោះដោយការដកហូតសរីរាង្គ និងមានបំណិនចូលរួមក្នុងការបង្ការនិងទប់ស្កាត់បទល្មើសផ្សេងៗជាពិសេសបទល្មើសការដកហូតសរីរាង្គ ព្រមទាំងអាចជួយលើកទឹកចិត្តមនុស្សជុំវិញឱ្យឆ្លើយថា ទេ ព្រមគ្នាចំពោះការដកហូតសរីរាង្គ។

## ខ- សកម្មភាពផ្ដើម

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើសុភាសិត " ការពារប្រសើរជាងព្យាបាល " មានន័យដូចម្ដេច ?

២- តើមនុស្សគ្រប់រូបត្រូវធ្វើដូចម្ដេចដើម្បីថែទាំសរីរាង្គរបស់ខ្លួនបានរឹងមាំល្អ?

## គ- ពាក្យគន្លឹះ

- **ការបង្ការ:** ការរារាំង ការប្រុងប្រយ័ត្ន ការទប់ស្កាត់សេចក្ដីអន្តរាយឬការខ្វះខាតក្រែងនឹងមានទៅខាងមុខដែលអាចកើតមានឡើងដោយយថាហេតុ។
- **ការទប់ស្កាត់:** ការបិទ ការរាំង ការឃាត់ឃាំង និងការពារមិនឱ្យគ្រោះថ្នាក់ ឬហានិភ័យអ្វីមួយដែលអាចកើតមានឡើងដល់ខ្លួន ដល់គ្រួសារ ដល់សហគមន៍ និងប្រទេសជាតិ។
- **ហានិភ័យ:** សំដៅដល់សកម្មភាពអ្វីមួយ ដែលអាក្រក់ មិនល្អ ហើយអាចកើតមានឡើងចំពោះអ្នកដូចជាការដកហូតសរីរាង្គ។

## ឃ- អត្ថបទអំណាន

សរីរាង្គរបស់មនុស្សក្នុងវិស័យវិទ្យាសាស្ត្រវេជ្ជសាស្ត្រមានតម្រូវការកាន់តែច្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ការព្យាបាលដោយវិធីដោះដូរសរីរាង្គមនុស្សម្នាក់ទៅឱ្យអ្នកជំងឺដែលមានតម្រូវការគឺត្រូវចំណាយថ្លៃខ្ពស់ជាលំដាប់ ជាហេតុនាំឱ្យជនខិលខូចឬជនសង្ស័យនៅលើសាកលលោក ខិតខំបង្កើតជារចនាសម្ព័ន្ធស្វែងរកនិងលក់ដូរឆ្លងប្រទេសទៀតផងដើម្បីផ្គត់ផ្គង់ក្នុងទីផ្សារងងឹតរបស់ពួកគេ។ ដោយសារការដកហូតសរីរាង្គមនុស្ស កាន់តែមានភាពឃោរឃៅទៅៗ និងរីករាលដាលកាន់តែខ្លាំងនៅជុំវិញពិភពលោក មនុស្សម្នាក់ៗត្រូវមានវិធីការពារខ្លួនឯងដូចខាងក្រោម៖

- នៅឱ្យឆ្ងាយពីជនដែលយើងមិនស្គាល់ (ជនខិលខូចឬជនសង្ស័យ)
- មិនត្រូវទទួលប្រាក់ ឬរបស់មានតម្លៃពីជនដទៃដើម្បីដោះដូរទៅនឹងសរីរាង្គរបស់អ្នក

- រៀនសង្កេតមើលសកម្មភាពជនប្លែកមុខដែលចូលមកក្នុងសាលារៀន និងសហគមន៍របស់អ្នក
- មិនត្រូវនៅកន្លែងស្ងាត់ ដាច់ឆ្ងាយពីគេ
- មិនត្រូវទទួលយកចំណីអាហារឬភេសជ្ជៈពីជនមិនស្គាល់ប្រវត្តិច្បាស់លាស់
- ត្រូវស្ដាប់ព័ត៌មានពិតរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ត្រូវខិតខំរៀនសូត្រឱ្យមានចំណេះដឹងខ្ពង់ខ្ពស់ទាំងភាសាជាតិ និងភាសាបរទេស ដើម្បីអាន ព័ត៌មានគ្រប់ជ្រុងជ្រោយនៅលើសាកលលោក និងចេះវិភាគបានត្រឹមត្រូវ
- ត្រូវរាយការណ៍បន្ទាន់ពីសកម្មភាពជនខិលខូចឬជនសង្ស័យ ទៅឪពុកម្ដាយ លោកគ្រូអ្នកគ្រូ អាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចពាក់ព័ន្ធ
- ត្រូវនិយាយថា "ទេ" ចំពោះការទិញ-លក់សរីរាង្គតាមគ្រប់រូបភាព។

## ករណីសិក្សា

**សុភី**ជានារីវ័យក្មេងមានអាយុ១៥ឆ្នាំ និងត្រូវជាកូនរបស់**ពូសំ** និង**មីងចន្ទី** រស់នៅក្នុងសហគមន៍មួយ និងមានជីវភាពខ្សត់ខ្សោយ។ ឪពុករបស់នាងធ្លាប់បានចាញ់បោកកលល្បិចជនខិលខូចឬជនសង្ស័យក្នុងករណីជួញដូរសរីរាង្គរហូតដល់បាត់បង់ជីវិត។ ក្រោយពេលមរណភាពរបស់ឪពុកដែលជាមេគ្រួសារ**សុភី** និងម្ដាយជាអ្នកទទួលបន្ទុកក្នុងការរកចំណូលផ្គត់ផ្គង់គ្រួសារ។ ទោះបី**សុភី**មិនបានបន្តការសិក្សាតាមប្រព័ន្ធពេញលេញនៅសាលាក៏ដោយ តែ**សុភី**បានចូលរៀនកម្មវិធីអក្ខរកម្មវិជ្ជាជីវៈក្នុងភូមិ ដែលអាចផ្ដល់ឱកាសឱ្យនាងមានមុខរបររកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារបាន។ ដោយបានឆ្លងកាត់បទពិសោធន៍ដ៏លំបាកនៃការបាត់បង់មេគ្រួសារក្នុងករណីជួញដូរសរីរាង្គ នាងបានចូលរួមធ្វើជាជនបង្គោលនៃក្រុមមិត្តអប់រំមិត្ត ដើម្បីផ្សព្វផ្សាយការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសអំពើដកហូតសរីរាង្គ។ នៅពេលចុះអប់រំផ្សព្វផ្សាយម្ដងៗ **សុភី**តែងតែរំលឹកដាស់តឿនដល់ពលរដ្ឋក្នុងសហគមន៍របស់នាងថា "សូមកុំចាញ់បោកកលល្បិចជនខិលខូចឬជនសង្ស័យក្នុងការលក់ដូរសរីរាង្គដោយដោះដូរជាមួយនឹងប្រាក់ ព្រោះវាមានហានិភ័យខ្ពស់ណាស់ដល់សុខុមាលភាពនិងអាយុជីវិតគ្រួសារយើង។ ករណីឪពុករបស់ខ្ញុំជាគំរូស្រាប់ ដោយសារតែជីវភាពខ្វះខាត ភាពទន់ខ្សោយផ្នែកចំណេះវិជ្ជា និងកង្វះព័ត៌មានសម្រាប់គាំទ្របំណិនពិចារណា ទើបឪពុករបស់ខ្ញុំសម្រេចចិត្តលក់សរីរាង្គរបស់គាត់ ដើម្បីយកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ តែទីបំផុតពុកត្រូវស្លាប់បាត់បង់ជីវិត ឯប្រាក់ដែលទទួលបានតែពាក់កណ្ដាលប៉ុណ្ណោះ ហើយលុយដែលយើងទទួលបានមិនបានជួយឱ្យជីវភាពគ្រួសារបានប្រសើរដូចការរំពឹងទុករបស់គាត់ទេ។ ទីបំផុតលុយក៏បានតិច ជីវិតក៏បាត់បង់គ្រួសារជួបទុក្ខលំបាក ខ្វះភាពកក់ក្ដៅ"។ នាងក៏បានបន្តទៀតថា "... ប្រសិនបើមានជនណាម្នាក់ចូលមកក្នុងសហគមន៍របស់ពួកយើង ហើយប្រើកលល្បិច

លួងលោម អូសទាញឱ្យបងប្អូន ពូមីង ដោះដូរសរីរាង្គជាមួយប្រាក់កម្រៃដូចករណីឪពុករបស់ខ្ញុំ សូមកុំចាញ់បោកពួកគេ ឬបើមានករណីសង្ស័យថាមានពលរដ្ឋណាម្នាក់ត្រូវបានគេលួងលោម គំរាមកំហែង ចាប់ពង្រត់ បង្ខិតបង្ខំ ឬបង្ខាំងក្នុងគោលបំណងទុច្ចរិត ត្រូវរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ជាបន្ទាន់ព្រោះករណីនេះគឺជាអំពើខុសច្បាប់។ បងប្អូន ពូមីងអាចរាយការណ៍ទៅកាន់លេខទូរស័ព្ទ ១២៨៨ និង ០៩២ ៣១១ ៥១១។ បើយើងមិនលោភលន់ មិនវង្វេងដោយសម្ភារនិយម ទោះបីយើងមិនបានចូលរៀនពេញលេញ តែយើងអាចមានក្រសួង ស្ថាប័ននិងរដ្ឋអំណាចមូលដ្ឋានដែលអាចជួយយើងឱ្យមានលទ្ធភាពទទួលបានជំនាញវិជ្ជាជីវៈដែលអាចជួយរកការងារធ្វើក្នុងស្រុកយើង បាននៅជិតគ្រួសារយើង និងអាចឱ្យយើងទទួលបានកម្រៃសមល្មមរស់នៅដោយសុភមង្គល។ សាររបស់សុភី ត្រូវបានសហគមន៍គាំទ្រ ហើយក៏មានយុវជនក្នុងភូមិជាច្រើននាក់យកទៅផ្សព្វផ្សាយបន្តទទួលបានជោគជ័យក្នុងការបង្ការទប់ស្កាត់អំពើអមនុស្សធម៌នោះ។

## ច្បាប់ និងបទដ្ឋានយុត្តពាក់ព័ន្ធ

### ១- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា១០ ការនាំយកដោយមិនស្របច្បាប់ដោយមានគោលដៅ ...ជនណានាំចេញយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬ ទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ) ឆ្នាំដល់១៥(ដប់ប្រាំ) ឆ្នាំ...។ ...ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំទៅ២០(ម្ភៃ)ឆ្នាំ ក្នុងករណីៈ ជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួន អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង...។

  ពាក្យថា ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត នៅក្នុងមាត្រានេះ មាត្រា១២ មាត្រា១៥ មាត្រា១៧ និងមាត្រា១៩ នៃច្បាប់នេះរួមមាន ការកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ រូបភាព និងសម្ភារៈអាសអាភាស ពាណិជ្ជកម្មផ្លូវភេទ សេវា ឬពលកម្មដោយបង្ខំ ទាសភាព ឬការអនុវត្តស្រដៀងគ្នានឹងទាសភាព ការបញ្ចាំខ្លួនដោះបំណុលសេរីភាពដោយមិនស្ម័គ្រចិត្ត ពលកម្មកុមារ ឬ ការដកហូតសរីរាង្គ។

- មាត្រា១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច ...ការជ្រើសរើសដោយមិនស្របច្បាប់នៅក្នុងច្បាប់នេះ មានន័យថា កាបញ្ចុះបញ្ចូល ការជួល ឬការឱ្យជនណាមួយបម្រើការក្រោមទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត តាមមធ្យោបាយបោកបញ្ឆោត បំពានដោយអំណាច ការបង្ខាំងខ្លួន ការប្រើប្រាស់កម្លាំង ការគំរាម

កំហែង ឬមធ្យោបាយបង្ខិតបង្ខំផ្សេងទៀត...។...ជនណាជ្រើសជនដទៃដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ) ឆ្នាំដល់១៥(ដប់ប្រាំ) ឆ្នាំ...។ ...ត្រូវផ្តន្ទាទោសពី១៥(ដប់ប្រាំ)ឆ្នាំដល់២០(ម្ភៃ)ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈដែលបំពានអំណាចរបស់ខ្លួនមកលើជនរងគ្រោះ...។

- មាត្រា១៥ អំពើលក់ ដូរមនុស្សដោយមានគោលដៅ... ជនណាលក់-ដូរជនដទៃដោយមានគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់នៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំដល់១៥ (ដប់ប្រាំ) ឆ្នាំ...។...ត្រូវផ្តន្ទាទោសពី១៥(ដប់ប្រាំ) ឆ្នាំដល់២០(ម្ភៃ)ឆ្នាំ ក្នុងករណី ជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង...។

## ២- ច្បាប់ស្តីពីការគ្រប់គ្រងលើការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា និងសរីរាង្គមនុស្ស

- មាត្រា២០ ...អំពើប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល ក្នុងការបរិច្ចាគ ការផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១ (មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងត្រូវពិន័យជាប្រាក់ពី២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល...។
- មាត្រា២២ ...អំពើដកយកកោសិកា ជាលិកា ឬសរីរាង្គមនុស្សដោយគ្មានការបង្ហាញឆន្ទៈយល់ព្រមបរិច្ចាគពីអ្នកបរិច្ចាគត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ) ឆ្នាំទៅ ១៥ (ដប់ប្រាំ) ឆ្នាំ...។
- មាត្រា២៣ ...អំពើផ្សាំកោសិកា ជាលិកា ឬសរីរាង្គមនុស្ស ក្នុងគោលបំណងពាណិជ្ជកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់)ឆ្នាំ ទៅ២០(ម្ភៃ) ឆ្នាំ...។
- មាត្រា២៤ ...អំពើផ្សព្វផ្សាយពាណិជ្ជកម្មទាក់ទងនឹងការទិញលក់សរីរាង្គមនុស្សត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ)ឆ្នាំ ទៅ១០(ដប់) ឆ្នាំ...។
- មាត្រា២៦ ...អំពើមិនផ្តល់ព័ត៌មានអំពីដំណើរការនៃការបរិច្ចាគកោសិកា ជាលិកា ឬសរីរាង្គមនុស្ស និងផលប៉ះពាល់ ឬផលវិបាក ឬគ្រោះថ្នាក់ ដែលអាចកើតមានឡើងដល់អ្នកបរិច្ចាគ មុននឹងសុំការយល់ព្រម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៦(ប្រាំមួយ) ខែទៅ២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ពី១ ០០០ ០០០(មួយលាន) រៀលទៅ៤ ០០០ ០០០ (បួនលាន) រៀល...។

## ង- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម និងចូលរួមសម្តែងតួ៖

១- តើសុភីធ្វើអ្វីទើបអាចទទួលបានចំណេះដឹង និងជំនាញវិជ្ជាជីវៈរកចំណូលចិញ្ចឹមគ្រួសារបាន?

២- តើសុភីបានបង្ហាញពីលកល្បិចរបស់ជនខិលខូចឬជនសង្ស័យក្នុងបទជួញដូរ ឬដកហូតសរីរាង្គ មានដូចម្តេចខ្លះ?

៣- តើត្រូវធ្វើដូចម្តេច ទើបចៀសផុតពីអំពើដកហូតសរីរាង្គ?

៤- ចូរពិភាក្សាជាក្រុមដើម្បីសម្តែងតួ មួយក្រុមមានគ្នា៥នាក់ ម្នាក់ជាជនរងគ្រោះ ដោយពីនាក់សម្តែងតួជាជនខិលខូច ឬជនសង្ស័យដែលមានគម្រោងប្រើល្បិចខុសពីករណីឪពុករបស់សុភី ទៅលើជនងាយរងគ្រោះដើម្បីមហិច្ឆតាលក់ដូរសរីរាង្គ។ ពីរនាក់ផ្សេងទៀត ដើរតួជាអ្នកតាមអង្កេត និងអូសទាញ ជនខិលខូចឬជនសង្ស័យខាងលើឱ្យលះបង់បំណងក្នុងទង្វើអមនុស្សធម៌នោះ ឬធ្វើសេចក្តីរាយការណ៍ទៅសមត្ថកិច្ច។

## ច- កិច្ចការផ្ទះ

១- ការបង្ការនិងការទប់ស្កាត់ការដកហូតសរីរាង្គ ត្រូវការចូលរួមពីគ្រប់មជ្ឈដ្ឋាន។ ចូរផ្គូផ្គងតួអង្គជាមួយសកម្មភាពចូលរួមបង្ការ ទប់ស្កាត់ការដកហូតសរីរាង្គក្នុងតារាងខាងក្រោម៖

| តួអង្គ | សកម្មភាព |
|---|---|
| ក- សិស្សានុសិស្ស<br>ខ- រាជរដ្ឋាភិបាល<br>គ- គ្រូបង្រៀន<br>ឃ- នគរបាល<br>ង- តុលាការ | ☐ ១- តាមដាន ឃ្លាំមើលសកម្មភាពនានាក្នុងសហគមន៍ អនុវត្តប្រតិបត្តិការបន្ទាន់ករណីមានការដកហូតសរីរាង្គ<br>☐ ២- បណ្តុះបណ្តាល អំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស<br>☐ ៣- ផ្សព្វផ្សាយព័ត៌មានពិតពាក់ព័ន្ធការដកហូតសរីរាង្គ<br>☐ ៤- ណែនាំមិត្តភក្តិ ក្រុមគ្រួសារឱ្យចៀរចាកពីការដកហូតសរីរាង្គ<br>☐ ៥- ប្រកាន់ជំហរស្អាតស្អំ មិនអត់ឱនចំពោះការប្រព្រឹត្តការដកហូតសរីរាង្គ។ |

២- ក្នុងចំណោមសកម្មភាពខាងក្រោម តើសកម្មភាពណាជាសកម្មភាពបង្ការ និងសកម្មភាពណាជាសកម្មភាពទប់ស្កាត់ ? ចូរប្អូនសរសេរពាក្យ ការបង្ការ និង ការទប់ស្កាត់នៅខាងដើមឃ្លា។

........................... ១- ការបង្កើតនិងដាក់ចេញឱ្យអនុវត្តច្បាប់ផ្សេងៗ។

........................... ២- នៅមន្ទីរពេទ្យនេះ វេជ្ជបណ្ឌិតឯកទេសមិនអាចកាត់ប្តូរសរីរាង្គបានទេ បើគ្មានការអនុញ្ញាត។

.......................... ៣- ការបង្កើតប្រព័ន្ធតាមដាននិងរាយការណ៍ទាន់ហេតុការណ៍ពីបទល្មើស។

.......................... ៤- ការដាក់ពង្រាយកងកម្លាំងមានសមត្ថកិច្ចនៅតាមគោលដៅនីមួយៗ។

.......................... ៥- ការផ្សព្វផ្សាយនិងអប់រំដល់មនុស្សទាំងអស់អំពីផលអាក្រក់នៃការជួញដូរកុមារ។

.......................... ៦- ការដាក់កាមេរ៉ាសុវត្ថិភាពនៅតាមទីសាធារណៈ។

.......................... ៧- ការអប់រំនិងការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌ។

.......................... ៨- ការអនុវត្តឱ្យបានខ្ជាប់ខ្ជួនអំពីក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុងនៅតាមអង្គភាព។

.......................... ៩- ការណែនាំមិត្តភក្តិ ក្រុមគ្រួសារឱ្យវៀរចាកសកម្មភាពមិនល្អនិងខុសច្បាប់។

........................១០- ការដាក់ទោសឱ្យធ្ងន់ធ្ងរចំពោះជនប្រព្រឹត្តអំពើល្មើសច្បាប់ទាក់ទងនឹងសុខភាពមនុស្ស។

## ការវាយតម្លៃ លទ្ធផលសិក្សាជំពូកទី៤

១- ចូរគូសសញ្ញា (✓) នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

- អ្នកជំងឺធ្ងន់ធ្ងរដែលមានធនធានច្រើនអាចព្យាបាលជំងឺឱ្យជាសះស្បើយបានដោយការដោះដូរ
  - ☐ សរសៃឈាម ☐ ខួរក្បាល ☐ ពោះវៀន ☐ តម្រងនោម
- ផលប៉ះពាល់ឬផលអាក្រក់ចំពោះអ្នកដែលត្រូវបានគេដកហូតសរីរាង្គគឺ ៖
  - ☐ សុខភាពបរិបូរណ៍ ☐ ប្រាក់កម្រៃច្រើន ☐ ជំងឺប្រចាំកាយ ☐ ផ្លូវចិត្តស្ងប់ស្ងាត់
- ជនខិលខូចឬជនសង្ស័យប្រើកលល្បិច លួងលោមដកហូតសរីរាង្គពីជនរងគ្រោះដែល
  - ☐ មានជីវភាពធូរធារ ☐ ខ្វះចំណេះដឹង ☐ មានចំណេះដឹងច្រើន
  - ☐ មានចំណេះដឹងផ្នែកច្បាប់
- ដើម្បីចៀសផុតពីល្បិចជនខិលខូចឬជនសង្ស័យដែលមានបំណងដកហូតសរីរាង្គគឺ
  - ☐ តុលាការកាត់ទោស ☐ អាជ្ញាធរមូលដ្ឋាន ☐ សួរលើប៉ូលីស
  - ☐ នៅឱ្យឆ្ងាយពីជនមិនស្គាល់

២- ចូរផ្គូផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| ១- ជនងាយរងគ្រោះ<br>២- ទីផ្សារងងឹត<br>៣- សុខភាពផ្លូវចិត្ត<br>៤- ផលប៉ះពាល់និងផលអាក្រក់នៃការដកហូតសរីរាង្គ | ក- ទីប្រជុំដែលមានសកម្មភាពលក់ទិញវត្ថុផ្សេងៗ ដែលមិនស្របច្បាប់ឬដោយលួចលាក់។<br>ខ- ក្រុមមនុស្សដែលគេងាយកេងប្រវ័ញ្ច និងធ្លាក់ខ្លួនក្នុងគ្រោះថ្នាក់ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត។<br>គ- ស្ថានភាពនៃផ្លូវចិត្តមនុស្សដែលរាប់បញ្ចូលការគិត ឥរិយាបថ សុខភាព ផ្នែកអារម្មណ៍។<br>ឃ- ការបាត់បង់កម្លាំងពលកម្ម ប្រាក់ចំណូលសមាជិកគ្រួសារជាទីស្រឡាញ់ គ្រួសារបង្កើនបន្ទុកចំណាយ។<br>ង- អ្នករងគ្រោះមិនទទួលបានគ្រប់គ្រាន់ផ្នែកអាហាររូបត្ថម្ភ ការថែទាំសុខភាព។ | ១→ .....<br>២→ .....<br>៣→ .....<br>៤→ ..... |

៣- ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ ៖

- ការលក់ដូរសរីរាង្គ បានផ្ដល់ផលអាក្រក់ដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់ជនរងគ្រោះ............ និងសង្គម។
- ជនខិលខូចឬជនសង្ស័យតែងតែប្រើគ្រប់វិធីដើម្បីអូសទាញជនងាយរងគ្រោះដែលមានជីវភាព.......ខ្វះចំណេះដឹង មិនយល់ពីផ្នែកវេជ្ជសាស្ត្រឱ្យលក់សរីរាង្គឱ្យខ្លួន។

៤- តើជនខិលខូចឬជនសង្ស័យដែលជួញដូរសរីរាង្គត្រូវមានទោសដូចម្ដេចខ្លះ ?

# ជំពូកទី ៥ ការបង្ការ ទប់ស្កាត់អំពើពពោះជំនួស



នាពេលបច្ចុប្បន្ន គេបានរកឃើញថា មានមនុស្សមួយចំនួនដែលមិនអាចមានកូនបាន និងមិនអាចពពោះដោយខ្លួនឯងដោយសារមានបញ្ហាសុខភាពបន្តពូជ សរីរាង្គមិនអំណោយផល និងដោយភរិយាមិនឯកភាពពពោះ ព្រោះខ្លាចបាត់បង់សម្រស់ ឬដោយភាពមមាញឹកក្នុងការងារជំនួញជាដើម។ល។ ដោយមូលហេតុខាងលើ មានក្រុមមនុស្សមួយចំនួនបានអះអាងថា ចង់បានបុត្រដែលកើតចេញពីខ្សែលោហិតរបស់ស្វាមី និងបានស្វះស្វែងរកសេវាកម្មពពោះជំនួសដើម្បីជួយពួកគេឱ្យសម្រេចបំណងមានកូន។ ករណីនេះបាននាំឱ្យប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្លាយជាគោលដៅពេញនិយមរបស់ពួកគេ។ តែករណីពពោះជំនួសនេះ និងការសុំកូនមួយចំនួនក៏បានផ្តល់មេរៀនអមនុស្សធម៌មួយចំនួនផងដែរ ដូចជា ការធ្វើទារុណកម្មទៅលើកុមារដែលមិនមែនជាកូនបង្កើត ការលក់ដូរកុមារពីគ្រួសារមួយទៅគ្រួសារមួយ ការយកកុមារទៅជាធ្វើជាទាសករក្នុងគ្រួសារ និងការជួញដូរសរីរាង្គជាដើម។ រាជរដ្ឋាភិបាលកម្ពុជាបានមើលឃើញភាពប្រឈម ដែលអាចធ្វើឱ្យកើតអំពើជួញដូរទារកតាមរយៈសកម្មភាពពពោះជំនួសនេះ ពីព្រោះក្រុមជនខិលខូចឬជនសង្ស័យអាចសម្ងំលាក់ខ្លួននៅក្នុងក្រុមមនុស្សដែលស្វែងរកសេវាកម្មនេះ ព្រមទាំងបាននិងកំពុងរៀបចំតាក់តែងច្បាប់ ស្តីពីការពពោះជំនួសនេះផងដែរ។ ក្នុងជំពូកនេះ អ្នកសិក្សានឹងសិក្សាស៊ីជម្រៅអំពី ៖

មេរៀនទី១ សញ្ញាណ និងផលប៉ះពាល់នៃអំពើពពោះជំនួស

មេរៀនទី២ ការបង្ការ ទប់ស្កាត់អំពើពពោះជំនួស

មេរៀនទី ១

# សញ្ញាណ និងផលប៉ះពាល់នៃអំពើពពោះជំនួស

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាពន្យល់បានអំពីនិយមន័យ មូលហេតុ សញ្ញាណ និងផលប៉ះពាល់នៃអំពើពពោះជំនួស និងកំណត់បានពីកលល្បិចជនខិលខូចឬជនសង្ស័យ ព្រមទាំងចូលរួមរាយការណ៍ ផ្តល់ព័ត៌មានដល់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់អំពើអមនុស្សធម៌នេះ និងអាចលើកស្ទួយតម្លៃគ្រួសារ ប្រពៃណីជាតិ។

## ខ- សកម្មភាពផ្តើម

១- ចូរសង្កេតរូបភាពទាំងពីរ រួចឆ្លើយសំណួរខាងក្រោម៖




*រូបទី១*



*រូបទី២*

- តើអ្នកគិតថារូបភាពទាំងពីរបង្ហាញអំពីអ្វី សភាពខុសគ្នាដូចម្តេច?
- តើអ្វីទៅជាការពពោះ? តើអ្វីជាការពពោះជំនួស ?
- តើអ្នកធ្លាប់បានឮអំពើពពោះជំនួសដែរឬទេ?តើវាមានលក្ខណៈដូចម្តេច ?
- តើជនប្រភេទណាដែលស្វែងរកសេវាកម្មពពោះជំនួស ?
- តើការពពោះជំនួសអាចមានផលល្អ ឬផលអាក្រក់ដូចម្តេចខ្លះ ?

## គ- ពាក្យគន្លឹះ

- **អំពើពពោះជំនួស**៖ ការស្ម័គ្រចិត្តក្នុងការពពោះ និងផ្តល់កំណើតដល់ទារកដោយស្ត្រីម្នាក់ ឬច្រើននាក់ជំនួសជនដទៃដោយមានកិច្ចព្រមព្រៀងដោះដូរនឹងប្រាក់កាស ឬវត្ថុមានតម្លៃពេលប្រគល់ទារកទៅឱ្យជននោះ។

## ឃ- អត្ថបទអំណាន

ជាការពិតណាស់នៅក្នុងជីវិតរស់នៅរបស់មនុស្សមិនអាចខ្វះបាន គឺការមានកូនដើម្បីបន្តវង្សត្រកូលរបស់ខ្លួន តែជាអកុសលមនុស្សមួយចំនួនមិនអាចមានកូនបានដោយខ្លួនឯង ព្រោះតែភរិយាមានបញ្ហាសុខភាពធ្ងន់ធ្ងរ ដោយសារសរីរាង្គកាយមិនអំណោយផលដល់ការបង្កកំណើត ឬដោយភរិយាមិនឯកភាពពពោះព្រោះខ្លាចបាត់បង់សម្រស់ឬដោយភាពមមាញឹកក្នុងការងារជំនួញជាដើម។ ហេតុដូចនេះ ទើបមានក្រុមគ្រួសារខ្លះ បានស្វែងរកសេវាកម្ម ឬមនុស្សស្រីដែលអាចពពោះជំនួសភរិយារបស់គេ។ ដល់ពេលសម្រាលកូន ពួកគេមកយកជាថ្នូរជាមួយការផ្តល់ប្រាក់កាសមួយចំនួនអាស្រ័យកិច្ចសន្យា។ ជនដែលមិនអាចមានកូនតាមបំណងបានសម្លឹងរកឱកាស ជាពិសេសនៅតាមប្រទេសកំពុងអភិវឌ្ឍ ដូចជាប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលជាគោលដៅពេញនិយមរបស់ពួកគេ ព្រោះប្រទេសមួយចំនួននៅក្នុងតំបន់នេះ មានការអភិវឌ្ឍយឺតយ៉ាវ សម្បូរប្រជាជនមានជីវភាពក្រីក្រ និងមានកូនច្រើន។ ក្រោយពេលពួកគេជួលស្ត្រីក្រីក្រមួយចំនួននៅក្នុងតំបន់នេះឱ្យទទួលសេវាកម្មពពោះជំនួស បានប្រើបច្ចេកវិទ្យាបែបវេជ្ជសាស្ត្រទំនើបដែលអាចបង្កជាបញ្ហាជាច្រើនទៅលើសុខភាពផ្លូវកាយ ផ្លូវចិត្តរបស់ស្ត្រីអ្នកទទួលពពោះជំនួស និងបានអនុវត្តផ្ទុយពីច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធរបស់ប្រទេសដែលស្ត្រីទទួលសេវារស់នៅ។ ទង្វើនេះបានជំរុញឱ្យប្រទេសទាំងអស់នោះបិទសេវាកម្មទទួលពពោះជំនួស។


គូស្នេហ៍ដែលមានភេទដូចគ្នា


ស្វាមី ភរិយាដែលជាអ្នកមាន


ស្ត្រីនិងបុរសនៅលីវ


សេវាកម្មពពោះជំនួស

ប្រទេសកម្ពុជាក៏បានក្លាយជាគោលដៅបន្ទាប់សម្រាប់ធ្វើសកម្មភាពមួយនេះ។ រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន បានមើលឃើញពីភាពប្រឈមនានា ពាក់ព័ន្ធទៅនឹងករណីថ្មីមួយនេះ ដែលកំពុងកើតមាន និងបន្តកើតមានជាហូរហែ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុខភាពប្រជាជន ទំនៀមទម្លាប់ប្រពៃណី សន្តិសុខសាធារណៈ ហើយក៏អាចធ្វើឱ្យកើតមានបទល្មើសជួញដូរទារកដើម្បីនាំឆ្លងដែនទៅក្រៅប្រទេសតាមរយៈសកម្មភាពនេះផងដែរ។ ក្រុមជនខិលខូចឬជនសង្ស័យក៏កំពុងសម្ងំលាក់ខ្លួនរកស៊ីនៅក្នុងមុខជំនួញថ្មីមួយនេះដោយពួកគេបានទាញយកប្រយោជន៍តាមរយៈការធ្វើជាឈ្មួញកណ្តាលក្នុងការស្វែងរកស្ត្រីក្រីក្រមានសុខភាពបន្តពូជល្អ មានកម្លាំងមាំមួន

ដើម្បីជួលឱ្យទទួលសេវាកម្មពពោះជំនួស។ ចំណែកឯជនខិលខូចឬជនសង្ស័យអាចទទួលបានប្រាក់កម្រៃដើងសារយ៉ាងច្រើនក្រាស់ក្រែល។ អំពើពពោះជំនួសនេះអាចជាសកម្មភាពនាំយក ឬលក់ដូរទារក ក្នុងគោលបំណងមិនល្អ គឺពិតជាធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទារក និងជាអំពើប្រាសចាកពីក្រមសីលធម៌ មិនគួរគប្បីនឹងប្រព្រឹត្តឡើយ។ ករណីពពោះជំនួស អាចកើតមានដោយក្រុមមនុស្សក្នុងដូចរូបខាងលើផងដែរ។

## ករណីសិក្សា

**ស្រីអូន និងបញ្ញា** ជាមិត្តភក្តិនឹងគ្នាតាំងពីតូចមកម្ល៉េះ និងរស់នៅស្រុកជាអ្នកភូមិផងរបងតែមួយ។ **ស្រីអូន** និង**បញ្ញា**មានវ័យប្រហាក់ប្រហែលគ្នា។ ក្រោយពួកគេរៀបការប្តីរៀងៗខ្លួន ពួកគេហាក់មានជីវភាពខ្វះខាត ពីព្រោះពួកគេម្នាក់ៗ មានកូនរហូតដល់ទៅ៤នាក់ ហើយប្តីរបស់ពួកគេទាំងពីរនាក់ ម្នាក់មានមុខរបរជាអ្នកឡើងត្នោត ឯម្នាក់ទៀតជាអ្នករត់ម៉ូតូឌុប។ ដោយមើលឃើញជីវភាពយ៉ាប់យ៉ឺនបែបនេះ ស្ត្រីទាំងពីរបានសម្រេចចិត្តមកធ្វើការងាររោងចក្រកាត់ដេរមួយនៅទីក្រុង ដោយទុកកូនៗឱ្យប្តីរបស់ពួកគេជាអ្នកមើលថែ។ ក្រោយពេល**ស្រីអូន និងបញ្ញា** បានមកធ្វើការក្នុងរោងចក្រ ជីវភាពគ្រួសាររបស់ពួកគេ មានភាពគ្រាន់បើជាងមុន។ ដោយមានបន្ទុកត្រូវផ្ញើលុយទៅប្តីនៅឯស្រុកផង និងត្រូវចំណាយលើការហូបចុកផង ជួលបន្ទប់ស្នាក់នៅផង ធ្វើឱ្យពួកគេមិនមានសេសសល់លុយកាក់អ្វីសម្រាប់សន្សំទុកនោះឡើយ។ ថ្ងៃមួយពេល**ស្រីអូន** និង**បញ្ញា**កំពុងតែពិភាក្សាគ្នាពីការខ្វះខាតក្នុងជីវភាពដែលមានកូនច្រើន ពិបាកក្នុងការរកលុយដើម្បីចិញ្ចឹមបីបាច់ និងផ្គត់ផ្គង់គ្រួសាររបស់ពួកគេនោះ ក៏ស្រាប់តែមានបុរស ឈ្មោះ **លី** ជាអ្នកបកប្រែភាសា ក្នុងរោងចក្រម្នាក់បានស្តាប់ឮពួកគេនិយាយគ្នា។ ឮដូច្នេះ**ពូលី** សប្បាយចិត្តយ៉ាងខ្លាំង ហើយក៏លាន់មាត់ថា "អឺយ៉ា! រកឧសប្រទះចង្ក្រានហ្គាសហើយតើ!" មិនបង្អង់យូរបុរសនោះក៏បានដើរសំដៅមក រក**ស្រីអូន** និង**បញ្ញា**យ៉ាងលឿន។ **ពូលី** បាននិយាយទៅកាន់**ស្រីអូន** និង**បញ្ញាថា** "អ្នកទាំងពីរមានកូនច្រើន និងមានជីវភាពខ្វះខាតខ្លាំងមែនទេ?" ស្ត្រីទាំងពីរក៏បានឆ្លើយតបយ៉ាងលឿន និងព្រមៗគ្នាថា "ចាស មែនហើយពូ"។ **ពូលី**ក៏បានបន្តទៀតថា "ខ្ញុំមានមុខរបរថ្មីមួយឱ្យអ្នកទាំងពីរធ្វើ ជាមុខរបរងាយៗ ហើយរកលុយបានច្រើន ជាពិសេសអ្នកងាយមានកូនដូចអ្នកទាំងពីរទៀតត្រូវម៉ាច់តែម្តង"។ **ស្រីអូន**ក៏សួរទៅ**ពូលី**ថា "មុខរបរអីទៅពូ? "។ បុរសឆ្លើយតបថា "គឺជាការស៊ីឈ្នួលទទួលពពោះជំនួស ព្រោះមានជនបរទេសធ្វើការក្នុងរោងចក្រយើងដែរ គាត់រៀបការជាមួយគ្នាយូរហើយតែគាត់មិនអាចមានកូនទេ ខ្ញុំក៏មិនដឹងមូលហេតុអ្វីដែរ។ កាលពីសប្តាហ៍មុន ពួកគាត់ទាំងពីរនាក់បានមកប្រាប់ខ្ញុំថា បើលោកជួយរកស្ត្រីពីរនាក់មកទទួលពពោះជំនួស នោះពួកគាត់នឹងឱ្យលុយទៅស្ត្រីនោះក្នុងម្នាក់ៗ១ម៉ឺនដុល្លារ" ។ ឮដូចនេះ **បញ្ញា**ក៏មានចម្ងល់វិញម្តង "ពូ ហើយគេធ្វើយ៉ាងម៉េចទៅពូ? ពួកខ្ញុំខ្លាចណាស់! មកធ្វើការឆ្ងាយផ្ទះផង ប្តីដឹងថាដើម ប្តីពួកខ្ញុំនឹងចោទថា ពួកខ្ញុំមានសាហាយ

វាយពួកខ្ញុំស្លាប់មិនខាន" ។ **ពូលី**តបវិញថា "អ្នកទាំងពីរអាចយករឿងនេះទៅពិភាក្សាជាមួយប្តីរបស់អ្នកទាំងពីរសិនក៏បាន ប្រាប់ពួកគាត់ទៅថា ជនបរទេសនោះគេមិនបានមកប៉ះពាល់ខ្លួនប្រាណអ្នកទាំងពីរទេ គឺគេគ្រាន់តែឱ្យគ្រូពេទ្យចាក់បញ្ចូលមេជីវិតរបស់ពួកគេចូលតែប៉ុណ្ណោះ បើមិនជឿពេលគេចាក់បញ្ចូលហ្នឹង ឱ្យប្តីរបស់អ្នកទាំងពីរមកមើល ដោយផ្ទាល់ក៏បានដែរ" ។ **ស្រីអូន** និង**បញ្ញា**ហាក់អស់ចម្ងល់ ហើយក៏បានសុំពេលមួយសប្តាហ៍ ដើម្បីពិគ្រោះជាមួយប្តីរបស់ពួកគេសិន។ ល្ងាចឡើងពេលចេញពីធ្វើការមកដល់បន្ទប់ជួលភ្លាម **ស្រីអូន** និង**បញ្ញា** ក៏ទាញទូរសព្ទចុចទៅប្តីរៀងៗខ្លួន និងបានរៀបរាប់ប្រាប់ដល់ប្តីដូចអ្វីដែល**ពូលី** បានប្រាប់ដល់ពួកគេមិនឱ្យបាត់មួយពាក្យណាឡើយ។ ដោយឮប្រពន្ធប្រាប់រឿងរ៉ាវពាក់ព័ន្ធនឹងការទទួលស៊ីឈ្នួលពពោះជំនួសមានភាពងាយស្រួល និងទទួលបានប្រាក់កម្រៃច្រើន ណាមួយឮថា ជនបរទេសជាអ្នកជួល មិនបានប៉ះពាល់ដល់រាងកាយប្រពន្ធខ្លួនផងនោះ រឹតតែធ្វើឱ្យប្តីរបស់**ស្រីអូន** និង**បញ្ញា** ឆ្លើយតបជាមួយប្រពន្ធរៀងៗខ្លួនថា "ធ្វើទៅបងមិនថាអីទេ ដើម្បីជីវភាពយើង ប៉ុន្តែដល់ថ្ងៃចាក់មេជីវិត បងសុំទៅចូលរួមមើលដែរ"។ ស្អែកឡើងពេលទៅដល់រោងចក្រ **ស្រីអូន** និង**បញ្ញា**បានទៅរក**ពូលី**ភ្លាមៗ ហើយក៏ប្រាប់ទៅ**ពូលី**ថា "ពូ ប្តីយើងទាំងពីរព្រមហើយ អីចឹងពូកុំបោកពួកខ្ញុំណា!" ។ **ពូលី** ឆ្លើយតបថា "កុំព្រួយអីក្មួយទាំងពីរ ពូសុំធានា ថ្ងៃដែលក្មួយទាំងពីរទៅចាក់បញ្ចូលមេជីវិត ពូនឹងឱ្យក្មួយម្នាក់ៗ១ពាន់ដុល្លារភ្លាម ពេលក្មួយចាក់រួចហើយ ក្មួយៗមិនបាច់មកធ្វើការនៅរោងចក្រយើងទៀតទេ ដេកសម្រាកថែទាំគភ៌នៅបន្ទប់ជួលចុះ ចំពោះថ្លៃផ្គត់ផ្គង់ការហូបចុកប្រចាំខែ ពូឱ្យក្មួយៗម្នាក់១លានរៀលជារៀងរាល់ដើមខែ ហើយដល់ពេលក្មួយៗទាំងពីរសម្រាលកូនពេលណា ពូនឹងឱ្យក្មួយៗម្នាក់៩ពាន់ដុល្លារបន្ថែមទៀតបង្គ្រប់លើតម្លៃ១ម៉ឺនដុល្លារ ក្មួយទាំងពីរត្រៀមទៅពីរថ្ងៃទៀត ពូនឹងនាំក្មួយៗទៅចាក់មេជីវិតនៅគ្លីនិកមួយ"។ ពីរថ្ងៃក្រោយមក **ពូលី**បាននាំ**ស្រីអូន** និង**បញ្ញា** រួមទាំងប្តីរបស់ពួកគេទាំងពីរឱ្យទៅចូលរួមរង់ចាំការចាក់មេជីវិត។ ក្រោយពេលចាក់បញ្ចូលមេជីវិតរួចរាល់**ស្រីអូន**និង**បញ្ញា** ក៏ទទួលបានប្រាក់ក្នុងម្នាក់ៗ១ពាន់ដុល្លារដូចការសន្យាពី**ពូលី**មែន ដោយអ្នកទាំងពីរមិនបានឃើញមុខជនបរទេសដែលជួលពួកគេឱ្យពពោះជំនួសនោះទេ។ ជារៀងរាល់ដើមខែនីមួយៗ **ពូលី**តែងយកប្រាក់ថ្លៃអាហារហូបចុកចំនួន១លានរៀលមកឱ្យ**ស្រីអូន** និង**បញ្ញា**ដល់មាត់ទ្វារបន្ទប់ជួល។ ស្រាប់តែខែទី៦ចូលមកដល់ជិតពាក់កណ្តាលខែហើយ មិនឃើញពូលីយកលុយមកឱ្យឡើយ **ស្រីអូន** និង**បញ្ញា**បានទៅរក**ពូលី**ដល់រោងចក្រ ដែលពួកគេធ្លាប់ធ្វើការជាមួយគ្នា។ ពេលទៅដល់រោងចក្រទើប**ស្រីអូន** និង**បញ្ញា**បានទទួលដំណឹងថា **ពូលី**ត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួនជិតមួយខែកន្លងមកហើយ ពាក់ព័ន្ធនឹងបទល្មើសលក់ដូរទារក និងនាំយកទារកចេញទៅក្រៅប្រទេសដោយមិនស្របច្បាប់។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ទោះបីជាព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានច្បាប់ស្តីពីអំពើពពោះជំនួសក៏ដោយ ក៏ប៉ុន្តែយើងនៅតែព្យាយាមបង្ក្រាប និងដាក់ទោសទណ្ឌទៅលើជនល្មើសតាមរយៈមាត្រាពាក់ព័ន្ធមួយចំនួននៃច្បាប់ ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ ក្នុងករណីដែលមានបណ្តឹង ឬមានការរាយការណ៍ពីសំណាក់សាធារណជន។

### ១- ក្រមព្រហ្មទណ្ឌ

- មាត្រា៣៣០ បទញុះញង់ឱ្យបោះបង់ទារក... អំពើនៅក្នុងគោលដៅចង់បានកម្រៃញុះញង់ដោយផ្ទាល់ដល់ឳពុកម្តាយ ឬដល់ឳពុក ឬម្តាយឱ្យបោះបង់ទារកដែលកើតមកហើយឬដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែ ទៅ៦ (ប្រាំមួយ) ខែនិងពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន)រៀល ទៅ១ ០០០ ០០០ (មួយលាន) រៀល...។
- មាត្រា៣៣១ បទអន្តរការរវាងអ្នកសុំកូន និងអ្នកបោះបង់កូន... អំពើប្រព្រឹត្តនៅក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹម និងឳពុកម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១(មួយ) ខែទៅ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន) រៀលទៅ ១ ០០០ ០០០ (មួយលាន) រៀល។
- មាត្រា៣៣២ បទអន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ... អំពើប្រព្រឹត្តក្នុងគោលបំណងចង់បានកម្រៃធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹម និងស្ត្រីយល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះឱ្យទៅអ្នកសុំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន) រៀល ទៅ១ ០០០ ០០០ (មួយលាន) រៀល។
- មាត្រា៣៣៤ ការប៉ុនប៉ង... ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទមជ្ឈិមខាងលើដែរ...។

### ២- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា១៦ ...ជនណាដែលលក់ ដូរជនដទៃក្នុងគោលដៅប្រគល់ ឬនាំយកចេញទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំ ដល់១៥ (ដប់ប្រាំ)ឆ្នាំ។ ជនណាដែលលក់ ដូរជនដទៃក្នុងប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅប្រគល់ឬនាំជននោះទៅប្រទេសផ្សេងទៀតត្រូវផ្តន្ទាទោសដូចទៅនឹងកថាខ័ណ្ឌទី១ ខាងលើ...។ ... ត្រូវផ្តន្ទាទោសពី១៥ (ដប់ប្រាំ) ឆ្នាំ

ដល់២០(ម្ភៃ)ឆ្នាំ ក្នុងករណីអំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ។ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរពិភាក្សាក្រុម ដោយអ្នកសិក្សាបែងចែកជា២ក្រុមធំ ដោយមួយក្រុមគាំទ្រឱ្យមានអំពើពពោះជំនួស និងមួយក្រុមទៀតមិនគាំទ្រឱ្យមានអំពើពពោះជំនួស។ សមាជិកនៃក្រុមនីមួយៗពិភាក្សា ដោយស្វះស្វែងរកគំនិតបញ្ចេញយោបល់ដើម្បីការពារទស្សនៈក្រុមរៀងៗខ្លួនពាក់ព័ន្ធនឹង៖

១- តើអំពើពពោះជំនួសប៉ះពាល់អ្វីខ្លះដល់សង្គមជាតិ?

២- តើអំពើពពោះជំនួសអាចបង្កហានិភ័យអ្វីខ្លះដល់ស្ត្រីពពោះ និងក្រុមគ្រួសារ?

៣- តើអំពើពពោះជំនួសជាជម្រើសល្អក្នុងការរកប្រាក់ ដើម្បីជួយដោះស្រាយបញ្ហាជីវភាពមែនដែរ ឬទេ?

៤- តើកម្ពុជាមានច្បាប់ទាក់ទងនឹងការពពោះជំនួសដែរឬទេ ?

៥- តើស្ត្រីដែលពពោះជំនួសត្រូវមានទោសដែរឬទេ?

## ច- កិច្ចការផ្ទះ

ចូរស្រាវជ្រាវរកករណីបទល្មើសពាក់ព័ន្ធការពពោះជំនួសពីគ្រប់ប្រព័ន្ធផ្សព្វផ្សាយ ឬនៅក្នុងសហគមន៍របស់អ្នក ដើម្បីធ្វើការចែករំលែកដល់មិត្តរួមថ្នាក់របស់អ្នក។

# មេរៀនទី ២ ការការពារ និងបង្ការទប់ស្កាត់អំពើពពោះជំនួស

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សារៀបរាប់បានអំពីវិធីការពារខ្លួន និងមានបំណិនចូលរួមបង្ការទប់ស្កាត់បទល្មើសពពោះជំនួសមិនឱ្យកើតមានដល់ខ្លួនឯង មិត្តភក្តិ និងមនុស្សនៅជុំវិញខ្លួន។

## ខ- សកម្មភាពផ្ដើម

១- ចូរមើលរូបភាពទាំងបីខាងក្រោម រួចឆ្លើយសំណួរៈ



- តើរូបភាពណាដែលអ្នកយល់ថាពាក់ពន្ធទៅនឹងករណីស៊ីឈ្នួលពពោះជំនួស? ហេតុអ្វី?
- ហេតុអ្វីបានជាអំពើពពោះជំនួសជាអំពើមិនត្រឹមត្រូវ? ហេតុអ្វី?
- តើមានវិធីណាដើម្បីកុំឱ្យប្រជាពលរដ្ឋខ្មែរយើងប្រកបរបរពពោះជំនួស?

## គ- ពាក្យគន្លឹះ

- **អន្តរការីក្នុងអំពើពពោះជំនួសៈ** ជនដែលជាប់ពាក់ព័ន្ធក្នុងការសម្របសម្រួល ឬទទួលបានប្រយោជន៍ពីអំពើជួញដូរមនុស្សក្នុងទម្រង់ពពោះជំនួស។

## ឃ- អត្ថបទអំណាន

តាមរយៈឯកសារវេជ្ជសាស្ត្របានបញ្ជាក់ថា ស្ត្រីដែលស៊ីឈ្នួលពពោះជំនួសត្រូវបានគេប្រើប្រាស់ថ្នាំជាច្រើនលើស្ត្រីដែលពពោះបែបធម្មជាតិ ដើម្បីការរក្សាគភ៌របស់ពួកគេ (ស្ត្រីស៊ីឈ្នួលពពោះ) ដែលជាកត្តានាំឱ្យប៉ះពាល់ដល់សុខភាពយ៉ាងធ្ងន់ធ្ងរ។ ចំពោះទារកដែលកើតចេញពីអំពើពពោះជំនួស យើងពិតជាមិនអាច ប៉ាន់ស្មានបានឡើយថា ក្រុមជនខិលខូចឬជនសង្ស័យទាំងនោះនឹងនាំយកពួកគេ (ទារក) ទៅក្នុងគោលបំណងអ្វីដែរ។ ប្រហែលជាទារកទាំងនោះត្រូវបានក្រុមជនខិលខូចឬជនសង្ស័យប្រើប្រាស់ឱ្យធ្វើនូវអំពើអ្វីមួយ ដើម្បីបម្រើផលប្រយោជន៍ដល់ក្រុមឧក្រិដ្ឋជន នៅពេលទារកទាំងនោះពេញវ័យ ឬអាចធ្វើជាក្រុមឧទ្ទាម ឬជាក្រុមសកម្មប្រយុទ្ធ ជាភេរវករ ឬទុកជាឧបករណ៍សម្រាប់ការពិសោធន៍វិទ្យាសាស្ត្រ ឬក៏ចិញ្ចឹមទុកលក់ ឬទុកវះយកសរីរាង្គ

ផ្សេងៗ សម្រាប់លក់ឱ្យអ្នកមានទ្រព្យធនច្រើននិងមានជំងឺធ្ងន់ធ្ងរ ដែលត្រូវការការវះកាត់ផ្លាស់ប្តូរសរីរាង្គផងក៏អាចថាបាន។

### ករណីសិក្សាទី១

**ប៊ុន លី** មានអាយុ២៨ឆ្នាំ ជាស្ត្រីមេម៉ាយមានស្រុកកំណើតនៅខេត្តមួយជាប់ដងទន្លេ បានមកធ្វើជាកម្មការិនីនៅក្នុងរោងចក្រកាត់ដេរមួយកន្លែងនៅតំបន់ជាយរាជធានី និងបានជួលបន្ទប់ស្នាក់នៅជុំជាមួយមិត្តភក្តិជាកម្មកររោងចក្រជាមួយគ្នា។ ថ្ងៃមួយក្នុងម៉ោងសម្រាកថ្ងៃត្រង់ ពេលនាងកំពុងហូបបាយជុំគ្នាជាមួយមិត្តភ័ក្តិ នាងបានជួបស្ត្រីម្នាក់ដែលទំនងមិនមែនជាអ្នកធ្វើការនៅរោងចក្រនេះទេ តែដោយសារ **ប៊ុន លី** និងស្ត្រីនោះអង្គុយរួមតុជាមួយគ្នា នាងបានស្តាប់ឮការជជែកឆ្លងឆ្លើយរវាងស្ត្រីនោះជាមួយមិត្តភ័ក្តិរបស់នាង។ **ប៊ុន លី** ក៏បានសំដែងការគួរសមនិងចូលរួមការជជែកជាមួយមិត្តភ័ក្តិរបស់នាងដែរ។ ការជជែកឆ្លើយឆ្លងបានចាប់ផ្តើមពីការសួរសុខទុក្ខគ្រួសាររៀងៗខ្លួន ហើយបានបន្តដោយមានអ្នកខ្លះក៏បានត្អូញត្អែរពីការនឹករលឹកប្តីនិងកូន អ្នកខ្លះថានឹកម្តាយចាស់ជរាកំពុងឈឺ ឯអ្នកខ្លះទៀតថាជិតដល់ពេលបង់ការប្រាក់ធនាគារហើយបើបង់មិនទាន់នឹងត្រូវបាត់បង់ដីស្រែ។ល។ បន្ទាប់ពីការជជែកគ្នាត្រូវបានបន្ថយសំឡេងបានមួយសំទុះ ស្ត្រីម្នាក់នោះក៏បានលូកមាត់ភ្ជាប់ការសន្ទនាជាមួយក្រុមមិត្តរបស់**ប៊ុន លី**។ ស្ត្រីនោះបាននិយាយថា "សួស្តីប្អូនៗ! បងឈ្មោះ មុំ សព្វថ្ងៃនេះបងជាអ្នកជួយរកអ្នកស្ម័គ្រចិត្តពពោះបង្កើតកូនឲ្យប្តីប្រពន្ធដែលគ្មានលទ្ធភាពអាចមានកូនបាន។ បើមានអ្នកណាយល់ព្រមទៅពពោះឱ្យគេ គេនឹងឱ្យលុយជាច្រើន!"។ គ្រាន់តែបានឮស្ត្រីនោះនិយាយបែបនេះ **ប៊ុន លី** និងមិត្តភ័ក្តិបានមើលមុខគ្នាដោយងឿងឆ្ងល់។ ភ្លាមនោះក្នុងចំណោមមិត្តភ័ក្តិនាងដែលទំនងជាមានចំណាប់អារម្មណ៍ បានសួរទៅស្ត្រីនោះថា "បានលុយច្រើនមែនឬបង? បានប៉ុន្មានទៅ? ហើយគេធ្វើយ៉ាងម៉េចខ្លះបង?"។ ដោយឃើញមានអ្នកចាប់អារម្មណ៍បែបនេះ ស្ត្រីនោះក៏ឆ្លើយទាំងញញឹមថា "បានច្រើនណាស់អូន! ប៉ុន្តែគេយកតែអ្នកដែលធ្លាប់មានកូនហើយទេ! បើមានអូនណាចង់សាកល្បង នេះលេខទូរស័ព្ទរបស់បង! បងសុំលាទៅសិនហើយណា៎!"។

បន្ទាប់ពីស្ត្រីនោះចាកចេញទៅបាត់ មិត្តភ័ក្តិរបស់ **ប៊ុន លី** ទាំងអស់គ្នាបាននិយាយថា "បើអីចឹងមានតែ **ប៊ុន លី** ទេដែលអាចទៅរួច ព្រោះឯងធ្លាប់មានកូនពីរនាក់រួចហើយ"។ **ប៊ុន លី** បាននៅស្ងៀមហាក់ដូចជាកំពុងគិតរឿងអ្វីមួយ បន្ទាប់មកនាងក៏ឆ្លើយតបវិញថា "អត់ទេ! ខ្ញុំមិនដឹងថាតើវាមានគ្រោះថ្នាក់ឬអត់? ហើយតើវាខុសច្បាប់ដែរឬទេ? ជួនកាលយើងអាចត្រូវបានគេបោកប្រាស់ផងក៏មិនដឹង ហើយចុងក្រោយបង្កើតកូនឱ្យគេមួយ តែលុយមិនដឹងនៅឯណាទេ!"។ នាងបន្តទៀតថា "យកល្អកុំប្រថុយអី! បញ្ហាមើលមិនឃើញទេ ប្រឹងធ្វើការចិញ្ចឹមជីវិតដោយសមត្ថភាពខ្លួនវិញទៅប្រសើរជាង" និយាយចប់ត្រឹមនេះ ស្នូរកណ្តឹងជាសញ្ញាប្រាប់ឱ្យកម្មការិនីត្រលប់ចូលធ្វើការក្នុងរោងចក្រវិញក៏បន្លឺឡើង។ ពួកគេក៏ប្រញាប់ប្រញាល់ទៅធ្វើការវិញដូចសព្វមួយដង។

## ករណីសិក្សាទី២

**សុភី** អាយុ២៨ឆ្នាំ ជាកសិករ មានប្ដីឈ្មោះ**ចាន់** អាយុ៣០ឆ្នាំ ជាកម្មករសំណង់។ ចំណងដៃអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរមានកូនប្រុសពីរនាក់និងកូនស្រីម្នាក់។ ពីមួយឆ្នាំទៅមួយឆ្នាំ កម្រិតជីវភាពរបស់អ្នកទាំងពីរមិនមានអ្វីប្លែកនោះទេ ព្រោះអ្នកទាំងពីរមានឪពុកម្ដាយជាអ្នកក្រដូចគ្នា ហើយទទួលបានការអប់រំបានត្រឹមតែកម្រិតបឋមសិក្សាតែប៉ុណ្ណោះ។ អ្នកទាំងពីរតែងតែគិតចង់បានផ្ទះមួយខ្នង មានដីស្រែខ្លះសម្រាប់បង្កបង្កើនផល និងកូនៗបានទៅសាលារៀនដូចកូនអ្នកភូមិផ្សេងទៀត កុំឱ្យថ្ងៃក្រោយល្ងង់ដូចពួកគាត់។ លោកស្រី**ផល្លា** ដែលជាបណ្ដាញមេខ្យល់បានមកធ្វើការបញ្ចុះបញ្ចូល អូសទាញក្រុមគ្រួសាររបស់**ចាន់** និង**សុភី** ឱ្យសម្រេចចិត្តពពោះជំនួសឱ្យបុរសជនជាតិបរទេសដែលស្រឡាញ់ភេទដូចគ្នាជាថ្នូរនឹងទឹកប្រាក់៨ ០០០ដុល្លារ។ ដោយមានបំណងចង់បានប្រាក់ចំណូលបន្ថែមលឿន **សុភី** និង**ចាន់**ជាស្វាមី បានឯកភាពតាមសំណើរបស់មេ ខ្យល់។ ក្នុងរយៈពេលពពោះ **សុភី** ត្រូវបានលោកស្រី **ផល្លា**ដែលជាអន្តរការីនាំទៅពិនិត្យនិងថែទាំគភ៌ ដោយយកចិត្តទុកដាក់ជារៀងរាល់ខែ និងទទួលបានការចាក់ថ្នាំបំប៉នបុត្រក្នុងផ្ទៃឱ្យមានការលូតលាស់ល្អ។

នៅថ្ងៃគំរប់កាលវេលាសម្រាលបុត្រ សុភីត្រូវបានភាគីអន្តរការីស្នើសូមឱ្យសម្រាលតាមវិធីវះកាត់ ដោយមូលហេតុបុត្រក្នុងគភ៌មានការលូតលាស់ធំធាត់ខ្លាំង និងខ្លាចប៉ះទង្គិចដល់កូននៅពេលដែលសម្រាលតាមធម្មជាតិ។ កូនដែល**សុភី**ស៊ីឈ្នួលពពោះ និងបង្កើតមកនោះជាកូនប្រុស។ បន្ទាប់ពីសម្រាលកូនហើយ **សុភី** បាននិយាយថា ប្រាក់ឈ្នួលដែលទទួលបានពីការពពោះ និងបង្កើតមកនោះមិនបានជួយស្ដារជីវភាពគ្រួសារពួកគាត់ឱ្យល្អប្រសើរជាងមុនទេ។ ពួកគាត់គ្មានលទ្ធភាពសង់ផ្ទះឡើយ ដោយពួកគាត់បន្តរស់នៅក្នុងផ្ទះខ្ទមលើដីភូមិតូចចង្អៀតដដែល។ ការថែទាំសុខភាពក្រោយពេលសម្រាលមិនបានពេញលេញ បានធ្វើឱ្យសុខភាពរបស់**សុភី** ស្រុតចុះទ្រុឌទ្រោមយ៉ាងខ្លាំង និងត្រូវចំណាយស្ទើរតែអស់ប្រាក់ឈ្នួលថែមទាំងមានជំងឺប្រចាំកាយថែមទៀតផង។ មិនតែប៉ុណ្ណោះ ជាទូទៅក្នុងអំឡុងពេលពពោះនោះ **សុភី** តែងតែមានជម្លោះជាមួយប្ដី រងនូវសម្ដីត្រគោះបោះបោក រងអំពើហិង្សាផ្លូវចិត្ត ព្រោះគាត់ត្រូវគោរពតាមលក្ខខណ្ឌជាមួយអ្នកជួលសម្រាប់ការពពោះនោះ។ ទន្ទឹមនេះ **សុភី**មានការខ្មាសអៀនចំពោះមនុស្សនៅក្នុងសហគមន៍ ព្រោះកូនដែលកើតមកមានមុខមាត់ ពណ៌សម្បុរ និងសក់មិនដូចកូនរបស់ខ្លួនមុនៗ។ ម្យ៉ាងទៀត នាងមានអារម្មណ៍យល់ថា គ្រួសារខ្លួនបានធ្វើនូវអំពើដែលមិនគួរធ្វើ ជាទង្វើដែលខុសពីប្រពៃណីទំនៀមទម្លាប់ និងព្រះពុទ្ធសាសនា។ ដោយបញ្ហាសុខភាព **សុភី** មិនអាចធ្វើការងារអ្វីដើម្បីរកចំណូលបន្ថែមជួយគ្រួសារដូចមុនឡើយ។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ទោះបីជាព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានច្បាប់ស្តីពីអំពើពពោះ ក៏ដោយ ក៏ប៉ុន្តែយើង នៅតែព្យាយាមបង្ក្រាប និងដាក់ទោសទណ្ឌទៅលើជនល្មើសតាមរយៈមាត្រាពាក់ព័ន្ធមួយចំនួននៃ ក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ ក្នុងករណី ដែលមានបណ្តឹង ឬមានការរាយការណ៍ពីសំណាក់សាធារណជន។

### ១- ក្រមព្រហ្មទណ្ឌ

- មាត្រា៣៣០ បទញុះញង់ឱ្យបោះបង់ទារក... អំពើនៅក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬដល់ឪពុក ឬម្តាយឱ្យបោះបង់ទារកដែលកើត មកហើយឬដែលនឹងកើត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ)ខែ ទៅ៦ (ប្រាំមួយ) ខែនិងពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន)រៀល ទៅ១ ០០០ ០០០ (មួយលាន) រៀល...។
- មាត្រា៣៣១ បទអន្តរការរវាងអ្នកសុំកូន និងអ្នកបោះបង់កូន... អំពើប្រព្រឹត្តនៅក្នុង គោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬប្តីប្រពន្ធដែលចង់សុំកូន យកមកចិញ្ចឹម និងឪពុកម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹង កើត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី១(មួយ) ខែទៅ៦ (ប្រាំមួយ) ខែ និងពិន័យជា ប្រាក់ពី ១០០ ០០០ (មួយសែន) រៀលទៅ ១ ០០០ ០០០ (មួយលាន) រៀល។
- មាត្រា៣៣២ បទអន្តរការរវាងអ្នកសុំកូន និងស្ត្រីពពោះ... អំពើប្រព្រឹត្តក្នុងគោល បំណងចង់បានកម្រៃធ្វើជាអន្តរការីរវាងបុគ្គលម្នាក់ ឬប្តីប្រពន្ធដែលចង់សុំកូនយក មកចិញ្ចឹម និងស្ត្រីយល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះឱ្យទៅអ្នកសុំ ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន) រៀលទៅ ១ ០០០ ០០០ (មួយលាន) រៀល។
- មាត្រា៣៣៤ ការប៉ុនប៉ង... ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងជំពូកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងការប្រព្រឹត្តបទមជ្ឈិមខាងលើដែរ...។

### ២- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា១៦ ...ជនណាដែលលក់ ដូរជនដទៃក្នុងគោលដៅប្រគល់ ឬនាំយកចេញទៅ ក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំ ដល់១៥ (ដប់ប្រាំ)ឆ្នាំ។ ជនណាដែលលក់ ដូរជនដទៃក្នុងប្រទេសណាមួយក្រៅពីព្រះរាជា ណាចក្រកម្ពុជាក្នុងគោលដៅប្រគល់ឬនាំជននោះទៅប្រទេសផ្សេងទៀតត្រូវផ្តន្ទា ទោសដូចទៅនឹងកថាខ័ណ្ឌទី១ ខាងលើ...។ ... ត្រូវផ្តន្ទាទោសពី១៥ (ដប់ប្រាំ) ឆ្នាំ

ដល់២០(ម្ភៃ)ឆ្នាំ ក្នុងករណីអំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ។ អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង...។

## ឆ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើបញ្ហាអ្វីខ្លះដែលគ្រួសារចាន់និងសុភី ជួបប្រទះបន្ទាប់ពីស៊ីឈ្នួលពពោះជំនួសរួចហើយ?

២- តើលោកស្រី ផល្លា ដែលជាបណ្ដាញមេខ្យល់នៅក្នុងសហគមន៍មានកំហុសឬទេ? ចូរបង្ហាញ។

៣- តើការពពោះជំនួស អាចមានផលអាក្រក់ដូចម្ដេចខ្លះ ?

៤- តើការពពោះជំនួស ជាអំពើជួញដូរមនុស្សនិងជាការរំលោភសិទ្ធិកុមារដែរឬទេ? ព្រោះអ្វី?

៥- តើការពពោះជំនួស មានការប៉ះពាល់ដល់ទំនៀមទម្លាប់ប្រពៃណីជាតិដែរឬទេ? ហេតុអ្វី ?

៧- តើយោបល់របស់ ប៊ុន លី ក្នុងករណីសិក្សាទី១ ត្រឹមត្រូវដែរឬទេ? ហេតុអ្វី?

## ច- កិច្ចការផ្ទះ

១- ហេតុអ្វីបានជា រាជរដ្ឋាភិបាលអំពាវនាវដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រីកុំចាប់យកការពពោះជំនួសជាមធ្យោបាយដោះស្រាយជីវភាព និងចាត់ទុកថាអំពើពពោះជំនួស គឺជាអំពើអមនុស្សធម៌?

២- ចូរជ្រើសរើសដោយគូស (✓) ចំពោះឃ្លាណាដែលអ្នកគិតថាជាអំពើដែលទាក់ទងនឹងសិទ្ធិកុមារ និងច្បាប់

- ☐ ក- អំពើពពោះជំនួសជាអំពើប្រាស់ចាកក្រមសីលធម៌ ប៉ះពាល់ឬរំលោភសិទ្ធិទារក ។
- ☐ ខ- ឱ្យតែអាចសម្រេចបំណងខ្លួនឯងបាន គឺមិនចាំបាច់គិតពីអ្នកដទៃឡើយ។
- ☐ គ- សហការផ្ដល់ព័ត៌មាន និងរាយការណ៍ពីបទល្មើសការពពោះជំនួសដល់អាជ្ញាធរមានសមត្ថកិច្ច។
- ☐ ឃ-ការពពោះជំនួស អាចជាមុខរបរទទួលបានប្រាក់កម្រៃច្រើន ។
- ☐ ង- ផ្សព្វផ្សាយអប់រំ ដល់ប្រជាពលរដ្ឋទាំងអស់អំពីច្បាប់ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីចូលរួមទប់ស្កាត់អំពើពពោះជំនួស។
- ☐ ច- ច្បាប់ពាក់ព័ន្ធនឹងអំពើពពោះជំនួស គួរដាក់ទោសឱ្យធ្ងន់ចំពោះមេខ្យល់ដែលអូសទាញឱ្យមានការពពោះជំនួស។

□ ឆ- មនុស្សដែលស្រឡាញ់ភេទដូចគ្នា ឬគូស្វាមីភរិយាដែលគ្មានលទ្ធភាពផ្តល់កំណើត និយមស្វែងរកអ្នកពពោះជំនួស។

□ ជ- ប្រទេសដែលមានការអភិវឌ្ឍយឺតយ៉ាវ សម្បូរប្រជាជនមានជីវភាពក្រីក្រ និងមានកូនច្រើន ជាគោលដៅនៃការពពោះជំនួស។

□ ឈ-ទារកដែលកើតចេញពីអំពើពពោះជំនួស ត្រូវបានបញ្ជូនបន្តទៅអ្នកដែលមិនមែនជាមាតាបិតាបង្កើត។

□ ញ- ស្ត្រីទទួលពពោះជំនួស ប្រឈមនឹងវិប្បដិសារីដែលបង្កឡើងដោយការចង់បានទ្រព្យខុសគន្លង។

## ការវាយតម្លៃ លទ្ធផលសិក្សាជំពូកទី៥

១- ចូរគូសសញ្ញា (✓) នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

- អំពើពពោះជំនួសគឺជាដំណើរការនៃការពពោះដោយស្ត្រីម្នាក់ជំនួសជនដទៃដើម្បី
  - ☐ ផ្តល់កំណើត ☐ កម្រៃ ☐ កូនរបស់ខ្លួន ☐ ចង់បានកូនទៀត
- ក្រុមជនខិលខូចឬជនសង្ស័យអាចទាញយកប្រយោជន៍តាមរយៈសកម្មភាពពពោះនេះ ដើម្បី
  - ☐ មនុស្សធម៌ ☐ ជួញដូរទារក ☐ ជួយអ្នកដែលចង់បានកូន
  - ☐ ថែរក្សាសុខភាពស្ត្រីខ្លះ
- មនុស្សមួយចំនួនមិនអាចមានកូនដោយខ្លួនឯងបាន ដោយសារការមិនអំណោយផលនៃ
  - ☐ សុខភាពបន្តពូជ ☐ ការមានការងារច្រើន
  - ☐ ខូចសម្រស់រាងកាយ ☐ បញ្ហាសុខភាពធ្ងន់ធ្ងរ
- ក្រុមជនខិលខូចឬជនសង្ស័យនឹងយកទារកដែលបានពីការពពោះជំនួសដើម្បី
  - ☐ ទុកធ្វើជាកូន ☐ ទុកធ្វើជាទាហាន ☐ ប្តូរយកកម្រៃជើងសារ
  - ☐ ទុកវះយកសរីរាង្គលក់
- បច្ចុប្បន្ននេះ អន្តរការីក្នុងអំពើពពោះជំនួស ត្រូវប្រឈមទៅនឹងទោសទណ្ឌចែងក្នុងច្បាប់
  - ☐ ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
  - ☐ ចរាចរណ៍ ☐ អប់រំ ☐ ប្រយុទ្ធប្រឆាំងអំពើជួញដូរគ្រឿងញៀន

២- ចូរផ្គូផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| ១- អំពើពពោះជំនួស<br>២- សកម្មភាពនៃការពពោះជំនួស | ក- អំពើនេះអាចកើតមានឡើងក្នុងគោលបំណងមិនល្អអាចលក់ដូរទារក គឺពិតជាធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទារកជាអំពើប្រាសចាកក្រមសីលធម៌។<br>ខ- ដំណើរការនៃការផ្តល់កំណើតដោយស្ត្រីម្នាក់ដោយឱ្យពពោះជំនួសជនដទៃនិងប្រគល់ទារកនោះឱ្យជននោះវិញ។<br>គ- ប្រទេសមួយចំនួននៅក្នុងតំបន់ដែលមានការអភិវឌ្ឍយឺតយ៉ាវ សម្បូរប្រជាជនមានជីវភាពក្រីក្រ និងមានកូនច្រើន។<br>ឃ- ប្រទេសមានកម្លាំងពលកម្មច្រើន ប្រាក់ចំណូលទាបគ្រួសារបង្កើនបន្ទុកចំណាយ។ | ១→ .....<br>២→ ..... |

៣- តើអ្នកពពោះជំនួស និងអន្តរការីត្រូវមានទោសដូចម្តេចខ្លះ ?

ជំពូកទី
៦

# ការបង្ការទប់ស្កាត់អំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារ តាមអ៊ីនធឺណិតឬអនឡាញ




ការប្រើប្រាស់សេវាកម្មអ៊ីនធឺណិតឬអនឡាញ នាពេលបច្ចុប្បន្ននេះ មានចំនួនអ្នកប្រើប្រាស់កើនឡើងជាលំដាប់នៅលើពិភពលោក ក្នុងគោលបំណងបំពេញតម្រូវការផលប្រយោជន៍ក្នុងជីវភាពរស់នៅ ផលប្រយោជន៍ក្នុងការសិក្សា ស្រាវជ្រាវ អាជីវកម្មនានា ក៏ដូចជាការទំនាក់ទំនងកាន់តែឆាប់រហ័ស។ ក្នុងនោះ ធនធានដ៏ច្រើនក្រៃលែង និងប្រភពដ៏សម្បូរបែប បានប្រមូលផ្តុំទៅដោយចំណេះដឹងគ្រប់រូបភាព គ្រប់វិស័យទាំងអស់ ជាពិសេសចំណេះដឹងក្នុងវិស័យអប់រំ។ សេវាកម្មលើបណ្តាញអ៊ីនធឺណិតឬអនឡាញ និងពាណិជ្ជកម្ម ពិតជាត្រូវបានទទួលស្គាល់ថាពិតជាគាំទ្រដល់ការអភិវឌ្ឍផ្នែកធុរកិច្ចក៏ដូចជាកំណើនសេដ្ឋកិច្ច។ ប៉ុន្តែអ៊ីនធឺណិតឬអនឡាញក៏មានគុណវិបត្តិផងដែរ នៅពេលដែលអ្នកប្រើប្រាស់មិនមានការប្រុងប្រយ័ត្នដូចជា ការចូលលួចព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកប្រើប្រាស់ ការជ្រៀតចូលនូវមេរោគ និងហានិភ័យផ្សេងៗទៀត។

ជំពូកនេះ អ្នកសិក្សានឹងបានយល់ស៊ីជម្រៅពាក់ព័ន្ធទៅនឹងគ្រោះថ្នាក់ឬបញ្ហាប្រឈមដែលអាចកើតមានក្នុងដំណើរការប្រើប្រាស់អ៊ីនធឺណិតឬអនឡាញ ជាពិសេសគឺបញ្ហាកេងប្រវ័ញ្ចផ្លូវភេទ និងវិធីបង្ការទប់ស្កាត់បញ្ហាទាំងនោះ តាមរយៈមេរៀនចំនួន២ រួមមាន៖

មេរៀនទី១ ការប្រឈមចំពោះហានិភ័យតាមអ៊ីនធឺណិត ឬអនឡាញ

មេរៀនទី២ ការលើកកម្ពស់ការយល់ដឹងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមអ៊ីនធឺណិតឬអនឡាញ

# មេរៀនទី ១ ការប្រយ័ត្នចំពោះហានិភ័យតាមអ៊ីនធឺណិតឬអនឡាញ

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចកំណត់និងវិនិច្ឆ័យបានពីភាពខុសគ្នារវាងសកម្មភាពដែលមានសុវត្ថិភាពនិងគ្មានសុវត្ថិភាពនៅលើអ៊ីនធឺណិតឬអនឡាញ ព្រមទាំងអាចទទួលបានបំណិនសម្រាប់ការអនុវត្តសកម្មភាពនានាជាប្រយោជន៍ប្រកបដោយសុវត្ថិភាពសម្រាប់គាំទ្រដំណើរការប្រតិបត្តិនានាលើអ៊ីនធឺណិតឬអនឡាញ។

## ខ- សកម្មភាពផ្តើម

ចូរសង្កេតរូបភាពខាងក្រោម និងបង្ហាញពីការយល់ឃើញពាក់ព័ន្ធនឹងអត្ថប្រយោជន៍របស់អ៊ីនធឺណិតឬអនឡាញ ចំពោះជីវភាពប្រចាំថ្ងៃរបស់មនុស្សជំនាន់ថ្មីនៃយុគសម័យឌីជីថលនេះ។




## គ- ពាក្យគន្លឹះ

- **ប្រព័ន្ធទំនាក់ទំនងសង្គម:** គេហទំព័រ និងកម្មវិធីនានាដែលអនុញ្ញាតឱ្យអ្នកប្រើអាចចែករំលែកខ្លឹមសារជាមួយអ្នកដទៃ រួមមានរូបភាព ឃ្លីបវីដេអូ ចំណាប់អារម្មណ៍ផ្សេងៗ ព័ត៌មាន និងខ្លឹមសារផ្សេងៗជាច្រើនទៀត។ ឧទាហរណ៍: កម្មវិធីទំនាក់ទំនងសង្គមមានដូចជា Facebook, YouTube, Instagram, Twitter...។
- **វេទិកាទំនាក់ទំនងតាមអ៊ីនធឺណិតឬអនឡាញ:** វេទិកាដែលអនុញ្ញាតឱ្យមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយបុគ្គល ឬក្រុមផ្សេងៗទៀតតាមរយៈសារសំណេរ សំឡេង ឬវីដេអូ។

- **កម្មវិធីវីដេអូ និងកម្មវិធីផ្សាយផ្ទាល់:** កម្មវិធីអាចឱ្យអ្នកប្រើប្រាស់មើលឃើញរូប និងថតវីដេអូពេលកំពុងចាក់ផ្សាយ។
- **វេទិកាល្បែងអនឡាញ:** ទម្រង់អន្តរកម្មដែលអ្នកលេងល្បែងអាចប្រាស្រ័យទំនាក់ទំនងជាមួយដៃគូលេងល្បែងជាមួយគ្នាបានជាក្រុម។
- **កម្មវិធីរុករកគេហទំព័រ:** កម្មវិធីដែលអនុញ្ញាតឱ្យអ្នកស្វែងរកព័ត៌មានឬឯកសារនានានៅលើអ៊ីនធឺណិតឬអនឡាញ ខណៈដែលកម្មវិធីឱ្យស្វែងរកព័ត៌មានយោងទៅតាមពាក្យគន្លឹះឬអាសយដ្ឋានសម្រាប់សម្គាល់។
- **ហានិភ័យ:** សកម្មភាព ឬស្ថានភាពអាក្រក់អ្វីមួយដែលអាចនឹងកើតមានឡើងនៅពេលប្រតិបត្តិការនានាលើអ៊ីនធឺណិតឬអនឡាញ។
- **DM (Direct Message):** ការបញ្ជូនឬទទួលសារដោយផ្ទាល់តាមរយៈកម្មវិធីទំនាក់ទំនងសង្គម។
- **ឥរិយាបថ:** ផ្លូវឬគន្លងនៃឥរិយាបថ គឺការដើរ ឈរ អង្គុយ និងដេក។
- **រូបភាពអាសអាភាស:** រូបភាពដែលបង្ហាញពីកេរខ្មាសរបស់កុមារ បុរស ឬស្ត្រីដែលនាំឱ្យមានអារម្មណ៍ខ្មាសអៀន ឬរំភើប ឬរំជួលដល់ចំណង់ភេទ។

## ឃ- អត្ថបទអំណាន

នាពេលបច្ចុប្បន្ននេះ ចំនួនប្រជាជនប្រហែលជាងពាក់កណ្តាលនៅលើពិភពលោក បានប្រើប្រាស់អ៊ីនធឺណិតឬអនឡាញ ហើយចំនួននេះមានកំណើនជាបន្តបន្ទាប់ជារៀងរាល់ថ្ងៃ។ អ្នកដែលប្រើប្រាស់ទាំងនោះរាប់បញ្ចូលទាំងប្រជាជនដែលរស់នៅតាមតំបន់ដាច់ស្រយាលផងដែរ។ អ៊ីនធឺណិតឬអនឡាញបាននិងកំពុងវិវត្តស្របតាមបច្ចេកវិទ្យាតាមទម្រង់ថ្មីៗដែលត្រូវបានអភិវឌ្ឍឥតឈប់ឈរ ដើម្បីផ្តល់ជម្រើសដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់មនុស្សនិងសង្គមនាយុគសម័យសតវត្សទី២១នេះ។

អ៊ីនធឺណិតឬអនឡាញដែលបាននិងកំពុងប្រើប្រាស់រាល់ថ្ងៃ គឺជាមធ្យោបាយមួយសម្រាប់ភ្ជាប់ទំនាក់ទំនងមនុស្សជាមួយមនុស្ស និងផ្តល់ព័ត៌មានគ្មានទីបញ្ចប់លើប្រធានបទគ្រប់ប្រភេទ។ អ៊ីនធឺណិតឬអនឡាញផ្តល់អត្ថប្រយោជន៍សម្រាប់ការរៀនសូត្រ ការកម្សាន្ត សកម្មភាពសង្គម និងអន្តរទំនាក់ទំនងរវាងមនុស្សនិងមនុស្សគ្រប់ជាតិសាសន៍ និងសាសនានានានៅលើសាកលលោក។

ការចែករំលែកត្រូវបានចាត់ទុកជារឿងសំខាន់សម្រាប់អ្នកប្រើប្រាស់តាមអ៊ីនធឺណិតឬអនឡាញ ដូចជា ចែករំលែកព័ត៌មាននានា បទពិសោធ ចំណេះដឹង រូបថត សារវីដេអូ សារសំឡេង និងវីដេអូឯកសារជាដើម។ ការចែករំលែកគឺជាវិធីដ៏ល្អមួយក្នុងការភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃ។ តែការចែករំលែកព័ត៌មានឯកជននៅលើអ៊ីនធឺណិតឬអនឡាញមិនអាចធានាបានទាំងស្រុងថា

អាចរក្សាការសម្ងាត់កម្រិតបុគ្គលឡើយ។ ឧទាហរណ៍ អ្នកនៅក្នុងបន្ទប់អ៊ីនធឺណិតឬអនឡាញរបស់អ្នក ធ្វើទំនាក់ទំនងជាមួយមិត្តរបស់អ្នកដែលគេនៅក្នុងបន្ទប់អ៊ីនធឺណិតឬអនឡាញរបស់គេដែរ។ អ្នកបង្ហាញរូបភាពរបស់អ្នកដល់មិត្តរបស់អ្នក ដោយគិតថារូបរបស់អ្នក មានតែមិត្តរបស់អ្នកម្នាក់គត់ដែលបានឃើញ និងស្ថិតក្នុងស្ថានភាពសុវត្ថិភាពឯកជនឬបុគ្គល។ ផ្ទុយទៅវិញនៅលើអ៊ីនធឺណិតឬអនឡាញ អ្វីៗខុសពីការប្រាស្រ័យទាក់ទងដោយផ្ទាល់។ រូបភាពដែលអ្នកបានផ្ញើទៅមិត្តនោះអាចត្រូវបានចម្លងទុក ឬបញ្ជូនបន្តទៅអ្នកផ្សេងបានយ៉ាងងាយស្រួល ហើយត្រូវបានចែកចាយបន្តនៅលើអ៊ីនធឺណិតឬអនឡាញ។ ទោះបីជាអ្នកលុបរូបថតនោះចោលក៏ដោយ តែអ្នកដទៃអាចមានរូបថតនោះរួចទៅហើយ ដែលអាចធ្វើឱ្យអ្នកបានបាត់បង់ការគ្រប់គ្រងរបស់អ្នកលើអ្វីដែលកើតឡើង។

ដូច្នេះរាល់សកម្មភាពដែលអ្នកបានធ្វើនៅលើអ៊ីនធឺណិតឬអនឡាញ អ្នកត្រូវគិតដល់ការអនុវត្តនូវវិធានការឆ្លាតវៃ និងមានសុវត្ថិភាពផងដែរ ដូចជា គិតពីរដងមុនពេលអ្នកបង្ហោះអ្វីមួយនៅលើអ៊ីនធឺណិតឬអនឡាញ រក្សាព័ត៌មានផ្ទាល់ខ្លួននៅក្រៅអ៊ីនធឺណិតឬអនឡាញ មិនត្រូវរួមចំណែកក្នុងស្ថានភាពដែលអាចឱ្យនរណាម្នាក់ទទួលរងគ្រោះដោយសារអ្នកឡើយ។

## បញ្ហាប្រឈម ឬហានិភ័យ

ការយល់ដឹងពីហានិភ័យ និងវិធីបង្ការទប់ស្កាត់ដែលកើតមានឡើងនៅលើអ៊ីនធឺណិតឬអនឡាញ គឺជាជំហានដំបូងក្នុងការការពារខ្លួនពីការកេងប្រវ័ញ្ចនានា។

- ការគំរាមកំហែងតាមអ៊ីនធឺណិតឬអនឡាញ គឺនៅពេលដែលជនខិលខូចឬជនសង្ស័យគំរាមធ្វើបាប បៀតបៀន តាមរយៈការសរសេរសារ ឬបង្ហោះអ្វីដែលធ្វើឱ្យមានទុក្ខទោសលើមនុស្សម្នាក់ផ្សេងទៀតនៅលើអ៊ីនធឺណិតឬអនឡាញ ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយផ្ទុយពីឆន្ទៈរបស់អ្នក។
- ការលួងលោមតាមអ៊ីនធឺណិតឬអនឡាញ ជនខិលខូចឬជនសង្ស័យបង្កើតនិងរក្សាទំនាក់ទំនងជាមួយកុមារ ដោយសន្យាបំពេញបំណងប្រាថ្នា ឬក្តីសង្ឃឹមរបស់កុមារនូវអ្វីដែលកុមារពេញចិត្ត ចង់បានដែលឆ្លើយតបនឹងតម្រូវការរបស់កុមារ ពោលសរសើរចំពោះមុខមាត់របស់កុមារ ឬអ្វីដែលពួកគេធ្វើ ដើម្បីទទួលបានទំនុកចិត្តពីកុមារ រួចបញ្ឆោះបញ្ឆូលឱ្យកុមារប្រព្រឹត្តបទល្មើសអ្វីមួយ ដូចជាការលួចយក ទ្រព្យសម្បត្តិក្នុងផ្ទះឱ្យចេញទៅក្រៅផ្ទះដើម្បីយកវត្ថុឬកញ្ចប់អ្វីមួយទៅទុកក្នុងកន្លែងមួយផ្សេងទៀត ចេញទៅក្រៅផ្ទះជាមួយរួចចាប់ជំរិត។ល។
- ការបញ្ជូនឱ្យកុមារមើលរូបភាពអាសអាភាស ជនខិលខូចឬជនសង្ស័យអាចទាក់ទាញកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទដោយខ្លួនឯង តាមរយៈការមើលរូបភាព

អាសអាភាស ពិសេសរូបភាពអាសអាភាសរបស់កុមារដទៃ ដែលធ្វើឱ្យកុមារមានអារម្មណ៍ គ្មានភាពអៀនខ្មាស ភ័យខ្លាច និងហ៊ានចូលរួមសកម្មភាពផ្លូវភេទ។

- ការបញ្ចុះបញ្ចូលបបួលលេងល្បែងជាមួយ  ជនខិលខូចឬជនសង្ស័យអាចទាក់ទាញកុមារដែលប្រើប្រាស់អ៊ីនធឺណិតឬអនឡាញ ដោយការបញ្ជូនអាសយដ្ឋានគេហទំព័រប្លែកឱ្យកុមារចុចលើរួចចូលរួម លេងល្បែងជាមួយ បង្កើតជំនក់ល្បែងលែងរៀនសូត្រ ឬអាចយកប្រាក់កាសទៅទិញល្បែងអនឡាញ
- ការចុចលើគេហទំព័រដែលផ្ទុកមេរោគ ជនខិលខូចឬជនសង្ស័យនៅលើអ៊ីនធឺណិតឬអនឡាញបង្កើត គេហទំព័រដែលមានឈ្មោះប្រហាក់ប្រហែលអាសយដ្ឋានបម្រើផ្នែកអប់រំ ឬសុខភាពជាដើម រួចបង្ហោះ តាមអ៊ីនធឺណិត ដែលអាចធ្វើឱ្យអ្នកមិនស្គាល់ច្បាស់ចុចបើកមើល រួចទទួលយកដោយមិនដឹងខ្លួននូវមេរោគចូលក្នុងឧបករណ៍ ដូចជាកុំព្យូទ័រ ឬទូរស័ព្ទ ធ្វើឱ្យខូចគាំង ឬកំទេចចោលគ្មានសល់ឯកសារនានា ដែលបានរក្សាទុក ឬលួចយកឯកសារសំខាន់ៗ។

## ការចូលរួមទប់ស្កាត់ហានិភ័យ

អាស្រ័យហេតុនេះ អ្នកប្រើប្រាស់អ៊ីនធឺណិតឬអនឡាញ ត្រូវដឹងពីរបៀបប្រើប្រាស់ប្រកបដោយសុវត្ថិភាព។ អ្នកដែលពាក់ព័ន្ធក្នុងការរក្សាសុវត្ថិភាពកុមារ ឱ្យចៀសផុសពីបញ្ហាខាងលើរួមមាន កុមារ មាតាបិតា ឬអ្នកអាណាព្យាបាល គ្រូបង្រៀន សហគមន៍ នគរបាល និងអ្នកអនុវត្តច្បាប់។

- មាតាបិតា ឬអ្នកអាណាព្យាបាល មានតួនាទីក្នុងការការពារកូនៗរបស់ពួកគេ ក្នុងការសម្រេចចិត្តឱ្យបានត្រឹមត្រូវ និងជួយផ្តល់យោបល់នៅពេលដែលកូនៗត្រូវការ ពាក់ព័ន្ធការប្រើប្រាស់អ៊ីនធឺណិតឬអនឡាញ។
- គ្រូបង្រៀន ជាមនុស្សដែលមានពេលវេលាសំខាន់បំផុតជាមួយកុមារក្នុងនាមជាអ្នកអប់រំពួកគេ ឱ្យយល់ដឹងពីការកេងប្រវ័ញ្ចផ្លូវភេទ ហានិភ័យ និងស្ថានភាពគំរាមកំហែងកុមារនៅលើអ៊ីនធឺណិតឬអនឡាញ។
- សហគមន៍ មានតួនាទីក្នុងការការពារកុមារពីកេងប្រវ័ញ្ចផ្លូវភេទនិងហានិភ័យតាមប្រព័ន្ធអ៊ីនធឺនណិតផងដែរ។ ការនិយាយអំពីការកេងប្រវ័ញ្ចផ្លូវភេទ អាចជួយកុមារឱ្យចេះរាយការណ៍អំពីការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ីនធឺណិតឬអនឡាញបាន។
- នគរបាល និងអ្នកអនុវត្តច្បាប់ ត្រូវតែយល់ដឹងអំពីហានិភ័យផ្សេងៗចំពោះកុមារ និងរបៀបដែលជនល្មើសបង្កើតទំនាក់ទំនងជាមួយកុមារតាមអ៊ីនធឺណិតឬអនឡាញ ហើយប្រាប់ពីវិធីការពារខ្លួន ការរាយការណ៍ និងស្វែងរកយុត្តិធម៌ជូនកុមារ។

## ករណីសិក្សា

**បូរី** និង**លក្ខិណា** ជាមិត្តភក្តិតាំងពីថ្នាក់ទី៧រហូតមកដល់បច្ចុប្បន្ន។ ទើបតែចូលដល់ឆ្នាំថ្មីនេះ **បូរី**ហ៊ានសួរ**លក្ខិណា**ថា ‘នាងយល់ព្រមធ្វើជាមិត្តស្រីរបស់ខ្លួនដែរឬទេ’។ នាងក៏យល់ព្រមដោយរីករាយ។ ពួកគេផ្ញើសារព្រមទាំងរូបថតឱ្យគ្នាទៅវិញទៅមកជារៀងរាល់ថ្ងៃ។ ថ្ងៃមួយ**បូរី** បានសួរ**លក្ខិណា**ថា តើនាងអាចផ្ញើរូបថតកេរខ្មាសរបស់នាងថែមទៀតបានឬទេ។ **លក្ខិណា**ហាក់ដូចមានអារម្មណ៍មិនល្អ ប៉ុន្តែនាងស្រឡាញ់**បូរី**ហើយមិនចង់ធ្វើឱ្យអន្តរាយដល់ទំនាក់ទំនងរវាងពួកគេទាំងពីរនោះ ក៏សម្រេចចិត្តផ្ញើរូបអាក្រាតកាយឱ្យទៅ**បូរី**។ **បូរី**ក៏ស្រឡាញ់**លក្ខិណា**ដែរ ហើយគាត់គ្មានបំណងចង់ធ្វើបាបនាងទេ។ ប៉ុន្តែនៅពេលដែលគាត់បានទទួលរូបថត គាត់មានអារម្មណ៍រំភើបណាស់ ហើយចង់ឱ្យមិត្តជិតស្និទ្ធបានឃើញថា មិត្តស្រីរបស់ខ្លួនមានរូបសម្រស់ស្រស់ស្អាតណាស់។ **បូរី**បានផ្ញើរូបថតតាមរយៈបណ្តាញទំនាក់ទំនងសង្គមមួយទៅមិត្តជិតស្និទ្ធម្នាក់ទៀត ហើយប្រាប់ថា កុំផ្ញើរូបនេះទៅអ្នកផ្សេងទៀត។ ប៉ុន្តែមិត្តរបស់គាត់ម្នាក់នោះ បានសម្រេចចិត្តចែកចាយបន្តទៅមិត្តផ្សេងទៀត។ នៅថ្ងៃបន្ទាប់ រូបថតនោះ ត្រូវបានគេចែករំលែកដល់សិស្សជាច្រើនទៀតនៅក្នុងសាលារៀន។ នៅពេលដែល**លក្ខិណា**បានដឹងរឿងនេះ នាងមានអារម្មណ៍ខ្មាសអៀន ដែល**បូរី**បានក្បត់សន្យា ហើយបានសម្រេចបែកបាក់គ្នាជាមួយ**បូរី**។ ថ្ងៃមួយ **លក្ខិណា** បានទទួលសារមួយពីមនុស្សម្នាក់ដែលនាងមិនដែលស្គាល់ពីមុនមក ប្រាប់នាងថា បើនាងមិនចង់ឱ្យរូបអាក្រាតកាយរបស់នាងត្រូវបានផ្សព្វផ្សាយបន្តច្រើនទៅទៀត នាងត្រូវផ្ញើប្រាក់ឱ្យគេតាមប្រព័ន្ធធនាគារចំនួនមួយលានរៀល នោះគេនឹងជួយលុបចោលឱ្យអស់។ ដោយការបារម្ភ **លក្ខិណា**បានសុំលុយពីម្តាយផ្ញើទៅឱ្យបុរសនោះ ដោយភូតភរម្តាយថា នាងត្រូវការប្រាក់ដើម្បីយកទៅជួយ អ្នកគ្រូជាទីស្រឡាញ់ម្នាក់ដែលរងគ្រោះថ្នាក់ចរាចរណ៍ ហើយកំពុងត្រូវការជំនួយបន្ទាន់។ មួយសប្តាហ៍ក្រោយមក បុរសនោះបានផ្ញើសារគំរាមជាលើកទីពីរ និងបង្ខំនាងឱ្យផ្ញើលុយចំនួនពីរលានរៀលបន្ថែមទៀត។ ដោយមិនអាចទ្រាំនឹងការគំរាមពីសំណាក់ជននោះតទៅទៀតបាន លក្ខិណាបានសម្រេចយករឿងរ៉ាវទាំងនោះជម្រាបទៅឪពុកម្តាយរបស់ខ្លួន។ ក្រោយពីព័ត៌មាននេះបានដឹងដល់ឪពុកម្តាយរបស់**លក្ខិណា** ពួកគាត់បានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធីច្បាប់ជាធរមាន។ មិនយូរប៉ុន្មាន ផ្អែកតាមទិន្នន័យព័ត៌មានដែល**លក្ខិណា**បានផ្តល់ជូនអាជ្ញាធរមានសមត្ថកិច្ច ជនអនាមិកនោះត្រូវបានឃាត់ខ្លួន និងទទួលទោសទណ្ឌតាមច្បាប់កំណត់។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ទោះបីជាព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានច្បាប់ស្តីពីការរំលោភបំពានតាមអ៊ីនធឺណិតក៏ដោយ ក៏ប៉ុន្តែយើងនៅតែព្យាយាមបង្ក្រាប និងដាក់ទោសទណ្ឌទៅលើជនល្មើសតាមរយៈមាត្រាពាក់ព័ន្ធមួយចំនួននៃក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងករណីដែលមានបណ្តឹង ឬមានការរាយការណ៍ពីសំណាក់សាធារណជន។

## ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា៣៨ រូពភាពនិងសម្ភារៈអាសអាភាស ...នៅក្នុងច្បាប់នេះមានន័យថា ជាសម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិកដែលពិព័ណ៌នាអំពីកេរភេទ ឬភាពអាសអាភាស ប្រហាក់ប្រហែលផ្សេងទៀតដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ...។
- មាត្រា៣៩ រូបភាពនិងសម្ភារៈអាសអាភាស ...ជនណាចែកចាយ លក់ដូរ ដាក់តាំងបញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាស ត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ) ថ្ងៃដល់១(មួយ) ខែ និងពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន )រៀលដល់២០០ ០០០(ពីរសែន)រៀល...។ ...ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយក ទៅប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសខាងលើត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ខាងលើ...។ ...ជនណាផលិត រូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២នៃមាត្រានេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ដល់១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី២០០ ០០០ (ពីរសែន)រៀល ដល់២ ០០០ ០០០(ពីរលាន)រៀល។
- មាត្រា៤០ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ...នៅក្នុងច្បាប់នេះមានន័យថា សម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជនដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ។
- មាត្រា៤១ រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ...ជនណាចែកចាយ លក់ ជួលដាក់តាំងបញ្ចាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំដល់៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀល ដល់១០ ០០០ ០០០(ដប់លាន)រៀល...។ ...ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ត្រូវផ្តន្ទាទោសដូចគ្នា...។ ...ជនណាផលិតរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ដល់១០ (ដប់) ឆ្នាំ...។ ...ជនណាផលិតរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១និងទី២ ខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់) ឆ្នាំដល់២០ (ម្ភៃ) ឆ្នាំ...។

## ង- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើអ្នកបង្កើតអ៊ីនធឺណិតឬអនឡាញមានបំណងជួយសង្គមដែរឬទេ? តើការប្រឈមមានអ្វីខ្លះ?

២- ហេតុអ្វីបានជាលក្ខិណាយល់ព្រមផ្ញើរូបអាក្រាតកាយឱ្យបូរី?

៣- តើបូរីស្នើសុំរូបថតដែលបង្ហាញពីរាងកាយអាក្រាតរបស់លក្ខិណាដើម្បីអ្វី?

៤- តើលក្ខខណ្ឌដែលលក្ខិណាបានកំណត់ជាមួយបូរី មានសុវត្ថិភាពដែរឬទេ? ហេតុអ្វី?

៥- តើរូបភាពរបស់លក្ខិណាត្រូវបានចែករំលែកដល់សិស្សនៅក្នុងសាលារៀនដោយរបៀបណា?

៦- តើការចែកចាយរូបភាពរបស់លក្ខិណាបន្តខុសដែរឬទេ? ហេតុអ្វី?

៧- ប្រសិនបើអ្នកជាលក្ខិណា តើអ្នកគិតថាអ្វីជាវិធីល្អបំផុត ដើម្បីបង្ការទប់ស្កាត់សកម្មភាពនេះកុំឱ្យកើតមានឡើង?

## ច- កិច្ចការផ្ទះ

១- ចូរគូសរង្វង់លើចម្លើយដែលត្រឹមត្រូវ៖

- នៅពេលអ្នកប្រើប្រាស់កម្មវិធីផ្សាយផ្ទាល់ អ្នកគួរដឹងថា៖

  ក- ដោយសារវីដេអូផ្សាយផ្ទាល់ទាំងនោះមិនមានការត្រួតពិនិត្យជាមុន ហើយអាចមានខ្លឹមសារដែលមិនល្អ និងបង្កគ្រោះថ្នាក់

  ខ- កម្មវិធីផ្សាយផ្ទាល់ដែលអនុញ្ញាតឱ្យមានការដោះដូរជាប្រាក់ ឬអំណោយជារូបិយវត្ថុ អាចបណ្តាលឱ្យមានការកេងប្រវ័ញ្ចកុមារ

  គ- ជនល្មើសតាមអ៊ីនធឺណិតឬអនឡាញអាចប្រើប្រាស់បណ្តាញជាក់លាក់មួយចំនួនដែលវីដេអូផ្ទាល់ខ្លួនរបស់កុមារត្រូវបានចែករំលែក ដើម្បីមានទំនាក់ទំនងជាមួយពួកគេ

  ឃ- ចម្លើយទាំងអស់ខាងលើត្រឹមត្រូវ។

- ការទទួលបាននូវព័ត៌មាននិងការផ្សព្វផ្សាយដែលមិនបានស្នើសុំក្នុងអំឡុងពេលដែលយើងកំពុងប្រើប្រាស់អ៊ីនធឺណិតឬអនឡាញ គឺជាហានិភ័យមួយនៃការប្រើប្រាស់កម្មវិធីប្រាស្រ័យទាក់ទង។

  ក- ត្រូវ

  ខ- ខុស។

- ល្បែងអនឡាញអាចបង្កហានិភ័យដូចជា៖

  ក- ជនល្មើសប្រើប្រាស់វាជាចំណុចចាប់ផ្តើមដើម្បីកសាងទំនាក់ទំនងជាមួយកុមារ

  ខ- វាអនុញ្ញាតឱ្យកុមារអាចប្រាស្រ័យទាក់ទងគ្នាអំពីល្បែង

  គ- ការមើលឃើញមាតិកាដែលមានលក្ខណៈហិង្សា និងអាសអាភាស

  ឃ- ក និង គ ជាចម្លើយដែលត្រឹមត្រូវ។

- ការប្រើប្រាស់កម្មវិធីស្វែងរកដូចជា Google, Yahoo, Bing… តែងតែមានសុវត្ថិភាព ពីព្រោះវាគ្រាន់តែផ្តល់ឱ្យយើងអាចស្វែងរកព័ត៌មាន និងចំណេះដឹង។

  ក- ត្រូវ

  ខ- ខុស។

២- ចូរបង្ហាញពីផលវិជ្ជមាន និងអវិជ្ជមាននៃការប្រើប្រាស់អ៊ីនធឺណិតឬអនឡាញ ។

| ផលវិជ្ជមាន | ផលអវិជ្ជមាន |
|---|---|
| - | - |
| - | - |
| - | - |
| - | - |
| - | - |

**មេរៀនទី ២**

# ការឆ្លើយតបចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិតឬអនឡាញ

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សានឹងកំណត់បានអំពីរបៀបរាយការណ៍ក្នុងករណីមានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិតឬអនឡាញ និងចេះស្វែងរកជំនួយដើម្បីសុវត្ថិភាពផ្ទាល់ខ្លួន និងមនុស្សជុំវិញខ្លួន។

## ខ- សកម្មភាពផ្ដើម

ចូរសង្កេតរូបខាងក្រោម រួចបង្ហាញពីគំនិតរបស់អ្នកពាក់ព័ន្ធទៅនឹងអត្ថប្រយោជន៍ និងការប្រឈម ក្នុងដំណើរការនៃការប្រើប្រាស់មធ្យោបាយផ្សេងៗតាមអ៊ីនធឺណិតឬអនឡាញ។







## គ- ពាក្យគន្លឹះ

- **ការរំលោភបំពាន:** ការប្រព្រឹត្តល្មើសលើជនដទៃ ល្មើសសិទ្ធិបុគ្គល ឬល្មើសច្បាប់។
- **អាជ្ញាធរមានសមត្ថកិច្ច:** អ្នកទទួលអំណាចពីរាជការ(រដ្ឋ) អ្នកកាន់អំណាចតាមមុខតំណែងនៅតាមក្រសួង មន្ទីរ និងនៅមូលដ្ឋាន ដូចជា មេឃុំ ចៅសង្កាត់ អភិបាលក្រុង ស្រុក ខណ្ឌ។ល។
- **អន្តរាគមន៍:** ការជួយអះអាង សម្របសម្រួល ដោះស្រាយ ការចេញពាំងមុខដោយអំណាចក្នុងរឿងអ្វីមួយ ឬជួយសង្គ្រោះ។

## ឃ- អត្ថបទអំណាន

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិតឬអនឡាញ គួរត្រូវបានយកចិត្តទុកដាក់ដូចការកេងប្រវ័ញ្ចផ្លូវភេទដែលកើតឡើងនៅក្រៅអ៊ីនធឺណិតឬអនឡាញដែរ។ ទោះបីមិនមានការប៉ះពាល់រាងកាយរបស់កុមារដោយផ្ទាល់ក៏ដោយ តែអំពើនេះអាចបង្កផលប៉ះពាល់អវិជ្ជមានទៅ

ដល់អាកប្បកិរិយារបស់កុមារក៏ដូចជាសុខភាពផ្លូវកាយនិងផ្លូវចិត្តរបស់ពួកគេ។ ផលប៉ះពាល់នេះអាចមានឥទ្ធិពលរយៈពេលយូរ ជាពិសេសប្រសិនបើកុមារមិនទទួលបានការព្យាបាលត្រឹមត្រូវ។ សញ្ញាទូទៅមួយចំនួននៃផលប៉ះពាល់ទាំងនោះអាចមានដូចជា ការបន្ទោសខ្លួនឯង ការមិនផ្តល់តម្លៃលើខ្លួនឯង ជំងឺថប់អារម្មណ៍ ជំងឺធ្លាក់ទឹកចិត្ត ការគំរាមកំហែងខ្លួនឯង ការពិបាកផ្តោតអារម្មណ៍លើការសិក្សា ការយល់សុបិនអាក្រក់ ការគេងមិនលក់ ជំងឺអស់កម្លាំងល្ហិតល្ហៃ ការប្រើប្រាស់អ៊ីនធឺណិតឬអនឡាញហួសកម្រិត ការបាត់បង់ចំណង់បរិភោគអាហារ ការបាត់ទំនុកចិត្តលើខ្លួនឯង ការបាត់បង់ភាពស្មោះត្រង់ចំពោះខ្លួនឯងនិងមនុស្សជុំវិញខ្លួន ការធ្លាក់ខ្លួនទៅប្រើប្រាស់ថ្នាំញៀនឬគ្រឿងស្រវឹង និងមានបញ្ហាក្នុងការទាក់ទងជាមួយមនុស្សនៅជុំវិញខ្លួន។

ជនខិលខូចឬជនសង្ស័យក្នុងបទល្មើសរំលោភបំពានផ្លូវភេទរបស់កុមារអាចទាក់ទងកុមារតាម អ៊ីនធឺណិតឬអនឡាញទាំងថ្ងៃទាំងយប់ដែលបង្កការព្រួយបារម្ភណ៍និងបង្កើនអារម្មណ៍អស់សង្ឃឹមចំពោះកុមារ។ ដោយសារតែដំណើរការនៃការលួងលោមកុមារតាមអ៊ីនធឺណិតឬអនឡាញមានភាពងាយស្រួលនិងរហ័សជាងការជួបប្រាស្រ័យដោយផ្ទាល់ជាមួយកុមារ ពិសេសគឺកុមារក៏អាចនឹងរហ័សទទួលសំណើរបស់ជនខិលខូចឬជនសង្ស័យ ព្រោះកុមារអាងថាមិនជួបផ្ទាល់។ នោះជាមូលហេតុមួយដែលក្រោយកើតហេតុការណ៍រំលោភបំពានហើយធ្វើឱ្យកុមារមានអារម្មណ៍ស្តីបន្ទោសខ្លួនឯងកាន់តែខ្លាំង និងបាត់បង់ជំនឿលើខ្លួនឯងព្រមទាំងបាត់បង់ភាពម្ចាស់ការ។ ទោះជាយ៉ាងនេះក្តី ការស្វែងរកជំនួយអន្តរាគមន៍ អាចកាត់បន្ថយផលប៉ះពាល់រយៈពេលវែងនៃការរំលោភបំពាន រីឯកុមារក៏អាចទទួលបានការព្យាបាលនិងស្តារសុខុមាលភាពបានទាន់ពេលវេលាផងដែរ។

ការប្រាស្រ័យទំនាក់ទំនងល្អជាមួយមនុស្សដែលយើងបានស្គាល់ច្បាស់តាមអ៊ីនធឺណិតឬអនឡាញជារៀងរាល់ថ្ងៃ ជាមនុស្សដែលអាចជួយកុមារក្នុងករណីមានការគំរាមកំហែងតាមអ៊ីនធឺណិតឬអនឡាញ។ ការអនុញ្ញាតឱ្យពួកគេដឹងពីសកម្មភាពរបស់អ្នកនៅលើអ៊ីនធឺណិតឬអនឡាញពួកគេអាចជួយបង្ការហានិភ័យផ្សេងៗ ដែលអាចកើតមានចំពោះអ្នក និងជួយស្វែងរកជំនួយក្នុងករណីមានការរំលោភបំពាន។ ជាពិសេសឪពុកម្តាយ ឬអ្នកអាណាព្យាបាលគឺជាមនុស្សដំបូងដែលកុមារមានទំនុកចិត្តគ្រប់គ្រាន់ក្នុងការប្រាប់អំពីការរំលោភបំពានដែលបានកើតឡើងចំពោះពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការនិយាយជាមួយឪពុកម្តាយមិនទទួលបានលទ្ធផលដូចការរំពឹងទុក កុមារអាចរកអ្នកផ្សេងជួយបាន ដូចជា មនុស្សពេញវ័យដែលអ្នកទុកចិត្ត គ្រូបង្រៀន មិត្តភក្តិ បងប្អូន អ្នកនៅជុំវិញខ្លួន និងអាជ្ញាធរមានសមត្ថកិច្ចអ្នកជាដើម។

## ករណីសិក្សា

**សុភារ័ត្ន**មានអាយុ១៥ឆ្នាំ។ នៅពេលដែលនាងចាប់ផ្តើមបង្កើតទំនាក់ទំនងក្នុងបណ្តាញសង្គមហ្វេសប៊ុកតាមអ៊ីនធឺណិតឬអនឡាញ នាងបានទទួលសារពីមនុស្សជាច្រើនមានស្រី មានប្រុស មានព្រះសង្ឃបានផ្ញើសំណើសុំធ្វើជាមិត្ត។ ក្នុងនោះ មានមនុស្សជាច្រើន នាងមិនដែលស្គាល់ពីមុនមកទេ ប៉ុន្តែដោយយោងតាមរូបភាព ឃើញហាក់ដូចជាមានអាយុប្រហែលគ្នានឹងនាងដែរ នាងបានទទួលសំណើក្នុងបញ្ជីជាមិត្ត។ ក្នុងចំណោមមិត្តទាំងនោះ មានមិត្តម្នាក់ដែលបានប្រាស្រ័យទាក់ទងគ្នាញឹកញាប់ក្នុងរយៈពេលយូរមកហើយ និងបានផ្លាស់ប្តូរសារជាច្រើន ព្រមទាំងរូបថតគ្នាទៅវិញទៅមកទៀតផង។ ក្រោយមកបុគ្គលនោះបានយករូបថតរបស់នាងទៅកាត់ត និងកែច្នៃដើម្បីឱ្យមើលទៅហាក់ដូចជានាងអាក្រាត ហើយគាត់បានផ្ញើរូបថតដែលបានកាត់តនោះទៅនាង ដោយគំរាមថា បើនាងមិនផ្ញើរូបអាក្រាតពិតទៅគាត់ទេនោះ គាត់នឹងផ្ញើវាទៅឱ្យមិត្តភក្តិទាំងអស់របស់នាងនៅលើបណ្តាញទំនាក់ទំនងសង្គម។ ដោយភាពភ័យខ្លាច **សុភារ័ត្ន**បានផ្ញើរូបថតអាក្រាតផ្នែកខាងលើរបស់នាងទៅឱ្យបុគ្គលនោះ។ ប៉ុន្តែវាមិនបានបញ្ឈប់សកម្មភាពគំរាមនោះទេ។ ជននោះបានបន្តការគំរាមឱ្យនាងផ្ញើរូបអាក្រាតបន្ថែមទៀត និងឱ្យនាងទៅជួបផ្ទាល់ដើម្បីរួមភេទ។ រៀងរាល់ថ្ងៃជននោះតែងផ្ញើរូបភាពនិងវីដេអូអាសអាភាសមកនាង។ ដោយមានការតក់ស្លុត ភ័យខ្លាច និងអស់សង្ឃឹមយ៉ាងខ្លាំងចំពោះខ្លួនឯង **សុភារ័ត្ន** លែងគិតអ្វីឃើញបានត្រឹមសម្រេចពួនសំងំលាក់ខ្លួននៅក្នុងបន្ទប់គេចមិនជួបមុខគ្រួសារ គេចមិនទៅសាលារៀន ដោយភូតភរម្តាយឪពុកថានាងមានជំងឺ រហូតដល់ខកខានមិនបានចូលរួមប្រឡងឆមាសទៀតផង។ ការគេចវេសពីបញ្ហាមិនបានជួយដោះស្រាយបញ្ហារបស់នាងឡើយ **សុភារ័ត្ន**បានសម្រេចចិត្តសរសេរសំបុត្រជម្រាបឪពុកម្តាយរបស់នាងអំពីទោសកំហុសរបស់នាង និងការគំរាមពីជនមិនស្គាល់ប្រវត្តិនោះមកលើនាង។ សំណាងល្អឪពុករបស់នាងបានយកព័ត៌មាននេះទៅពិគ្រោះជាមួយនាយកសាលា និងទទួលបានការចុះជួយធ្វើអន្តរាគមន៍យកនាងទៅព្យាបាលទាន់ពេលវេលា។ បន្ទាប់មកឪពុករបស់**សុភារ័ត្ន**បានដាក់ពាក្យបណ្តឹងតាមនីតិវិធីទៅអាជ្ញាធរមានសមត្ថកិច្ច។ ជាលទ្ធផលនៃការអន្តរាគមន៍**សុភារ័ត្ន**បានធូរស្បើយពីជំងឺផ្លូវចិត្តដែលបានញាំញីរូបនាងឱ្យមានអារម្មណ៍ភ័យខ្លាចទាំងយប់ទាំងថ្ងៃ និងបានធ្វើឱ្យនាងបាត់បង់ជំនឿលើខ្លួនឯងព្រមទាំងបាត់បង់ស្មារតីសិក្សារៀនសូត្រ ងាកមកទទួលពន្លឺជីវិតជាថ្មី ខិតខំរៀនសូត្រ និងរស់នៅជួបជុំគ្រួសារប្រកបដោយសុភមង្គលដូចដើមវិញ។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ទោះបីជាព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានច្បាប់ស្តីពីការរំលោភបំពានតាមអ៊ីនធឺណិតឬអនឡាញក៏ដោយ ក៏ប៉ុន្តែយើងនៅតែព្យាយាមបង្ក្រាប និងដាក់ទោសទណ្ឌទៅលើជនល្មើសតាមរយៈមាត្រាពាក់ព័ន្ធមួយចំនួននៃក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ ក្នុងករណីដែលមានបណ្តឹងឬមានការរាយការណ៍ពីសំណាក់សាធារណជន។

- មាត្រា៣៨ រូបភាពនិងសម្ភារៈអាសអាភាស ...នៅក្នុងច្បាប់នេះមានន័យថា ជាសម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិកដែលពិព័ណ៌នាអំពីកេរភេទ ឬភាពអាសអាភាស ប្រហាក់ប្រហែលផ្សេងទៀតដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ...។
- មាត្រា៣៩ រូបភាពនិងសម្ភារៈអាសអាភាស ...ជនណាចែកចាយ លក់ដូរ ដាក់តាំងបញ្ជាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាស ត្រូវ ផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ) ថ្ងៃដល់១(មួយ) ខែ និងពិន័យជាប្រាក់ពី១០០ ០០០ (មួយសែន )រៀលដល់២០០ ០០០(ពីរសែន)រៀល...។ ...ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយក ទៅប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសខាងលើត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខណ្ឌទី១ខាងលើ...។ ...ជនណាផលិត រូបភាព និងសម្ភារៈអាសអាភាសក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងកថាខណ្ឌទី១ និងទី២នៃមាត្រានេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ដល់១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ២០០ ០០០ (ពីរសែន)រៀល ដល់២ ០០០ ០០០(ពីរលាន)រៀល។
- មាត្រា៤០ រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ...នៅក្នុងច្បាប់នេះមានន័យថាសម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈអេឡិចត្រូនិច ដែលបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជនដែលធ្វើឱ្យរំភើប ឬរំជួលដល់ចំណង់ផ្លូវភេទ។
- មាត្រា៤១ រូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ...ជនណាចែកចាយ លក់ ជួលដាក់តាំងបញ្ជាំង ឬបង្ហាញនៅទីសាធារណៈនូវរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំដល់៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៤ ០០០ ០០០ (បួនលាន)រៀល ដល់១០ ០០០ ០០០(ដប់លាន)រៀល...។ ...ជនណាកាន់កាប់ ដឹកជញ្ជូន នាំចូល ឬនាំចេញនូវរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងកថាខ័ណ្ឌទី១ខាងលើ ត្រូវផ្តន្ទាទោសដូចគ្នា...។ ...ជនណាផលិតរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ដល់១០ (ដប់) ឆ្នាំ...។ ...ជនណាផលិតរូបភាពនិងសម្ភារៈអាសអាភាសនៃកុមារ ក្នុងគោលដៅយកទៅប្រើប្រាស់នៅក្នុងការប្រព្រឹត្តបទល្មើសណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១និងទី២ខាងលើ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០(ដប់) ឆ្នាំដល់២០ (ម្ភៃ) ឆ្នាំ...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរមើលរូបដើមឈើបញ្ហាខាងក្រោម រួចស្វែងរកចម្លើយពាក់ព័ន្ធទៅនឹង (១)មូលហេតុដែលនាំឱ្យ កើតមានករណីកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើ សុភារ័ត្ន (២)សកម្មភាពកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើ សុភារ័ត្ន (៣)ផលប៉ះពាល់នៃអំពើកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើ សុភារ័ត្ន និងក្រុមគ្រួសារ និង(៤) ដំណោះស្រាយបញ្ហាដែលអាចជួយ សុភារ័ត្ន និងទប់ស្កាត់អំពើកេងប្រវ័ញ្ចរំលោភបំពានផ្លូវភេទលើកុមារ។




## ច- កិច្ចការផ្ទះ

១- ចូរអានការបរិយាយពីស្ថានភាពក្នុងតារាងខាងក្រោម រួចគូសរង្វង់ជុំវិញពាក្យមានសុវត្ថិភាព ឬគ្មានសុវត្ថិភាពតាមស្ថានភាព បន្ទាប់មកត្រូវសរសេរនៅក្នុងតារាងជួរឈរបន្ទាប់ ថាតើវាស្ថិតក្នុងទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទមួយណា?

| ស្ថានភាព | ការវាយតម្លៃ | ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទ |
|---|---|---|
| **ក- ពេជ្រ** កំពុងលេងល្បែង Mobile Legend Bang Bang ជាក្រុមជាមួយដៃគូ ហើយអ្នកលេងម្នាក់បានបន្តផ្ញើមតិយោបល់ផ្លូវភេទដល់គាត់។ **ពេជ្រ** បានសុំឱ្យគាត់ឈប់ប៉ុន្តែអ្នកលេងម្នាក់នោះនៅតែបន្ត។ | មានសុវត្ថិភាព<br>គ្មានសុវត្ថិភាព | |

| | | |
|---|---|---|
| **ខ-** មិត្តភក្តិរបស់ **ចន្ទី** បានស្នើសុំឱ្យនាងថតវីដេអូជាមួយគ្នាដើម្បីបង្ហោះលើ Tiktok ដែលពួកគេច្រៀងនិងរាំបទចម្រៀងដែលពួកគេចូលចិត្តដោយសម្លៀកបំពាក់ខើចក្រោមលេចលើ។ | មានសុវត្ថិភាព<br>គ្មានសុវត្ថិភាព | |
| **គ- មាស** បានសរសេរលើបណ្តាញសង្គមហ្វេសប៊ុកថា គាត់ពិតជាចង់រកការងារធ្វើបន្ថែមលើការងារបច្ចុប្បន្ន។ ក្រោយមកគាត់ទទួលបានសារជាលក្ខណៈឯកជនពីបុរសម្នាក់ ដែល និយាយថាគាត់អាចឱ្យលុយច្រើន ហើយអ្វីដែលគាត់ត្រូវធ្វើគឺត្រូវផ្សាយផ្ទាល់នូវវីដេអូនៅក្នុងបន្ទប់គេងផ្ទាល់របស់ខ្លួន ដែលនៅទីនោះគាត់ត្រូវលេងកន្លែងកេរខ្មាសរបស់គាត់។ | មានសុវត្ថិភាព<br>គ្មានសុវត្ថិភាព | |
| **ឃ- គុនីឡា** និង **វិសាល** មានទំនាក់ទំនងជាមួយគ្នា ហើយម្តងម្កាលពួកគេផ្លាស់ប្តូររូបភាពស្និទ្ធស្នាលជាមួយគ្នា។ រយៈពេលពីរបីខែក្រោយមក **គុនីឡា**មានអារម្មណ៍ថា នាងមិនសប្បាយចិត្តក្នុងទំនាក់ទំនង ហើយនាងបានសម្រេចចិត្តបញ្ចប់វា។ ប៉ុន្តែក្រោយមក **វិសាល** បានគំរាមនាងថា ប្រសិនបើនាងបែកបាក់ជាមួយគាត់ គាត់នឹងផ្ញើរូបថតស្និទ្ធស្នាលទាំងអស់របស់នាងនៅលើបណ្តាញសង្គមជាសាធារណៈ។ | មានសុវត្ថិភាព<br>គ្មានសុវត្ថិភាព | |
| **ង- ស្រីលីន** ចង់មានមិត្តភក្តិច្រើនតាមអាចធ្វើទៅបាននៅលើហ្វេសប៊ុក។ ដូច្នេះគាត់បានទទួលជាមិត្តភក្តិដែលបានស្នើសុំ។ មនុស្សម្នាក់ដែលគាត់បានទទួលជាមិត្តបានបញ្ជូនឱ្យគាត់នូវតំណគេហទំព័រអាសអាភាស។ | មានសុវត្ថិភាព<br>គ្មានសុវត្ថិភាព | |

២- ចូរប្អូនជ្រើសរើសដោយគូស (✓) ក្នុងប្រអប់ណាដែលយល់ថាជាព័ត៌មានពាក់ព័ន្ធទៅនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិតឬអនឡាញ និងប៉ះពាល់ផ្លូវចិត្តកុមារៈ

☐ ក- អត្ថបទប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជានាសម័យអង្គរ។

☐ ខ- ការបង្ហាញរូបភាពអាក្រាតរបស់ស្ត្រី ជាពិសេសកុមារ។

☐ គ- រូបភាពវីដេអូដែលគ្រូបង្រៀនគ្រប់មុខវិជ្ជាតាមអនឡាញ។

☐ ឃ- សុខផ្ញើរូបថតស្និទ្ធស្នាលជាមួយបុប្ផាទៅមិត្តភក្តិតាមហ្វេសប៊ុក។

□ ង- កុមារមិនផ្ដោតអារម្មណ៍លើការសិក្សា ធ្លាក់ទឹកចិត្ត។

□ ច- ខ្លឹមសារដែលមានលក្ខណៈហិង្សានិងអាសអាភាសចំពោះកុមារ។

□ ឆ- កុមារថប់អារម្មណ៍ មានសុបិនអាក្រក់ គេងមិនលក់ មិនបរិភោគអាហារ។

□ ជ- ការផ្ញើសារឱ្យមិត្តភក្តិទៅដើរកម្សាន្តរួចបបួលមិត្តទៅជួបមនុស្សចម្លែកម្នាក់។

□ ឈ- រូបភាពគ្រប់ប្រភេទដែលទាក់ទងនឹងរូបចម្លាក់ រូបទេសភាព ...។

□ ញ- ពួសៅថតរូបកុមារីពេជ្រដែលគ្មានអាវក្រៅរួចបង្ហោះក្នុងហ្វេសប៊ុក។

៣- ចូរសរសេររឿងខ្លី (មិនលើសពីមួយទំព័រ) របស់ក្មេងប្រុស ឬក្មេងស្រីដែលកំពុងប្រឈមនឹងការគំរាមកំហែងតាមអ៊ីនធឺណិតឬអនឡាញ ដែលក្នុងខ្លឹមសារនៃរឿងនោះ បង្ហាញពីដំណើររឿងរបស់ក្មេងប្រុស ឬក្មេងស្រីនោះពាក់ព័ន្ធការគំរាមកំហែង ពីអារម្មណ៍របស់ក្មេងប្រុសឬក្មេងស្រីនោះ ពីដំណោះស្រាយរបស់ តួអង្គក្មេងប្រុសឬក្មេងស្រីនោះ និងការចូលរួមលើកកម្ពស់ការយល់ដឹងពីការបង្ការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអ៊ីនធឺណិតឬអនឡាញ។

## ការវាយតម្លៃ លទ្ធផលសិក្សាជំពូកទី៦

១- ចូរគូសសញ្ញា (✓) នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

- យើងចែករំលែកព័ត៌មាននិងរូបភាពជាមួយអ្នកដទៃតាមកម្មវិធីបណ្តាញទំនាក់ទំនងសង្គម

☐ ណូតប៊ុក ☐ ហ្វេសប៊ុក ☐ ហ្គោហ្គល ☐ ភីឌីអេហ្វ

- រាល់សកម្មភាពដែលមានសុវត្ថិភាព តាមអ៊ីនធឺណិតឬអនឡាញ ចាំបាច់ត្រូវគិតដល់៖

☐ វិធានត្រៃឋាន ☐ វិធានការ ☐ វិធានការឆ្លាតវៃ ☐ បញ្ញាវិធី

- អ្នកដែលពាក់ព័ន្ធការរក្សាសុវត្ថិភាពកុមារចៀសផុតពីការកេងប្រវ័ញ្ចផ្លូវភេទតាមអ៊ីនធឺណិតឬអនឡាញនៅតាមគ្រឹះស្ថានសិក្សា គឺ

☐ សិប្បករ ☐ កងខេមរភូមិន្ទ ☐ គ្រូបង្រៀន ☐ វិចិត្រករ

២- ចូរផ្គូផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| ១- ការលួងលោមតាមអ៊ីនធឺណិតឬអនឡាញ<br>២- ការផ្ញើសារបែបផ្លូវភេទ<br>៣- ការគំរាមកំហែងតាមអនឡាញ | ក- ការបញ្ជូនរូបភាពអត្ថបទអាសអាភាសពាក់ព័ន្ធផ្លូវភេទផ្ទាល់ខ្លួនជាមួយកុមារឱ្យគ្នាទៅវិញទៅមក។<br>ខ- ជនខិលខូចឬជនសង្ស័យបង្កើតទំនាក់ទំនង ជាមួយកុមារដោយសន្យាផ្តល់តាមតម្រូវការដើម្បីទទួលបានទំនុកចិត្តពីកុមារ ។<br>គ- ជនខិលខូចឬជនសង្ស័យសរសេរឬបង្ហោះអ្វីដែលបៀតបៀនលើកុមារដោយបញ្ហាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ។<br>ឃ-ជនខិលខូចឬជនសង្ស័យទាក់ទាញកុមារឱ្យចូលរួមក្នុងសកម្មភាពផ្លូវភេទដោយខ្លួនឯង។ | ១→ .....<br>២→ .....<br>៣→ ..... |

៣- ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

- ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអ៊ីនធឺណិតឬអនឡាញ អាចប៉ះពាល់ដល់សុខភាព.................និង....................ដល់កុមារ។
- អ្នកត្រូវចៀសវាងការចែកចាយព័ត៌មាននិងរូបភាពផ្ទាល់ខ្លួនតាមអ៊ីនធឺណិតឬអនឡាញព្រោះវាអាច.......................។

៤- ចូរឆ្លើយសំណួរ

- តើការប្រើប្រាស់អ៊ីនធឺណិតឬអនឡាញមានសារៈប្រយោជន៍ដូចម្តេចខ្លះ?
- ដើម្បីចៀសវាងហានិភ័យដែលកើតមានឡើងលើអ៊ីនធឺណិតឬអនឡាញ តើប្អូនត្រូវធ្វើដូចម្តេច?

# ជំពូកទី ៧ ការបង្ការ ទប់ស្កាត់ អំពើរត់ពន្ធមនុស្ស




ទំនោរអារម្មណ៍ពាក់ព័ន្ធតម្រូវការក្នុងជីវិតរបស់មនុស្សគ្រប់ពូជសាសន៍នៅលើសាកលលោកមិនដូចគ្នា។ មនុស្សខ្លះដែលរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឬប្រទេសមានការអភិវឌ្ឍតិចតួច មានទំនោរផ្លាស់ប្តូរបរិស្ថានរស់នៅដោយជ្រើសរើសការធ្វើអន្តោប្រវេសន៍ស្របច្បាប់និងខុសច្បាប់ទៅកាន់ប្រទេសរីកចម្រើនមួយចំនួននៅក្នុងពិភពលោក។ ក្នុងនោះ មានមនុស្សខ្លះមានបំណងគេចចេញពីការរស់នៅក្នុងរបត់សង្គមដែលមានទំនៀមទម្លាប់តឹងរ៉ឹង ដើម្បីទៅរស់នៅក្នុងប្រទេសដែលមានរបៀបរបបរស់នៅបែបសេរី ខ្លះស្វែងរកបទពិសោធន៍រស់នៅថ្មី ខ្លះស្វែងរកសេវាសាធារណៈល្អ (ការសិក្សា សុខុមាលភាព សុវត្ថិភាពសង្គម...) ខ្លះស្វែងរកប្រទេសដែលមានស្ថេរភាពនយោបាយល្អ និងមានប្រាក់ចំណូលខ្ពស់។ តាមរយៈការសិក្សាស្រាវជ្រាវ និងរបាយការណ៍សកល បានបង្ហាញថាការធ្វើដំណើរចេញពីប្រទេសមួយទៅប្រទេសមួយទៀតរបស់មនុស្សមួយចំនួនអាចប្រឈមនឹងការកេងប្រវ័ញ្ច ឬបទល្មើសផ្សេងៗ ជាពិសេសអំពើរត់ពន្ធមនុស្ស។ អំពើរត់ពន្ធមនុស្សត្រូវបានចាត់ទុកជាអំពើខុសច្បាប់ឬជាបទល្មើស ដែលបង្កឱ្យជនរងគ្រោះមានការប្រឈមខ្លាំងក្នុងដំណាក់កាលនៃការធ្វើដំណើរដើម្បីឆ្លងកាត់ព្រំដែនអន្តរជាតិទៅកាន់ប្រទេសគោលដៅ ដូចជា ការដឹកជញ្ជូន តាមរយៈផ្លូវគោក ផ្លូវទឹក ផ្លូវអាកាស ការផ្ទេរសំចត និងការលាក់បំពួនជាដើម។ នៅក្នុងជំពូកនេះ អ្នកសិក្សានឹងសិក្សាស៊ីជម្រៅអំពី៖

មេរៀនទី១ សញ្ញាណ និងការបង្ការទប់ស្កាត់ហានិភ័យបង្កដោយអំពើរត់ពន្ធមនុស្ស

មេរៀនទី២ ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយភាពឈ្លាសវៃ

មេរៀនទី ១

# សញ្ញាណ និងការបង្ការទប់ស្កាត់ហានិភ័យ បង្កដោយអំពើរត់ពន្ធមនុស្ស

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចរៀបរាប់បានអំពីសញ្ញាណនៃអំពើរត់ពន្ធមនុស្ស ហើយកំណត់បាននូវសកម្មភាពដែលជាអំពើរត់ពន្ធមនុស្ស និងអាចបង្កើនស្មារតីប្រុងប្រយ័ត្នដើម្បីការពារខ្លួនឯង ក៏ដូចជាមនុស្សជុំវិញខ្លួនឱ្យចៀសផុតពីអំពើរត់ពន្ធមនុស្ស។

## ខ- សកម្មភាពផ្តើម

ចូរពិនិត្យមើលរូបភាពខាងក្រោម តើរូបភាពមួយណាជាសកម្មភាពនៃអំពើរត់ពន្ធមនុស្ស និងរូបភាពណាជាសកម្មភាពនៃអំពើជួញដូរមនុស្ស រួចដាក់ចំណងជើង និងពណ៌នាអំពីខ្លឹមសារនៃបទល្មើស។



*រូបទី១*



*រូបទី២*



*រូបទី៣*



*រូបទី៤*

## គ- ពាក្យគន្លឹះ

- **អំពើរត់ពន្ធមនុស្ស:** (ពិធីសារប៉ាឡឺម៉ូ) "ការធ្វើអាជីវកម្មនូវសេវាដើម្បីទទួលបាន ដោយផ្ទាល់ ឬដោយប្រយោលនូវអត្ថប្រយោជន៍ជាហិរញ្ញវត្ថុ ឬសម្ភារៈផ្សេងទៀតក្នុងការនាំជនណាម្នាក់ឱ្យចូលទៅក្នុងរដ្ឋមួយដោយខុសច្បាប់ ហើយដែលជននោះមិនមែនជាប្រជាជន ឬជាជនដែលមាននិវេសនដ្ឋានអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះ"។ ការរត់ពន្ធ មនុស្សរាប់បញ្ចូលទាំង តាមផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស។
- **ជនទេសន្តរប្រវេសន៍:** ជនដែលធ្វើបំលាស់ទីពីកន្លែងដែលខ្លួនកំពុងរស់នៅ ទៅកាន់ទីកន្លែងផ្សេងទៀត ក្នុងគោលបំណងធ្វើការងារ ប្រកបរបរអ្វីមួយដែលមានរយៈពេលវែង ឬខ្លីរស់នៅបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ ទោះជាទីតាំងនោះស្ថិតក្នុងប្រទេសតែមួយ ឬឆ្លងព្រំដែនចូលទៅកាន់ប្រទេសផ្សេង។ ពាក្យ "ជនទេសន្តរប្រវេសន៍" នេះប្រើចំពោះអ្នកនៅក្នុងតំបន់ហៅអ្នកដែលធ្វើបំលាស់ទីទៅតំបន់ផ្សេង ឬក្រៅប្រទេស។
- **ជនអន្តោប្រវេសន៍:** ជនដែលធ្វើបំលាស់ទីពីប្រទេសរបស់ខ្លួន ឆ្លងព្រំដែនអន្តរជាតិចូលមកកាន់ប្រទេសមួយ ក្នុងគោលបំណងធ្វើការងារ ប្រកបរបរអ្វីមួយដែលមានរយៈពេលវែងឬខ្លី ចូលសញ្ជាតិ និងរស់នៅបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។ ពាក្យ "ជនអន្តោប្រវេសន៍" ប្រើចំពោះអ្នកនៅក្នុងប្រទេសគោលដៅ ហៅអ្នកដែលបានធ្វើបំលាស់ទីពីប្រទេសកំណើតមករស់នៅក្នុងប្រទេសខ្លួន។
- **និវេសនដ្ឋាន:** លំនៅដ្ឋានដែលរស់នៅជាប្រចាំ (លំនៅដ្ឋានអចិន្ត្រៃយ៍)។

## ឃ- អត្ថបទអំណាន

អំពើរត់ពន្ធមនុស្ស គឺជាបរិបទសកលដែលនៅតែបន្តកើតមានរហូតដល់បច្ចុប្បន្ននេះ។ អំពើរត់ពន្ធមនុស្ស កើតឡើងអាស្រ័យដោយកត្តាសំខាន់៤ គឺការអប់រំ សង្គម ការអនុវត្តច្បាប់ និងការឆក់ឱកាសរបស់ជនខិលខូចឬជនសង្ស័យដើម្បីផលប្រយោជន៍បុគ្គល។ អំពើរត់ពន្ធមនុស្ស មិនត្រូវចាត់ទុកជាបទល្មើសជួញដូរមនុស្សនោះទេ ប៉ុន្តែវាជាមូលហេតុដែលនាំឱ្យមានអំពើកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទ។ កន្លងមកក៏មានលេចចេញនូវបាតុភាពថ្មីមួយចំនួនដែលពាក់ព័ន្ធទៅនឹងអំពើជួញដូរសរីរាង្គ ឬជួញដូរទារកផងដែរ។ អំពើរត់ពន្ធមនុស្ស ភាគច្រើនកើតឡើងនៅក្នុងប្រទេសក្រីក្រមានសេដ្ឋកិច្ចទន់ខ្សោយ ប្រឈមនឹងអំពើហិង្សា ឬសង្គ្រាម។

អំពើរត់ពន្ធមនុស្សបានបណ្តាលឱ្យមនុស្សជាច្រើននាក់ស្លាប់ក្នុងដំណាក់កាលនៃការធ្វើដំណើរ កើតឡើងនូវការរំលោភសិទ្ធិមនុស្ស ការកេងប្រវ័ញ្ចមកលើមនុស្ស និងសកម្មភាពឧក្រិដ្ឋកម្មផ្សេងៗ។ អំពើរត់ពន្ធមនុស្ស ជាក្តីបារម្ភកម្រិតអន្តរជាតិ ដូចនេះ ប្រទេសនីមួយៗត្រូវបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ ធ្វើការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកតាមរយៈយន្តការពង្រឹង

សកម្មភាពត្រួតពិនិត្យតាមច្រកព្រំដែនទាំងផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ដើម្បីទប់ស្កាត់ឱ្យបាននូវលំហូរចេញចូលដោយខុសច្បាប់ដែលអាចមានបង្កប់នូវអំពើរត់ពន្ធនិងជួញដូរមនុស្ស។ ត្រូវបង្កើនសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់តាមរយៈការជួយគ្នាទៅវិញទៅមកក្នុងការផ្លាស់ប្តូរបទពិសោធន៍ ការបណ្តុះបណ្តាលជំនាញរវាងប្រទេសពាក់ព័ន្ធ។ ប្រទេសនីមួយៗគួររៀបចំក្រុមប្រចាំការអចិន្ត្រៃយ៍ ដើម្បីត្រៀមសហការទប់ស្កាត់ហេតុការណ៍បន្ទាន់នានាពាក់ព័ន្ធទៅនឹងអំពើរត់ពន្ធមនុស្ស ឆ្លងកាត់ព្រំដែន។ ប្រទេសពាក់ព័ន្ធគួរបង្កើនប្រសិទ្ធភាពនៃកិច្ចសហការជាមួយអាជ្ញាធរដែនដី ជាពិសេសតំបន់ជាប់ព្រំដែនដើម្បីអប់រំប្រជាពលរដ្ឋឱ្យជ្រួតជ្រាបយល់ដឹងពីគ្រោះថ្នាក់ និងផលប៉ះពាល់នៃអំពើរត់ពន្ធ ក៏ដូចជាកលល្បិចរបស់ជនជួញដូរមនុស្ស។

**កត្តាដែលនាំឱ្យមនុស្សមួយចំនួនធ្លាក់ក្នុងអន្ទាក់នៃអំពើរត់ពន្ធមនុស្ស៖**

- ការរត់គេចចេញពីប្រទេសដែលមានទំនៀមទម្លាប់តឹងរ៉ឹង ទៅកាន់ប្រទេសដែលមានរបៀបរស់នៅបែបសេរី
- ការស្វែងរកបទពិសោធន៍រស់នៅថ្មី
- ស្វែងរកសេវាសាធារណៈល្អ (ការសិក្សា សុខុមាលភាព សុវត្ថិភាពសង្គម......)
- ស្វែងរកប្រទេសដែលមានស្ថេរភាពនយោបាយល្អ
- ស្វែងរកប្រទេសដែលមានប្រាក់ចំណូលខ្ពស់។

**ភាពខុសគ្នារវាងអំពើរត់ពន្ធមនុស្ស និងអំពើជួញដូរមនុស្ស**

| អំពើរត់ពន្ធមនុស្ស | អំពើជួញដូរមនុស្ស |
|---|---|
| - ជនដែលត្រូវបានគេរត់ពន្ធ គឺស្ម័គ្រចិត្ត | - ជនដែលត្រូវគេជួញដូរគឺត្រូវបានគេបោកបញ្ឆោត បង្ខិតបង្ខំ |
| - ពេលទៅដល់គោលដៅមិនត្រូវបានគេកេងប្រវ័ញ្ច | - ត្រូវបានគេកេងប្រវ័ញ្ចនៅពេលទៅដល់គោលដៅ |
| - ឆ្លងកាត់ព្រំដែនអន្តរជាតិ | - មិនឆ្លងកាត់ ឬឆ្លងកាត់ព្រំដែនអន្តរជាតិ |
| - ឯកសារមិនស្របច្បាប់ | - ឯកសារស្របច្បាប់ ឬមិនស្របច្បាប់ |
| - ប្រទេសគោលដៅជាអ្នករងគ្រោះ | - ជនត្រូវបានគេជួញដូរគឺជនរងគ្រោះ |
| - អំពើរត់ពន្ធមនុស្សគឺបទល្មើសប្រឆាំងទៅនឹងច្បាប់របស់រដ្ឋ | - អំពើជួញដូរមនុស្សគឺជាបទល្មើសប្រឆាំងនឹងមនុស្សជាតិ |

## ករណីសិក្សា

**ពូយ៉ាន**ជាបុរសពោះម៉ាយមានកូនពីរនាក់ រស់នៅក្នុងផ្ទះជួលមួយកន្លែងក្នុងរាជធានី។ គាត់ប្រកបរបរចិញ្ចឹមជីវិតជាកម្មករសំណង់នៅការដ្ឋានមួយកន្លែងនៅជិតផ្ទះរបស់គាត់។ កូនទាំង

ពីររបស់**ពូយ៉ាន**កំពុងរៀននៅសាលាមធ្យមសិក្សាបឋមភូមិដែលនៅមិនឆ្ងាយពីផ្ទះជួលនោះ។ ថ្ងៃមួយ**ពូយ៉ាន**បានជួបបុរសម្នាក់ឈ្មោះ**ឌីន**ដែលជាកម្មករសំណង់ទើបត្រឡប់មកពីបម្រើការងារនៅប្រទេសជិតខាង។ ការវិលត្រឡប់ចូលស្រុកវិញរបស់**ឌីន** គឺដោយមូលហេតុត្រូវសមត្ថកិច្ចនៃប្រទេសជិតខាងនោះចាប់បញ្ជូនមកវិញដោយសារគាត់ទៅធ្វើការងារដែលគ្មានឯកសារស្របច្បាប់ ទើប**ឌីន**បានសម្រេចចិត្តមកធ្វើការងារជាកម្មករសំណង់ជាមួយ**ពូយ៉ាន**។ នៅពេលទទួលទានអាហារថ្ងៃត្រង់នៅក្បែរ**ពូយ៉ាន** អ្នកទាំងពីរបានជជែកសំណេះសំណាលជាមួយគ្នាពីរឿងនេះរឿងនោះ រហូតដល់រឿងរបស់**ឌីន**ដែលត្រូវបានសមត្ថកិច្ចប្រទេសជិតខាងចាប់បញ្ជូនមកវិញ។ ក្នុងការសន្ទនានោះ**ឌីន**បានប្រាប់**ពូយ៉ាន**ថា"ខ្លួនមកធ្វើការងារនៅទីនេះគ្រាន់តែជាបណ្ដោះអាសន្នប៉ុណ្ណោះ ព្រោះត្រូវរង់ចាំពេលវេលាត្រឡប់ទៅធ្វើការនៅប្រទេសជិតខាងនោះវិញ"។ **ពូយ៉ាន**មានការងឿងឆ្ងល់ ហើយក៏បានសួរទៅ**ឌីន**ថា "ចុះឯងមិនខ្លាច សមត្ថកិច្ចចាប់ម្ដងទៀតទេឬ?"។ **ឌីន** ឆ្លើយប្រាប់ថា "មិនអីទេពូ ខ្ញុំស្គាល់បុរសម្នាក់គួរឱ្យទុកចិត្តបាន ហើយបុរសនោះបានធានាជួយរកការងារដែលមានប្រាក់ចំណូលខ្ពស់ និងអាចជួយខ្ញុំឱ្យគេចផុតពីការចាប់បញ្ជូនពីសំណាក់សមត្ថកិច្ចទីនោះបានទៀតផង"។ **ឌីន** បានញញឹមនិងនិយាយបន្តទៀតថា "ខ្ញុំអាចរកបានចំណូលច្រើន ហើយនៅទីក្រុងគេពិតជាស៊ីវិល័យណាស់ពូ"។ ក្រោយបានស្ដាប់**ឌីន**និយាយហើយ **ពូយ៉ាន**មានការចាប់អារម្មណ៍ខ្លាំងណាស់ ដោយគាត់គិតថានឹងទៅធ្វើការនៅប្រទេសគេដែរ ក្រែងបានលុយច្រើនហើយបានស្គាល់ទីក្រុងស៊ីវិល័យរបស់គេទៀត។ **ពូយ៉ាន**បានគិតពីរឿងនេះរហូត នៅពេលទៅដល់ផ្ទះបានយករឿងនេះប្រាប់ទៅកូនទាំងពីររបស់គាត់ថា "ប៉ាចង់ទៅធ្វើការនៅប្រទេសជិតខាងមួយរយៈ ព្រោះនៅទីនោះប៉ាអាចរកលុយបានច្រើន ហើយអាចឱ្យពួកឯងចាយវាយប្រចាំខែបានគ្រប់គ្រាន់ជាងនេះ។ ប៉ាគិតថាហៅយាយឯងមកពីស្រុកដើម្បីមកជួយមើលថែពួកឯង។ ប៉ានឹងទុកលុយខ្លះឱ្យពួកឯងចាយពីរបីខែនៅពេលប៉ាចេញទៅ។ ពេលប៉ាបានការងារ ប៉ានឹងផ្ញើលុយប្រចាំខែមកឱ្យកូនៗ"។ កូនទាំងពីររបស់គាត់បានឮហើយក៏មិនបានប្រកែកអ្វីដែរ។ ស្អែកឡើង**ពូយ៉ាន**បានទៅធ្វើការដូចរាល់ថ្ងៃ ហើយក៏បានជួបនិយាយរឿងនេះ ជាមួយ**ឌីន**នៅពេលបាយថ្ងៃត្រង់ថា "ខ្ញុំចង់ទៅធ្វើការជាមួយឯងដែរ តើឯងអាចជួយនិយាយឱ្យបុរសដែលឯងស្គាល់នោះនាំខ្ញុំទៅបានទេ?។ **ឌីន** ឆ្លើយថា "មិនអីទេពូ! ពូឯងរកលុយពីរលានមក! ខ្ញុំទៅប្រាប់គាត់ឱ្យ ហើយពូឯងមិនបាច់បារម្ភរឿងឯកសារអីទេ! ម្យ៉ាងទៀតបីថ្ងៃទៀតខ្ញុំត្រូវទៅហើយ ដូច្នេះពូឯងត្រូវរកលុយឱ្យហើយទៅ យើងយកទៅឱ្យគាត់ជាមួយគ្នាតែម្ដង"។ **ពូយ៉ាន**សប្បាយចិត្តណាស់ប្រញាប់ប្រញាល់ទូរស័ព្ទទៅម្ដាយរបស់គាត់ដែលមានអាយុ៧៥ឆ្នាំរស់នៅខេត្តជាមួយគ្រួសារប្អូនស្រីរបស់គាត់ ឱ្យមកភ្នំពេញជួយមើលកូនរបស់គាត់ និងបានស្នើសុំម្ដាយជួយយកស្រែមួយអំពករបស់គាត់ទៅបញ្ចាំ ដើម្បីយកលុយបានបីលានរៀលមកប្រើការសិន។ **ពូយ៉ាន** បានទុកលុយមួយចំនួនឱ្យម្ដាយរបស់គាត់និងកូនៗល្មមសម្រាប់ការចាយវាយរយៈពេលពីរបីខែ និងលុយពីរលាននៅសល់គាត់ត្រៀមសម្រាប់យកទៅ

ឱ្យអ្នកនាំផ្លូវទៅរកការងារក្រៅប្រទេស។ គាត់បានសន្យាជាមួយម្តាយថា "ខ្ញុំនឹងផ្ញើលុយឱ្យចាយវាយប្រចាំខែ និងពេលសន្សំលុយបានច្រើនហើយខ្ញុំនឹងប្រញាប់ត្រឡប់មកផ្ទះយើងវិញ"។ លុះដល់ថ្ងៃណាត់ **ពូយ៉ាន**បានទៅជួប**ឌីន** ហើយធ្វើដំណើររួមជាមួយគ្នាទៅខេត្តជាប់ព្រំដែនតាមរថយន្តឈ្នួល ដើម្បីទៅជួបជាមួយបុរសដែល**ឌីន**ស្គាល់នោះ។ លុះទៅដល់គោលដៅ ពួកគេទាំងពីរនាក់បានទៅជួបគ្នាជាមួយបុរសនោះនៅជិតគុម្ពោតព្រៃមួយជាប់ជិតព្រំដែនប្រាកដមែន និងបានប្រគល់លុយគ្រប់ចំនួនដល់បុរសនោះ។ **ពូយ៉ាន** និង**ឌីន** ត្រូវបានគេដឹកជញ្ជូនរួមជាមួយមនុស្សប្រុសស្រីប្រមាណដប់នាក់តាមរថយន្តដឹកទំនិញពេញគ្របដោយដំបូលក្រណាត់ខ្មៅក្រាស់បិទជិតមួយបើកឆ្លងព្រំដែន។ ពេលធ្វើដំណើរឆ្លងកាត់ព្រំដែន **ពូយ៉ាន**មានអារម្មណ៍ភ័យណាស់ហើយបានខ្សិបសួរទៅ**ឌីន**រហូត ថាអាចមានបញ្ហាអ្វីទេ? តែ**ឌីន**ឆ្លើយថា"មិនអីទេ មិនអីទេ កុំភ័យពេក កុំភ័យពេក!"។ ដំណើរដោយលួចលាក់ឆ្លងកាត់ព្រំដែន បាននាំពួកគេទៅដល់កន្លែងមួយដែលនៅឆ្ងាយដាច់ស្រយាលពីទីប្រជុំជននៃប្រទេសគោលដៅ។ រថយន្តដឹកទំនិញបានឈប់ ហើយមានបុរសម្នាក់ឈរបញ្ជាជាភាសាបរទេសឱ្យពួកគេចុះពីរថយន្ត តម្រង់ជាជួរ រួចបញ្ជាឱ្យដើរឆ្ពោះទៅបុរសម្នាក់ទៀតដែលឈររង់ចាំប្រមូលលុយពីពួកគេ។ បន្ទាប់មកក៏មានបុរសម្នាក់ទៀតបានមកដល់ហើយបាននាំពួកគេជិះរថយន្តទ្រុងមួយទៀត បន្តដំណើរយ៉ាងឆ្ងាយឆ្ពោះទៅការដ្ឋានសំណង់មួយកន្លែងស្ថិតនៅក្បែរជើងភ្នំជិតមាត់សមុទ្រដើម្បីធ្វើការ។ **ពូយ៉ាន** មានអារម្មណ៍ហត់នឿយយ៉ាងខ្លាំង ម្យ៉ាងគាត់ពុលឡានដែលគាត់ត្រូវពួនសំងំក្នុងគំនរទំនិញដ៏ច្រើនស្ទើររកខ្យល់ដកមិនបានតាមផ្លូវដ៏វែងឆ្ងាយ។ ឃើញទិដ្ឋភាពកន្លែងការងារគាត់អស់សង្ឃឹម និងស្តាយក្រោយចំពោះការសម្រេចចិត្តធ្វើចំណាកស្រុកនាពេលនេះ។ **ពូយ៉ាន**មើលទៅ**ឌីន**ហាក់មិនមានអ្វីសោកស្តាយនោះទេ ព្រមទាំងហាក់មានអារម្មណ៍សប្បាយ និងត្រេកត្រអាលរត់ទៅរកភេសជ្ជៈដែលខ្លួនចូលចិត្ត និងខកខានមិនបានផឹកជាយូរមកហើយទៀតផង។ **ពូយ៉ាន**គិតថាមិនដឹងពេលណាទើបបានត្រឡប់ទៅផ្ទះវិញទេ។ ការបម្រើការងារនៅការដ្ឋានសំណង់នៅទីនោះពិតជាមិនដូចការងារនៅស្រុកកំណើតឡើយទោះជាបានប្រាក់តិចជាងក៏ពិតមែន តែបាននៅជុំក្រុមគ្រួសារ និងបានប្រាស្រ័យទាក់ទងមនុស្សដែលប្រើភាសាជាតិតែមួយ។ ដោយអារម្មណ៍នឹកផ្ទះនិងគ្រួសារខ្លាំង រួមនឹងការប្រើកម្លាំងហួសសមត្ថភាព សម្រាកមិនបានគ្រប់គ្រាន់ **ពូយ៉ាន**បានធ្លាក់ខ្លួនឈឺគ្រុនក្តៅខ្លាំងមិនអាចចេញទៅធ្វើការនៅការដ្ឋានបាន។ **ពូយ៉ាន**បានពឹងពាក់ឱ្យ**ឌីន**ដែលចេះភាសាជួយសូមការអនុញ្ញាតពីមេការសំណង់សម្រាកពីរបីថ្ងៃ តែក៏ត្រូវបានគេកាត់ប្រាក់កម្រៃរបស់គាត់ដែរ។ ស្របពេលដែលរដ្ឋាភិបាលនៃប្រទេសជិតខាងធ្វើការត្រួតពិនិត្យស្ថិតិពលករបរទេសដែលធ្វើចំណាកស្រុកខុសច្បាប់មកធ្វើការក្នុងស្រុកគេផងនោះ កម្លាំងសមត្ថកិច្ចបានចុះចាប់និងប្រមូលពលករទាំងនោះ រួចបញ្ជូនមកស្រុកកំណើតវិញ រួមមាន **ពូយ៉ាន** និង **ឌីន** ផងដែរ។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ទោះបីជាព្រះរាជាណាចក្រកម្ពុជា ពុំទាន់មានច្បាប់ស្តីពីអំពើរត់ពន្ធមនុស្សក៏ដោយ ក៏ប៉ុន្តែយើងនៅតែព្យាយាមបង្ក្រាប និងដាក់ទោសទណ្ឌទៅលើជនល្មើសតាមរយៈមាត្រាពាក់ព័ន្ធមួយចំនួននៃក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ ក្នុងករណីដែលមានបណ្តឹង ឬមានការរាយការណ៍ពីសំណាក់សាធារណជន។

### ១- ក្នុងពិធីសារប៉ាឡឺម៉ូ (Palermo Protocol)

- មាត្រា៦..."ជនទេសន្តរប្រវេសន៍មិនត្រូវជាប់ទោសព្រហ្មទណ្ឌទេ" (នៅក្នុងការផ្ទេរ ឬប្រទេសគោលដៅដែលជននោះកំពុងស្ថិតនៅ) គោលបំណងនៃពិធីសារនេះ មិនដាក់ទោសព្រហ្មទណ្ឌលើជនទេសន្តរប្រវេសន៍ណា ដែលជាកម្មវត្ថុនៃដំណើរការរត់ពន្ធជនទេសន្តរប្រវេសន៍ នេះទេ...។

### ២- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

- មាត្រា៤ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ... អ្នកសមគំនិត និងអ្នកផ្តើមគំនិតក្នុងបទល្មើសឧក្រិដ្ឋឬមជ្ឈិមទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ត្រូវផន្ទាទោស និងត្រូវទទួលខុសត្រូវដូចចារីដែលប្រព្រឹត្តបទល្មើស។
- មាត្រា១០ ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ... ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ ស្មុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងៗទៀត ត្រូវផន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ដល់១៥(ដប់ប្រាំ)ឆ្នាំ។...ត្រូវផន្ទាទោសដាក់ពន្ធនាគារពី ១៥(ដប់ប្រាំ)ឆ្នាំ ទៅ២០(ម្ភៃ)ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់ តាំង...។
- មាត្រា១១ ការនាំចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន... ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ដល់១៥(ដប់ប្រាំ)ឆ្នាំ។ ... ត្រូវផន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ)ឆ្នាំ ទៅ២០ (ម្ភៃ)ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង...។

- មាត្រា១៧ ការដឹកជញ្ជូនដោយមានគោលដៅ... ជនណាដែលដឹកជញ្ជូនជនដទៃដែលត្រូវបាននាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬដឹកជញ្ជូនដោយដឹងថាជននោះត្រូវបាននាំចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬដឹកជញ្ជូន ក្នុងគោលដៅដើម្បីស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងៗទៀត ត្រូវផន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ)ឆ្នាំ។... ត្រូវផន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ)ឆ្នាំទៅ ២០(ម្ភៃ)ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន អំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង...។
- មាត្រា១៨ អំពើនាំឆ្លងដែន... ជនណាដែលនាំយកជនដទៃដោយដឹងថាជននោះ ត្រូវបាននាំចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់ ដូរ ឬដឹកជញ្ជូនទៅក្រៅ ព្រះរាជាណាចក្រកម្ពុជា ត្រូវផន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ)ឆ្នាំ ដល់១៥ (ដប់ប្រាំ) ឆ្នាំ។ ... ត្រូវផន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ)ឆ្នាំ ទៅ២០ (ម្ភៃ)ឆ្នាំ ក្នុងករណីអំពើល្មើសប្រព្រឹត្តឡើងដោយមន្ត្រីសាធារណៈដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ អំពើល្មើសប្រព្រឹត្តឡើងដោយក្រុមមានការចាត់តាំង...។
- មាត្រា២០ ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស...ជនណាដែលទទួល ផ្តល់ជម្រកឬលាក់បំពួនជនរងគ្រោះក្នុងអំពើនាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់ ដូរ ឬដឹកជញ្ជូនក្នុងគោលដៅដើម្បីជួយដល់ជនល្មើសដែលនាំយកដោយមិនស្របច្បាប់ ជ្រើសរើស លក់ដូរ ឬដឹកជញ្ជូនជនរងគ្រោះនោះ ត្រូវផន្ទាទោសដាក់ពន្ធនាគារពី២ (ពីរ)ឆ្នាំ ដល់៥ (ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន)រៀល ដល់១០ ០០០ ០០០ (ដប់លាន)រៀល។ ...ត្រូវផន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន...។

## ខ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើក្នុងករណីសិក្សាខាងលើមានតួអង្គប៉ុន្មាននាក់?

២- ហេតុអ្វីបានជាពូយ៉ានសម្រេចចិត្តធ្វើចំណាកស្រុកទៅរកការងារនៅប្រទេសជិតខាង?

៣- តើពូយ៉ានបានទទួលអ្វីៗដូចការរំពឹងគិតរបស់គាត់ដែរឬទេ? ហេតុអ្វី?

៤- តើការសម្រេចចិត្តនិងទង្វើរបស់ ពូយ៉ាន បង្កផលប៉ះពាល់ដល់អ្នកណាខ្លះ? ហេតុអ្វី?

៥- តើក្នុងករណីរត់ពន្ធនេះ មានអ្នកណាខ្លះដែលត្រូវទទួលទោសទណ្ឌ? ទោសទណ្ឌដូចម្ដេចខ្លះ?

៦- តើអាចមានមធ្យោបាយអ្វីខ្លះ ដែលអាចជួយកាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់បានទាំងស្រុងអំពើរត់ពន្ធមនុស្ស?

## ច- កិច្ចការផ្ទះ

ចូរឆ្លើយសំណួរខាងក្រោម ៖

១- តើនៅក្នុងសហគមន៍របស់ប្អូន មានអំពើរត់ពន្ធមនុស្សដែរឬទេ ?

២- តើជនប្រភេទណាដែលត្រូវបានគេរត់ពន្ធ ?

៣- ហេតុអ្វីបានជាមានអំពើរត់ពន្ធមនុស្ស ?

៤- ក្នុងនាមប្អូនជាសមាជិកម្នាក់នៃសហគមន៍ តើប្អូនចូលរួមធ្វើអ្វីខ្លះដើម្បីជួយទប់ស្កាត់អំពើរត់ពន្ធមនុស្ស ?

# មេរៀនទី ២ ការធ្វើទេសន្តរប្រវេសន៍ប្រកបដោយភាពឈ្លាសវៃ

## ក- លទ្ធផលរំពឹងទុក

បន្ទាប់ពីបានរៀនមេរៀននេះចប់ អ្នកសិក្សាអាចរៀបរាប់បានពីការធ្វើទេសន្តរប្រវេសន៍ ហើយបង្ហាញភាពខុសគ្នារវាងទេសន្តរប្រវេសន៍ និងអន្តោប្រវេសន៍ ព្រមទាំងមានស្មារតីទទួលខុសត្រូវក្នុងការសម្រេចចិត្តធ្វើ ទេសន្តរប្រវេសន៍ឬធ្វើខ្លួនជាជនអន្តោប្រវេសន៍ដោយភាពឈ្លាសវៃនិងមានកិត្តិយស។

## ខ- សកម្មភាពផ្តើម

ចូរមើលរូបទាំងបីខាងក្រោម រួចឆ្លើយសំណួរៈ

- តើរូបភាពទាំងបីមានខ្លឹមសារខុសគ្នា និងដូចគ្នាដូចម្តេច?
- តើអ្នកធ្លាប់ឮពាក្យចំណាកស្រុកដែរឬទេ?
- តើអ្នកធ្លាប់ធ្វើចំណាកស្រុកដែរឬទេ? ចូរនិយាយពីដំណើរចំណាកស្រុករបស់អ្នក។







## គ- ពាក្យគន្លឹះ

- **ការធ្វើចំណាកស្រុក/ការធ្វើទេសន្តរប្រវេសន៍:** ការចាកចេញពីស្រុកកំណើតដោយស្ម័គ្រចិត្ត ក្នុងគោលបំណងធ្វើការងារ ប្រកបរបរអ្វីមួយដែលមានរយៈពេលវែង ឬខ្លី រស់នៅបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ ទោះជាទីតាំងនោះស្ថិតក្នុងប្រទេសតែមួយ ឬឆ្លងព្រំដែនចូលទៅកាន់ប្រទេសផ្សេង។
- **ការធ្វើចំណាកស្រុកស្របច្បាប់ទៅក្រៅប្រទេស:** ការធ្វើបំលាស់ទីរបស់ជនណាម្នាក់ដោយមានឯកសារគ្រប់គ្រាន់ និងត្រូវបានអាជ្ញាធរមានសមត្ថកិច្ចប្រទេសគោលដៅ

អនុញ្ញាតផ្តល់សិទ្ធិឱ្យចូល ស្នាក់នៅ ឬធ្វើការក្នុងប្រទេសគេដោយស្របច្បាប់។ ដូចនេះ សិទ្ធិរបស់ពួកគេត្រូវបានការពារដោយច្បាប់ក្នុងប្រទេសថ្មី/ប្រទេសគោលដៅនោះ។

- **ការធ្វើចំណាកស្រុកមិនស្របច្បាប់ទៅក្រៅប្រទេស:** ការធ្វើបំលាស់ទីរបស់ជនណាម្នាក់ដោយគ្មានឯកសារគ្រប់គ្រាន់ និងមិនត្រូវបានអាជ្ញាធរមានសមត្ថកិច្ចប្រទេសគោលដៅអនុញ្ញាតឱ្យធ្វើដំណើរចូល ស្នាក់នៅ ឬធ្វើការងារក្នុងប្រទេសគោលដៅនោះឡើយ។

## ឃ- អត្ថបទអំណាន

ការធ្វើចំណាកស្រុកឬការធ្វើទេសន្តរប្រវេសន៍គឺជាលំហូរសកលដែលបានកើតឡើងស្ទើរគ្រប់ប្រទេស គ្រប់តំបន់នៃពិភពលោក។ ដោយឡែកនៅប្រទេសកម្ពុជាមានប្រជាពលរដ្ឋធ្វើចំណាកស្រុកពីភូមិ ឬស្រុក ឬខេត្តកំណើតទៅស្រុកឬខេត្តមួយផ្សេងទៀតក្នុងប្រទេសក្នុងគោលបំណងផ្សេងៗគ្នាដូចជា ការផ្លាស់ទីលំនៅដ្ឋាន ការជួបជុំគ្រួសារ ការស្វែងរកការងារធ្វើ ការបំពេញការងារ ការសិក្សា។ល។

ការធ្វើចំណាកស្រុកឬការធ្វើទេសន្តរប្រវេសន៍ក៏ត្រូវបានទទួលស្គាល់ថាជាសកម្មភាពមួយដែលអាចរួមចំណែកដល់ការលើកកម្ពស់ជីវភាព សមត្ថភាពបុគ្គលនិងគ្រួសារ ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ទន្ទឹមនេះ ការធ្វើចំណាកស្រុកឬការធ្វើទេសន្តរប្រវេសន៍ក៏ត្រូវបានរកឃើញថាជាមូលហេតុដែលនាំឱ្យមានបញ្ហាក្នុងសង្គមមួយផ្នែកផងដែរដូចជា ការបាត់បង់កម្លាំងពលកម្មការងារក្នុងស្រុក ការធ្វើឱ្យមានការប្រឈមចំពោះសមាជិកគ្រួសារ ដូចជាកុមារខ្វះការថែទាំ និងកង្វះភាពកក់ក្ដៅ។

អង្គការសហប្រជាជាតិ បានរៀបចំតាក់តែងអនុសញ្ញាអន្តរជាតិ និងក្របខណ្ឌគោលនយោបាយនានា ដើម្បីធានាដល់ការគោរពសិទ្ធិជនចំណាកស្រុកឬជនទេសន្តរប្រវេសន៍។ ដើម្បីធានាដល់ការអនុវត្តទៅតាមអនុសញ្ញាអន្តរជាតិ និងក្របខណ្ឌគោលនយោបាយនានា អង្គការទេសន្តរប្រវេសន៍និងអង្គការអន្តរជាតិ ត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងបញ្ហាចំណាកស្រុកឬបញ្ហាទេសន្តរប្រវេសន៍។ ដោយឡែកនៅព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានរៀបចំតាក់តែងលិខិតបទដ្ឋាននិងគោលនយោបាយពាក់ព័ន្ធការធ្វើចំណាកស្រុកឬទេសន្តរប្រវេសន៍ ព្រមទាំងយន្តការដ៏រឹងមាំ ដើម្បីលើកកម្ពស់សិទ្ធិជនចំណាកស្រុកឬជនទេសន្តរប្រវេសន៍ទាំងក្នុង និងក្រៅប្រទេស។

### មូលហេតុនៃការធ្វើចំណាកស្រុក

កត្តា ដែលបណ្តាលឱ្យមានការធ្វើចំណាកស្រុកឬការធ្វើទេសន្តរប្រវេសន៍មានមូលហេតុជាច្រើន តែជារួមមានមូលហេតុពីរសំខាន់គឺ កត្តាជំរុញ និងកត្តាអូសទាញ។

**កត្តាជំរុញដែលនាំឱ្យធ្វើចំណាកស្រុកមានៈ** ភាពក្រីក្រ គ្មានការងារធ្វើ ចំណងបំណុល គ្រោះធម្មជាតិ បញ្ហាសុខភាព វិបត្តិក្នុងគ្រួសារ ខ្វះទីផ្សារការងារក្នុងស្រុក ខ្វះទីផ្សារកសិផល ការផ្តល់សេវាសាធារណៈមិនពេញលេញ និងការតភ្ជាប់ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

**កត្តាអូសទាញដែលនាំឱ្យមានការធ្វើចំណាកស្រុកមានៈ** ចង់សាកល្បងទៅធ្វើការងារនៅក្រៅស្រុក ឱកាសរកការងារធ្វើសម្បូរបែប មានបរិស្ថានការងារល្អ រកចំណូលបានខ្ពស់ បរិស្ថានស៊ីវិល័យនៃប្រទេសគោលដៅ ទទួលបានសេវាសាធារណៈក្នុងប្រទេសគោលដៅ បានរួមដំណើរជាមួយមិត្តភក្តិ។ល។

## ប្រភេទចំណាកស្រុកឬទេសន្តរប្រវេសន៍

ការធ្វើចំណាកស្រុក/ការធ្វើទេសន្តរប្រវេសន៍មាន២ប្រភេទគឺ ក្នុងប្រទេសនិងក្រៅប្រទេស។

ការធ្វើចំណាកស្រុកទៅក្រៅប្រទេស គឺជាការបំលាស់ទី របស់ជនណាម្នាក់ឆ្លងព្រំដែនពីប្រទេសមួយទៅប្រទេសមួយផ្សេងទៀតក្នុងគោលបំណងស្វែងរកការងារធ្វើការសិក្សា ការជួបជុំគ្រួសារជាដើម។ ចំណាកស្រុកទៅក្រៅប្រទេសគឺអាចស្របច្បាប់ និងមិនស្របច្បាប់។

- **ហានិភ័យចំពោះការធ្វើចំណាកស្រុកមិនស្របច្បាប់**

នៅពេលដែលជនណាម្នាក់ធ្វើចំណាកស្រុក/ធ្វើទេសន្តរប្រវេសន៍ដោយមិនស្របច្បាប់ គេអាចនឹងជួបប្រទះបញ្ហាដូចជាៈ




- មិនទទួលបានសេវាសុខុមាលភាពសង្គមនិងអាហារូបត្ថម្ភ
- មិនទទួលបានការការពារផ្នែកច្បាប់និងសំណងនៅពេលដែលពួកគេជួបប្រទះគ្រោះថ្នាក់ក្នុងពេលបំពេញការងារ
- មិនទទួលបានសុវត្ថិភាពទាំងផ្លូវកាយទាំងផ្លូវចិត្ត
- គ្មានសិទ្ធិសេរីភាពក្នុងការធ្វើដំណើរការស្នាក់នៅ និងការបំពេញការងារ
- មិនទទួលបានការងារទៀងទាត់ជាប្រចាំ និងមិនទទួលបានប្រាក់កម្រៃដូចអ្នកធ្វើការងារស្របច្បាប់
- អាចជួបប្រទះបញ្ហាដូចជា ងាយត្រូវបានគេ(មេខ្យល់)ឆបោក កេងប្រវ័ញ្ច និងរំលោភបំពាន (ផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត)

- មិនហ៊ានរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច នៅពេលត្រូវបានគេឆបោក កេងប្រវ័ញ្ច និងរំលោភបំពានតាមទម្រង់ផ្សេងៗ
- ត្រូវបានគេដាក់ឱ្យធ្វើការងារក្នុងស្ថានភាពកខ្វក់ លំបាក និងមានគ្រោះថ្នាក់។

▪ **គុណប្រយោជន៍នៃការធ្វើចំណាកស្រុកស្របច្បាប់**



នៅពេលដែលជនណាម្នាក់ ធ្វើចំណាកស្រុកស្របច្បាប់ ពួកគេអាចរកជំនួយផ្លូវច្បាប់ពីប្រទេសគោលដៅ ឱកាសទទួលចំណេះដឹងជំនាញ និងរកប្រាក់ចំណូល ហើយមានសិទ្ធិធ្វើការទាមទារ ឬតវ៉ា ប្រសិនបើមានការរំលោភបំពាន និងអាចប្រើប្រាស់ប្រព័ន្ធថែទាំសុខភាពតាមតំបន់របស់ប្រទេសគេបាន។

ជនចំណាកស្រុកឬជនទេសន្តរប្រវេសន៍ធ្វើការងារស្របច្បាប់មានសិទ្ធិដូចជនដទៃដែរ ដោយទទួលបានការការពារពីសិទ្ធិមនុស្ស និងពីច្បាប់ការងារនៃប្រទេសទទួល។ សិទ្ធិជាមូលដ្ឋានរបស់ពួកគេ៖

- ធ្វើការងារ និងទទួលប្រាក់ឈ្នួលសមស្រប ទទួលប្រាក់ឈ្នួលស្មើគ្នាចំពោះការងារដូចគ្នា
- ទទួលបានសេរីភាពចាកផុតពីការរើសអើងនានា
- ទទួលបានការទទួលស្គាល់ស្មើភាពចំពោះមុខច្បាប់ និងមានកិច្ចការពារ
- ចៀសផុតពីពលកម្មដោយបង្ខំ និងមិនត្រូវគេនិរទេសឬចាប់បង្ខំឱ្យចាកចេញដោយកម្លាំងអាជ្ញាធរ
- ទទួលបានសិទ្ធិវិលត្រឡប់មកផ្ទះវិញ នៅពេលអ្នកបំពេញកិច្ចការងារតាមកិច្ចសន្យាដែលអ្នកបានធ្វើជាមួយថៅកែ
- ទទួលបានសិទ្ធិរស់នៅសមស្របក្នុងនាមជាមនុស្ស រួមទាំងការថែទាំសុខភាព
- ធ្វើការងារក្នុងលក្ខខណ្ឌនិងបរិយាកាសប្រកបដោយសុវត្ថិភាព និងមានអនាម័យ
- ទទួលបានការគោរពម៉ោងបំពេញការងារសមស្រប មានពេលសម្រាលកូន និងពេលលំហែមាតុភាពសមស្រប
- ទទួលបានសិទ្ធិសេរីភាពចៀសផុតពីការយាយីផ្លូវភេទនៅកន្លែងធ្វើការ
- ទទួលបានសិទ្ធិការពារពីការបង្ខិតបង្ខំឱ្យធ្វើការងារកន្លែងមានគ្រោះថ្នាក់នៅពេលមានផ្ទៃពោះ។

- **ប្រភេទការងារសម្រាប់ពលករចំណាកស្រុកទៅរកការងារនៅក្រៅប្រទេស**

នៅប្រទេសគោលដៅនៃការធ្វើចំណាកស្រុកមួយចំនួន ការងារភាគច្រើនជាប្រភេទការងារដែលប្រជាជនក្នុងប្រទេសទាំងនោះមិនចង់ធ្វើ ហើយត្រូវបំពេញដោយការរកកម្លាំងពលកម្មពីប្រទេសផ្សេងទៀតដែលមានប្រាក់កម្រៃឬប្រាក់ឈ្នួលទាប។ ការងារទាំងនោះជាទូទៅមានលក្ខណៈ ៣ប្រភេទ៖





**ប្រភេទទី១**:ជាការងារដែលប្រឈមនឹងគ្រោះថ្នាក់ខ្លាំងដូចជាការងារសំណង់អគារខ្ពស់ៗ ការងារនេសាទត្រីក្នុងសមុទ្រដែលប្រើរយៈពេលយូរ ការងារតាមការដ្ឋានផ្លូវថ្នល់ក្នុងតំបន់លំបាក ការងារតាមកសិកម្មដ្ឋានក្នុងតំបន់ត្រជាក់ខ្លាំង ការងារបាញ់ថ្នាំពុលគីមីលើបន្លែផ្លែឈើជាដើម។

**ប្រភេទទី២**: ជាការងារបម្រើតាមផ្ទះ ការងារក្នុងកសិដ្ឋានចិញ្ចឹមសត្វពាហនៈសម្រាប់សម្លាប់យកសាច់លក់ ការងារដាក់ចំណីនិងមើលថែសត្វក្នុងកសិដ្ឋាន ការងារប្រមូលសំរាមតាមផ្ទះឬតាមទីសាធារណៈ កម្មកររោងចក្រ អ្នកបម្រើក្នុងហាងលក់ទំនិញ កម្មករដាំដំណាំកសិកម្ម កម្មករសំណង់ ការងារតាមឧស្សាហកម្មនេសាទជាដើម។

**ប្រភេទទី៣**: ជាការងារលំបាក ដូចជាការលីសែងសម្ភារៈសំណង់ ការលើកដាក់អីវ៉ាន់ធ្ងន់ៗ និងការងារឧស្សាហកម្មរ៉ែតាមតំបន់ដាច់ស្រយាលជាដើម។

- **វិធីធ្វើចំណាកស្រុកឬធ្វើទេសន្តរប្រវេសន៍ដោយស្របច្បាប់**

ករណីដែលជនចំណាកស្រុក/ជនទេសន្តរប្រវេសន៍ ចង់ធ្វើការងារស្របច្បាប់ ចាំបាច់ត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម ៖

១- ត្រូវអាយុយ៉ាងតិច១៨ឆ្នាំ។

២- ត្រូវមានលិខិតព្រមព្រៀងដែលមានចុះហត្ថលេខារបស់មាតាបិតាឬអ្នកអាណាព្យាបាល (បើជាស្ត្រី)។

៣- ត្រូវមានលិខិតឆ្លងដែនដែលមានសុពលភាព ដែលជាឯកសារស្របច្បាប់។ លិខិតឆ្លងដែននេះទាមទារឱ្យមានការបញ្ជាក់ទិដ្ឋាការការងារចេញដោយស្ថានទូតឬធារ:ធាវីនៃប្រទេសគោលដៅ។ លិខិតឆ្លងដែនដែលគ្មានទិដ្ឋាការការងារមិនអាចឱ្យអ្នកធ្វើការងារនៅប្រទេសគេបានឡើយ។

៤- **ទិដ្ឋាការការងារ**: ស្ថានទូតនៃប្រទេសគោលដៅ (ប្រទេសដែលទទួលឱ្យធ្វើការ) ប្រចាំនៅប្រទេសកម្ពុជា នឹងចេញទិដ្ឋាការការងារដោយបិទលើលិខិតឆ្លងដែន។ ទិដ្ឋាការនេះផ្តល់សិទ្ធិឱ្យស្នាក់នៅ និងធ្វើការងារដោយស្របច្បាប់នៅប្រទេសរបស់គេក្នុងរយៈពេលមួយមានកំណត់។ ដើម្បីសុំទិដ្ឋាការការងារ គេត្រូវមានប័ណ្ណការងារ និងកិច្ចសន្យាការងារ។

៣- **ប័ណ្ណការងារ**: ជាលិខិតអនុញ្ញាតឱ្យធ្វើការនៅប្រទេសគោលដៅ ដែលចេញដោយក្រសួងការងារនៃប្រទេសគោលដៅ។ ទីភ្នាក់ងារជ្រើសរើសឯកជន ដែលមានអាជ្ញាប័ណ្ណពីក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងប្រទេសបញ្ជូន នឹងជួយអ្នកក្នុងការស្នើសុំប័ណ្ណការងារពីប្រទេសគោលដៅ។

៤- **កិច្ចសន្យាការងារ**: ជាកិច្ចព្រមព្រៀងការងាររវាងពលករនិងថៅកែ ឬទីភ្នាក់ងារជ្រើសរើសពលករឯកជនដែលកំណត់ពីតួនាទីនិងភារកិច្ចដែលត្រូវបំពេញដោយភាគីទាំង២។

៥- **លិខិតបញ្ជាក់សុខភាព**: ជាឯកសារពេទ្យដែលចេញដោយពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃប្រទេសបញ្ជូន (ព្រះរាជាណាចក្រកម្ពុជា)។



▪ **ផលវិបាកចំពោះកុមារក្នុងការធ្វើចំណាកស្រុក**

យោងតាមអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ ជាទូទៅកុមារទាំងអស់ត្រូវទទួលបានការ ការពារសុវត្ថិភាព សុខុមាលភាព ដើម្បីជួយដល់ការអភិវឌ្ឍសម្បទាទាំង៤របស់កុមារ រួមមានចំណេះសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ព្រមទាំងការធានាបាននូវសុខភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍។ ពាក់ព័ន្ធទៅនឹងករណីចំណាកស្រុក បញ្ហាដែលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតគឺសុវត្ថិភាពកុមារ។ នៅពេលដែលមាតាបិតាធ្វើចំណាកស្រុកក្នុងប្រទេសឬក្រៅប្រទេស ភាគច្រើនពួកគេតែងយកកុមារជាបុត្រឱ្យទៅរស់នៅជាមួយ ជីដូនឬជីតាឬឱ្យនៅជាមួយសាច់ញាតិ ឬពេលខ្លះនៅជាមួយអ្នកជិតខាងជួយមើលការខុសត្រូវលើបុត្រជំនួសខ្លួន ដែលជាមូលហេតុធ្វើឱ្យកុមារបាត់បង់សិទ្ធិមូលដ្ឋានពេញលេញរបស់ខ្លួននិងមានករណីខ្លះក៏ជាកត្តារុញច្រានកុមារឱ្យធ្លាក់ខ្លួនជាជនរងគ្រោះក្នុងបទល្មើសណាមួយដោយអចេតនា ឬទទួលរងគ្រោះថ្នាក់ដោយសារការថែទាំពុំបានពេញលេញឬខ្វះភាពកក់ក្តៅ។ ទន្ទឹមនេះក៏មានកត្តារុញច្រាន និងហេតុផលដែលបណ្តាលឱ្យកុមារធ្វើចំណាកស្រុកជាមួយគ្រួសារ ដូចជា គ្មានជម្រើសសាច់ញាតិណាដែលល្អជាងឪពុកម្តាយ កុមារនៅតូចត្រូវនៅជាមួយឪពុកម្តាយ (ក្រោមអាយុ៣ឆ្នាំ) គ្មានថវិកាគ្រប់គ្រាន់ក្នុងការចំណាយឱ្យគេមើលថែទាំកូនជំនួស។

ឪពុកម្តាយគ្រប់រូបសុទ្ធតែចង់ថែទាំកូនឱ្យបានល្អបំផុត។ នៅពេលដែលពួកគាត់ធ្វើចំណាកស្រុកស្វែងរកការងារធ្វើ ពួកគាត់រមែងជួបការប្រឈមទៅនឹងបញ្ហាសុវត្ថិភាពផ្លូវអារម្មណ៍ កង្វះទីជម្រករស់នៅសមរម្យ ការបាត់បង់ទំនាក់ទំនងជាមួយសាច់ញាតិបងប្អូន សុវត្ថិភាពធ្វើដំណើរ សេរីភាពក្នុងការបញ្ចេញមតិយោបល់ ការប្រឈមទៅនឹងអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងការរំលោភបំពានក្នុងទម្រង់ផ្សេងៗ។ ការធ្វើចំណាកស្រុកដោយសម្រេចចិត្តយកកុមារទៅជាមួយអាចបង្កផលពិបាកជាច្រើនចំពោះកុមារដែលត្រូវរស់នៅឆ្ងាយពីស្រុកកំណើត បាត់បង់ការសិក្សា អាចប្រឈមនឹងការកេងប្រវ័ញ្ចពលកម្មកុមារ ប្រឈមនឹងជំងឺផ្សេងៗដោយគ្មានការព្យាបាល ការចាប់ខ្លួនពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចអន្តោប្រវេសន៍ ការធ្វើទារុណកម្ម និងអាចប៉ះពាល់ដល់អាយុជីវិត។

## ករណីសិក្សា

**ពូសោម** និង **មីងសាត** មានកូនតូចៗចំនួនពីរនាក់ដែលមានអាយុក្រោម១០ឆ្នាំ គឺ**សុខ**និង**សាន**។ ដោយបញ្ហាជីវភាព **ពូសោម និងមីងសាត** បានសម្រេចធ្វើចំណាកស្រុកទៅរកការងារនៅប្រទេសជិតខាង ដោយយកកូនតូច **សាន**ដែលមានអាយុ២ឆ្នាំ ទៅផ្ញើនឹងម្តាយជរាជួយមើលថែ និងយក**សុខ** ដែលមានអាយុ៧ ឆ្នាំទៅជាមួយខ្លួន។ **ពូសោម និងមីងសាត** បានធ្វើការនៅប្រទេសគោលដៅជាកម្មករពន្លះសាច់ត្រីធ្វើប្រហិត ក្នុងសិប្បកម្មមួយក្នុងប្រទេសគោលដៅ។ រៀងរាល់ថ្ងៃ **ពូសោម និងមីងសាត** បានទុកសុខឱ្យនៅលេងជាមួយ កូនកម្មករផ្សេងទៀតនៅក្នុងតំបន់ស្នាក់នៅ។

ការងាររបស់ពួកគាត់ទាំងពីរបានបន្តតាមទម្លាប់ប្រចាំថ្ងៃ រហូតដល់ពីរឆ្នាំ និងពិតជាទទួលបានកម្រៃផ្ញើមកជួយម្តាយម៉េម៉ាយជារៀងរាល់ខែ ព្រមទាំងអាចសន្សំបានប្រាក់ កាសមួយចំនួនយកមកសងកម្ចីធនាគារដែលពួកគាត់បានខ្ចីមកសង់ផ្ទះក្បឿងមួយខ្នងតូចក្នុងភូមិកំណើត។ ថ្ងៃមួយក្នុងឆ្នាំទីបី នៃការងារនៅក្រៅប្រទេស **សុខ**ជាកូនបានជឿតាមមិត្តភក្តិជាកូនកម្មករបន្ទប់ជួលជិតគ្នាទៅចូលរួមនាំទំនិញខុសច្បាប់ទៅប្រគល់ឱ្យក្រុមអ្នកលេងនៅទីប្រជុំជន ដើម្បីបានកម្រៃជួយម្តាយឪពុក។ **សុខ** មិនស្គាល់ទំនិញនោះជាអ្វីទេ ដឹងត្រឹមតែជាកញ្ចប់តូចៗដែលមានដុំក្រាមពណ៌សថ្លាតែប៉ុណ្ណោះ។ កម្រៃដែល**សុខ**ទទួលបានធ្វើឱ្យសុខសប្បាយចិត្តយ៉ាងខ្លាំង និងសុខចិត្តបន្តសកម្មភាពនោះជាលើកទីពីរជាមួយមិត្តភក្តិ។ តែលើកនេះ **សុខ**ត្រូវសមត្ថកិច្ចប្រចាំការនៅទីប្រជុំជនចាប់ខ្លួនបានពីបទជួញដូរគ្រឿងញៀនត្រូវបញ្ជូនទៅមណ្ឌលអប់រំកែប្រែនិងមិនអនុញ្ញាតចេញមករស់នៅជាមួយឪពុកម្តាយបានទេ។ **ពូសោម** និង**មីងសាត** ពិបាកចិត្តណាស់តែមិនអាចផ្តល់ដំណឹងមកក្រុមគ្រួសាររបស់ខ្លួនឡើយ។ ថ្ងៃបន្ទាប់ **ពូសោម**និង**មីងសាត** បានទទួលទូរស័ព្ទពីម្តាយនៅស្រុកប្រាប់ថា ដោយមានទឹកជំនន់ **សាន** កូនពៅរបស់គាត់បានចុះលេងទឹកហើយបានលង់ទឹកស្លាប់និងត្រូវបានយាយយកទៅបូជារួចរាល់ហើយ។ ដំណឹងដ៏ សែនវេទនាទាំងពីរផ្ទួនៗ បានធ្វើឱ្យ**មីងសាត**ធ្លាក់ខ្លួនមានជំងឺជាទម្ងន់ មិនអាចបន្តបំពេញការងារបាន។ ម្យ៉ាងទៀតដោយកំហុសរបស់កូនពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន **មីងសាត**មិនអាចទទួលបានកម្រៃព្យាបាលសុខភាពពីសិប្បកម្មដែលគាត់ធ្វើការងារឡើយ។ **ពូសោម**និង**មីងសាត** បានសម្រេចចិត្តសុំឈប់ពីការងារ រួចវិលត្រឡប់មកស្រុកកំណើតវិញទាំងពីរនាក់។

## ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ក្នុងក្របខណ្ឌតំបន់ ដើម្បីធានាដល់សិទ្ធិក្នុងការឆ្លើយតបទៅនឹងការធ្វើចំណាកស្រុកនិងទប់ស្កាត់អំពើជួញដូរមនុស្ស នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០ ប្រទេសមួយចំនួនបានសហការរៀបចំរួមគ្នាឱ្យមានពិធីសារស្តីពីការបង្ការទប់ស្កាត់ និងការដាក់ទណ្ឌកម្មទៅលើអំពើជួញដូរមនុស្ស ពិសេសស្ត្រីនិងកុមារ បន្ថែមលើខ្លឹមសារមហាសន្និបាតអង្គការសហប្រជាជាតិប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែននិងច្បាប់ស្តីពីទេសន្តប្រវេសន៍អន្តរជាតិ។

ព្រះរាជាណាចក្រកម្ពុជា បានរៀបចំប្រព័ន្ធយន្តការទប់ស្កាត់ឆ្លើយតបនិងដោះស្រាយបញ្ហាពាក់ព័ន្ធទៅនឹងការធ្វើចំណាកស្រុកនិងការទប់ស្កាត់អំពើជួញដូរមនុស្ស។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដើម្បីដឹកនាំសម្របសម្រួលការងារក្រសួងស្ថាប័នពាក់ព័ន្ធពង្រឹងប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តិក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ពាក់ព័ន្ធទៅនឹងក្របខណ្ឌអន្តរជាតិ ព្រះរាជាណាចក្រកម្ពុជាជាសមាជិកផ្តួចផ្តើមថ្នាក់រដ្ឋមន្ត្រីមហាអនុតំបន់មេគង្គដែលប្រឆាំងនឹងការជួញដូរ (ខំមីត

COMMIT) ដែលមានប្រទេសជាសមាជិកចំនួន៦រួមមាន កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ វៀតណាម បានចុះអនុស្សរណៈយោគយល់គ្នាក្នុងឆ្នាំ២០០៤ និងបានផ្តល់សច្ចាប័នលើពិធីសារប៉ាឡឺម៉ូ (Palermo) បង្កើតអនុស្សារណៈយោគយល់ទាក់ទងនឹងការងារជួញដូរមនុស្ស ហើយបានបង្កើតនីតិវិធីប្រតិបត្តិការស្តង់ដារ ដើម្បីផ្តល់ការគាំទ្រ និងការពារដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

## ខ- សកម្មភាពប្រតិបត្តិ

ចូរឆ្លើយសំណួរខាងក្រោម៖

១- តើមានមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យពូសោម និងមីងសាត ធ្វើចំណាកស្រុកឬធ្វើទេសន្តរប្រវេសន៍?

២- តើការធ្វើចំណាកស្រុករបស់ ពូសោម និងមីងសាត ទទួលបានលទ្ធផលសមតាមបំណងប្រាថ្នា របស់ពួកគាត់ដែរឬទេ? ហេតុអ្វី?

៣- ហេតុអ្វី បានជាសុខ កូន របស់ពូសោម និងមីងសាត ធ្លាក់ខ្លួនចូលរួមដឹកជញ្ជូនគ្រឿងញៀន?

៤- តើសុភាសិតខ្មែរ ថា "ប្រាក់ក៏បង់ ថង់ក៏ដាច់" អាចប្រើក្នុងក្នុងករណី ដែរឬទេ? ហេតុអ្វី?

## ច- កិច្ចការផ្ទះ

ក- ចូរឆ្លើយសំណួរខាងក្រោម៖

១- តើការធ្វើចំណាកស្រុកផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ?

២- តើការធ្វើចំណាកស្រុកស្របច្បាប់ និងមិនស្របច្បាប់ ខុសគ្នាដូចម្តេចខ្លះ?

ខ- ចូរអ្នកស្វែងរកករណីដែលទាក់ទៅនឹងការធ្វើចំណាកស្រុកទៅក្រៅប្រទេស តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ឬប្រភពផ្សេងៗ រួចសរសេរអត្ថបទសង្ខេបពីរឿងនោះដើម្បីចែករំលែកដល់មិត្តក្នុងថ្នាក់។

## ការវាយតម្លៃ លទ្ធផលសិក្សាជំពូកទី៧

១- ចូរគូសសញ្ញា (✓) នៅក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់

- ការធ្វើបន្លាស់ទីរបស់មនុស្សម្នាក់ពីកន្លែងដែលកំពុងរស់នៅ ទៅកាន់ទីកន្លែងផ្សេងទៀតជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍ គឺ

  □ ទេសន្តរប្រវេសន៍ □ អំពើរត់ពន្ធមនុស្ស □ អំពើជួញដូរមនុស្ស □ អំពើអាជីវកម្មផ្លូវភេទ

- អំពើរត់ពន្ធមនុស្សជាបទល្មើសដែលកើតមានឡើង ដោយ

  □ ត្រូវបានគេបង្ខំ □ ស្ម័គ្រចិត្ត □ ការកេងប្រវ័ញ្ច □ អំពើជួញដូរមនុស្ស

- មូលហេតុពីរនៃការធ្វើចំណាកស្រុក មាន កត្តាជំរុញ និង កត្តា

  □ ខ្វះការងារធ្វើ □ វិបត្តិគ្រួសារ □ បញ្ហាសុខភាព □ កត្តាអូសទាញ

- កិច្ចព្រមព្រៀងការងាររវាងកម្មករ និងថៅកែ ឬ ទីភ្នាក់ងារជ្រើសរើសឯកជន ដែលកំណត់ពីតួនាទី និងភារកិច្ចដែលត្រូវបំពេញដោយភាគីទាំង២ ហៅថា

  □ លិខិតបញ្ជាក់សុខភាព □ កិច្ចសន្យាការងារ □ ប័ណ្ណការងារ □ ទិដ្ឋាការការងារ

២- ចូរផ្គូផ្គងផ្នែក ក និងផ្នែក ខ ឱ្យបានត្រឹមត្រូវ

| ក | ខ | ចម្លើយ |
|---|---|---|
| ១- អំពើរត់ពន្ធមនុស្ស | ក- ការចាកចេញពីផ្ទះរបស់ប្រជាជនដោយស្ម័គ្រចិត្តទៅទីកន្លែងណាមួយ ឬទីក្រុង ឬខេត្ត ឬប្រទេសណាមួយផ្សេងទៀត។ | ១→ ..... |
| ២- ការធ្វើទេសន្តរប្រវេសន៍ | ខ- ការធ្វើអាជីវកម្មដើម្បីទទួលបានហិរញ្ញវត្ថុក្នុងការនាំជនណាម្នាក់ឱ្យចូលទៅក្នុងរដ្ឋមួយដោយខុសច្បាប់។ | ២→ ..... |
| ៣- ប័ណ្ណការងារ | គ- លិខិតអនុញ្ញាតឱ្យធ្វើការដែលចេញដោយក្រសួងការងារនៃប្រទេសគោលដៅ។ | |
| ៤- លិខិតឆ្លងដែនដែលមានសុពលភាព | ឃ-ឯកសារស្របច្បាប់ដែលអាចឱ្យអ្នកធ្វើដំណើរទៅប្រទេសផ្សេង។ | |

៣- ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ ៖

- ការលក់ដូរសរីរាង្គ បានផ្តល់ផលអាក្រក់ដល់ជីវិតរស់នៅប្រចាំថ្ងៃរបស់ជនរងគ្រោះ............ និងសង្គម។
- ជនខិលខូចឬជនសង្ស័យតែងតែប្រើគ្រប់វិធីដើម្បីអូសទាញជនងាយរងគ្រោះដែលមានជីវភាព................ខ្វះចំណេះដឹង មិនយល់ពីផ្នែកវេជ្ជសាស្ត្រឱ្យលក់សរីរាង្គឱ្យខ្លួន។

៤- តើជនដែលរត់ពន្ធមនុស្សនិងជួញដូរមនុស្ស ត្រូវមានទោសដូចម្តេចខ្លះ ?

# លំនាំនៃការបង្រៀន
## ស្តីពី
## ការបង្ការ ការទប់ស្កាត់ អំពើជួញដូរមនុស្ស




មេរៀនទាំង១៩ ដែលមានក្នុងជំពូកទាំង៧នៃសៀវភៅស្តីពី «**ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន**»សម្រាប់ការអប់រំនៅកម្រិតបឋមសិក្សា បានបញ្ចូលទម្រង់បែបបញ្ញត្តិសិក្សាទៅក្នុងដំណើរនៃការអភិវឌ្ឍសម្បទាទាំងបួនរបស់យុវជនវ័យជំទង់នៅក្នុងការអប់រំពាក់ព័ន្ធទៅនឹងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើរត់ពន្ធមនុស្ស ដើម្បីលើកទឹកចិត្តយុវវ័យគ្រប់រូបអាចទទួលបានចំណេះដឹងសម្បទាពាក់ព័ន្ធទៅនឹងបរិបទនៃអំពើជួញដូរមនុស្សក៏ដូចជាបទល្មើសដែលមានក្នុងតថភាពសង្គមឱ្យមានសមត្ថភាពប្រើបំណិនចងចាំ បំណិនត្រិះរិះពិចារណា បំណិនបង្កើតដំណោះស្រាយសមស្របទៅតាមកាលៈទេសៈនិងស្ថានភាព សម្រាប់ការចូលរួមសកម្មឈានទៅសម្រេចគោលដៅអភិវឌ្ឍខ្លួនប្រកបដោយចរិយាសម្បទាប្រើប្រាស់សិទ្ធិមនុស្ស/កុមារជាជនបង្គោលក្នុងការកសាងគ្រួសារ និងសហគមន៍ ចៀសផុតហានិភ័យនានាដែលបង្កឡើង

ដោយអំពើជួញដូរមនុស្ស/កុមារ និងអំពើរត់ពន្ធមនុស្ស។ មិនតែប៉ុណ្ណោះ ផ្អែកលើសម្បទាខាងលើ អ្នកសិក្សាអាចធ្វើការវិនិច្ឆ័យទៅលើអំពើឬសកម្មភាពរបស់ជនខិលខូចឬជនសង្ស័យដើម្បីចូលរួមការពារទប់ស្កាត់ទង្វើអមនុស្សធម៌ ដែលបង្កដោយអំពើជួញដូរមនុស្សគ្រប់រូបភាព ដើម្បីសុវត្ថិភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ សុខដុមនីយកម្មនិងឧត្តមភាពជាកោសិកាសង្គមចូលរួមសកម្មក្នុងដំណើរអភិវឌ្ឍធនធានមនុស្សឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍជាតិឆ្នាំ២០៣០-២០៥០។

គ្រប់មេរៀនក្នុងសៀវភៅនេះបានរៀបចំឡើងក្នុងលំដាប់ឯកភាពរួមមាន លទ្ធផលរំពឹងទុក សកម្មភាពផ្តើម ពាក្យគន្លឹះ អត្ថបទអំណាន សម្រង់ច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ សកម្មភាពប្រតិបត្តិ និងកិច្ចការផ្ទះ។

ការឈានទៅសម្រេចលទ្ធផលរំពឹងទុកនៃមេរៀននីមួយៗ ការបង្រៀនទាមទារឱ្យបុគ្គលិកអប់រំប្រើសិល្បៈអប់រំក្នុងការបង្កើតបរិយាកាសទាក់ទាញឱ្យអ្នកសិក្សាអាចទទួលស្គាល់ថា បញ្ហាមានពិតនៅក្នុងតថភាពសង្គម ក្នុងបរិបទប្រទេស តំបន់ និងសាកលលោក។ ទន្ទឹមនេះ តាមរយៈអត្ថបទអំណាននៃមេរៀននីមួយៗដែលមានជូនភ្ជាប់ជាមួយនូវករណីសិក្សា បានផ្សារភ្ជាប់ទៅនឹងច្បាប់ជាតិ អន្តរជាតិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ អាចប្រើជាជំនួយដល់អ្នកសិក្សាឆ្លុះបញ្ចាំងពីការយកចិត្តទុកដាក់ និងឆន្ទៈមុះមុតដាច់ខាតរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដើម្បីមនុស្សជាតិ ក៏ដូចជាដើម្បីធនធានមនុស្សកម្ពុជា។

សកម្មភាពប្រតិបត្តិនៅតាមមេរៀននីមួយៗ មានបំណងលើកទឹកចិត្តអ្នកសិក្សាឱ្យប្រើបំណិនចងចាំទៅលើពុទ្ធិដែលទទួលបានតាមរយៈពាក្យគន្លឹះ អត្ថបទអំណាន ខ្លឹមសារច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដើម្បីគាំទ្រទៅលើការអភិវឌ្ឍបំណិនត្រិះរិះពិចារណាឆ្លើយទៅនឹងសំណួរត្រួតពិនិត្យ។ មិនតែប៉ុណ្ណោះ អ្នកសិក្សាអាចប្រើបំណិនត្រិះរិះពិចារណា ដើម្បីបង្កើតបានដំណោះស្រាយដែលមានអំណះអំណាងត្រឹមត្រូវពាក់ព័ន្ធទៅនឹងករណីសិក្សាឬការដើរតួតាមស្ថានភាពតម្រូវ។

រីឯការងារផ្ទះក៏បានលើកទឹកចិត្ត និងជំរុញឱ្យអ្នកសិក្សាប្រើបំណិនត្រិះរិះពិចារណា គួបផ្សំបំណិន ស្រាវជ្រាវបន្ថែម ដើម្បីបំពេញនូវកាតព្វកិច្ចសិក្សាតាមមេរៀននីមួយៗ និងដើម្បីអភិវឌ្ឍសមត្ថភាពកសាង ចរិយាសម្បទាក្លាយជាជនបង្គោលវ័យក្មេងដ៏ប៉ិនប្រសប់ ចូលរួមអនុវត្តការបង្ការទប់ស្កាត់គ្រោះថ្នាក់បង្កដោយអំពើជួញដូរមនុស្សគ្រប់ទម្រង់ដែលជនខិលខូចឬជនសង្ស័យបាន និងមានបំណងប្រព្រឹត្តមកលើយុវជន ឬកុមារ។

អាស្រ័យហេតុនេះ លំនាំនៃការបង្រៀនស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ទាមទារឱ្យប្រើតាមគោលវិធីសិស្សមជ្ឈមណ្ឌល ដែលគ្រូបង្រៀនដើរតួនាទីជាអ្នកសម្របសម្រួលដ៏មាន

ប្រសិទ្ធភាព ជាទីប្រឹក្សាយោបល់របស់អ្នកសិក្សាលើអត្ថបទអំណាន ករណីសិក្សា ផលនៃការស្រាវជ្រាវបន្ថែម ការធ្វើបទបង្ហាញ និងការអនុវត្តសមត្ថភាពពាំនាំព័ត៌មានផ្សព្វផ្សាយបន្តតាមទម្រង់មិត្តអប់រំមិត្ត។

ចំណុចគួរចងចាំសម្រាប់លំនាំនៃការបង្រៀនដែលទទួលបានលទ្ធផលពីអ្នកសិក្សា រួមមាន៖



# ជំនួយស្មារតីសម្រាប់ការបង្រៀន
## ស្ដីពី
## ការបង្ការ ការទប់ស្កាត់ អំពើជួញដូរមនុស្ស

| លំដាប់លំនាំនៃការបង្រៀន | សកម្មភាព | អត្ថប្រយោជន៍ |
|---|---|---|
| **ក- លទ្ធផលរំពឹងទុក** | - កំណត់វត្ថុបំណងមេរៀនពាក់ព័ន្ធទៅនឹងគោលដៅអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា<br>- ប្រាប់ពីវត្ថុបំណងខាងលើដល់អ្នកសិក្សា។ | - មានគោលដៅច្បាស់លាស់<br>- កំណត់វិធីអនុវត្តចំគោលដៅ<br>- កំណត់ការត្រួតពិនិត្យ<br>- លទ្ធផលរបស់អ្នកសិក្សាដែលឆ្លើយតបលទ្ធផលរំពឹងទុក។ |
| **ខ- សកម្មភាពផ្ដើម** | - ផ្ដល់សំណួរផ្ដោតលើចំណេះដឹងទូទៅពាក់ព័ន្ធរូបភាព<br>- ផ្ដល់សំណួររំលឹកមេរៀនចាស់<br>- ផ្ដល់សំណួរបំផុសពាក់ព័ន្ធទៅនឹង គោលដៅមេរៀនថ្មី<br>- ផ្ដល់ពុទ្ធិតាមទម្រង់ដើមឈើបញ្ហា។ | - ត្រួតពិនិត្យលទ្ធភាពពាក់ព័ន្ធ បំណិនសង្កេតនិងចំណេះដឹងទូទៅពាក់ព័ន្ធប្រធានបទ<br>- ត្រួតពិនិត្យលទ្ធផលពុទ្ធិសម្បទាតាមរយៈបំណិនចងចាំ<br>- ពង្រឹងបំណិនត្រិះរិះពិចារណារបស់អ្នកសិក្សា។ |
| **ខ.១- សិក្សាតាមរូបភាព** | - ឱ្យអ្នកសិក្សាសង្កេតរូបភាព<br>- ផ្ដល់សំណួរពីងាយទៅលំបាក<br>- ឱ្យអ្នកសិក្សាឆ្លើយនឹងសំណួរ<br>- លើកទឹកចិត្តអ្នកសិក្សាឱ្យបង្ហាញអត្ថន័យនៃរូបភាព។ | - ការទាញអារម្មណ៍របស់អ្នកសិក្សាឱ្យចង់រៀនមេរៀននិងឱ្យឆាប់យល់អត្ថបទមេរៀន។ |
| **ខ.២- រំលឹកមេរៀនចាស់** | - ផ្ដល់សំណួរពាក់ព័ន្ធការយល់ដឹងនិងការចងចាំខ្លឹមសារគោលនៃមេរៀនកន្លងមក<br>- ឱ្យអ្នកសិក្សាឆ្លើយសំណួរជាបុគ្គលឬជាក្រុម។ | - អ្នកសិក្សាអាចប្រើបំណិនចងចាំ បំណិនបកស្រាយចម្លើយនិងបំណិនត្រិះរិះពិចារណាដោះស្រាយបញ្ហានិងការសម្រេចចិត្ត |

| | | |
|---|---|---|
| | | - ផ្សព្វផ្សាយទៅដល់គ្រួសារ និងអ្នកនៅជុំវិញខ្លួន។ |
| **ខ.៣- សំណួរបំផុស** | - ផ្តល់សំណួរតាមទម្រង់ភ្ជាប់ខ្លឹមសារទៅរូបភាព ឬភ្ជាប់ខ្លឹមសារទៅប្រធានបទ<br>- ឱ្យអ្នកសិក្សាអាន ហើយសាកល្បងឆ្លើយសំណួរ<br>- ឱ្យអ្នកសិក្សាស្ម័គ្រចិត្ត ឬជ្រើសរើសអ្នកសិក្សាណាម្នាក់ឆ្លើយសំណួរ<br>- សម្របសម្រួលចម្លើយអ្នកសិក្សា<br>- លើកសរសើរអ្នកសិក្សាដែលក្លាហានចូលរួមឆ្លើយ។ | - ស្វាបស្ទង់ចំណេះដឹងរបស់អ្នកសិក្សា<br>- ពង្រឹងបំរុងប្រយ័ត្នរបស់អ្នកសិក្សា<br>- ពង្រឹងបំណិនសម្បទាក្នុងការត្រិះរិះពិចារណាឆ្ពោះទៅរកខ្លឹមសារមេរៀនថ្មី។ |
| **ខ.៤- បង្កើតដើមឈើបញ្ហាដែលទាញទៅរកពុទ្ធិថ្មីនៃមេរៀនថ្មី** (អាស្រ័យតាមលទ្ធភាព ធនធាន និងពេលវេលា) | - បែងចែកអ្នកសិក្សាជាក្រុមតូចៗ រួចឱ្យក្រដាសដែលមានរូបដើមឈើមួយដើម (មានដើម ឫស និងមែក)<br>- ឱ្យតំណាងក្រុមអ្នកសិក្សាសរសេរបញ្ហាណាមួយនៅលើដើមឈើ រួចឱ្យក្រុមអ្នកសិក្សាពិភាក្សាគ្នាដើម្បីរកឫសគល់នៃបញ្ហានោះ<br>- ប្រាប់អ្នកសិក្សាថាដើមតំណាងឱ្យបញ្ហាដែលត្រូវរកឫសគល់នៃបញ្ហាដោយសរសេរនៅត្រង់ឫស និងមែកតំណាងឱ្យផលវិបាក បន្ទាប់មកឱ្យរកផលប៉ះពាល់ដែលកើតចេញពីឫសនោះតើឫសនោះអាចបង្កផលអវិជ្ជមានអ្វីខ្លះ? | - លើកទឹកចិត្តនិងបង្កើតទម្លាប់ធ្វើការជាក្រុម<br>- អភិវឌ្ឍបំណិនត្រិះរិះពិចារណា ការសម្រេចចិត្ត កំណត់ឫសគល់បញ្ហាការវិភាគពីផលប៉ះពាល់ ការស្វែងរកដំណោះស្រាយបញ្ហានិងការចេះសម្របសម្រួលប្រមូលការគាំទ្រពីសមាជិកក្រុម និងសមូហភាព។ |

| | | |
|---|---|---|
| | - នៅពេលក្រុមអ្នកសិក្សារកឃើញផលអវិជ្ជមានឬផលប៉ះពាល់ហើយត្រូវដាក់ឱ្យពិភាក្សារួមគ្នា តើគេត្រូវធ្វើដូចម្ដេចទើបអាចលុបបំបាត់បញ្ហាទាំងនោះបាន?<br>- សម្របសម្រួលដំណោះស្រាយដែលអ្នកសិក្សារកឃើញ។ | |
| **គ- ពាក្យគន្លឹះ** | - ផ្ដល់សំណួរពាក់ព័ន្ធការយល់បឋមរបស់អ្នកសិក្សាលើពាក្យសំខាន់ៗដែលបានប្រើក្នុងអត្ថបទអំណាន<br>- ផ្ដល់ឱកាសដល់អ្នកសិក្សាស្វែងរកចម្លើយនៅក្នុងវចនានុក្រមខ្មែរឬឯកសារផ្សេងៗ<br>- ផ្ដល់ចម្លើយត្រឹមត្រូវពាក់ព័ន្ធខ្លឹមសារនៃពាក្យគន្លឹះទាំងនោះ។ | - ពង្រឹងសមត្ថភាពស្វែងយល់ខ្លឹមសារនៃពាក្យគន្លឹះ<br>- អភិវឌ្ឍសមត្ថភាពស្វែងរក និងផ្ទៀងផ្ទាត់ចម្លើយដែលមានក្នុងវចនានុក្រមខ្មែរ<br>- អភិវឌ្ឍសមត្ថភាពយល់ដឹងខ្លឹមសារអត្ថបទអំណាន។ |
| **ឃ- អត្ថបទអំណាន** | - អានឱ្យអ្នកសិក្សាស្ដាប់<br>- ជ្រើសរើសអ្នកសិក្សាម្នាក់អាន<br>- ជ្រើសរើសអ្នកសិក្សាអានបណ្ដាក់<br>- ផ្ដល់សំណួរបំផុសសម្រាប់ការស្វែងយល់ខ្លឹមសារអត្ថបទអំណាន និងស្វែងរកចម្លើយត្រឹមត្រូវ<br>- សម្របសម្រួលនិងណែនាំការអាន ទាំងការបន្លឺស័ព្ទ ការកំណត់អត្ថន័យសំខាន់ និងដង្ហើមនៃការអាន។ | - អភិវឌ្ឍសមត្ថភាពអំណានត្រឹមត្រូវ<br>- ជំរុញវប្បធម៌ស្រឡាញ់អំណាន<br>- អភិវឌ្ឍសមត្ថភាពកំណត់គោលដៅស្វែងយល់តាមរយៈអត្ថបទអំណាន |

| | | |
|---|---|---|
| ឃ.១- សកម្មភាពរួមនៃអំណាន | - ឱ្យអ្នកសិក្សាអានអត្ថបទមេរៀនដោយស្ងៀមស្ងាត់<br>- ណែនាំពីរបៀបនៃការអានអត្ថបទ (អានលើកដាក់សំឡេង អានលឿនហើយយល់ន័យអត្ថបទ អានលឿនហើយឆាប់យល់អត្ថន័យ)<br>- ណែនាំពីវិធីស្វែងយល់ន័យរបស់អត្ថបទ<br>- ផ្តល់សំណួរបញ្ជាក់ការយល់ដឹងលើអត្ថបទមេរៀន<br>- ឱ្យអ្នកសិក្សាសង្ខេបមេរៀន<br>- សម្របសម្រួលនិងណែនាំចំណុចខ្វះខាត<br>- លើកទឹកចិត្តអ្នកសិក្សាដែលខំអានអត្ថបទមេរៀន។ | - ទទួលបានចំណេះដឹងបទពិសោធ និងទ្រឹស្តីថ្មី<br>- យល់ដឹងពីស្ថានភាពសង្គម និងពិភពលោក<br>- បណ្តុះការគិតពិចារណាទៅលើការអនុវត្តក្នុងការរស់នៅតាមរយៈអត្ថបទអំណាន។ |
| ឃ.២- ជម្រើសវិធីអានផ្ទាល់ | - ឱ្យអ្នកសិក្សាអានបណ្តាក់គ្នាពីម្នាក់ទៅម្នាក់តាមវគ្គ<br>- បែងចែកអត្ថបទ ឬមេរៀនទាំងមូលជា៣ ឬ៤វគ្គ រួចបង្កើតសំណួរសម្រាប់វគ្គនីមួយៗដើម្បីអ្នកសិក្សាមុនពេលអានវគ្គទាំងនោះដើម្បីស្វែងរកចម្លើយ<br>- ផ្តល់សំណួរដែលបានត្រៀមមុនចាប់ផ្តើមឱ្យអ្នកសិក្សាអានវគ្គនីមួយៗ<br>- ពេលបញ្ចប់អំណាន ហៅអ្នកសិក្សា២ ឬ៣នាក់ឆ្លើយសំណួរ<br>- អាចបន្តការផ្តល់ចម្លើយរហូតដល់ការអានអត្ថបទចប់ ឬមេរៀនចប់។ | - ពង្រឹងសមត្ថភាពប្រុងប្រយ័ត្នរបស់អ្នកសិក្សាបានល្អ<br>- អភិវឌ្ឍនិងពង្រឹងសមត្ថភាពអំណានត្រឹមត្រូវនិងស្វែងរកចម្លើយឬចំណុចសំខាន់ៗនៅក្នុងមេរៀនដោយខ្លួនឯង។ |

| | | |
|---|---|---|
| ឃ.៣- ជម្រើសវិធីអានជាដៃគូ | - ប្រាប់មេរៀនដែលត្រូវរៀនរួចសួរសំណួរថា"តើប្អូនចង់ដឹង ឬចង់បានព័ត៌មានដើម្បីបំបាត់ភាពស្រពេចស្រពិលទាក់ទងទៅនឹងមេរៀនថ្មីនោះ ដែរឬទេ?"<br>- កត់សំណួររួចសរសេរនៅលើក្ដារខៀន<br>- ប្រាប់ចំណុចឬគោលដៅឱ្យអានមេរៀន ដើម្បីឆ្លើយសំណួរ<br>- ឱ្យសិទ្ធិអ្នកសិក្សាជ្រើសរើសចាប់ដៃគូធ្វើអំណានដោយកំណត់អ្នកត្រូវអានវគ្គទីមួយនិងសង្ខេប ហើយម្នាក់ទៀតជាដៃគូជាអ្នកបង្កើតសំណួរពីរឬបីសួរទៅកាន់ដៃគូទាក់ទងការសង្ខេបនៃវគ្គនោះ<br>- ឱ្យអ្នកសិក្សាដែលជាដៃគូចាប់ផ្ដើមអានវគ្គទី២ ឬទី៣ តែម្ដងនេះអ្នកដែលអាន និងសង្ខេបត្រូវដើរតួនាទីជាអ្នកឆ្លើយសំណួរវិញម្ដង<br>- ឱ្យអ្នកសិក្សាក្នុងថ្នាក់ផ្ទៀងផ្ទាត់អំណាន ចម្លើយ និងផ្ដល់យោបល់បន្ថែមដែលត្រឹមត្រូវ<br>- ឱ្យអ្នកសិក្សាធ្វើរបៀបនេះបន្តបន្ទាប់រហូតដល់ចប់មេរៀន។ | - យល់ពីរបៀបសង្ខេបខ្លឹមសារ អត្ថបទដែលមិនឃ្លាតឆ្ងាយគោលដៅនៃវត្ថុបំណងមេរៀន<br>- ចេះបង្កើតសំណួរដោយបំផុសការរកមើលន័យសំខាន់ៗពាក់ព័ន្ធ<br>- ពង្រឹងបំណិនត្រិះរិះពិចារណា ក្នុងការបង្កើតសំណួរ និងសង្ខេបអត្ថបទ។ |
| ឃ.៤- ករណីសិក្សា | - ឱ្យអ្នកសិក្សាម្នាក់ៗសង្កេតរូបភាព<br>- សួរសំណួរពីងាយទៅលំបាក<br>- ឱ្យអ្នកសិក្សាអានករណីសិក្សាហើយត្រៀមគំនិតឆ្លើយសំណួរ | - សមត្ថភាពវិនិច្ឆ័យស្ថានភាព តថៈក្នុងសង្គម<br>- អភិវឌ្ឍបំណិនត្រិះរិះពិចារណាដោះស្រាយបញ្ហានិង |

| | | |
|---|---|---|
| | - សួរសំណួរបញ្ជាក់ពីការយល់ដឹងពីករណីសិក្សា (សំណួរអាចសួរមុនអានអត្ថបទ)<br>- សម្របសម្រួលការឆ្លើយសំណួររបស់អ្នកសិក្សា។ | ការសម្រេចចិត្ត<br>- ផ្សព្វផ្សាយទៅដល់គ្រួសារនិងអ្នកនៅជុំវិញខ្លួន។ |
| **ឃ.៥- ច្បាប់និងបទដ្ឋានពាក់ព័ន្ធ** | - ប្រាប់ពីច្បាប់ឬបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលមានជាធរមានពាក់ព័ន្ធនឹងអត្ថបទមេរៀន និងករណីសិក្សានៅក្នុងមេរៀន<br>- ឱ្យស្វែងរកច្បាប់និងបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធអត្ថបទនិងករណីសិក្សា<br>- ឱ្យអ្នកសិក្សាអានសាចុះសាឡើងដើម្បីចងចាំ។ | - មានចំណេះដឹងអំពីច្បាប់និងបទដ្ឋានគតិយុត្តផ្សេងៗកម្រិតជាតិ និងអន្តរជាតិ<br>- គោរពនិងអនុវត្តតាមច្បាប់<br>- ផ្សព្វផ្សាយដល់អ្នកនៅជុំវិញខ្លួន និងសហគមន៍<br>- សង្គមមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់។ |
| **ង- សកម្មភាពប្រតិបត្តិ** | - អំណានសំណួរ<br>- ឱ្យផ្ទៀងផ្ទាត់សំណួរទៅនឹងពុទ្ធិដែលទទួលបានក្នុងអត្ថបទអំណាន<br>- ឱ្យជ្រើសរើសពាក្យមកបំពេញល្បះឱ្យមានន័យពេញលេញត្រឹមត្រូវ<br>- ឱ្យសម្តែងតួ។ល។ | - ពង្រឹងសមត្ថភាពចងចាំបានយូរ<br>- ធានាលទ្ធផលការសិក្សាពេញលេញពាក់ព័ន្ធទៅនឹងប្រធានបទមេរៀន<br>- លើកកម្ពស់លទ្ធភាពជាជនបង្គោល។ |
| **ង.១- ការឆ្លើយសំណួរ** | - ឱ្យអ្នកសិក្សាអានសំណួរ ហើយឱ្យឆ្លើយជាបុគ្គល<br>- ឱ្យអ្នកសិក្សាផ្សេងទៀតផ្ទៀងផ្ទាត់និងបង្ហាញចម្លើយរបស់ខ្លួន<br>- សម្របសម្រួលចម្លើយ<br>- ប្រមូលកិច្ចការរបស់អ្នកសិក្សាទៅត្រួតពិនិត្យនិងផ្តល់កំណែ។ | - ពង្រឹងកម្រិតយល់ដឹងរបស់អ្នកសិក្សា<br>- វាយតម្លៃវិធីបង្រៀន<br>- កំណត់គោលដៅច្បាស់លាស់សម្រាប់ការបង្រៀននិងបំពេញបន្ថែមចំណុចដែលអ្នកសិក្សាមិនទាន់យល់<br>- កែលម្អវិធីបង្រៀន។ |

| | | |
|---|---|---|
| **ង.២- ការសម្តែងតួ** | - បង្ហាញប្រធានបទនិងប្រាប់ពីគោលដៅអនុវត្ត<br>- ចែកអ្នកសិក្សាជាក្រុមដោយមានការគោរពសមភាពយេនឌ័រ ហើយឱ្យក្រុមនីមួយៗហ្វឹកហាត់ធ្វើសកម្មភាពក្នុងក្រុម<br>- ឱ្យគ្រប់ក្រុមឡើងសម្តែងតួនិងក្រុមដទៃទៀតសង្កេតនិងផ្តល់យោបល់ជួយកែលម្អ<br>- កំណត់ពេលវេលាសមស្របក្នុងពេលឡើងសម្តែងតួ។ | - បង្កើនការយល់ដឹងដូចជាឱ្យយកទ្រឹស្តីដែលបានរៀនទៅអនុវត្ត<br>- ពង្រឹងសមត្ថភាពអនុវត្តជាក់ស្តែង<br>- បង្កើនភាពក្លាហាននិងចេះរួមសាមគ្គីធ្វើការជាក្រុម។ |
| **ច- កិច្ចការផ្ទះ** | - ផ្តល់សំណួរត្រួតពិនិត្យពេលចប់មេរៀន<br>- កំណត់ពេលវេលាប្រមូល<br>- កែចម្លើយនៃកិច្ចការផ្ទះរបស់អ្នកសិក្សា និងផ្តល់លទ្ធផលកំណែតាមពេលវេលាកំណត់ជាពិសេសពេលចាប់ផ្តើមមេរៀនថ្មី<br>- អាចឱ្យអ្នកសិក្សាដៃគូ ធ្វើកំណែនិងផ្តល់ការវាយតម្លៃ។ | - ពង្រឹងការគោរពវិន័យ<br>- បង្កើតបំណិនស្រាវជ្រាវបន្ថែម<br>- ពង្រឹងវប្បធម៌អំណានបន្ថែម<br>- ពង្រឹងសមត្ថភាពនិងបំណិនវាយតម្លៃ<br>- បង្កើតវប្បធម៌មិត្តអប់រំមិត្តនិងការទទួលស្គាល់កំហុសសម្រាប់ការកែលម្អ។ |
| **ច.១- ការឆ្លើយសំណួរ** | - ដាក់សំណួរឱ្យធ្វើការស្រាវជ្រាវនិងធ្វើនៅផ្ទះ<br>- ឱ្យអ្នកសិក្សាផ្តល់អត្ថបទចម្លើយទាន់ពេលវេលាកំណត់<br>- កែកិច្ចការផ្ទះរបស់អ្នកសិក្សា<br>- សម្របសម្រួលចម្លើយឱ្យមានភាពត្រឹមត្រូវ។ | - បណ្តុះចំណេះដឹងវាយតម្លៃនិងស្វ័យវាយតម្លៃកម្រិតយល់ដឹងរបស់សិស្ស<br>- ដឹងពីសមត្ថភាពសិស្ស<br>- វាយតម្លៃវិធីបង្រៀនរបស់គ្រូ<br>- ឆ្លុះបញ្ចាំងការបង្រៀនឡើងវិញនូវចំណុចដែលសិស្សមិនទាន់យល់<br>- កែលម្អវិធីបង្រៀនឱ្យមានប្រសិទ្ធភាព។ |

| | | |
|---|---|---|
| ច.២- ការសម្ភាសន៍ | - ដាក់ប្រធានបទពាក់ព័ន្ធមេរៀន ឱ្យស្វែងរកព័ត៌មាន<br>- ឱ្យអ្នកសិក្សាត្រៀមសំណួរជាមុន<br>- ជួយសម្របសម្រួលសំណួរ ដែលរៀបរៀងដោយអ្នកសិក្សា<br>- ឱ្យសរសេររបាយការណ៍សង្ខេប ដើម្បីត្រៀមឡើងបង្ហាញ<br>- ឱ្យចងក្រងរបាយការណ៍ទុក ក្នុងបណ្ណាល័យ។ | - ភាពឈ្លាសវៃក្នុងការ ប្រមូលព័ត៌មានពិតក្នុង សហគមន៍<br>- បង្កើតបំណិនស្រាវជ្រាវនិង ដោះស្រាយបញ្ហាដែលអាច កើតមានចំពោះខ្លួន<br>- បង្កើតបំណិនចងក្រង របាយការណ៍និងស្នាដៃ។ |

## កំណត់សម្គាល់បន្ថែម

ផ្អែកតាមជំនួយស្មារតីខាងលើ ការបង្រៀនអាចអនុវត្តបានតាមស្ថានភាពជាក់ស្តែងដូចជា ការបង្រៀនមួយជំពូកក្នុងមួយពេល ឬមួយជំពូកសម្រាប់រយៈពេលពីរលើកជាដើម តាមទម្រង់សិក្សាដោយបណ្តុំអ្នកសិក្សាដែលទទួលបន្ទុកតាមមេរៀន។

ឧទាហរណ៍: ការសិក្សា១ពេល១ជំពូក ដោយគ្រូអាចបែងចែកអ្នកសិក្សាជាក្រុមឱ្យទទួលបន្ទុកអាន១ មេរៀន រួចធ្វើការបកស្រាយប្រាប់ពីខ្លឹមសារមេរៀននោះនៅក្នុងថ្នាក់ បន្ទាប់មកអាចសួរសំណួរដែលមានក្នុងផ្នែកការងារប្រតិបត្តិនៃមេរៀននោះ ឱ្យមិត្តក្នុងក្រុមផ្សេងទៀតឆ្លើយ។

ដើម្បីធានាបានលទ្ធផលនៃការចូលរួមបង្ការ ទប់ស្កាត់ អំពើជួញដូរមនុស្សគ្រប់ទម្រង់ ដើម្បីសុខសុវត្ថិភាព និងអនាគតភ្លឺថ្លារបស់យុវជននិងកុមារ គ្រប់មេរៀនក្នុងសៀវភៅ "ការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំនៃការបង្រៀន" គប្បីត្រូវបានបង្រៀននិងរៀន និងគប្បីត្រូវបានជ្រើសរើសដាក់បញ្ចូលជាប្រធានបទសម្រាប់ការវាយតម្លៃនានា ដូចជាប្រឡងប្រចាំខែ ប្រចាំឆមាស ប្រឡងជ្រើសរើសសិស្សពូកែ។ល។

ក្រសួងអប់រំ យុវជន និងកីឡា

គណៈកម្មាធិការជាតិ
ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

PLAN INTERNATIONAL

អង្គការផ្លែនអន្តរជាតិកម្ពុជា

CAMBODIAN WOMEN'S CRISIS CENTER (CWCC)

A21

SOLIDAR SUISSE
FIGHTING FOR GLOBAL FAIRNESS

Caritas CAMBODIA
Ending poverty
Promoting Justice
Restoring Dignity